# ១-ហេតុការណ៍សំខាន់ៗក្នុងនគរមគធៈ
# សម័យពុទ្ធកាល និងក្រោយពុទ្ធកាល

១-ព្រះសិទ្ធត្ថសាងព្រះផ្នួសកាត់ព្រះកេសា ។

២-ព្រះអង្គបួសហើយ បានជួបសន្ទនាជាមួយព្រះបាទពិម្ពិសារ សព្វថ្ងៃមានស្តូបនៅខាងកើតផ្លូវ ចេញពីក្រុងរាជគ្រឹះទៅពុទ្ធគយា ជិតដល់ច្រកទ្វារខាងត្បូងក្រុង ។

៣-ហេតុការណ៍ ៦ ឆ្នាំក្នុងផ្នួសរបស់ព្រះអង្គ គឺទ្រង់គង់នៅក្នុងនគរមគធៈតែប៉ុណ្ណោះ ដូចជាក្នុងរឿងរ៉ាវ អាឡារតាបស ឧទកតាបស ទុក្ករកិរិយា បញ្ចវគ្គីយ៍មកគាល់បម្រើជាដើម ។

៤-ហេតុការណ៍ក្នុងថ្ងៃត្រាស់ដឹង ដូចជាទទួលចង្ហាន់នាងសុជាតា ទទួលស្បូវពីសោត្ថិយព្រាហ្មណ៍ រឿងមារាធិរាជព្រមទាំងសេនាជាដើម រហូតដល់ការត្រាស់ដឹងក្រោមព្រះពោធិព្រឹក្ស ។

៥-ហេតុការណ៍ ៤៩ ថ្ងៃក្រោយអំពីការត្រាស់ដឹងហើយក្នុងសត្តមហាឋាន ។

៦-ហេតុការណ៍ ព្រហ្មម៉ឺនចក្កវាឡ មានសហម្បតីព្រហ្មជា





ប្រមុខមកអារាធនាព្រះអង្គ នៅដើមអជបាលនិគ្រោធ ក្នុងថ្ងៃដែលព្រះអង្គឆាន់ចង្ហាន់របស់ **តបុស្សៈ** និង **ភល្លិកៈ** ហើយ ។ ក្នុងទីនេះមានសេចក្ដីសំខាន់ ៣ យ៉ាងគឺ :

(១)-ទទួលចង្ហាន់នាងសុជាតា

(២)-សោយវិមុត្តិសុខក្នុងសប្ដាហ៍ទី ៥ ក្រោយពីត្រាស់ដឹង

(៣)-គង់ពិចារណាធម៌ដ៏មានជម្រៅ ក្នុងថ្ងៃទី៥០ បន្ទាប់ពីត្រាស់ដឹង ព្រហ្មអារាធនាសូមឱ្យព្រះអង្គត្រាស់សម្ដែងនូវព្រះធម៌-ទេសនា និងទ្រង់ពិចារណាមើលបុគ្គល ៤ ជំពូក ដូចផ្កាឈូកក្នុងជលដ្ឋាន ព្រមទាំងពិចារណានូវបុគ្គល ដែលព្រះអង្គត្រូវយាងទៅប្រោសជាដំបូង ។ ស្ថានទីនេះស្ថិតនៅខាងកើតស្ទឹងនេរញ្ជរា និងខាងកើតផ្ទះនាងសុជាតា មិនជាឆ្ងាយប៉ុន្មានឡើយ មើលឃើញច្បាស់ប្រមាណកន្លះគីឡូម៉ែត្រ ។ ព្រះអង្គយាងចេញពីទីឋាននេះឯង ក្នុងដំណើរទៅកាន់ព្រៃឥសិបតនមិគទាយវ័ន សម្ដែងព្រះធម្ម-ចក្កប្បវត្តនសូត្របឋមទេសនា ។

៧-ប្រោសជដិល ៣ នាក់បងប្អូន ព្រមទាំងបរិវារ នៅឧរុវេលាសេនានិគម ឱ្យបានជាឯហិភិក្ខុ សម្ដែងអាទិត្តបរិយាយ-សូត្រ នៅភ្នំគយាសីសៈ មាត់ស្ទឹងគយា ធ្វើឱ្យទាំង ៣ អង្គបងប្អូនព្រមទាំងបរិវារ រួមគ្នាទាំងអស់ ១០០០ អង្គបានសម្រេចនូវព្រះ

អរហត្តផល ។ ទីនេះនៅមិនឆ្ងាយពីកន្លែងដែលព្រះអង្គត្រាស់ដឹង ប៉ុន្មានឡើយ តាមផ្លូវទៅក្រុងរាជគ្រឹះ ធ្វើដំណើរដោយរថយន្ត ប្រមាណ ៣០ នាទី ។

៨.ព្រោសព្រះបាទពិម្ពិសារព្រមដោយបរិវារដ៏ច្រើននៅព្រៃត្នោត ជិតក្រុងរាជគ្រឹះ ។

៩.ព្រះបាទពិម្ពិសារ ថ្វាយវេឡុវនារាមដល់ព្រះភិក្ខុសង្ឃ មានព្រះពុទ្ធជាព្រះប្រធាន ។

១០.ព្រះអគ្គសាវ័កទាំង ២ ឧបសម្បទា ព្រមដោយបរិវារ រួមទាំងអស់ត្រូវជា ២៥០ អង្គ ដោយឯហិភិក្ខុឧបសម្បទា ។

១១.កំណើតមាឃបូជា ចាប់ផ្តើមដោយចតុរង្គសន្និបាត ក្នុងថ្ងៃ ១៥ កើតខែមាឃ ថ្ងៃព្រះសារីបុត្តបានសម្រេចនូវព្រះ-អរហត្តផល ក្រោយការត្រាស់ដឹងរបស់ព្រះសម្មាសម្ពុទ្ធ ៩ ខែគត់។

១២.ព្រះមហាកស្សបៈឧបសម្បទា ដោយទទួលយកនូវព្រះឱវាទ ៣ យ៉ាងអំពីព្រះសម្មាសម្ពុទ្ធ ។

១៣.ព្រះសម្មាសម្ពុទ្ធ ត្រាស់បង្គាប់ឱ្យធ្វើរូបរាងចីវរ តាមបែបស្រែនិងភ្លឺស្រែនៃអ្នកនគរមគធៈ ។

១៤.ហេតុការណ៍ ក្នុងរឿងពេទ្យជីវកកោមារភច្ច ជាពេទ្យពូកែអស្ចារ្យក្នុងសម័យនោះឯង ទាំងជាព្រះសោតាបន្ន មាន



ឧបការៈច្រើនក្នុងព្រះពុទ្ធសាសនា ។

១៥.មានសេដ្ឋី និងមហាសេដ្ឋី ច្រើនជាងនគរណា ៗ ទាំងអស់ ដូចជា ជោតិកសេដ្ឋី ជដិលសេដ្ឋី និងមេណ្ឌកសេដ្ឋី ជាដើម ។

១៦.សម្បូណ៌ព្រៃភ្នំល្អាងគុហា ទាំងអាកាសធាតុក៏សមរម្យ ទើបជាទីប្រជុំនៃអ្នកប្រព្រឹត្តតបធម៌ មានតាបសឥសី សូម្បីគ្រូមិច្ឆាទិដ្ឋិទាំង ៦ ក៏នៅក្នុងនគរនេះទាំងអស់ ។

១៧ មានការបង្កហេតុនាំឱ្យព្រះសម្មាសម្ពុទ្ធប្រកាសថា ៤ ខែទៀតនឹងសម្តែងយមកប្បាដិហារ្យ នៅជិតទ្វារក្រុងសាវត្ថី ។

១៨.មានធារទឹកក្តៅហូរចេញពីក្រោមភ្នំវេភារៈ រហូតដល់សព្វថ្ងៃ សម័យនោះមានវត្តឈ្មោះតបោទារាម ។

១៩.ព្រះទេវទត្តលបធ្វើឃាតព្រះសាស្តាដោយការទម្លាក់ថ្មលើព្រះអង្គ និងចាត់ចែងឱ្យខ្មាន់ធ្នូមកបាញ់ព្រះអង្គនិងម្យ៉ាងទៀតរៀបចំដំរីនាឡាគីរីឱ្យមកព្រេចព្រះអង្គទៀតផង ។

២០.ព្រះទេវទត្តបំបែកសង្ឃ ហើយនាំភិក្ខុ ៥០០ អង្គទៅកាន់ភ្នំគយាសីស កន្លែងដែលព្រះអង្គសម្តែងអាទិត្តបរិយាយសូត្រព្រោសបុរាណជដិល ១០០០ អង្គ ។ ទីនោះមានភ្នំព្រៃកដូចក្បាលដំរី សព្វថ្ងៃអ្នកស្រុកហៅភ្នំព្រហ្មយោនី ។

២១-ព្រះបាទអជាតសត្តុ ដណ្តើមរាជពីបិតា រហូតដល់ធ្វើឃាតព្រះបិតា ព្រោះមកអំពីការសេពគប់ជាមួយនឹងព្រះទេវទត្ត ។ ក្រោយមកបានពេទ្យជីវកកោមារភច្ច នាំទៅគាល់ព្រះសម្មាសម្ពុទ្ធនៅជីវកម្ពវ័ន ក្នុងក្រុងរាជគ្រឹះនោះឯង ហើយបានស្តាប់ព្រះធម៌ កើតការជ្រះថ្លាដ៏ក្រៃលែងក្នុងព្រះរតនត្រៃ ។

២២-ព្រះសារីបុត្ត បរិនិព្វាននៅផ្ទះដែលលោកប្រសូត គឺនៅនាលកគ្រាម ហៅស្រុកនាលន្ទា ។

២៣-ព្រះមហាមោគ្គល្លាន បរិនិព្វាននៅកាឡសិលាគុហានាភ្នំឥសិគិលិ ទិសនិរតីក្រុងរាជគ្រឹះ ។

២៤-ព្រះបាទអជាតសត្តុ បញ្ចុះព្រះបរមសារីរិកធាតុ ១ ចំណែកក្នុងក្រុងរាជគ្រឹះ ដែលដង្ហែមកអំពីនគរកុសិនារា ។

២៥-សង្គាយនាលើកទី ១ នៅសត្តបណ្ណគុហានាភ្នំវេភារៈ ទិសពាយព្យនៃក្រុងរាជគ្រឹះ ។

២៦-ព្រះមហាកស្សបត្ថេរ ជាព្រះប្រធាន រួមសហការជាមួយនឹងព្រះបាទអជាតសត្តុ បានធ្វើនូវធាតុនិធាន គឺកិរិយាកប់ទុកព្រះបរមសារីរិកធាតុ ៧ ចំណែក (វៀរព្រះធាតុនៅរាមគ្រាម ១ ចំណែក) ជាការកប់ទុកក្នុងទីដ៏ប្រណីតអស្ចារ្យ ការពារអន្តរាយតាមដែលព្រះមហាកស្សបត្ថេរបានជ្រាប ។



២៧-ព្រះមហាកស្សបត្ថេរ បរិនិព្វាននៅភ្នំកុក្កុដសមបាតក្នុងនគរមគធៈហ្នឹងឯង ។

២៨-សង្គាយនាលើកទី ៣ នៅអសោការាមក្រុងបាដលិ-បុត្រ សម័យកាលនៃព្រះបាទធម្មាសោក ។

២៩-សង្គាយនាលើកទី ៣ រួចភ្លាម មានការចាត់គណសង្ឃធម្មទូតចេញទៅផ្សព្វផ្សាយព្រះពុទ្ធសាសនា ៩ ផ្លូវ មានដំណើរទៅកាន់គន្ធាររដ្ឋ,សុវណ្ណភូមិ និងតម្ពបណ្ណិទ្វីប (លង្កា) ជាដើម ។

៣០-ព្រះបាទធម្មាសោកស្វែងរកនូវធាតុនិធានឃើញហើយបានកសាងព្រះចេតិយ ៨៤.០០០ ស្មើនឹងចំនួនព្រះធម្មក្ខន្ធ ហើយបានធ្វើបុណ្យឆ្លងព្រះចេតិយ បញ្ចុះព្រះបរមសារីរិកធាតុ ៧ ឆ្នាំ , ៧ ខែ , ៧ ថ្ងៃ នៅអសោការាម និងនៅក្រុងបាដលិបុត្រ ។

៣១-ហេតុការណ៍ទាក់ទងនឹងព្រះបាទធម្មាសោក សំខាន់ៗច្រើនរឿងទៀត ដូចជាប្រតិស្ឋានសសរស្តម្ភនៅពុទ្ធស្ថានផ្សេងៗជាដើម ។

៣២-ក្នុង៤៥ព្រះវស្សា ទ្រង់ត្រាស់សម្តែងព្រះធម៌តែភាសាមគធៈប៉ុណ្ណោះ ។

## ២_សរុបស្ថាននីចាំព្រះវស្សានៃព្រះពុទ្ធអង្គ

១_ព្រៃឥសិបតនមិគទាយវ័ន, នគរពារាណសី

២_វត្តវេឡុវ័នមហាវិហារ , **នគរមគធ:**

៣_វត្តវេឡុវ័នមហាវិហារ , **នគរមគធ:**

៤_វត្តវេឡុវ័នមហាវិហារ , **នគរមគធ:**

៥_កូដាគារសាលានាមហាវ័ន , នគរវេសាលី

៦_មកុលបពឹត , **នគរមគធ:**

៧_ក្រោមដើមបារិច្ឆត្តក: , ឋានតាវត្តិង្ស

៨_ភេសកឡាវ័ន , ភគ្គជនបទ

៩_ឃោសិតារាម , នគរកោសម្ពី

១០_ក្រោមដើមសាល: , ព្រៃបារិលេយ្យក:

១១_ភូមិព្រាហ្មណ៍ឯកនាលា , **នគរមគធ:**

១២_ក្រោមដើមស្ដៅ , នគរវេរញ្ជា

១៣_ចាលិកបពឹត , នគរចាលិកា

១៤_វត្តជេតពនមហាវិហារ ,នគរសាវត្ថី





១៥_និគ្រោធារាម , នគរកបិលពស្ដុ

១៦_អគ្គាឡវចេតិយ , នគរអាឡវី

១៧_វត្តវេឡុវ័នមហាវិហារ , **នគរមគធ:**

១៨_ចាលិកបពឹត , នគរចាលិកា

១៩_ចាលិកបពឹត , នគរចាលិកា

២០_វត្តវេឡុវ័នមហាវិហារ , **នគរមគធ:**

២១-៤៤_ជេតពន+បុព្វារាម , នគរសាវត្ថី

៤៥_វេឡុវគ្រាម , នគរវេសាលី ។

* -ព្រះអង្គគង់ចាំព្រះវស្សានៅនគរមគធ:ចំនួន ៧ វស្សា (២-៣-៤-៦-១១-១៧-២០ ) ។

ចាកអដ្ឋកថាគម្ពីរពុទ្ធវង្ស

# ៣-មគធៈនគរបឋម

១-បឋមក្នុងការទទួលព្រះសិទ្ធត្ថសាងព្រះផ្នួស
២-បឋមក្នុងការទទួលព្រះពុទ្ធត្រាស់ដឹង
៣-បឋមក្នុងការដែលព្រះពុទ្ធសាសនាចូលដល់ទីក្រុង
៤-បឋមក្នុងការដែលព្រះរាជាបានសម្រេចមគ្គផល
៥-បឋមក្នុងការទទួលវត្តវេឡុវន័
៦-បឋមក្នុងបុណ្យទក្ខិណានុប្បទាន
៧-បឋមក្នុងការទទួលអគ្គសាវ័កទាំងពីរអង្គ
៨-បឋមក្នុងការទទួលអគ្គសាវិកាស្ដាំ
៩-បឋមមាឃបុណ្ណមីថ្ងៃមាឃបូជា
១០-បឋមក្នុងរឿងធ្វើសង្ឃភេទ (ភិក្ខុទេវទត្តបំបែកសង្ឃ)
១១-បឋមសង្គាយនាព្រះធម៌វិន័យ ។





# ៤-បុគ្គលសំខាន់ៗក្នុងនគរមគធៈ

## ផ្នែកភិក្ខុ

### ១-ព្រះមហាកស្សបត្ថេរ

ព្រះមហាកស្សបត្ថេរ នាមដើមថា បិប្ផលិ តែសព្រហ្មចារី តែងហៅថា កស្សបៈ តាមត្រកូល។ លោកកើតនៅស្រុកព្រាហ្មណ៍ ឈ្មោះថា មហាតិត្ថៈ ក្នុងនគរមគធៈ ។ កាលមានអាយុ ២០ ឆ្នាំ បានរៀបការជាមួយនឹងនាង ភទ្ទកាបិលានី ស្រីរូបស្អាតនៅសាគលនគរ អាយុ ១៦ ឆ្នាំ ។

ដោយអ្នកទាំងពីរនាក់នេះ ជាអ្នកចុតិពីព្រហ្មលោកមកទាំងអស់គ្នា និងជាអ្នកបំពេញនូវនេក្ខម្មបារមីក្នុងជាតិមុននឹងទៅកាន់ព្រហ្មលោកនោះ ម្ល៉ោះហើយទើបមិនត្រេកអរក្នុងកាមារម្មណ៍ ឃើញទោសក្នុងការគ្រប់គ្រងផ្ទះដោយប្រការផ្សេងៗ ។ លុះដល់មានឱកាសហើយក៏ប្រគល់ទ្រព្យសម្បត្តិឱ្យអ្នកដទៃទាំងអស់ នាំគ្នាកោរសក់ ស្លៀកដណ្ដប់សំពត់កាសាវៈ បួសឧទ្ទិសចំពោះព្រះសម្មាសម្ពុទ្ធ ។

ទាំងពីររូបនេះជាគូឧបនិស្ស័យ ធ្លាប់ជាភរិយាស្វាមីនឹងគ្នា បំពេញបុណ្យបារមីជាមួយគ្នា រាប់ជាតិជាអនេក ហ្វឹនសែនផែនដី កន្លងមកហើយ ។ ជាតិនេះជាជាតិចុងក្រោយ អ្នកទាំងពីរបាន គោរពសក់ឱ្យដល់គ្នា សាងផ្នួសលាលោកិយ ផែនដីកក្រើកញាប់ញ័រ ដោយទ្រគុណអ្នកទាំងពីរមិនបាន ។

ព្រះបរមសាស្តា ទ្រង់គង់នៅព្រះគន្ធកុដិ នាវត្តវេឡុវន័ ព្រះអង្គទ្រង់ជ្រាបសព្វគ្រប់ហើយ ក៏បានយាងមកគង់នៅក្រោម ដើមជ្រៃ ឈ្មោះពហុបុត្តកនិគ្រោធ នៅរវាងក្រុងរាជគ្រឹះ និង នាលន្ទគ្រាម រង់ចាំទទួលព្រះមហាកស្សបៈ ។ ព្រះអង្គទ្រង់ប្រទាន ឧបសម្បទាឱ្យដល់ព្រះមហាកស្សបៈ ដោយការប្រទាននូវឱវាទ ៣ យ៉ាងគឺ :

១-ម្នាលកស្សបៈ អ្នកគប្បីសិក្សាថា ហិរិ និងឱត្តប្បៈដ៏ ក្លៀវក្លា អាត្មាអញនឹងតម្កល់ទុក ក្នុងភិក្ខុចាស់ទាំងឡាយ ក្នុងភិក្ខុថ្មី ទាំងឡាយ និងក្នុងភិក្ខុកណ្តាលទាំងឡាយ ។

២-ម្នាលកស្សបៈ អ្នកគប្បីសិក្សាថា អាត្មាអញនឹងស្តាប់នូវ ធម៌ ដែលប្រកបដោយកុសលណានីមួយ ហើយធ្វើនូវធម៌ទាំងអស់ នោះ ឱ្យជាប្រយោជន៍ ធ្វើទុកក្នុងចិត្ត ផ្ចង់ចិត្តទាំងពួង ផ្ចង់ត្រចៀក ចាំស្តាប់ធម៌ ។



៣-ម្នាលកស្សបៈ អ្នកគប្បីសិក្សាថា អាត្មាអញមិនគប្បី លះបង់នូវកាយគតាសតិដែលប្រកបដោយសេចក្តីសុខ ។

ព្រះមហាកស្សបត្ថេរ បានឧបសម្បទាជាភិក្ខុ ដោយការ ទទួលយកនូវព្រះបរមពុទ្ធោវាទ ៣ ប្រការនេះឯង ។ គ្រាបួស ហើយ លោកច្រើនគង់នៅបិប្ផលិគុហា នាភ្នំវេភារៈ លោក សមាទានធុតង្គ ១៣ អំពីព្រះសាស្តា ប្រារព្ធសេចក្តីព្យាយាមហើយ បានជាព្រះអរហន្តចាប់តាំងពីថ្ងៃទី ៨ បន្ទាប់ពីឧបសម្បទាហើយ។

ព្រះមហាកស្សបត្ថេរ បានជួយផ្សព្វផ្សាយព្រះពុទ្ធសាសនា សម្រេចប្រយោជន៍ដ៏អស្ចារ្យដល់មហាជន ជាទីគោរពសក្ការៈដល់ ពុទ្ធបរិស័ទជាទូទៅ ទាំងមនុស្ស ទាំងទេវតា ។ ជាពិសេស ក្រៃលែង ដែលមិនមានក្នុងសាវ័កដទៃគឺ ព្រះដ៏មានព្រះភាគជា ព្រះសាស្តា បានប្តូរផ្លាស់សង្ឃាដី ជាមួយនឹងលោក ជាកិត្តិយស ពោរពេញដោយអត្ថន័យ ។

ព្រះថេរៈជាគំរូដ៏ល្អដល់អ្នកបួសតមកក្រោយៗ ព្រោះទោះបី លោកបានសម្រេចនូវព្រះអរហត្តផលហើយក៏ដោយ លោកនៅតែ សមាទានធុតង្គដ៏យ៉ាងតឹងរ៉ឹង ដោយចំពោះធុតង្គ ៣ មុខ លោក កាន់ជាកិច្ចវត្តរហូតជីវិត គឺ ១-ទ្រង់សំពត់បង្សុកូលជាវត្ត ២-និមន្ត បិណ្ឌបាតជាវត្ត ៣-នៅព្រៃជាវត្ត ។ លោកបានទទួលតំណែង

ឯតទគ្គៈខាងទ្រទ្រង់នូវធុតង្គ និងឱ្យឱវាទដល់ភិក្ខុទាំងឡាយ អំពីការកម្ចាត់បង់នូវកិលេសដោយធុតង្គគុណ ។

ជីវិតចុងក្រោយរបស់ព្រះមហាកស្សបត្ថេរ មានសេចក្តីសំខាន់ដ៏ក្រៃលែង លោកបានជាប្រធានក្នុងការធ្វើសង្គាយនាគ្រាទី ១ នៅសត្តបណ្ណគុហា នាភ្នំវេភារៈ ។ លោកមានព្រះជន្មាយុ ១២០ ឆ្នាំ ។ ក្នុងគម្ពីរមហាសាវកនិព្វាន បានសម្តែងថា ព្រះមហាកស្សបត្ថេរ បរិនិព្វាននៅភ្នំកុក្កុដសមបាត សព្វថ្ងៃហៅភ្នំកុក្កុដបាទ ។

## ២ -ព្រះសារីបុត្ត

ព្រះសារីបុត្ត ជាអគ្គសាវ័កស្តាំរបស់ព្រះដ៏មានព្រះភាគ មានកិច្ចការជួយផ្សព្វផ្សាយព្រះសាសនា ជំនួសព្រះបរមសាស្តា យ៉ាងវិសេសឯក ។ លោកជាឯតទគ្គបុគ្គលខាងផ្នែកបញ្ញា បន្ទាប់ពីព្រះដ៏មានព្រះភាគមក មិនមានអ្នកណាស្មើឡើយ ។

ព្រះសារីបុត្តមានស្រុកកំណើតនៅនាលន្ទា ជាស្រុកមួយនៅជាប់នឹងក្រុងរាជគ្រឹះ ។ នាមដើមលោកឈ្មោះ **ឧបតិស្សៈ** បិតាជាព្រាហ្មណ៍ឈ្មោះវង្គន្តៈ ចំណែកម្តាយឈ្មោះ សារី ជាព្រាហ្មណី ។ លោកជាកូនច្បងគេ មានប្អូនប្រុស ៣ នាក់គឺ





ឧបសេន ១ , ចុន្ទ ១ និងរេវតៈ ១ ហើយមានប្អូនស្រី ៣ នាក់ដែរ គឺ នាងចាលា ១ , នាងឧបចាលា ១ និងនាងសីសុបចាលា ១ រួមទៅត្រូវជាបងប្អូន ៧ នាក់ ។

ឧបតិស្សមាណព កាលដែលនៅជាយរាវាស បានសម្រេចសិល្បវិទ្យាច្រើនសាស្ត្រ ព្រោះលោកជាអ្នកមានបញ្ញាមុតស្រួចសិក្សាបានឆាប់រហ័ស ។ ដោយអាស្រ័យមាតារបស់លោកឈ្មោះនាងសារី ទើបសព្រហ្មចារីហៅលោកថា សារីបុត្ត ។ ក្រោយមកលោកបានថិតនៅក្នុងយុវវ័យព្រមជាមួយសម្លាញ់គឺកោលិតៈ តែងតែនាំគ្នាដើរមើលមហោស្រពក្នុងក្រុងរាជគ្រឹះ ប៉ុន្តែដោយសារលោកមានឧបនិស្ស័យខ្លាំងដោយបញ្ញាហ្នឹងឯង លោកក៏បានពិចារណាកើតការសង្វេគឃើញថា មិនយូរឡើយមនុស្សទាំងអស់នេះនឹងស្លាប់ទៅ គឺអ្នកសម្តែងមហោស្រពក៏ស្លាប់ អ្នកមើលក៏ងាប់ ជីវិតរកសារៈមិនមានឡើយ ទើបកើតការធុញទ្រាន់ បំណងនឹងចេញបួសដើម្បីស្វែងរកមោក្ខធម៌ ។

ក្នុងកាលដែលពិចារណាថា នឹងចេញបួស ទាំងពីរនាក់សម្លាញ់ទើបទៅប្រឹក្សាជាមួយនឹងមាតាបិតា ។ លុះបានការអនុញ្ញាតពីមាតាបិតាសមតាមបំណងប្រាថ្នា ក៏នាំគ្នាទៅបួសព្រមដោយមាណពដទៃៗទៀត រួមទាំងអស់ ៥០០ នាក់ ដោយធ្វើ

ដំណើរទៅបួសក្នុងសំណាក់គ្រូសញ្ជ័យបរិព្វាជក ព្រោះជាគ្រូអាចារ្យល្បីឈ្មោះក្នុងសម័យនោះ ដែលជាហេតុឱ្យគ្រូសញ្ជ័យមានលាភសក្ការៈកើតឡើងដ៏ច្រើនសន្ធឹកសន្ធាប់ ។ លុះបួសហើយ ក៏បានសិក្សាក្នុងសំណាក់គ្រូសញ្ជ័យនោះឯង ទាល់តែអស់ចំណេះពីគ្រូអាចារ្យ ឃើញថាអត់សារៈខ្លឹមសារ ក៏ស្វែងរកអាចារ្យដទៃព្រមដោយសន្យាជាមួយកោលិតៈថា កាលបើអ្នកណាបានឃើញនូវធម៌អមតៈហើយ នឹងប្រាប់គ្នា ។

ថ្ងៃមួយ ឧបតិស្សៈដើរតាមផ្លូវចូលទៅក្រុងរាជគ្រឹះ បានជួបនឹងព្រះអស្សជិត្ថេរកំពុងនិមន្តបិណ្ឌបាត ក៏កើតសេចក្តីជ្រះថ្លាក្នុងកិរិយាស្ងប់នៃព្រះថេរៈ ។ ឧបតិស្សៈបានសាកសួរក្នុងបញ្ហាផ្សេងៗ ព្រមទាំងសូមឱ្យព្រះអស្សជិត្ថេរសម្តែងធម៌ដោយសង្ខេប ព្រះអស្សជិត្ថេរបានសម្តែងថា « ធម៌ណាកើតអំពីហេតុ ព្រះតថាគតទ្រង់ត្រាស់ហេតុនៃធម៌នោះ ... » ឧបតិស្សៈបានឃើញអមតធម៌នៅពេលស្តាប់នោះឯង ទើបបានទៅប្រាប់សម្លាញ់កោលិតៈ ធ្វើឱ្យសម្លាញ់បានឃើញនូវអមតៈផងដែរ ។

ឧបតិស្សៈ និងកោលិតៈបានចូលទៅរកគ្រូសញ្ជ័យដើម្បីនាំគ្នាចូលទៅគាល់ព្រះសាស្តា ប៉ុន្តែត្រូវគ្រូសញ្ជ័យបដិសេធព្រមទាំងក្តួតឈាមស្រស់ក្តៅៗទៀតផង ។ ឧបតិស្សៈ និងសម្លាញ់ព្រមទាំង





បរិវាររួមគ្នា ២៥០ នាក់ ធ្វើដំណើរចូលមកកាន់វត្តវេឡុវន័ ហើយបានទទួលឯហិភិក្ខុឧបសម្បទាពីព្រះដ៏មានព្រះភាគ ក្នុងថ្ងៃដែលព្រះសម្មាសម្ពុទ្ធត្រាស់ដឹងបាន ៨ ខែកន្លះកន្លងទៅហើយ ។

ព្រះឧបតិស្សៈ ឬព្រះសារីបុត្តបានសម្រេចនូវព្រះអរហត្តផល បន្ទាប់ពីឧបសម្បទាបានកន្លះខែ គឺចំថ្ងៃពេញបូណ៌មីខែមាឃនៅគុហាសូករខាតា នាភ្នំគិជ្ឈកូដ ។ នៅយប់ថ្ងៃនោះ មានសង្ឃសន្និបាតចំនួន ១២៥០ អង្គក្នុងវត្តវេឡុវន័ ព្រះបរមសាស្តាទ្រង់សម្តែងឱវាទបាដិមោក្ខក្នុងគ្រានោះឯង ។

ព្រះសារីបុត្ត បានទទួលនូវការទុកព្រះទ័យអំពីព្រះសម្មាសម្ពុទ្ធដ៏យ៉ាងក្រៃលែង ព្រះអង្គត្រាស់ឱ្យភិក្ខុទាំងឡាយយកព្រះសារីបុត្ត និងព្រះមហាមោគ្គល្លានជាតួយ៉ាង ឱ្យសេពគប់នឹងលោកទាំងពីរ ព្រោះលោកទាំងពីរជាបណ្ឌិត សង្គ្រោះដល់សព្រហ្មចារី ។ នៅពេលដែលព្រះទេវទត្តបំបែកសង្ឃ នាំភិក្ខុបួសថ្មីទាំង ៥០០ អង្គទៅកាន់ភ្នំគយាសីសៈ ព្រះសាស្តាទ្រង់ត្រាស់ឱ្យព្រះសារីបុត្ត និងព្រះមហាមោគ្គល្លាន និមន្តទៅនាំភិក្ខុទាំងនោះត្រឡប់មកវិញ ដោយព្រះទ័យករុណា ។

ព្រះសារីបុត្ត ជាព្រះឧបជ្ឈាយ៍បំបួសកុលបុត្របានច្រើនជាទីបំផុត ដោយចំពោះសាមណេរ សូម្បីតែព្រះរាហុល និង

សាមណេរដែលល្បីៗ ព្រះនាមផ្សេងទៀត សុទ្ធតែព្រះសារីបុត្តបំបួសទាំងអស់ ។ ព្រះសារីបុត្តមាននូវកតញ្ញូគួរឱ្យយកជាគំរូ ព្រះសាស្តា ទ្រង់ត្រាស់សរសើរកតញ្ញូតាធម៌របស់លោកតាំងតែពីជាតិមុន កាលនៅជាសត្វដំរីជាដើម ។ កាលដែលជ្រាបថាព្រះ-អស្សជិត្ថេរគង់នៅទិសណា លោកតែងតែសិងដាក់ព្រះសីសៈទៅទិសនោះ ជាការគោរពបូជាដល់គ្រូអាចារ្យ ។

លោកជាអគ្គសាវ័កស្តាំ បំពេញបារមីមក ១ អសង្ខេយ្យ និង ១ សែនមហាកប្ប តែលោកប្រកាសខ្លួនលោកដូចគោបាក់ស្នែង ដូចក្មេងចណ្ឌាល និងដូចសំពត់ជូតធូលីជាដើម ក្នុងន័យមិនប្រកាន់ កាយ មិនតម្កើងខ្លួនហើយមើលងាយអ្នកដទៃហ្នឹងឯង ។ ក្នុងជីវិត របស់លោកត្រូវនន្ទយក្ខវាយដោយដំបងទិព្វចំព្រះសីសៈ តែមិនមានគ្រោះថ្នាក់អ្វីដល់លោកឡើយ រីឯនន្ទយក្ខភ្លាមនោះ ស្រាប់តែក្តៅក្រហាយរោលរាលពេញរូបកាយ ធ្លាក់ចុះមកដី ដីបើកចន្លោះ ហើយភ្លើងនរកក៏ស្រូបទាញយកទៅទាំងរស់ក្នុងគ្រានោះឯង ។

ក្នុងជីវិតចុងក្រោយរបស់ព្រះសារីបុត្ត លោកបានទូលលាព្រះដ៏មានព្រះភាគនៅឯវត្តជេតពន ដើម្បីបរិនិព្វានក្នុងស្រុកកំណើត ជាប្រយោជន៍ជួយមាតាឱ្យរួចពីការយល់ខុស ព្រោះមាតា



របស់លោកគោរពជឿលើព្រះព្រហ្មតែប៉ុណ្ណោះ ។ នៅពេលដែលលោកកំពុងតែចុះនូវព្រះលោហិត មានអាពាធខ្លាំងក្លា មហា-ព្រហ្មក៏បានចុះមកសូមខ្លួនជាអ្នកបម្រើ តែលោកមិនអនុញ្ញាតដោយអាងថាមានព្រះចុន្ទជាប្អូននៅបម្រើហើយ ។ មាតារបស់លោកឃើញដូច្នេះ ក៏នឹកជ្រះថ្លាដល់ព្រះសម្មាសម្ពុទ្ធ ដែលជាគ្រូជាសាស្តារបស់លោកកូនដ៏ក្រៃលែង ។ គ្រានោះព្រះសារីបុត្តបានបញ្ជាក់ប្រាប់ម្តាយថា ព្រះព្រហ្មដូចជាសាមណេរបម្រើភិក្ខុ កាលព្រះសម្មាសម្ពុទ្ធយាងចុះពីឋានទេវលោកមកដែនសង្កស្សៈ ព្រះឥន្ទ ព្រះព្រហ្ម ព្រមទាំងទេវតាទាំងឡាយ ដង្ហែព្រះអង្គយាងចុះមក ។ សូម្បីតែពេលដែលព្រះអង្គទ្រង់ប្រសូត ក៏ព្រះព្រហ្មយាងមកទទួលព្រះអង្គចាកព្រះគភ៌មុនគេ រីឯការត្រាស់សម្តែងនូវព្រះធម៌របស់ព្រះអង្គរហូតមក ក៏មហាព្រហ្មហ្នឹងឯង ជាអ្នកអារាធនា ព្រមដោយព្រហ្មម៉ឺនចក្កវាឡ ...។ ព្រះសារីបុត្តបានសម្តែងអំពីព្រះ-ពុទ្ធគុណ មានបទថា **អរហំសម្មាសម្ពុទ្ធោ**ជាដើម រហូតដល់មាតាបានសម្រេចនូវសោតាបត្តិផល ។ លោកបរិនិព្វាននៅបន្ទប់ដែលលោកប្រសូត ក្នុងថ្ងៃ ១៥ កើតខែកត្តិក មុនការបរិនិព្វានរបស់ព្រះសម្មាសម្ពុទ្ធ ៦ ខែគត់ ។

## ៣-ព្រះមហាមោគ្គល្លាន

ព្រះមហាមោគ្គល្លានត្ថេរ នាមដើម **កោលិតៈ** នៅកោលិតគ្រាមជាប់គ្នានឹងភូមិកំណើតព្រះសារីបុត្ត ។ លោកជាអគ្គសាវ័កឆ្វេងរបស់ព្រះដ៏មានព្រះភាគ ឯតទគ្គៈកំពូលខាងមានឫទ្ធិ ។ បិតាមិនប្រាកដនាម ឯមាតាមាននាមថា **នាងមោគ្គល្លី** ក្រោយមកសព្រហ្មចារីហៅលោកថា **ព្រះមហាមោគ្គល្លាន** តាមឈ្មោះរបស់ម្ដាយ ។

កោលិតៈ បានចេញបួសជាមួយនឹងសម្លាញ់ឧបតិស្សៈ ក្នុងពេលដែលបានសម្រេចសោតាបត្តិផលរួចហើយ ។ កោលិតៈ គឺព្រះមហាមោគ្គល្លាន ឧបសម្បទាបាន ៧ ថ្ងៃ លោកអាស្រ័យនៅ **កល្លវាលមុត្តគ្រាម** នានគរមគធៈ ក្នុងពេលដែលបំពេញនូវសមណធម៌ លោកត្រូវគ្របសង្កត់ដោយការងងុយងោកងក់ ពេលនោះព្រះដ៏មានព្រះភាគ បានសម្ដែងប្រាប់អំពីវិធីកម្ចាត់បង់នូវការងងុយនោះៗ ដោយវិធីផ្សេងៗ លុះដល់លោកស្វាងល្អហើយ ព្រះអង្គទ្រង់ត្រាស់ អំពីធម៌ទាំងពួងមិនគួរប្រកាន់ថាជារបស់មាំមួន ... ការសោយអារម្មណ៍គឺវេទនាមិនទៀងជាដើម អាស្រ័យព្រះធម៌ទេសនារបស់ព្រះសាស្ដា លោកក៏បានសម្រេចជាព្រះអរហន្ត ព្រមដោយអភិញ្ញា ដោយចំពោះភាពខ្លាំងក្លានៃឫទ្ធិហ្នឹងឯង ។





ព្រះមហាមោគ្គល្លាន មានការងារផ្សព្វផ្សាយព្រះពុទ្ធសាសនា ប្រព្រឹត្តទៅដ៏យ៉ាងខ្លាំងក្លា ព្រោះអាស្រ័យឫទ្ធិរបស់លោកមួយផ្នែកធំ ដែលធ្វើឱ្យម្ចាស់លទ្ធិដទៃៗសាបសូន្យនូវលាភសក្ការៈដូចទឹកសន្សើមត្រូវកម្ដៅព្រះអាទិត្យដូច្នោះឯង ។ លោកបានធ្វើដំណើរទៅកាន់ទេវលោក និងព្រហ្មលោក ហើយមានពេលខ្លះ លោកនិមន្តទៅកាន់ឋាននរកទៀតផង ព្រមទាំងបាននាំដំណឹងមកប្រាប់ដល់មនុស្សលោក ឱ្យបានជ្រាបនូវស្ថានទាំងអស់នោះដោយសព្វគ្រប់ ។ មានការលំបាកៗ លោកច្រើនតែបានទទួលបង្គាប់អំពីព្រះដ៏មានព្រះភាគទៅធ្វើការងារនោះៗ ដូចជាការទូន្មាននន្ទោបនន្ទនាគរាជ កោសិយសេដ្ឋីធ្វើនំអំបែង និងអគ្គិទត្តៈអ្នកបួសក្រៅព្រះពុទ្ធសាសនាជាដើម ។ លោកបានទទួលនូវការគោរពជ្រះថ្លាអំពីសាធុជនដ៏ច្រើន ដែលជាហេតុធ្វើឱ្យពួកម្ចាស់លទ្ធិដទៃរកឧបាយកម្ចាត់បង់លោកចោល រហូតទាល់តែបានសម្រេច ។

សូម្បីលោកជាព្រះអរហន្ត បានទទួលការតែងតាំងអំពីព្រះដ៏មានព្រះភាគ ជាភិក្ខុកំពូលខាងមានឫទ្ធិក៏ដោយ ប៉ុន្តែលោកត្រូវបានបញ្ចប់ជីវិត ហើយបរិនិព្វានដោយការប្រហារអំពីអ្នកដទៃដែលមិនមានឫទ្ធិអ្វីទាំងអស់ ។ ក្នុងកាលនោះ លោកគង់នៅកាឡសិលា

នាភ្នំឥសិគិលិជិតក្រុងរាជគ្រឹះ មានពួកចោររាប់រយនាក់ បានមកឡោមព័ទ្ធកុដិរបស់លោក ទោះជាលោកគេចជាច្រើនដង ក៏ពួកចោរនៅតែព្យាយាមមករកលោកដដែល ។ លុះលោកពិចារណាឃើញបាបកម្មចាស់របស់លោកតាមមកទាន់ លោកក៏ឈប់គេចដែលធ្វើឱ្យពួកចោរវាយសំពងលោក ទាល់តែខ្ទេចឆ្អឹងដូចគ្រាប់អង្ករ ។ លោកបានប្រមូលអដ្ឋិធាតុដោយឫទ្ធិ ទៅក្រាបទូលលាព្រះដ៏មានព្រះភាគឯវត្តវេឡុវ័ន ហើយលោកបាននិមន្តមកបរិនិព្វាននៅកាឡសិលានាគុហាភ្នំឥសិគិលិនេះឯង ដែលធ្វើឱ្យពុទ្ធបរិស័ទស្លុតចិត្តយ៉ាងក្រៃលែង។ លោកបរិនិព្វាននៅថ្ងៃ ១៥ រោចខែកត្តិកក្រោយព្រះសារីបុត្តកន្លះខែ ព្រះដ៏មានព្រះភាគ ស្តេចយាងទៅធ្វើឈាបនកិច្ច ក្នុងសភាពដ៏គគ្រឹកគគ្រេងទៅដោយមនុស្ស និងទេវតា នាំយកអដ្ឋិធាតុមកបញ្ចុះក្នុងចេតិយ នាខ្លោងទ្វារវត្តវេឡុវ័ន ក្បែរចេតិយព្រះអញ្ញាកោណ្ឌញ្ញៈ ដើម្បីសាធុជនបានធ្វើសក្ការបូជា ។

គួរគិតពិចារណាថា មនុស្សយើងទោះបីឋិតនៅក្នុងវណ្ណៈណា មានសមត្ថភាពនិងការចេះដឹងខ្ពស់ដល់កម្រិតណា មានឫទ្ធិហោះហើរដើរលើអាកាសបានយ៉ាងណាៗ ឬក៏មានយសស័ក្តិឋានៈខ្ពង់ខ្ពស់ប៉ុនណាក៏ដោយ រមែងរត់ពីបាបកម្មដែលខ្លួនបានធ្វើហើយ



នោះ មិនបានឡើយ ទាល់តែព្រះនិព្វានទើបបានរួចពីផលកម្មគ្រប់យ៉ាង ។

## ៤-ព្រះឧបសេនត្ថេរ

ព្រះឧបសេនត្ថេរកើតនៅស្រុកនាលន្ទា ជាបុត្ររបស់វង្គន្ត-ព្រាហ្មណ៍ និងនាងសារីព្រាហ្មណី ត្រូវជាប្អូនប្រុសរបស់ព្រះសារី-បុត្ត។ តាមពិតបងប្អូន ៧ នាក់ពោះម៉ែ១ ឪមួយបានចេញបួសក្នុងព្រះពុទ្ធសាសនា ហើយបានសម្រេចនូវព្រះអរហត្តទាំងអស់អង្គ ។

កាលដែលលោកចម្រើនវ័យហើយ បានសិក្សាចប់គម្ពីរត្រៃវេទ ក្រោយមកបាននូវឱកាសស្តាប់ព្រះធម៌ទេសនារបស់ព្រះ-សម្មាសម្ពុទ្ធ ក៏មានសេចក្តីជ្រះថ្លា ទើបសូមព្រះសារីបុត្តជួយឱ្យបានបួស ។

កាលបួសហើយបាន ១ វស្សា លោកក៏ជាព្រះឧបជ្ឈាយ៍ ឱ្យឧបសម្បទាដល់កុលបុត្រ ព្រោះលោកគិតថា ព្រះពុទ្ធសាសនានឹងចម្រើនរុងរឿងក្រៃលែងឡើងបាន ក៏ដោយសារមានភិក្ខុច្រើនអង្គហ្នឹងឯង ។

ពេលចេញវស្សាហើយ លោកបាននាំសទ្ធិវិហារិករបស់លោក ទៅគាល់ព្រះដ៏មានព្រះភាគ ដោយសង្ឃឹមថា ព្រះអង្គនឹងពេញព្រះហឫទ័យជាពុំខាន ប៉ុន្តែផ្ទុយស្រឡះ ព្រះដ៏មានព្រះភាគ

ទ្រង់តិះដៀលថា លោកជាអ្នកប្រាថ្នាច្រើន ទើបតែបួស ១ វស្សា មិនគួរឱ្យឧបសម្បទាដល់កុលបុត្រទេ ហើយទ្រង់បញ្ញត្តសិក្ខាបទ ហាមមិនឱ្យភិក្ខុដែលមានវស្សាមិនទាន់គ្រប់ ១០ វស្សា ធ្វើជាឧបជ្ឈាយ៍ឱ្យឧបសម្បទាដល់កុលបុត្រឡើយ ។

កាលដែលត្រូវព្រះសាស្តាទ្រង់តិះដៀលហើយនោះ ជំនួសការដែលរួញរាចិត្ត ធុញទ្រាន់ក្នុងការបំពេញសេចក្តីល្អ លោកបែរជាមានកម្លាំងចិត្ត ដើម្បីនឹងប្រព្រឹត្តព្យាយាមធ្វើសេចក្តីល្អឱ្យខ្លាំងឡើងទៀត គឺឱ្យទាល់តែគាប់ព្រះហឫទ័យនៃព្រះបរមសាស្តា ។ លោកមានព្រះភក្ត្រស្រស់បស់ដូចព្រះចន្ទពេញបូណ៌មី ក្រាបថ្វាយបង្គំលាព្រះដ៏មានព្រះភាគ ត្រឡប់មកបំពេញសេចក្តីព្យាយាមចម្រើនវិបស្សនាកម្មដ្ឋាន រហូតដល់បានសម្រេចជាព្រះអរហន្ត ហើយសមាទានធុតង្គទាំង ១៣ យ៉ាងឧក្រិដ្ឋ ទាំងជាអ្នកអាចសម្តែងព្រះធម៌ពីរោះ មានកេរ្តិ៍ឈ្មោះល្បីសុសសាយ ។

ដោយសារព្រះថេរៈចេញពីត្រកូលខ្ពង់ខ្ពស់មកបួស និងជាធម្មកថិកឆ្លាតក្នុងការសម្តែងព្រះធម៌ ដូច្នេះហើយទើបមានកុលបុត្រក្នុងត្រកូលញាតិ មិត្ត អាមាត្យ និងត្រកូលខ្ពង់ខ្ពស់ដទៃ នាំគ្នាចេញមកបួស ហើយនៅក្នុងសំណាក់របស់លោក ។ លោកពោលថា យើងជាអ្នកនៅព្រៃជាវត្ត ដូច្នេះអ្នកទាំងឡាយក៏ចូរនៅព្រៃផង





ដែរ លោកប្រាប់អំពីធុតង្គទាំង ១៣ ឱ្យប្រព្រឹត្តជាវត្តនៅក្នុងសំណាក់របស់លោក ។

កាលដែលលោកមានវស្សា ១០ ហើយ បានសិក្សាព្រះវិន័យច្បាស់លាស់ លោកបានឱ្យឧបសម្បទាដល់កុលបុត្រទាំងឡាយ ។ ភិក្ខុប្រមាណ ៥០០ អង្គ បានជាបរិវាររបស់លោក ដោយប្រការដូច្នេះឯង ។

គ្រាកាលដែលព្រះដ៏មានព្រះភាគ គង់ប្រថាប់នៅជេតពនមហាវិហារ ទ្រង់ឱ្យប្រកាសដល់សង្ឃថា ព្រះអង្គទ្រង់ប្រាថ្នាពួនសម្ងំនៅដោយភាពស្ងប់ស្ងាត់កន្លះខែ ។ ក្នុងគ្រានោះ សង្ឃបានកំណត់ដល់គ្នាថា អង្គណាចូលគាល់ព្រះសាស្តាក្នុងរវាងកន្លះខែនេះ នឹងត្រូវអាបត្តិបាចិត្តិយៈ ។

គ្រានោះ ព្រះឧបសេនត្ថេរ បាននាំសទ្ធិវិហារិករបស់លោកមកវត្តជេតពនដើម្បីគាល់ព្រះសាស្តា ។ ដោយព្រះបរមសាស្តាជ្រាបថា សទ្ធិវិហារិករបស់លោក សុទ្ធតែមានការប្រព្រឹត្តនូវធុតង្គវត្តតាមព្រះឧបជ្ឈាយ៍របស់ខ្លួន ព្រះអង្គទ្រង់ប្រទានសាធុការសរសើរដល់ព្រះឧបសេនត្ថេរ និងទ្រង់អនុញ្ញាតឱ្យព្រះភិក្ខុទ្រទ្រង់នូវធុតង្គគុណទាំងអស់ ចូលគាល់ព្រះអង្គតាមសប្បាយ ។

ក្រោយមកព្រះពុទ្ធអង្គ ទ្រង់បានលើកតម្កើងព្រះឧបសេន-

ត្ថេរ ក្នុងកណ្តាលភិក្ខុសង្ឃថា លោកជាឯតទគ្គៈក្នុងការនាំមកនូវសេចក្តីជ្រះថ្លាដោយជុំវិញ ។

ក្នុងគ្រាដែលភិក្ខុវត្តឃោសិតារាម ក្រុងកោសម្ពី បែកបាក់សាមគ្គីគ្នា មានភិក្ខុ ១ អង្គមានបំណងគេចចេញពីជម្លោះនោះ បានសាកសួរដល់ព្រះឧបសេនត្ថេរថា ខ្ញុំព្រះករុណានឹងបដិបត្តិយ៉ាងណាក្នុងសភាពការណ៍បែបនេះ ។ លោកបានសម្តែងជាព្រះគាថាដែលមានសេចក្តីពីរោះដូចតទៅ :

ភិក្ខុគប្បីសេពនូវសេនាសនៈស្ងាត់ ប្រាសចាកសំឡេងគឹកកង ដែលម្រឹគសាហាវអាស្រ័យហើយ ព្រោះហេតុនៃការពួនសម្ងំ ។ ភិក្ខុគប្បីនាំមកនូវកំណាត់សំពត់អំពីគំនរនៃសំរាម ឬព្រៃស្មសាន ឬចន្លោះនៃថ្នល់ ធ្វើជាសង្ឃាដី ដោយកំណាត់សំពត់ដែលខ្លួននាំមកនោះ ហើយទ្រទ្រង់នូវចីវរដ៏សៅហ្មង ។ ភិក្ខុគប្បីធ្វើចិត្តឱ្យទាប គ្រប់គ្រងនូវទ្វារ សង្រួមដោយប្រពៃ ហើយត្រាច់ទៅកាន់ផ្ទះជាលំដាប់ គឺចេញពីត្រកូល ១ ទៅកាន់ត្រកូល ១ ទៀត ដើម្បីបិណ្ឌបាត ។

ម្យ៉ាងទៀត ភិក្ខុត្រូវសន្តោសដោយវត្ថុសៅហ្មង មិនគប្បីប្រាថ្នានូវរសឯទៀតឱ្យច្រើនទេ ចិត្តរបស់ភិក្ខុអ្នកជាប់ញ៉ាមក្នុងរសទាំងឡាយ រមែងមិនត្រេកអរក្នុងឈាន ។ មុនីគប្បីជាអ្នកមាននូវ





សេចក្តីប្រាថ្នាតិច ជាអ្នកសន្តោស ជាអ្នកស្ងប់ស្ងាត់ នៅមិនច្រឡូកច្រឡំដោយបុគ្គល ២ ពួក គឺគ្រហស្ថ និងបព្វជិត ។

បណ្ឌិតគប្បីសម្តែងខ្លួនឱ្យដូចជាមនុស្សឆ្កួត ល្ងីល្ងើ និងមនុស្សគយ៉ាងនោះឯង (បានដល់ការលះបង់អំនួតអួតអាង ) មិនគប្បីពោលឱ្យហួសប្រមាណ ក្នុងកណ្តាលសង្ឃ ។

បណ្ឌិតនោះ មិនគប្បីតិះដៀលបុគ្គលណាមួយ គប្បីវៀរបង់នូវការបៀតបៀនផង សង្រួមក្នុងបាតិមោក្ខផង ដឹងប្រមាណក្នុងភោជនផង ។

បណ្ឌិត គប្បីជាអ្នកឈ្លាសវៃក្នុងការកើតឡើងនៃចិត្តដែលមាននិមិត្តកំណត់ល្អហើយ គប្បីប្រកបរឿយៗនូវសមថៈ និងវិបស្សនាតាមកាលដ៏គួរ គប្បីជាអ្នកបរិបូណ៌ដោយព្យាយាមប្រព្រឹត្តទៅរឿយៗ ប្រកបក្នុងធម៌ដ៏សមគួរសព្វៗកាល ។

បើមិនទាន់ដល់ព្រះនិព្វាន ដែលជាទីបំផុតនៃទុក្ខក្នុងវដ្តៈទេ កុំអាលដល់នូវសេចក្តីទុកចិត្តឡើយ ។

កាលភិក្ខុប្រាថ្នានូវសេចក្តីបរិសុទ្ធ រស់នៅដោយសុខសម្រាន្តយ៉ាងនេះ អាសវៈទាំងពួងរមែងអស់ទៅ ភិក្ខុនោះរមែងដល់នូវការរលត់ទុក្ខ ។

ក្នុងគម្ពីរឧទាន បានសម្តែងថា គ្រាមួយ ព្រះដ៏មានព្រះភាគ

ទ្រង់គង់នៅវត្តវេឡុវ័ន ព្រះឧបសេនវង្គន្តបុត្ត លោកពូនសម្ងំនៅតាមសមណវិស័យ បានមានសេចក្តីត្រិះរិះកើតឡើងថា គឺជាលាភរបស់យើង ព្រោះយើងបានល្អហើយនូវព្រះដ៏មានព្រះភាគអរហន្តសម្មាសម្ពុទ្ធជាព្រះសាស្តា យើងបានចេញបួសក្នុងធម្មវិន័យដែលព្រះបរមសាស្តា ព្រះអង្គទ្រង់ត្រាស់សម្តែងល្អហើយ ទាំងសព្រហ្មចរិរបស់យើង ក៏មានសីល មានកល្យាណធម៌ ។ យើងបានធ្វើឱ្យបរិបូណ៌ក្នុងសីលទាំងឡាយ ជាបុគ្គលមានចិត្តតាំងមាំដោយល្អ ជាព្រះអរហន្តខីណាស្រព និងជាអ្នកមានឫទ្ធិច្រើន មានអានុភាពច្រើន ជីវិតយើងចម្រើន(ព្រោះជាបុញ្ញក្ខេត្តដ៏ប្រសើរ) រីឯសេចក្តីស្លាប់ក៏ចម្រើន (ព្រោះជាការបរិនិព្វានមិនមានបដិសន្ធិ)។

## ៥-ព្រះមហាចុន្ទ

ព្រះមហាចុន្ទ នាមដើមរបស់លោក គឺចុន្ទ ស្រុកកំណើតរបស់លោកនៅនាលន្ទា ក្នុងនគរមគធៈ ជាប្អូនបង្កើតរបស់ព្រះ-សារីបុត្ត ។

ព្រះមហាចុន្ទ មានព្រះអានន្ទជាព្រះឧបជ្ឈាយ៍ លោកបានអភិញ្ញា៦ សម្រេចជាព្រះអរហន្តតាំងពីសាមណេរព្រះជន្ទ ៧ ឆ្នាំ។

លោកបានពោលគាថា ២ គាថា :



**សុស្សូសា សុតវឌ្ឍនី សុតំ បញ្ញាយ វឌ្ឍនំ**
**បញ្ញាយ អត្ថំ ជានាតិ ញាតោ អត្ថោ សុខាវហោ ។**

ការស្តាប់ធម៌ដោយល្អ នាំឱ្យចម្រើនក្នុងការស្តាប់ ការស្តាប់នាំឱ្យចម្រើននូវបញ្ញា បុគ្គល រមែងយល់សេចក្តីបានដោយសារបញ្ញា សេចក្តីដែលយល់ហើយ រមែងនាំសុខមកឱ្យ ។

**សេវេថ បន្តានិ សេនាសនានិ**
**ចរេយ្យ សំយោជនវិប្បមោក្ខំ**
**សចេ រតឹ នាធិគច្ឆេយ្យ តត្ថ**
**សង្ឃេ វសេ រក្ខិតត្តោ សតីមាតិ ។**

បុគ្គល គួរសេពសេនាសនៈស្ងាត់ គួរប្រព្រឹត្តធម៌ដែលជាហេតុរួចស្រឡះចាកសំយោជនៈ បើមិនបានសេចក្តីត្រេកអរក្នុងទីស្ងាត់នោះទេ គប្បីជាអ្នកមានសតិរក្សាខ្លួន នៅក្នុងសង្ឃចុះ ។

ព្រះមហាចុន្ទ បានក្រាបទូលសួរព្រះដ៏មានព្រះភាគ អំពីវិធីលះមិច្ឆាទិដ្ឋិ សឹងមានប្រាកដនៅក្នុង **សល្លេខសូត្រ** បិដកលេខ ២០ ទំព័រ ១៣០ ។

ព្រះមហាចុន្ទ បានឱ្យឱវាទដល់ភិក្ខុទាំងឡាយ នៅក្នុង **មហាចុន្ទសូត្រ** បិដកលេខ ៤៦,ទំព័រ១៥២ និងបិដកលេខ ៥០,ទំព័រ ៩៣។

ព្រះមហាចុន្ទ មានការចេះដឹងច្បាស់ក្នុងពោជ្ឈង្គទាំង ៧ រហូតដល់បានទទួលកិត្តិយសអំពីព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់បង្គាប់ឱ្យលោកសម្តែងនូវពោជ្ឈង្គ ៧ ដែលក្នុងកាលនោះ ព្រះដ៏-មានព្រះភាគទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ជិតក្រុងរាជគ្រឹះ ហើយព្រះអង្គទ្រង់កំពុងតែមានអាពាធជាទម្ងន់ផង សឹងមានប្រាកដក្នុង **គិលានសូត្រ** បិដកលេខ ៣៧ , ទំព័រ ២១០ ។

ព្រះមហាចុន្ទ លោកមានឧបការគុណក្នុងព្រះសាសនា លោកសម្លឹងមើលកាលវែងឆ្ងាយទៅអនាគត ដើម្បីការតាំងនៅនៃព្រះពុទ្ធសាសនា សឹងប្រាកដក្នុង **បាសាទិកសូត្រ** បិដកលេខ ១៨ , ទំព័រ ២៣៧ និង **សាមគាមសូត្រ** បិដកលេខ ២៦ ,ទំព័រ ៩៤ ។

ព្រះមហាចុន្ទ លោកមានឫទ្ធិខ្លាំងក្លា ដែលព្រះដ៏មានព្រះភាគទ្រង់ទទួលស្គាល់ សឹងប្រាកដក្នុង **ធម្មបទដ្ឋកថា** ពុទ្ធវគ្គ យមកប្បាដិហារិយ៍។ ក្នុងកាលនោះលោកនៅជាសាមណេរ ៧ ឆ្នាំ ប៉ុន្តែជាព្រះខីណាស្រពហើយ លោកបានចូលទៅគាល់ព្រះដ៏មានព្រះភាគ សូមអនុញ្ញាតថា « បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសូមធ្វើបាដិហារិយ៍ ជំនួសព្រះអង្គ » ។ ព្រះដ៏មានព្រះភាគ ត្រាស់សួរអំពីការសម្តែងឫទ្ធិរបស់សាមណេរចុន្ទយ៉ាងណាខ្លះនោះ កាលព្រះអង្គជ្រាបហើយទ្រង់ត្រាស់ថា « តថាគតទទួលស្គាល់អានុភាព



របស់អ្នក » ប៉ុន្តែព្រះអង្គទ្រង់ហាមគ្រប់សាវ័កទាំងអស់ មានព្រះមហាមោគ្គល្លានជាដើម ព្រោះព្រះអង្គមានព្រះបំណងសម្តែងនូវយមកប្បាដិហារិយ៍ ដែលមិនមានអ្នកណាក្រៅអំពីព្រះសម្មា-សម្ពុទ្ធសម្តែងបានឡើយ ។

ព្រះមហាចុន្ទត្ថេរ ធ្លាប់បម្រើព្រះបរមសាស្តា និងមានការតាមបម្រើព្រះធម្មសេនាបតីជាព្រះម្ចាស់បង មានទំនាក់ទំនងនឹងការបរិនិព្វានរបស់ព្រះសារីបុត្ត មានប្រាកដក្នុង **ចុន្ទសូត្រ** បិដកលេខ ៣៨ , ទំព័រ ៥១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពនរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ព្រះសារីបុត្តដ៏មានអាយុ មានអាពាធ មានសេចក្តីទុក្ខ មានជំងឺធ្ងន់នៅក្នុងស្រុកនាឡកៈ ក្នុងដែនមគធៈ ។ មានសាមណេរឈ្មោះចុន្ទ ជាឧបដ្ឋាករបស់ព្រះសារីបុត្តដ៏មានអាយុ ។ គ្រានោះឯងព្រះសារីបុត្ត ក៏បរិនិព្វានដោយអាពាធនោះ ។

លំដាប់នោះឯង ចុន្ទសាមណេរក៏កាន់យកបាត្រ និងចីវររបស់ព្រះសារីបុត្តដ៏មានអាយុ ហើយចូលទៅរកព្រះអានន្ទដ៏មានអាយុឯវត្តជេតពនរបស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះអានន្ទដ៏មានអាយុ ហើយអង្គុយ

ក្នុងទីដ៏សមគួរ ។ លុះចុន្ទសាមណេរអង្គុយក្នុងទីសមគួរហើយ បានពោលនឹងព្រះអានន្ទដ៏មានអាយុដូច្នេះថា បពិត្រព្រះអានន្ទដ៏ចម្រើន ព្រះសារីបុត្តដ៏មានអាយុបរិនិព្វានហើយ នេះបាត្រចីវររបស់លោក ។ ម្នាលអាវុសោចុន្ទ នេះជាដំណឹងដែលអ្នកនាំមកជាដំបូង ម្នាលអាវុសោចុន្ទ មក យើងនឹងនាំគ្នាចូលទៅរកព្រះដ៏-មានព្រះភាគ ដើម្បីគាល់ព្រះអង្គ លុះចូលទៅដល់ហើយ នឹងក្រាបបង្គំទូលសេចក្តីនោះ ចំពោះព្រះដ៏មានព្រះភាគ ។ ចុន្ទសាមណេរក៏ទទួលពាក្យព្រះអានន្ទដ៏មានអាយុថា ករុណាលោកម្ចាស់ ។

គ្រានោះឯង ព្រះអានន្ទដ៏មានអាយុ និងចុន្ទសាមណេរ ក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទដ៏មានអាយុអង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះដ៏មាន-ព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ចុន្ទសាមណេរនេះបាននិយាយយ៉ាងនេះថា បពិត្រលោកដ៏ចម្រើន ព្រះសារីបុត្តដ៏មានអាយុបរិនិព្វានហើយ នេះបាត្រចីវររបស់លោក ។ បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត កាយរបស់ខ្ញុំព្រះអង្គហាក់ដូចជារឹងស្ពូកស្ពឹង ទាំងទិសទាំងឡាយក៏មិនប្រាកដដល់ខ្ញុំព្រះអង្គ ទាំងធម៌ទាំងឡាយក៏មិនភ្លឺច្បាស់ដល់ខ្ញុំព្រះអង្គដែរ ព្រោះឮថាព្រះសារីបុត្ត





ដ៏មានអាយុបរិនិព្វានទៅហើយ ។

ម្នាលអានន្ទ សារីបុត្តនាំយកសីលក្ខន្ធ បរិនិព្វានទៅហើយឬ នាំយកសមាធិក្ខន្ធ បរិនិព្វានទៅហើយឬ នាំយកបញ្ញាខន្ធបរិនិព្វានទៅហើយឬ នាំយកវិមុត្តិក្ខន្ធ បរិនិព្វានទៅហើយឬ នាំយកវិមុត្តិញ្ញាណទស្សនក្ខន្ធ បរិនិព្វានទៅហើយឬ ។ បពិត្រព្រះ-អង្គដ៏ចម្រើន ព្រះសារីបុត្តដ៏មានអាយុរបស់ខ្ញុំព្រះអង្គ នាំយកសីលក្ខន្ធ បរិនិព្វានទៅ ក៏ទេ ។បេ។ នាំយកវិមុត្តិញ្ញាណទស្សនក្ខន្ធបរិនិព្វានទៅក៏ទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ប៉ុន្តែព្រះសារីបុត្តដ៏មានអាយុរបស់ខ្ញុំព្រះអង្គ លោកជាអ្នកប្រដៅ ជាអ្នកពន្យល់ ជាអ្នកបំភ្លឺ ជាអ្នកបបួល ជាអ្នកឱ្យអាចហាន ជាអ្នកឱ្យរីករាយ ជាអ្នកមិនខ្ជិលច្រអូស ជាអ្នកអនុគ្រោះដល់ពួកសព្រហ្មចារីដោយធម៌ទេសនា យើងខ្ញុំទាំងឡាយតែងរលឹកតាមនូវធម្មឱជារស ធម្ម-សម្បត្តិ ធម្មានុគ្រោះ របស់ព្រះសារីបុត្តដ៏មានអាយុនេះ ។

ម្នាលអានន្ទ ដំណើរនោះ តថាគតបានប្រាប់មុនហើយថា ការផ្សេងៗគ្នា ការព្រាត់ប្រាសគ្នា ការប្រព្រឹត្តទៅទីទៃពីគ្នា ចាកសត្វនិងសង្ខារទាំងពួង ជាទីស្រឡាញ់ ជាទីពេញចិត្ត ម្នាលអានន្ទអ្នកគប្បីបានដំណើរនោះអំពីទីឯណាដូច្នេះ មិនមែនឫ ។ របស់ណាដែលកើតហើយ ចម្រើនហើយ បច្ច័យតាក់តែងហើយ របស់

នោះឯង តែងមានសេចក្តីវិនាសទៅជាធម្មតា បុគ្គលនឹងសង្ឃឹមថា សូមឱ្យរបស់នោះកុំបីវិនាសឡើយ ហេតុនុ៎ះមិនដែលមានឡើយ ។

ម្នាលអានន្ទ ដូចដើមឈើធំក្រៃលែងជាងឈើធំ ដែលមានខ្លឹម កំពុងតាំងនៅ ស្រាប់តែរលំទៅ យ៉ាងណា ។ ម្នាលអានន្ទ កាលបើភិក្ខុសង្ឃជាច្រើន ប្រកបដោយសារធម៌ កំពុងឋិតនៅ ស្រាប់តែសារីបុត្តបរិនិព្វានទៅ ក៏យ៉ាងនោះឯង ម្នាលអានន្ទ ដំណើរនោះ អ្នកគប្បីបានអំពីទីណា ។ របស់ណាដែលកើតហើយ ចម្រើនហើយ បច្ច័យតាក់តែងហើយ តែងមានសេចក្តីវិនាសទៅជាធម្មតា បុគ្គលនឹងសង្ឃឹមថា សូមឱ្យរបស់នោះកុំវិនាសទៅឡើយ ហេតុនុ៎ះមិនដែលមានឡើយ ។ ម្នាលអានន្ទ ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកទាំងឡាយចូរមានខ្លួនជាទីពឹង មានខ្លួនជាទីរលឹក កុំបីមានវត្ថុដទៃជាទីរលឹកឡើយ ។

ម្នាលអានន្ទ ភិក្ខុដែលមានខ្លួនជាទីពឹង មានខ្លួនជាទីរលឹក មិនមានវត្ថុដទៃជាទីរលឹក មានធម៌ជាទីពឹង មានធម៌ជាទីរលឹក មិនមានវត្ថុដទៃជាទីរលឹក តើដូចម្តេច ។ ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ តែងពិចារណាឃើញនូវកាយក្នុងកាយជាប្រក្រតី មានព្យាយាមដុតកម្តៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈា និងទោមនស្សក្នុងលោកចេញ ។ ជាអ្នកពិចារណា



ឃើញនូវវេទនាក្នុងវេទនាទាំងឡាយ នូវចិត្តក្នុងចិត្ត នូវធម៌ក្នុងធម៌ទាំងឡាយជាប្រក្រតី មានព្យាយាមដុតកម្តៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈា និងទោមនស្សក្នុងលោកចេញ ។ ម្នាលអានន្ទ ភិក្ខុមានខ្លួនជាទីពឹង មានខ្លួនជាទីរលឹក មិនមានវត្ថុដទៃជាទីរលឹក មានធម៌ជាទីពឹង មានធម៌ជាទីរលឹក មិនមានវត្ថុដទៃជាទីរលឹក យ៉ាងនេះឯង ។

ម្នាលអានន្ទ ពួកភិក្ខុឯណានីមួយ ក្នុងកាលឥឡូវនេះក្តី ក្នុងកាលអំណើះអំពីតថាគតទៅក្តី នឹងមានខ្លួនជាទីពឹង មានខ្លួនជាទីរលឹក កុំបីមានវត្ថុដទៃជាទីរលឹក មានធម៌ជាទីពឹង មានធម៌ជាទីរលឹក កុំបីមានវត្ថុដទៃជាទីរលឹកចុះ ។ ម្នាលអានន្ទ ពួកភិក្ខុឯណានីមួយជាអ្នកប្រាថ្នាការសិក្សា ភិក្ខុទាំងនោះនឹងប្រាកដមានក្នុងចំណែកដ៏ប្រសើរក្រៃលែង ។

## ៦-ព្រះរេវតខទិរវនិយត្ថេរ

ព្រះរេវតខទិរវនិយត្ថេរ នាមដើមរបស់លោកគឺ រេវតៈ លោកជាប្អូនពៅរបស់ព្រះសារីបុត្ត ។ ព្រះរេវតៈជាបុគ្គលឆ្លាតតាំងតែពីក្មេង លោកបានជាព្រះអរហន្តតាំងតែពីលោកនៅជាសាមណេរម្ល៉េះ ។

ត្រកូលព្រះសារីបុត្តមានទ្រព្យរហូតដល់ទៅ ៥៦០ កោដិកហាបណៈ លោកបានលះបង់ចេញបួស បបួលទាំងប្អូនស្រី ៣ នាក់ និងប្អូនប្រុស ២ នាក់ឱ្យបានចេញបួសផងដែរ គឺ នៅសល់តែកុមាររេវតៈម្នាក់ប៉ុណ្ណោះ ។

មាតារបស់លោកបានគិតថា ឧបតិស្សៈបុត្ររបស់យើងលះទ្រព្យប្រមាណប៉ុណ្ណេះបួសហើយ ទាំងបានណែនាំបបួលប្អូនៗឱ្យចេញទៅបួសអស់ ៥ នាក់ទៀតផង ឥឡូវនៅតែរេវតៈកូនពៅប៉ុណ្ណោះ បើឧបតិស្សៈមកបបួលទៅបួសទៀត ទ្រព្យរបស់យើងទាំងអស់នឹងវិនាស វង្សត្រកូលនឹងសាបសូន្យ ដូច្នេះ យើងត្រូវចងរេវតៈដោយចំណង គឺការគ្រប់គ្រងផ្ទះ ទាំងដែលកូននៅក្មេងនៅឡើយ ។

ចំណែកព្រះសារីបុត្ត បានផ្តាំនឹងភិក្ខុទាំងឡាយទុកជាមុនហើយថា បើរេវតៈបំណងនឹងបួស ចូរបំបួសគេផងចុះ ព្រោះមាតារបស់ខ្ញុំព្រះករុណាជាបុគ្គលមិច្ឆាទិដ្ឋិ មិនចាំបាច់ថ្វីដែលរេវតៈត្រូវលាមកបួសនោះឡើយ ខ្ញុំព្រះករុណាផ្ទាល់ជាមាតាបិតា របស់រេវតៈនោះឯង ។

មាតាបិតាបានឱ្យកុមាររេវតៈដែលទើបតែមានអាយុ ៧ ឆ្នាំប៉ុណ្ណោះរៀបការ ជាមួយនឹងក្មេងស្រីម្នាក់ក្នុងត្រកូលដទៃដែល





មានជាតិស្មើគ្នា ។ កាលកំណត់ថ្ងៃហើយបានប្រដាប់តាក់តែងកុមាររេវតៈ នាំទៅកាន់ត្រកូលខាងកុមារី ព្រមដោយបរិវារយ៉ាងច្រើន ។ លំដាប់នោះ កាលពួកញាតិនៃត្រកូលទាំងពីរ ប្រជុំគ្នាធ្វើនូវមង្គល ពួកញាតិបានឱ្យកុមាររេវតៈ និងកុមារីជ្រលក់ដៃទៅក្នុងថាសទឹក ហើយពោលនូវមង្គលទាំងឡាយ ដោយបំណងឱ្យមានសេចក្តីចម្រើនដល់កូនស្រី ទើបពោលថា នាងចូរឃើញធម៌ដែលយាយរបស់នាងបានឃើញហើយ នាងចូររស់នៅអស់កាលយូរដូចជាយាយដែរណ៎ា ។

រេវតៈគិតថា អ្វីទៅហ្ន៎ ឈ្មោះថាធម៌ដែលយាយបានឃើញហើយ ទើបសួរថា អ្នកណាជាយាយ ?

ពួកញាតិបានប្រាប់រេវតៈថា មនុស្សដែលមានអាយុ ១២០ ឆ្នាំ របួតធ្មេញអស់ សក់ស្កូវ ស្បែកជ្រីវជ្រួញ ខ្នងកោងនោះ ចៅមិនឃើញទេឬ នោះហើយគឺជាយាយបង្កើតរបស់កូនស្រី ។

រេវតៈសួរពួកញាតិថា សូម្បីកូនស្រីនេះ ក៏នឹងទៅជាយ៉ាងហ្នឹងដែរឬ ?

ពួកញាតិប្រាប់ថា បើគេមានអាយុវែង គេនឹងទៅជាយ៉ាងហ្នឹងឯងដូចគ្នា ។

កាលបានស្តាប់ដូច្នេះហើយ រេវតៈបានគិតថា ដែលជា

សរីរៈ សូម្បីមានសភាពបែបនេះ ក៏ដល់នូវសភាពប្លែកចម្លែកទៅនេះព្រោះតែជរា ។ ព្រះម្ចាស់បងឧបតិស្សៈ មុខតែឃើញនូវហេតុបែបនេះឯងទើបបានជាចេញបួស ដូច្នេះយើងគួរតែរត់ទៅបួសក្នុងថ្ងៃនេះដែរ ។

រេវតៈមានឧបាយរត់ចូលទៅក្នុងព្រៃ បានដល់សំណាក់ភិក្ខុប្រមាណ ៣០ អង្គ ហើយក៏បានថ្វាយបង្គំលោកសូមបព្វជ្ជា ។ ភិក្ខុទាំងឡាយកាលបើបានជ្រាបថា រេវតៈជាប្អូនប្រុសរបស់ព្រះធម្ម-សេនាបតីហើយ ក៏ឱ្យបព្វជ្ជាជាសាមណេរក្នុងពេលនោះទៅ រួចទើបបញ្ជូនដំណឹងទៅដល់ព្រះសារីបុត្ត ។

សាមណេររេវតៈ បានគិតថា បើយើងនៅក្នុងទីនេះ ពួកញាតិនឹងដេញតាមមករក ហើយនាំខ្លួនត្រឡប់ទៅវិញពុំខាន ទើបរៀនព្រះកម្មដ្ឋានចេញចាកអំពីសំណាក់ភិក្ខុទាំងនោះ កាន់បាត្រនិងចីវរ ចូលទៅក្នុងព្រៃជ្រៅ នៅក្នុងព្រៃគគីរ ចាំវស្សាទីនោះ ។ ក្នុងរវាង ៣ ខែក្នុងវស្សានោះឯង លោកបានសម្រេចនូវព្រះ-អរហត្តព្រមដោយបដិសម្ភិទាទាំងឡាយ ។

ពេលចេញវស្សាហើយ ព្រះសារីបុត្តបានទូលលាព្រះ-សាស្តា ដើម្បីនិមន្តទៅកាន់ទីដែលព្រះរេវតៈគង់នៅ ។ ព្រះសាស្តាទ្រង់ត្រាស់ថា « សារីបុត្ត តថាគតក៏ទៅដែរ » ។ ព្រះដ៏មាន-



ព្រះភាគទ្រង់យាងទៅព្រមដោយភិក្ខុ ៥០០ អង្គ ។ នៅពេលយាងនិងនិមន្តដល់ផ្លូវបែកជាពីរ ព្រះអានន្ទបានក្រាបទូលព្រះសាស្តាថា « បពិត្រព្រះអង្គដ៏ចម្រើន ផ្លូវវាង ៦០ យោជន៍ ជាទីនៅនៃមនុស្សទាំងឡាយ ឯផ្លូវត្រង់ប្រមាណ ៣០ យោជន៍ ដែលពួកអមនុស្សគ្រប់គ្រង » ។

**ព្រះសាស្តា**-អានន្ទ តើ **សីវលី** មកជាមួយពួកយើងដែរទេ?

**ព្រះអានន្ទ**-លោកនិមន្តមកព្រះអង្គ ។

**ព្រះសាស្តា**-បើ **សីវលី**មក ពួកយើងទៅតាមផ្លូវត្រង់នេះ ។

កាលព្រះបរមសាស្តា ស្តេចយាងព្រមដោយភិក្ខុសង្ឃទៅតាមផ្លូវត្រង់នោះ ពួកទេវតាបានចាត់ចែងសាងវិហារតាមផ្លូវហើយចាត់ចែងចង្ហាន់បិណ្ឌបាតដ៏ជាទិព្វ សម្រាប់ព្រះសីវលី ។

ព្រះសីវលី បានឱ្យពួកទេវតាថ្វាយភត្តដែលនាំមកដើម្បីខ្លួនដល់ព្រះភិក្ខុសង្ឃ មានព្រះពុទ្ធជាព្រះប្រធាន ។

ព្រះបរមសាស្តា ព្រមដោយភិក្ខុបរិវារ សោយបុណ្យរបស់ព្រះសីវលី ក្នុងចម្ងាយផ្លូវ ៣០ យោជន៍ ។

ចំណែកព្រះរេវតៈ បានជ្រាបអំពីដំណើររបស់ព្រះបរម-សាស្តា ស្តេចយាងមក ទើបនិម្មិតព្រះគន្ធកុដិសម្រាប់ព្រះដ៏មាន-ព្រះភាគ និម្មិតផ្ទះកំពូល ៥០០ ខ្នង ទីចង្ក្រម ៥០០ និងទីសម្រាប់

សំណាក់យប់ថ្ងៃ ៥០០ ដោយឡែក ។

ព្រះបរមសាស្តាគង់ប្រថាប់នៅក្នុងសំណាក់ព្រះរេវតៈនោះ អស់កាលប្រមាណ ១ ខែ សូម្បីក្នុងរយៈពេលទ្រង់គង់ប្រថាប់នៅក្នុងទីនោះ ក៏សោយបុណ្យរបស់ព្រះសីវលីនោះផងដែរ ។

ក្នុងកាលនោះ មានភិក្ខុ ២ អង្គបានគិតថា ព្រះរេវតៈបានធ្វើការកសាងធំដុំយ៉ាងនេះ នឹងប្រព្រឹត្តសមណធម៌បានយ៉ាងដូចម្តេចទៅ ព្រះសាស្តាទ្រង់យល់មុខប្អូនប្រុសព្រះសារីបុត្ត ទើបស្តេចយាងមកកាន់សំណាក់របស់លោក ជាអ្នកប្រកបដោយនវកម្មមានសភាពបែបនេះ ។

ព្រះដ៏មានព្រះភាគ ទ្រង់ជ្រាបនូវសេចក្តីត្រិះរិះរបស់ភិក្ខុទាំងពីរអង្គនោះ ។ លុះដល់ពេលដែលព្រះអង្គទ្រង់ស្តេចយាងត្រឡប់ទៅសាវត្ថីវិញ ទ្រង់បានអធិដ្ឋានឱ្យភិក្ខុទាំងពីរអង្គនោះឯងភ្លេចនូវបរិក្ខារផ្សេងៗ លុះព្រះអង្គយាងផុតអំពីទីនោះបានបន្តិចទើបទ្រង់រំសាយឫទ្ធិ។

គ្រានោះ ភិក្ខុទាំង ២ អង្គទើបដឹងខ្លួនថាភ្លេចនូវបរិក្ខារ ក៏វិលត្រឡប់មកវិញដើរជាន់បន្ទា មិនឃើញកុដិ មិនឃើញសាលា ឯបរិក្ខារនៅពាក់នឹងមែកឈើ ។

នៅឯភូមិគ្រឹះរបស់នាងវិសាខា ព្រះបរមសាស្តា និងភិក្ខុ





សង្ឃទ្រង់ទទួលបិណ្ឌបាត។ កាលស្រេចភត្តកិច្ចហើយ នាងវិសាខាបានទូលសួរព្រះសាស្តាអំពីទីគង់នៅនៃព្រះរេវតៈ ព្រះអង្គទ្រង់ត្រាស់ថា :

**គាមេ វា យទិ វា រញ្ញេ និន្នេ វា យទិ វា ថលេ**
**យត្ថ អរហន្តោ វិហរន្តិ តំ ភូមិរាមណេយ្យកំ ឱ**

ព្រះអរហន្តទាំងឡាយ នៅក្នុងទីណា ជាស្រុកក៏ដោយ ជាព្រៃក៏ដោយ ទីទាបក៏ដោយ ទីទួលក៏ដោយ ទីនោះគឺជាភូមិឋានមនោរម្យ ។

ព្រះរេវតៈ ជាកំពូលលើភិក្ខុទាំងឡាយផ្នែកខាងនៅព្រៃ ព្រោះភិក្ខុទូទៅកាលដែលនៅព្រៃរមែងជ្រើសរើសព្រៃ ទឹក និងទីដែលសម្រាប់និមន្តបិណ្ឌបាត ឱ្យជាទីពេញចិត្តទើបនៅ ឯចំណែកព្រះរេវតៈវិញ មិនបានជ្រើសរើសព្រៃឱ្យត្រូវចិត្តដូច្នេះឡើយ ។

ព្រះរេវតៈកាលដែលបាននិមន្តទៅថ្វាយបង្គំព្រះសាស្តា និងព្រះធម្មសេនាបតីជាដើម លោកគង់នៅក្នុងទីនោះមិនបានប៉ុន្មានថ្ងៃឡើយ លោកក៏ត្រឡប់មកព្រៃគគីររបស់លោកវិញ នៅដោយសេចក្តីសុខក្នុងផលសមាបត្តិ និងដោយព្រហ្មវិហារធម៌ ។

កាលកន្លងទៅដោយសភាពយ៉ាងនេះ វ័យចាស់ក៏ចូលមកដល់ដោយលំដាប់ ។ ថ្ងៃមួយលោកនិមន្តទៅថ្វាយបង្គំព្រះសាស្តា

សម្រាកនៅក្នុងទីមិនឆ្ងាយពីក្រុងសាវត្ថី ពេលនោះពួកចោរប្លន់អ្នកស្រុកក្នុងនគរ បាននាំគ្នារត់សំដៅមករកលោក ដោយសារមានកងកម្លាំងអ្នករក្សានគរដេញតាមមក ពួកចោរក៏បោះទ្រព្យមកក្បែរព្រះថេរៈ ។ ព្រះរេវតៈត្រូវគេចោទថាជាចោរ ហើយចាប់ទៅថ្វាយព្រះរាជា ។ កាលព្រះរាជាសាកសួរ ក៏បានឆ្លើយតបដោយព្រះថេរគាថា( បិដកលេខ ៥៧,ទំព័រ ៣៥ )យ៉ាងពីរោះមានដូចតទៅ :

ខ្ញុំចេញចាកផ្ទះចូលកាន់ផ្នួស ក្នុងកាលណា កាលណោះ ខ្ញុំមិនដែលនឹកនូវសេចក្តីត្រិះរិះមិនប្រសើរ ដែលប្រកបដោយទោសទេ ។ ក្នុងចន្លោះកាលដ៏វែងនេះ ខ្ញុំមិនដែលនឹកនូវសេចក្តីត្រិះរិះថាពួកសត្វទាំងនេះចូរលំបាកចុះ ចូរស្លាប់ចុះ ចូរដល់នូវសេចក្តីទុក្ខចុះដូច្នេះទេ ។ ប៉ុន្តែខ្ញុំធ្លាប់នឹកនូវមេត្តារកប្រមាណមិនបាន ដែលបានចម្រើនល្អហើយ បានសន្សំហើយ តាមលំដាប់ ដូចព្រះពុទ្ធទ្រង់សម្តែងហើយ ។ ខ្ញុំមានសត្វទាំងពួងជាមិត្ត មានសត្វទាំងពួងជាសម្លាញ់ ជាអ្នកអនុគ្រោះដល់សត្វទាំងពួង បានចម្រើននូវមេត្តា-ចិត្ត ត្រេកអរក្នុងការមិនបៀតបៀនសព្វកាល ។ ខ្ញុំត្រេកអរចំពោះចិត្តដែលមិនងើកងាក មិនកម្រើក ខ្ញុំចម្រើនព្រហ្មវិហារធម៌ ដែលព្រះអរិយៈជាបុរសមិនថោកទាបគប់រកហើយ ។ សាវ័ករបស់ព្រះ-សម្មាសម្ពុទ្ធ ដល់នូវឈានមិនមានវិតក្កៈ រមែងជាអ្នកប្រកបដោយ





តុណ្ហីភាពដ៏ប្រសើរ ក្នុងខណៈនោះ។ ភ្នំថ្មមិនកម្រើក តាំងនៅស៊ប់យ៉ាងណាមិញ ភិក្ខុរមែងមិនញាប់ញ័រដូចជាភ្នំព្រោះអស់ទៅនៃមោហៈ ក៏យ៉ាងនោះដែរ ។ សប្បុរសមិនមានទីទួលគឺកិលេស អ្នកស្វែងរកនូវសេចក្តីស្អាតជានិច្ច ទុកជាមានបាបបន្តិចបន្តួច ប៉ុនចុងរោមកន្ទុយសត្វ ក៏ប្រាកដដូចជាប៉ុនមេឃ ។ នគរជាទីបំផុតនៃដែន ដែលគេគ្រប់គ្រងហើយ ទាំងខាងក្នុងទាំងខាងក្រៅយ៉ាងណាមិញ អ្នកទាំងឡាយ ចូរគ្រប់គ្រងខ្លួនយ៉ាងនោះ ខណៈកុំកន្លងនូវអ្នកទាំងឡាយឡើយ ។ ខ្ញុំមិនត្រេកអរនឹងសេចក្តីស្លាប់ ខ្ញុំមិនត្រេកអរនឹងការរស់នៅទេ ខ្ញុំរង់ចាំតែកាល( បរិនិព្វាន )ប៉ុណ្ណោះដូចអ្នកស៊ីឈ្នួល ទន្ទឹងតែអស់ថ្ងៃ ។ ខ្ញុំមិនត្រេកអរនឹងសេចក្តីស្លាប់ ខ្ញុំមិនត្រេកអរនឹងការរស់នៅ ខ្ញុំជាអ្នកដឹងខ្លួន មានស្មារតីតាំងមាំរង់ចាំតែកាល ( បរិនិព្វាន ) ប៉ុណ្ណោះ ។ ព្រះសាស្តាខ្ញុំបានបម្រើហើយ ព្រះពុទ្ធសាសនាខ្ញុំបានធ្វើហើយ ភារៈធ្ងន់ខ្ញុំបានដាក់ចុះហើយ តណ្ហាគ្រឿងនាំសត្វទៅកាន់ភព ខ្ញុំបានដកចោលហើយ ។ ខ្ញុំចេញចាកផ្ទះ ចូលកាន់ផ្នួស ដើម្បីប្រយោជន៍ណា ប្រយោជន៍គឺការអស់ទៅនៃសំយោជនៈទាំងពួងនោះ ខ្ញុំបានដល់ហើយ ។ អ្នកទាំងឡាយ ចូរឱ្យដល់ព្រម ដោយសេចក្តីមិនប្រមាទចុះ នេះជាពាក្យប្រៀនប្រដៅរបស់ខ្ញុំ ណ្ហើយចុះ ខ្ញុំនឹងបរិនិព្វាន ខ្ញុំជាអ្នកមាន

ចិត្តរួចស្រឡះហើយចាកកិលេសទាំងពួង ។

គ្រាកាល **ព្រះរេវតខទិរវនិយត្ថេរ** សម្តែងអំពីចំណុចបដិបត្តិដែលជាប្រយោជន៍ដល់អ្នកដទៃយ៉ាងនេះហើយ បានហោះឡើងទៅអង្គុយនៅកណ្តាលអាកាស ចូលតេជោធាតុសមាបត្តិ អធិដ្ឋានឱ្យភ្លើងឆេះសរីរៈរបស់លោក ។ ព្រះថេរៈរំលត់ខន្ធបរិនិព្វានទៅដោយមិនមានកិលេស និងបញ្ចក្ខន្ធសល់នៅ ក្នុងស្ថានទីនោះឯង ឱហ្ន៎ ! សង្ខារធម៌មិនទៀងមែនពិត ។

### ៧ -ព្រះឧរុវេលកស្សបត្ថេរ

ព្រះឧរុវេលកស្សបត្ថេរ លោកកើតនៅនគរមគធៈ ក្នុងត្រកូលព្រាហ្មណ៍ កស្សបគោត្រ ។ លោកមានប្អូនប្រុសពីរនាក់គឺ **នទីកស្សបៈ និងគយាកស្សបៈ** ។ បងប្អូនទាំងបីនាក់ រួមទាំងបរិវារ ១000 នាក់បាននាំគ្នាចេញបួសតាំងតែមុនព្រះពុទ្ធបានត្រាស់ម្ល៉េះគឺបួសជាជដិលបូជាភ្លើង។ កន្លែងដែលអ្នកទាំងបីព្រមទាំងបរិវារបួសនោះ នៅមិនឆ្ងាយពីកន្លែងត្រាស់ដឹងនៃព្រះសម្មាសម្ពុទ្ធឡើយ។

ព្រះសម្មាសម្ពុទ្ធ ទ្រង់យាងទៅសម្តែងបាដិហារិយ៍ ៣៥00 មុខ រហូតទាល់តែអ្នកទាំងអស់នោះ ដាក់ចុះនូវមានះ ហើយសូម





ឧបសម្បទានឹងព្រះអង្គ ។ ព្រះដ៏មានព្រះភាគ ទ្រង់ព្រះករុណាប្រោសប្រទាននូវឧបសម្បទា ដោយឯហិភិក្ខុឧបសម្បទាគ្រប់គ្នាទាំងអស់ ។

ពេលនោះ ព្រះបរមសាស្តាទ្រង់គង់ប្រថាប់នៅគយាសីសប្រទេស លើផែនថ្មភ្នំ ឱ្យបុរាណជដិលភិក្ខុជួបជុំទាំង ១000 អង្គ ទ្រង់ប្រកាសសម្តែងនូវ **អាទិត្តបរិយាយសូត្រ** ។ ភពទាំង ៣ ប្រាកដដល់ភិក្ខុទាំងនោះ ដូចជាភ្លើងកំពុងឆេះសន្ធោសន្ធៅ កាលដែលចេះតែពិចារណាតាមក្រសែនៃធម៌ទៅ ចិត្តក៏ផុតស្រឡះចាកអាសវក្កិលេស សម្រេចបានជាព្រះអរហន្តទាំងអស់អង្គ ព្រមដោយអភិញ្ញា និងបដិសម្ភិទា ។

ការដែលបានចាក់ឫសគល់ព្រះពុទ្ធសាសនាជ្រៅ នៅនគរមគធៈនោះ គឺបានព្រះឧរុវេលកស្សបៈនេះឯង ជាកម្លាំងដ៏សំខាន់នៃព្រះដ៏មានព្រះភាគ ដែលជួយធ្វើឱ្យអ្នកនគរមគធៈជាដើម រាប់អានព្រះពុទ្ធសាសនាបានដោយងាយ ។ ព្រោះថា កាលដើមឡើយ អ្នកនគរមគធៈ និងអង្គៈ មានការរាប់អានឧរុវេលកស្សបៈនេះជាខ្លាំង ដោយសម្គាល់ថាជាព្រះអរហន្តរបស់ខ្លួនទៀតផង ។ លុះដល់ព្រះឧរុវេលកស្សបៈ សម្តែងឫទ្ធិហោះទៅលើមេឃ ហើយចុះមកថ្វាយបង្គំព្រះបរមសាស្តា ចុះឡើងច្រើនសា ប្រកាសខ្លួនជា

សាវ័ករបស់ព្រះដ៏មានព្រះភាគ ដូច្នេះអ្នកស្រុកទាំងអស់មានព្រះ-បាទពិម្ពិសារជាប្រមុខ ក៏បានតាំងចិត្តស្តាប់ព្រះធម៌ ហើយក៏បានឃើញនូវសច្ចៈទាំង ៤ ។

គុណសម្បត្តិរបស់ព្រះឧរុវេលកស្សបត្ថេរ គឺជាអ្នកជួយក្នុងការប្រតិស្ឋានព្រះពុទ្ធសាសនា ក្នុងនគរមគធៈ និងជាអ្នកជួយប្រកាសព្រះពុទ្ធសាសនា ដោយការចេះដឹងប្រកបដោយសមត្ថភាពខ្ពស់ ព្រមទាំងពូកែក្នុងការគ្រប់គ្រងបរិស័ទ ។ ព្រោះអាស្រ័យហេតុដូច្នេះ លោកទើបមានបរិស័ទជាបរិវារច្រើន រហូតដល់ទៅបានជាឯតទគ្គៈលើភិក្ខុទាំងឡាយ ផ្នែកខាងមានបរិវារច្រើនទៀតផង ។

នៅក្នុងព្រះថេរគាថា ព្រះឧរុវេលកស្សបត្ថេរ បានសម្តែងថា :

ខ្ញុំឃើញបាដិហារិយ៍របស់ព្រះគោតម ព្រះអង្គមានយសដល់ម្ល៉ោះ ក៏នៅតែមិនក្រាបសំពះ ព្រោះតែសេចក្តីច្រណែន និងសេចក្តីប្រកាន់ ធ្វើឱ្យភាន់ច្រឡំ ។

ព្រះបរមសាស្តា ជាសារថីរបស់ជន ទ្រង់ជ្រាបសេចក្តីត្រិះរិះរបស់ខ្ញុំហើយ បានដាស់តឿន លំដាប់នោះ ខ្ញុំមានសេចក្តីសង្វេគ និងសេចក្តីព្រឺរោម ដែលមិនធ្លាប់កើតមាន ។





ការសម្រេចនូវលាភសក្ការៈណាបន្តិចបន្តួច គ្រាកាលដែលខ្ញុំធ្លាប់នៅជាជដិលនោះ ខ្ញុំបានលះបង់នូវការសម្រេចលាភសក្ការៈនោះហើយ មកបួសក្នុងសាសនាព្រះជិនស្រី ។

កាលពីដើម ខ្ញុំជាអ្នកត្រេកអរក្នុងការបូជាភ្លើង មានកាមា-រម្មណ៍ជាប្រមុខ (ប្រាថ្នាកាមក្នុងសុគតិភព) លុះក្រោយមក ខ្ញុំបានដករាគៈ ទោសៈ និងមោហៈចោលហើយ ។

ខ្ញុំដឹងខ្លួនដែលធ្លាប់អាស្រ័យនៅ ក្នុងកាលពីដើមបានជម្រះនូវទិព្វចក្ខុឱ្យស្អាត ជាអ្នកមានឫទ្ធិ ដឹងចិត្តអ្នកដទៃ ទាំងបានសម្រេចទិព្វសោត ។

មួយទៀត កុលបុត្រចេញចាកផ្ទះ មកបួសក្នុងធម្មវិន័យណា ប្រយោជន៍នោះខ្ញុំបានដល់ហើយ តាមលំដាប់ ទាំងធ្វើឱ្យអស់នូវសំយោជនធម៌ទាំងពួង ។

**នទីកស្សបត្ថេរ** បានសម្តែងដូច្នេះថា :

អាត្មាអញបានស្តាប់ព្រះធម៌ របស់ព្រះពុទ្ធអង្គណា ហើយវៀរបង់មិច្ឆាទិដ្ឋិ ព្រះពុទ្ធអង្គនោះយាងមកហើយកាន់ស្ទឹងនេរញ្ជរា ដើម្បីប្រយោជន៍ដល់អាត្មាអញមែនពិត ។

អាត្មាអញបានបូជាយញ្ញទាំងឡាយ ទាំងខ្ពស់ទាំងទាប និង

បានបូជាភ្លើង កាលនៅជាបុថុជ្ជន ងងឹតងងល់ សម្គាល់ថាការបូជានេះឯង ជាសេចក្តីបរិសុទ្ធ ។

អាត្មាអញស្ទុះទៅកាន់ព្រៃស្បាតគឺទិដ្ឋិមានការស្ពាបអង្អែល ដោយទិដ្ឋិប្រកបដោយការវង្វេង ជាមនុស្សងងឹត ល្ងង់ខ្លៅមិនដឹងអ្វី សម្គាល់ផ្លូវមិនបរិសុទ្ធ ថាជាផ្លូវបរិសុទ្ធ ។

មិច្ឆាទិដ្ឋិ អាត្មាអញបានលះបង់ហើយ ភពទាំងពួងអាត្មាអញបានទម្លាយហើយ អាត្មាអញបូជាភ្លើង គឺព្រះសម្មាសម្ពុទ្ធ ជាទក្ខិណេយ្យបុគ្គល ខ្ញុំសូមនមស្ការចំពោះព្រះតថាគត ។

មោហៈទាំងពួង អាត្មាអញបានលះបង់ហើយ ភវតណ្ហាអាត្មាអញបានទម្លាយចេញហើយ ជាតិសង្សារអស់រលីងហើយ ឥឡូវនេះភពថ្មីទៀតនៃអាត្មាអញមិនមានទេ ។

**គយាកស្សបត្ថេរ** បានសម្តែងដូច្នេះថា :

អាត្មាអញចុះទឹកក្នុងកំពង់ឈ្មោះ គយា ក្នុងមួយថ្ងៃ ៣ ដង គឺពេលព្រឹក ថ្ងៃត្រង់ និងល្ងាច ក្នុងកាលមហោស្រពឈ្មោះ គយផគ្គុ ។ បាបណាដែលអាត្មាអញធ្វើហើយ ក្នុងជាតិទាំងឡាយអំពីកាលមុន ឥឡូវនេះ អាត្មាអញបណ្តែតចោលនូវបាបនោះ ក្នុងកំពង់ឈ្មោះ គយានេះ ទិដ្ឋិយ៉ាងនេះ មានហើយក្នុងកាលមុន ។





អាត្មាអញស្តាប់វាចាជាសុភាសិត ជាបទប្រកបដោយធម៌ និងអត្ថ (គឺប្រកបដោយហេតុផល ) ហើយពិចារណានូវសេចក្តីតាមគួរដល់ការពិត ដោយឧបាយនាំឱ្យកើតប្រាជ្ញា ។

អាត្មាអញមានបាបទាំងពួងលាងចេញហើយមិនមានមន្ទិល មានកិលេសលាងចេញហើយ ជាអ្នកស្អាតបរិសុទ្ធ ជាពុទ្ធទាយាទ (អ្នកគួរទទួលនូវមរតកអំពីព្រះពុទ្ធ ) ជាកូនកើតអំពីព្រះឱរា គឺទ្រូងនៃព្រះពុទ្ធ (មានទេសនាញាណនៃព្រះពុទ្ធជាសមុដ្ឋាន ) ។

អាត្មាអញចុះកាន់ខ្សែនៃមគ្គប្រកបដោយអង្គ ៨ ហើយបណ្តែតចោលនូវបាបទាំងពួង ដល់នូវវិជ្ជា ៣ សាសនារបស់ព្រះពុទ្ធ អាត្មាអញបានធ្វើស្រេចហើយ ។

## ៨ -ព្រះភារទ្វាជត្ថេរ

ព្រះភារទ្វាជត្ថេរ កាលដើមលោកជាព្រាហ្មណ៍នៅក្នុងក្រុងរាជគ្រឹះ មានបងប្អូន ៤ នាក់គឺ ទី ១ ភារទ្វាជៈ , ទី ២ អក្កោសកភារទ្វាជៈ, ទី ៣ អសុរិន្ទកភារទ្វាជៈ និងទី ៤ ពិលង្គិកភារទ្វាជៈ ជាត្រកូលដែលមានការប្រកាន់មាំទាំក្នុងសាសនាព្រាហ្មណ៍ មិនជ្រះថ្លាក្នុងព្រះពុទ្ធសាសនាឡើយ ។

ភារទ្វាជព្រាហ្មណ៍ បានរៀបការជាមួយនឹងនាង **ធនញ្ជានី**

ជាព្រះសោតាបន្នបុគ្គល ។ រាល់ពេលដែលនាងធនញ្ជានីកណ្តាស់ នាងតែងតែបន្លឺឧទានថា « **នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស** » ជានិច្ច ។ ការឧទានរបស់នាងធនញ្ជានី មិនជាទីពេញចិត្តរបស់ភារទ្វាជព្រាហ្មណ៍ដែលជាប្តីឡើយ ។ ថ្ងៃមួយព្រាហ្មណ៍មានការខឹងក្រោធនឹងប្រពន្ធជាខ្លាំង បានជេរប្រពន្ធរបស់ខ្លួនដោយពាក្យអាក្រក់ផ្សេងៗ ក្នុងរឿងដែលធនញ្ជានីឧទានសរសើរនូវព្រះគុណរបស់ព្រះសម្មាសម្ពុទ្ធហ្នឹងឯង ហើយបានពោលថា « ថ្ងៃនេះយើងនឹងទៅលើកវាទៈ សួរដេញដោល សង្កត់សង្កិន ដោយពាក្យសម្តីចំពោះគ្រូរបស់ហាងឯង » ។

នាងធនញ្ជានីបានពោលពាក្យបញ្ជូនព្រាហ្មណ៍ជាប្តី ដោយសេចក្តីថា « ក្នុងលោកនេះ ខ្ញុំមិនដែលឃើញអ្នកណាលើកវាទៈចំពោះព្រះដ៏មានព្រះភាគ ដែលធ្វើឱ្យព្រះអង្គដោះស្រាយពុំបាននោះឡើយ ប៉ុន្តែ ចូរព្រាហ្មណ៍អញ្ជើញទៅចុះ កាលទៅហើយនឹងដឹងពុំខាន » ។

ព្រាហ្មណ៍ខឹងអន់ចិត្ត ដើរចូលទៅកាន់វត្តវេឡុវ័ន ហើយលើកយកប្រស្នាមកទូលសួរ ក្នុងគំនិតគិតចំពោះព្រះដ៏មានព្រះភាគហាក់ដូចព្រះអង្គជាមនុស្សធម្មតា បញ្ញាឆ្លាតមិនដល់គាត់ ។

ព្រះដ៏មានព្រះភាគមានព្រះហឫទ័យករុណាសត្វដ៏ក្រៃលែង





ទ្រង់សម្តែងព្រះធម៌ឆ្លើយដោះប្រស្នារបស់ព្រាហ្មណ៍ បានធ្វើឱ្យព្រាហ្មណ៍មានការត្រឡប់ចិត្តជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ។ កាលជ្រះថ្លាហើយក៏សូមព្រះអង្គបួស កាលបានបួសហើយ ក៏តាំងចិត្តបដិបត្តិធម៌ដ៏យ៉ាងត្រឹមត្រូវ មិនយូរឡើយ លោកក៏បានសម្រេចជាព្រះអរហន្តមួយព្រះអង្គដែរ ។

សូម្បីព្រាហ្មណ៍ជាប្អូន កាលដែលបានដឹងថា បងប្រុសទៅបួសក្នុងព្រះពុទ្ធសាសនា ក៏ខឹងក្រោធខ្លាំងឥតឧបមា ចងគាថាជេរព្រះដ៏មានព្រះភាគ ដោយប្រការផ្សេងៗ ប៉ុន្តែភ្លើងកំហឹងទាំងអស់ត្រូវបានរលត់ដោយទឹក គឺព្រះហឫទ័យប្រកបដោយមេត្តា និងព្រះធម៌ទេសនារបស់ព្រះដ៏មានព្រះភាគ ក៏នាំគ្នាត្រឡប់ចិត្តជ្រះថ្លាក្នុងព្រះពុទ្ធសាសនា បានឧបសម្បទាហើយ មិនយូរប៉ុន្មានក៏បានសម្រេចជាព្រះអរហន្តគ្រប់អង្គដែរទៅ ។

បុគ្គល ដែលបានត្រឡប់ចិត្ត មកជ្រះថ្លានឹងព្រះគុណរបស់ព្រះសម្មាសម្ពុទ្ធ រមែងបានដើរនៅលើផ្លូវ ដែលឆ្ពោះមុខទៅរកទីបំផុតទុក្ខ ។ ឱហ្ន៎ ! ព្រះពុទ្ធត្រាស់ដឹងឡើងក្នុងលោក ដើម្បីបានជាប្រយោជន៍ដល់ពពួកជនច្រើនដ៏យ៉ាងក្រៃលែង ។

## ៩-ព្រះមហាបន្ថកត្ថេរ

ព្រះមហាបន្ថកត្ថេរ ជាបុត្ររបស់កូនស្រីនៃ **ធនសេដ្ឋី** នៅក្នុងក្រុងរាជគ្រឹះ ។ កូនស្រីសេដ្ឋីក្រុងរាជគ្រឹះរូបនេះបានលបលាក់ស្រឡាញ់គ្នាជាមួយនឹងទាសៈរបស់ខ្លួន ដោយខ្លាចក្នុងរឿងផ្សេងៗ ក៏បាននាំគ្នារត់ចេញពីស្រុក ជាប់ដោយទ្រព្យសម្បត្តិបន្តិចបន្តួចទៅជាមួយ ។

អាស្រ័យការនៅជាមួយគ្នា ទើបតាំងគភ៌ លុះគភ៌គ្រប់ខែ ក៏បានគិតថា ត្រូវប្រសូតបុត្រនៅផ្ទះញាតិ ។ នាងមានការនឹកផ្ទះ នឹកម៉ែ នឹកឪជាខ្លាំង ដោយខ្លួនធ្លាប់តែស្រណុក រស់នៅក្នុងការស្រឡាញ់ពេញបន្ទុកពីមាតាបិតា ព្រោះថានាងជាកូនស្រីតែមួយគត់ក្នុងត្រកូល ។ ទោះបីប្ដីនាងមិនអនុញ្ញាតក៏ដោយ នាងក៏ត្រូវដើរផ្លូវត្រឡប់មកផ្ទះ ដើម្បីប្រសូតបុត្រ ។ ក្នុងរវាងផ្លូវនោះឯង ត្រូវស្វាមីតាមឱ្យត្រឡប់ទៅវិញ ប៉ុន្តែមិនអាចត្រឡប់បាន ព្រោះឈឺពោះជិតប្រសូតទៅហើយ ទីបំផុតនាងក៏ប្រសូតបុត្រនៅរវាងផ្លូវនោះឯង ហើយបានដាក់ឈ្មោះឱ្យកូនប្រុសថា **បន្ថកៈ** ។

ក្រោយមកនាងតាំងគភ៌ ហើយប្រសូតបានកូនប្រុសម្នាក់ទៀត នៅតាមផ្លូវដូចមុនដែរ ទើបដាក់ឈ្មោះថា **ចូឡបន្ថកៈ** ឯកូនច្បងហៅថា **មហាបន្ថកៈ** ។ កាលក្មេងទាំងពីរចម្រើនវ័យដោយ





លំដាប់ហើយ បានទាមទារឱ្យម្ដាយនាំមករកលោកយាយ លោកតា ។ ព្រោះករុណាបុត្រ ទើបនាំកូនមកដល់ក្រុងរាជគ្រឹះ ហើយបញ្ជូនដំណឹងទៅជម្រាបដល់មាតាបិតា ។ ខ្លួនឯងសែននឹក តែពុំហ៊ានទៅជួបឡើយ ឱ! ព្រះជាម្ចាស់ដ៏មានគុណទាំងពីរអើយ កូនខុសហើយ សូមលោកទាំងពីរអភ័យទោសឱ្យកូនផង ។

សេដ្ឋីជាមាតាបិតា ទទួលចំពោះតែចៅទាំងពីរប៉ុណ្ណោះ មិនអាចឱ្យអភ័យដល់កូនស្រីនិងប្ដីនាងឡើយ បានបញ្ជូនដំណឹងមកប្រាប់កូនថា « បុគ្គលដែលមិនធ្លាប់ជាកូនក្នុងសង្សារវដ្តនេះមិនមានឡើយ ឯអ្នកទាំងពីរមានកំហុសចំពោះយើងខ្លាំងណាស់ មិនអាចមកជួបមុខយើងបានឡើយ តែក្មេងទាំងពីរដែលមិនមានកំហុសនោះ ត្រូវឱ្យមកនៅជាមួយយើង » ។

ធនសេដ្ឋី និងភរិយាបានបញ្ជូនទ្រព្យមួយចំនួនឱ្យមកកូនស្រីរបស់ខ្លួន និងប្ដីរបស់នាង ដើម្បីចិញ្ចឹមជីវិតក្នុងស្ថានទីដែលខ្លួនពេញចិត្ត ដោយមិនឱ្យកូនទៅរស់នៅជាមួយវិញឡើយ ។

ចំណែកពីរនាក់ប្ដីប្រពន្ធជាកូន ព្រោះខ្លួនមានកំហុស ក៏មិនហានតវ៉ាអ្វីទាំងអស់ ទោះជាស្រឡាញ់កូនប្រុសទាំងពីររបស់ខ្លួនស្មើជីវិត មិនប្រាថ្នាឱ្យកូនឃ្លាតពីដើមទ្រូងទៅឡើយក៏ដោយ ប៉ុន្តែដើម្បីអនាគតដ៏ស្រស់បស់ និងដើម្បីសេចក្ដីសុខរបស់កូនផង ទើប

កាត់ចិត្ត កាត់អាល័យព្រមដោយក្តីសោក វិយោគយោបំ ទទួលយកប្រាក់ ហាក់ដូចជាយកកូនទាំងពីរមកលក់ « សូមកូនទាំងពីរទៅនៅជាមួយលោកតា លោកយាយ ឱ្យបានសុខចុះ នេះជាកម្មពៀរ របស់ម្តាយ ... » ។

ក្នុងក្មេងទាំងពីរនាក់នោះ មិនមានភាពកក់ក្តៅដូចនៅជាមួយឪពុកម្តាយឡើយ ។ ចូឡបន្ថកៈនៅក្មេងតូចណាស់ ចំណែកមហាបន្ថកៈតែងតែទៅកាន់សំណាក់នៃព្រះដ៏មានព្រះភាគ តាមលោកតា បានឃើញព្រះសាស្តាព្រមដោយការស្តាប់ព្រះធម៌ ក៏កើតសទ្ធា ព្រោះភាពនៃបុគ្គលដែលសម្បូណ៌ដោយឧបនិស្ស័យ ហើយក៏សូមលោកតាបួស ។ លោកតាមានសេចក្តីត្រេកអរជាងអ្នកណាៗ ដែលបួសទាំងអស់ ក្រាបទូលដល់ព្រះបរមសាស្តា ហើយក៏ឱ្យចៅបានបព្វជ្ជា ក្រោយពីបព្វជ្ជាហើយ បានប្រឹងប្រែងសិក្សាបដិបត្តិបានជាបព្វជិតដ៏ល្អ ។

សាមណេរមហាបន្ថកៈ ព្យាយាមរៀននូវព្រះពុទ្ធវចនៈបានយ៉ាងច្រើន លុះព្រះជន្មគ្រប់ ២០ ឆ្នាំបរិបូណ៌ហើយ ក៏ឧបសម្បទាជាភិក្ខុ ។ សេចក្តីព្យាយាមនាំសេចក្តីសម្រេចមកឱ្យ ព្រះមហាបន្ថកៈបានតាំងចិត្តចម្រើនសមណធម៌ដោយសេចក្តីព្យាយាម មិនយូរប៉ុន្មានលោកក៏បានសម្រេចជាព្រះអរហន្ត ។



ព្រះមហាបន្ថកត្ថេរ លោកបានជាឯតទគ្គៈលើភិក្ខុទាំងឡាយផ្នែកខាងបញ្ញាវិវដ្តៈ ព្រោះលោកបានសម្រេចនូវអរូបាវចរជ្ឈានទាំង ៤ លុះចេញចាកពីអរូបជ្ឈានហើយ បញ្ញាវិវដ្តៈបានកើតឡើងគឺវិបស្សនា ដែលធ្វើឱ្យបានចូលដល់ព្រះនិព្វានជាវិវដ្តៈ នេះជាការឆ្លាតក្នុងវិបស្សនារបស់ព្រះថេរៈហ្នឹងឯង ។

ព្រះមហាបន្ថកត្ថេរ លោកត្រូវបានសង្ឃសន្មតឱ្យធ្វើជា **ភត្តុទ្ទេសក៍** គឺជាអ្នកចែកភត្ត និងជាអ្នកចាត់ចែងព្រះសង្ឃដើម្បីនិមន្តទៅទទួលទេយ្យទានអំពីទាយក ។

## ១០-ព្រះចូឡបន្ថកត្ថេរ

កាលដែលព្រះមហាបន្ថកត្ថេរ ណែនាំឱ្យប្អូនប្រុសបានបួសហើយ ចូឡបន្ថកៈនោះឯងមានកម្មពៀរជាប់មកជាមួយ ធ្វើឱ្យរៀនធម៌មិនចេះ ទន្ទេញធម៌មិនចាំទាល់តែសោះ ក៏ជាទីរង្កៀសនៃព្រះម្ចាស់បង ។ ព្រះមហាបន្ថកត្ថេរ បានពោលទៅរកលោកប្អូនដូច្នេះថា « បន្ថកៈ អ្នកជាមនុស្សអភ័ព្វក្នុងព្រះសាសនានេះ អ្នកមិនអាចចាំគាថាសូម្បីតែមួយបាទក្នុងពេល ៤ ខែ អ្នកនឹងធ្វើកិច្ចរបស់បព្វជិតឱ្យសម្រេចបានយ៉ាងដូចម្តេចទៅ អ្នកចូរចេញអំពីទីនេះទៅ » ។

ចូឡបន្ថកៈត្រូវលោកម្ចាស់បងបណ្តេញដូច្នេះ ទើបទៅឈរយំនៅខាងក្រោយព្រះវិហារ ។ សម័យនោះឯង ព្រះបរមសាស្តាទ្រង់ចូលគង់អាស្រ័យនៅនាក្រុងរាជគ្រឹះ ប្រថាប់នៅ **ជីវកម្ពវ័ន** ចម្ការស្វាយរបស់ពេទ្យជីវក ។ ពេទ្យជីវក បាននិមន្តព្រះសាស្តាព្រមដោយភិក្ខុ ៥០០ អង្គ ។ ព្រះមហាបន្ថកៈជាភត្តុទ្ទេសក៍ បានចាត់ចែងភិក្ខុទាំងអស់ វៀរតែចូឡបន្ថកៈ ។ ព្រះចូឡបន្ថកៈបានស្តាប់ពាក្យនោះហើយ ក៏ទោមនស្សតូចចិត្តដ៏ក្រៃលែង លោកយំដើរចេញពីវត្ត បំណងនឹងទៅសឹកចាកសិក្ខាបទ ។ ព្រះបរមសាស្តាប្រកបដោយព្រះមហាករុណាដ៏ធំធេង បានជ្រាបហើយក៏ព្រះអង្គទ្រង់យាងស្ទាក់ផ្លូវព្រះចូឡបន្ថកៈ ព្រះអង្គបានប្រាកដនៅចំពោះមុខហើយ ទើបទ្រង់ត្រាស់ថា :

**ពុទ្ធ**- បន្ថកៈដូចម្តេចបានជាយំ ?

**បន្ថកៈ**- លោកម្ចាស់បងបណ្តេញខ្ញុំព្រះអង្គ ។

**ពុទ្ធ**- បន្ថកៈលោកម្ចាស់បងរបស់អ្នកមិនមានអាសយានុសយញ្ញាណ ( ញាណដឹងអធ្យាស្រ័យ និងអនុស័យ ) ឡើយ អ្នកជាបុគ្គលដែលមានឧបនិស្ស័យនឹងតថាគត គួរសម្រាប់តែតថាគតជាអ្នកណែនាំប៉ុណ្ណោះ ។ ភ្លាមនោះព្រះអង្គទ្រង់សម្តែងឫទ្ធិបណ្តាលឱ្យកើតមានសំពត់មួយផ្ទាំងតូចស្អាតល្អ ហើយប្រទានឱ្យចូឡបន្ថកៈ





ទ្រង់ត្រាស់ប្រាប់ « បន្ថកៈ អ្នកចូរយកសំពត់មួយផ្ទាំងនេះ ភាវនាថា **រជោហរណំ រជោហរណំ** » ។

ចូឡបន្ថកៈ អង្គុយយកដៃស្ទាបសំពត់ដែលព្រះសាស្តាប្រទានឱ្យនោះ ភាវនាថា **រជោហរណំ រជោហរណំ** កាលស្ទាបចាប់ជូត ប៉ះពាល់ដល់រាងកាយនេះរឿយៗ សំពត់ក៏សៅហ្មងរហូតក្លាយទៅដូចជាសំពត់ជូតធ្នាំងបាយ ។ លោកអាស្រ័យបញ្ញាដែលចាស់ក្លា បានគិតឃើញនូវសំពត់នេះ ដែលស្អាតបរិសុទ្ធ តែដោយអាស្រ័យសរីរៈនេះ ទើបសៅហ្មង សូម្បីចិត្តនេះឯង ក៏មានគតិយ៉ាងដូច្នោះដែរ ហើយចម្រើនសមាធិ ធ្វើរូបាវចរជ្ឈាន ៤ ឱ្យប្រាកដ សម្រេចនូវព្រះអរហត្តព្រមដោយបដិសម្ភិទា ។ លោកសម្រេចបាននូវ **មនោមយិទ្ធិ** អាចធ្វើមនុស្សម្នាក់ឱ្យទៅជាច្រើននាក់បាន ហើយច្រើននាក់អាចធ្វើឱ្យបានទៅជាមនុស្សតែម្នាក់ក៏បាន ឯព្រះត្រៃបិដក និងអភិញ្ញា ៦ ក៏បានមកដល់ព្រះចូឡបន្ថកៈព្រមជាមួយនឹងព្រះអរហត្តនោះដែរ ។

ថ្ងៃស្អែកឡើង ព្រះសាស្តាស្តេចយាងទៅព្រមមួយអន្លើដោយភិក្ខុ ៥០០ អង្គ ប្រថាប់គង់ក្នុងនិវេសន៍របស់ពេទ្យជីវក ។ ចំណែកព្រះចូឡបន្ថកៈ លោកមិនបាននិមន្តទៅ ព្រោះលោកមិនបានទទួលនិមន្តនោះឯង ។ ដល់ពេលហើយ ពេទ្យជីវកចាប់ផ្តើម

ថ្វាយយាគូ ព្រះសាស្ដាទ្រង់យកព្រះហស្ដបិទបាត្រ ពេទ្យជីវកទូល សួរថា ព្រោះហេតុអ្វីព្រះអង្គ ទើបទ្រង់មិនទទួល ? ព្រះអង្គត្រាស់ថា នៅមានភិក្ខុ ១ អង្គទៀតក្នុងវិហារ ។

ពេទ្យជីវក បានបញ្ជូនបុរសម្នាក់ឱ្យទៅនិមន្តព្រះគុណម្ចាស់ ១ អង្គទៀតនៅឯវិហារ « អ្នកចូរទៅនិមន្តឱ្យឆាប់ » ។ កាលបុរសនោះឯងទៅជិតដល់ជីវកម្ពវ័ន ព្រះចូឡបន្ថកៈក៏បាននិម្មិតភិក្ខុ ១០០០ អង្គ ធ្វើមិនឱ្យដូចគ្នាឡើយ ហើយមួយអង្គៗប្រព្រឹត្តនូវសមណកិច្ចរៀងៗខ្លួន ។ បុរសនោះ ទៅដល់ឃើញភិក្ខុយ៉ាងច្រើនក្នុងវិហារ (គឺក្នុងវត្ត) ទើបត្រឡប់ទៅជម្រាបដល់ពេទ្យជីវកវិញថា «ជម្រាបប្រសាសន៍លោកនាយ ភិក្ខុក្នុងវិហារមានច្រើនអង្គណាស់ ខ្ញុំបាទមិនស្គាល់លោកម្ចាស់អង្គណា ដែលត្រូវនិមន្តនោះទេ » ។

ពេទ្យជីវកបានក្រាបទូលសួរព្រះបរមសាស្ដាថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុនៅក្នុងវិហារនោះ ព្រះនាមអ្វីព្រះអង្គ ?

**ពុទ្ធ–** ម្នាលជីវក លោកឈ្មោះ ចូឡបន្ថកៈ ។

ពេទ្យជីវកពោលទៅរកបុរសអ្នកបម្រើថា អ្នកចូរទៅសួរថា លោកម្ចាស់អង្គណាព្រះនាមចូឡបន្ថកៈ ហើយនិមន្តលោកមក ។

បុរសអ្នកបម្រើ មកដល់វិហារ សួរថា អង្គណាព្រះនាមចូឡបន្ថកៈ ? អាត្មាឈ្មោះចូឡបន្ថកៈ អាត្មាឈ្មោះចូឡបន្ថកៈ ទាំង





១០០០ អង្គ ក្នុងគ្រានោះឯង ។ បុរសនោះ បានត្រឡប់ទៅជម្រាបពេទ្យជីវកទៀតថា « ជម្រាបប្រសាសន៍លោកនាយ ភិក្ខុប្រមាណ ១០០០ អង្គ សុទ្ធតែឆ្លើយថា អាត្មាឈ្មោះចូឡបន្ថកៈ ខ្ញុំបាទមិនដឹងថា ចូឡបន្ថកៈអង្គណា ដែលត្រូវនិមន្ត » ។

ពេទ្យជីវកបានជ្រាបដោយន័យថា « ភិក្ខុមានឫទ្ធិ ព្រោះចាក់ផ្ទះនូវសច្ចៈ » ហើយបានពោលថា អ្នកចូរចាប់ជាយចីវរនូវភិក្ខុអង្គណាដែលឆ្លើយមុន ។ បុរសនោះទៅវិហារម្តងទៀត បានធ្វើតាមពាក្យរបស់ពេទ្យជីវកប្រាប់នោះឯង ក្នុងពេលនោះ ភិក្ខុប្រមាណ ១០០០ អង្គក៏បាត់អស់ទៅ ហើយបុរសអ្នកបម្រើក៏បាននាំព្រះចូឡបន្ថកៈមកកាន់និវេសន៍ តាមព្រះពុទ្ធបំណង រួចហើយព្រះបរមសាស្ដា ក៏ទ្រង់ទទួលនូវយាគូក្នុងគ្រានោះដែរ ។

កាលព្រះទសពលធ្វើភត្តកិច្ចស្រេចហើយ ស្ដេចទ្រង់យាងត្រឡប់មកកាន់វិហារ ។ ពួកភិក្ខុមានការសន្ទនានៅឯធម្មសភាសាលាថា « ធម្មតាព្រះពុទ្ធជាម្ចាស់ទាំងឡាយ មាននូវអានុភាពដ៏ធំយ៉ាងហ្នឹងហ្ន៎ ទ្រង់ធ្វើភិក្ខុដែលមិនអាចចាំគាថា ១ ក្នុងពេលរហូត ៤ ខែ ឱ្យទៅជាបុគ្គលមានឫទ្ធិច្រើនយ៉ាងនេះបាន » ។

ព្រះចូឡបន្ថកត្ថេរ បានជាឯតទគ្គៈលើភិក្ខុទាំងឡាយផ្នែក **ចេតោវិវដ្ដ:** និងខ្លាំងពូកែខាងមនោមយិទ្ធិ ។

អតីតជាតិរបស់ព្រះចូឡបន្ថកៈ លោកធ្លាប់ជាមនុស្សមានព្យាយាម ឆ្លាតក្នុងការសន្សំដូចជាមេឃ្មុំ ។ កាលដែលលោកកើតជាក្មេងកំសត់ម្នាក់ បានរើសកណ្តុរងាប់ យកទៅលក់ឱ្យអ្នកចិញ្ចឹមឆ្មា បានប្រាក់បន្តិចបន្តួចយកទៅទិញទឹកអំពៅ ចិត្តល្អឱ្យទឹកអំពៅដល់អ្នកច្រូតស្មៅ គេលក់ស្មៅបានប្រាក់ គេឱ្យមកខ្លះព្រោះតែស្រឡាញ់រាប់អាន ។ ក្មេងលែងកំសត់ ដោយសារមានអ្នករាប់អានច្រើន ទំនាក់ទំនងរកស៊ីទាំងផ្លូវគោក ទាំងផ្លូវទឹក រហូតបានប្រាក់រាប់សែនកហាបណៈ នឹកឃើញគុណ ចូឡកសេដ្ឋីដែលប្រាប់ឱ្យរើសកណ្តុរងាប់ ក៏យក ១ សែនកហាបណៈទៅជូន ជាការតបគុណ ។

ចូឡកសេដ្ឋី ឃើញក្មេងនោះថាជាមនុស្សល្អ ងាយប្រដៅ ឧស្សាហ៍ព្យាយាម ចិត្តល្អ ឆ្លាត ចេះសេពគប់មនុស្ស ចេះស្គាល់កាលៈទេសៈ និងជាពិសេសមានកតញ្ញូតាធម៌ ក៏លើកធីតារបស់ខ្លួនផ្សំផ្គុំឱ្យទៅ ក្រោយមកក៏បានជាសេដ្ឋីក្រុងពារាណសី ប្រកបដោយសិរីសួស្តី ។

ចូឡកសេដ្ឋី មិនមែនអ្នកដទៃណាឡើយ គឺជាព្រះបរម-ពោធិសត្វ បានជួយប្រាប់និមិត្តក្នុងរឿងកណ្តុរស្លាប់ និងជួយឱ្យបានជាសេដ្ឋីសម្រេចនូវសម្បត្តិលោកិយ នេះជាប្រវត្តិអតីតជាតិរបស់





ចូឡបន្ថកត្ថេរ ១ រឿង ។ ឯការមិនចាំធម៌ ព្រោះហេតុចំអកមាក់ងាយ ដល់បព្វជិតអ្នកមានសីលក្នុងព្រះសាសនានៃព្រះសម្មា-សម្ពុទ្ធអង្គមុននោះឯង ។

## ១១-ព្រះបិណ្ឌោលភារទ្វាជត្ថេរ

ព្រះបិណ្ឌោលភារទ្វាជៈ លោកមានការនិយាយពិត និងធ្វើពិត ទាំងមានសមត្ថភាពសម្តែងឥទ្ធិប្បាដិហារ្យដ៏អស្ចារ្យ ក្នុងរឿងយកបាត្រខ្លឹមចន្ទន៍ ដែលធ្វើឱ្យមនុស្សមានសេចក្តីជ្រះថ្លាដ៏ក្រៃលែងក្នុងក្រុងរាជគ្រឹះទៀតផង ។ លោកជាភិក្ខុមួយអង្គក្នុងអសីតិ-មហាសាវ័ក អាចរលឹកជាតិបានមួយសែនមហាកប្ប ព្រមទាំងជាឯតទគ្គៈលើភិក្ខុទាំងឡាយ ផ្នែកខាងបន្លឺសីហនាទ ។

នៅពេលដែលព្រះបិណ្ឌោលភារទ្វាជៈ បានសម្រេចជាព្រះ-អរហន្តហើយ លោកតែងតែនិមន្តពីកន្លែងមួយទៅកាន់កន្លែងមួយទៀត ដោយការបន្លឺសីហនាទក្នុងជំនុំសង្ឃថា « បុគ្គលណាមានសេចក្តីសង្ស័យក្នុងមគ្គ និងផល ចូរសួរដល់ខ្ញុំព្រះករុណាចុះ » ។

នៅក្នុងវិន័យបិដកលេខ ១០ ,ទំព័រ ១៤២ ខុទ្ទកវត្ថុក្ខន្ធកៈ មានសម្តែងអំពីការហោះទៅយកបាត្រខ្លឹមចន្ទន៍ ហើយព្រះបរម-គ្រូទ្រង់បញ្ញត្តសិក្ខាបទ ។ ក្នុងអដ្ឋកថាគម្ពីរធម្មបទ ពុទ្ធវគ្គ បាន

សម្ដែងជារឿងរ៉ាវខាងដើមដែលនាំឱ្យព្រះសម្មាសម្ពុទ្ធទ្រង់ប្រកាសសម្ដែងនូវយមកប្បាដិហារិយ៍ ។

ព្រះបិណ្ឌោលភារទ្វាជៈ បាននិមន្តទៅជួយសង្គ្រោះព្រាហ្មណ៍មិច្ឆាទិដ្ឋិម្នាក់ ដែលធ្លាប់ជាមិត្តសម្លាញ់កាលនៅពីគ្រហស្ថ ។ លោកបានពោលពីអានិសង្សនៃការឱ្យទានដល់ព្រាហ្មណ៍ ដែលព្រាហ្មណ៍នោះ ជាមនុស្សមានសេចក្ដីកំណាញ់ ។ ព្រាហ្មណ៍បានស្ដាប់ហើយ សម្ដែងទឹកមុខមិនល្អ ដោយគិតថា ព្រះថេរៈនេះបំណងនឹងញ៉ាំងទ្រព្យរបស់យើងឱ្យវិនាស ហើយបានពោលថា « ខ្ញុំនឹងប្រគេនអាហារមួយវែកដល់លោក »។ ព្រះថេរៈបានពោលថា « អ្នកចូរថ្វាយដល់ព្រះសង្ឃចុះ កុំថ្វាយដល់អាត្មាឡើយ »។ ព្រាហ្មណ៍សម្ដែងការមិនពេញចិត្តទៀតដោយគិតថា ព្រះថេរៈនេះបំណងនឹងឱ្យយើងថ្វាយទានដល់ភិក្ខុចំនួនច្រើន ។

ព្រះថេរៈបានញ៉ាំងព្រាហ្មណ៍ឱ្យជ្រះថ្លា ដោយនិមន្តព្រះ-ធម្មសេនាបតីមកសម្ដែងអំពីសង្ឃទាន ដែលមានផលច្រើន ។ ដើម្បីកុំឱ្យព្រាហ្មណ៍មានការយល់ច្រឡំថា លោកបបួលឱ្យធ្វើទាននេះ ព្រោះតែមានចំណង់ក្នុងរសនៃអាហារ លោកសម្ដែងជាព្រះថេរគាថា បញ្ជាក់ឱ្យដឹងថា លោកបានកំណត់ដឹងនូវអាហារដោយប្រការទាំងពួងហើយ ឯសេចក្ដីនៃព្រះគាថាគឺ :



ជីវិតនៃអាត្មានេះ រមែងមិនប្រព្រឹត្តទៅ នៅក្នុងការមិនសមគួរឡើយ (គឺមិនមានការចិញ្ចឹមជីវិតខុស ) អាហារមិនបានធ្វើចិត្តឱ្យស្ងប់ទេ អាត្មាឃើញថា រូបកាយតាំងនៅបានដោយសារអាហារ ទើបបានស្វែងរកអាហារក្នុងផ្លូវដ៏ប្រពៃ ។

ការសំពះ និងការបូជាណាដែលមានក្នុងត្រកូលទាំងឡាយ បណ្ឌិតទាំងឡាយ បានពោលនូវការសំពះ និងការបូជានោះថាជាអន្លង់ភក់ដ៏ស្អិត សរ គឺកិលេសដ៏ល្អិត គេដកបានដោយក្រ សក្ការៈក៏បុរសអាក្រក់លះបានដោយក្រដែរ ។

ព្រះបិណ្ឌោលភារទ្វាជត្ថេរ បានសម្ដែងនូវព្រះគាថា មានសេចក្ដីដោយប្រការដូច្នេះឯង ( បិដកលេខ ៥៦ , ទំព័រ ១៧៤ ) ។ ព្រាហ្មណ៍បានស្ដាប់នូវពាក្យទាំងនេះហើយ ក៏បានជាអ្នកមានសេចក្ដីជ្រះថ្លាដ៏ក្រៃលែងក្នុងព្រះថេរៈ ។

ក្នុងគម្ពីរឧទាន បិដកលេខ ៥២ , ទំព័រ ២១៣ ព្រះដ៏មានព្រះភាគទ្រង់ឧទាន ប្រារព្ធព្រះបិណ្ឌោលភារទ្វាជៈ។ ដោយព្រះអង្គទ្រង់ទតឃើញព្រះថេរៈប្រព្រឹត្តធុតង្គ ជាអ្នកប្រាថ្នាតិច មានសេចក្ដីសន្តោស មានសេចក្ដីស្ងប់ស្ងាត់ មិនទៅលាយឡំដោយពួក ប្រារព្ធព្យាយាម ជាអ្នកពោលពាក្យឱ្យមានព្យាយាមកម្ចាត់បង់នូវកិលេសប្រកបរឿយៗនូវអធិចិត្ត អង្គុយផ្គត់ភ្នែន តម្រង់កាយត្រង់ ក្នុងទីជិត

ព្រះអង្គ ។ លុះព្រះដ៏មានព្រះភាគ ទ្រង់ជ្រាបច្បាស់នូវសេចក្តីនោះ ហើយ ទើបទ្រង់បន្លឺឧទាននេះ ក្នុងវេលានោះថា :

**អនូបវាទោ អនូបឃាតោ　　បាតិមោក្ខេ ច សំវរោ**
**មត្តញ្ញុតា ច ភត្តស្មឹ　　បន្តញ្ច សយនាសនំ**
**អធិចិត្តេ ច អាយោគោ　　ឯតំ ពុទ្ធានសាសនន្តិ ។**

កិរិយាមិនតិះដៀលអ្នកដទៃ ១ , កិរិយាមិនបៀតបៀនអ្នកដទៃ ១ , កិរិយាសង្រួមក្នុងបាតិមោក្ខ ១ , ភាវៈដឹងប្រមាណក្នុងភត្តាហារ ១ , ទីដេកទីអង្គុយដ៏ស្ងាត់ ១ , កិរិយាបំពេញព្យាយាមក្នុងអធិចិត្ត ១ នោះជាពាក្យប្រដៅនៃព្រះពុទ្ធទាំងឡាយ ។

ក្នុងបិដកលេខ ៣៥ , ទំព័រ ២៥៤ ព្រះបិណ្ឌោលភារទ្វាជត្ថេរ បានសម្តែងធម៌ញ៉ាំងព្រះបាទឧទេនឱ្យជ្រះថ្លា ព្រះសូត្រនោះឈ្មោះថា **ភារទ្វាជសូត្រ** ដែលមានព្រះធម៌ទាំងស្រុងដូចតទៅ :

សម័យមួយ ព្រះមានព្រះភាគ និងព្រះបិណ្ឌោលភារទ្វាជៈមានអាយុ គង់នៅក្នុងវត្តឃោសិតារាម ជិតក្រុងកោសម្ពី ។ គ្រានោះព្រះបាទឧទេន ស្តេចចូលទៅរកព្រះបិណ្ឌោលភារទ្វាជៈមាន-អាយុ លុះស្តេចចូលទៅដល់ហើយ ទ្រង់ធ្វើសេចក្តីរីករាយជាមួយនឹងព្រះបិណ្ឌោលភារទ្វាជៈមានអាយុ លុះបញ្ចប់ពាក្យដែលគួររីក-រាយ និងពាក្យគួររលឹកហើយ ក៏ទ្រង់គង់ក្នុងទីដ៏សមគួរ ។ លុះ





ព្រះបាទឧទេន ទ្រង់គង់នៅក្នុងទីដ៏សមគួរហើយ ទើបទ្រង់មានព្រះបន្ទូលទៅនឹងព្រះបិណ្ឌោលភារទ្វាជៈមានអាយុដូច្នេះថា បពិត្រព្រះភារទ្វាជៈដ៏ចម្រើន អ្វីជាហេតុ អ្វីជាបច្ច័យ ដែលនាំឱ្យពួកភិក្ខុនេះ នៅក្មេងកំលោះ មានសក់ខ្មៅ ប្រកបដោយវ័យដ៏ចម្រើនគឺបឋមវ័យ មិនឈ្លក់នៅក្នុងកាមទាំងឡាយ ប្រព្រឹត្តព្រហ្មចរិយធម៌បរិបូណ៌ បរិសុទ្ធអស់មួយជីវិត ទាំងញ៉ាំងបវេណិធម៌ឱ្យប្រព្រឹត្តទៅអស់កាលយូរអង្វែងបាន ។ ព្រះបិណ្ឌោលភារទ្វាជៈថ្វាយព្រះពរថា បពិត្រមហារាជ ពាក្យនេះ ព្រះមានព្រះភាគ អរហន្ត សម្មាសម្ពុទ្ធព្រះអង្គនោះទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ បានត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរមក ចូរតាំងចិត្តឱ្យដូចជាមាតាក្នុងពួកស្រីល្មមជាមាតា ចូរតាំងចិត្តឱ្យដូចជាបងប្អូនស្រី ក្នុងពួកស្រីល្មមជាបងប្អូនស្រី ចូរតាំងចិត្តឱ្យដូចជាកូនស្រី ក្នុងពួកស្រីល្មមជាកូនស្រី ។ បពិត្រមហារាជ នេះឯងជាហេតុ នេះឯងជាបច្ច័យដែលនាំឱ្យពួកភិក្ខុនេះ នៅក្មេងកំលោះ មានសក់ខ្មៅ ប្រកបដោយវ័យដ៏ចម្រើនគឺ បឋមវ័យ មិនឈ្លក់នៅក្នុងកាមទាំងឡាយ ប្រព្រឹត្តព្រហ្មចរិយធម៌បរិបូណ៌ បរិសុទ្ធ អស់មួយជីវិត ទាំងញ៉ាំងបវេណិធម៌ឱ្យប្រព្រឹត្តទៅ អស់កាលយូរអង្វែងបាន ។

បពិត្រ ព្រះភារទ្វាជៈដ៏ចម្រើន ចិត្តជាធម្មជាតិឡេះឡោះ

ជូនកាល លោភធម៌កើតឡើងក្នុងពួកស្រី ល្មមជាមាតាក៏មាន លោភធម៌កើតឡើងក្នុងពួកស្រីល្មមជាបងប្អូនស្រីក៏មាន លោភធម៌កើតឡើងក្នុងពួកស្រីល្មមជាកូនស្រីក៏មាន ។ បពិត្រព្រះភារទ្វាជៈដ៏ចម្រើន ហេតុដទៃ បច្ច័យដទៃទៀត មានដែរឬ ដែលនាំឱ្យពួកភិក្ខុនេះ នៅក្មេងកំលោះ មានសក់ខ្មៅ ។បេ។ ទាំងញុំាងបវេណិធម៌ឱ្យប្រព្រឹត្តទៅអស់កាលជាយូរអង្វែងបាន ។ បពិត្រមហារាជ ពាក្យនេះ ព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ បានត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរមកអាយ ចូរពិចារណានូវកាយនេះឯង តាំងអំពីបាតជើងឡើងទៅលើ អំពីចុងសក់ចុះមកក្រោម ដែលមានស្បែកជាទីបំផុត ពេញដោយវត្ថុមិនស្អាត មានប្រការផ្សេងៗ ថា ក្នុងកាយនេះមាន សក់ រោម ក្រចក ធ្មេញ ស្បែក សរសៃ ឆ្អឹង ខួរក្នុងឆ្អឹង តម្រងទឹកមូត្រ បេះដូង ថ្លើម វាវ ក្រពះ សួត ពោះវៀនធំ ពោះវៀនតូច អាហារថ្មី អាហារចាស់ ប្រមាត់ ស្លេស្ម ខ្ទុះ ឈាម ញើស ខ្លាញ់ខាប់ ទឹកភ្នែក ខ្លាញ់រាវ ទឹកមាត់ ទឹកសម្បោរ ទឹករំអិល ទឹកមូត្រ ។ បពិត្រមហារាជ នេះឯងជាហេតុ នេះឯងជាបច្ច័យ ដែលនាំឱ្យពួកភិក្ខុនេះ នៅក្មេងកំលោះ មានសក់ខ្មៅ ។បេ។ ទាំងញុំាងបវេណិធម៌ឱ្យប្រព្រឹត្តទៅអស់កាល





ជាយូរអង្វែងបាន ។

បពិត្រ ព្រះភារទ្វាជៈដ៏ចម្រើន ភិក្ខុទាំងឡាយណា ដែលបានចម្រើនកាយ ចម្រើនសីល ចម្រើនចិត្ត ចម្រើនបញ្ញាហើយ កិច្ចគឺការពិចារណាឱ្យឃើញថាជាអសុភនោះ ភិក្ខុទាំងនោះ មិនមែនធ្វើបានដោយលំបាកឡើយ ។ បពិត្រព្រះភារទ្វាជៈដ៏ចម្រើន តែភិក្ខុទាំងឡាយណា ដែលមិនបានចម្រើនកាយ មិនបានចម្រើនសីល មិនបានចម្រើនចិត្ត មិនបានចម្រើនបញ្ញាហើយ កិច្ចនោះ ភិក្ខុទាំងនោះ ធ្វើបានដោយកម្រណាស់ ។ បពិត្រព្រះភារទ្វាជៈដ៏ចម្រើន ជួនកាលយើងខ្ញុំគិតថា នឹងធ្វើទុកក្នុងចិត្តថា អារម្មណ៍មិនល្អក៏ប្រែក្លាយទៅជាអារម្មណ៍ល្អវិញក៏មាន បពិត្រព្រះភារទ្វាជៈដ៏ចម្រើន ក្រែងមានហេតុដទៃ បច្ច័យដទៃទៀតដែរឬ ដែលនាំឱ្យពួកភិក្ខុនេះ នៅក្មេងកំលោះ មានសក់ខ្មៅ ។បេ។ ទាំងញុំាងបវេណិធម៌ឱ្យប្រព្រឹត្តទៅអស់កាលជាយូរអង្វែងបាន ។ បពិត្រមហារាជ ពាក្យនេះ ព្រះមានព្រះភាគអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ បានត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរមកអាយ ចូររក្សាទ្វារក្នុងឥន្ទ្រិយទាំងឡាយ អ្នកទាំងឡាយបានឃើញនូវរូបដោយចក្ខុហើយ កុំប្រកាន់និមិត្ត កុំប្រកាន់អនុព្យញ្ជនៈ អកុសលធម៌ទាំងឡាយដ៏

លាមកគឺអភិជ្ឈានិងទោមនស្ស គប្បីគ្របសង្កត់នូវបុគ្គលដែលមិនសង្រួមនូវឥន្ទ្រិយនុ៎ះ ព្រោះហេតុតែចក្ខុន្ទ្រិយណា អ្នកទាំងឡាយចូរប្រតិបត្តិ ដើម្បីសង្រួមនូវចក្ខុន្ទ្រិយនោះ ចូររក្សានូវចក្ខុន្ទ្រិយ ចូរដល់នូវសេចក្ដីសង្រួមក្នុងចក្ខុន្ទ្រិយ ។ ឮសំឡេងដោយត្រចៀក ។ ធុំក្លិនដោយច្រមុះ ។ ជញ្ជាបរសដោយអណ្ដាត ។ ពាល់ត្រូវផោដ្ឋព្វៈដោយកាយ ។ អ្នកទាំងឡាយដឹងច្បាស់នូវធម្មារម្មណ៍ដោយចិត្តហើយ កុំប្រកាន់និមិត្ត កុំប្រកាន់អនុព្យញ្ជនៈ អកុសល-ធម៌ទាំងឡាយដ៏លាមកគឺអភិជ្ឈានិងទោមនស្ស គប្បីគ្របសង្កត់នូវបុគ្គលដែលមិនសង្រួមមនិន្ទ្រិយនុ៎ះ ព្រោះហេតុតែមិនសង្រួមមនិន្ទ្រិយណា អ្នកទាំងឡាយ ចូរប្រតិបត្តិ ដើម្បីសង្រួមនូវមនិន្ទ្រិយនោះ ចូររក្សាមនិន្ទ្រិយ ចូរដល់នូវសេចក្ដីសង្រួមក្នុងមនិន្ទ្រិយ ។ បពិត្រមហារាជ នេះឯងជាហេតុ នេះឯងជាបច្ច័យ ដែលនាំឱ្យពួកភិក្ខុនេះ នៅក្មេងកំលោះ មានសក់ខ្មៅ ប្រកបដោយវ័យដ៏ចម្រើនគឺបឋមវ័យ មិនឈ្លក់នៅក្នុងកាមទាំងឡាយ ប្រព្រឹត្តព្រហ្មចរិយធម៌បរិបូណ៌ បរិសុទ្ធ អស់មួយជីវិត ទាំងញ៉ាំងបវេណិ-ធម៌ឱ្យប្រព្រឹត្តទៅ អស់កាលយូរអង្វែងបាន ។

បពិត្រព្រះភារទ្វាជៈដ៏ចម្រើន អស្ចារ្យណាស់ បពិត្រព្រះ-ភារទ្វាជៈដ៏ចម្រើន មិនដែលមានទេ ។ បពិត្រព្រះភារទ្វាជៈដ៏





ចម្រើន ពាក្យនេះ ព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ បានត្រាស់ទុកដោយប្រពៃហើយ បពិត្រព្រះភារទ្វាជៈដ៏ចម្រើន នេះហើយជាហេតុ នេះហើយជាបច្ច័យ ដែលនាំឱ្យពួកភិក្ខុនេះ នៅក្មេងកំលោះ មានសក់ខ្មៅ ប្រកបដោយវ័យដ៏ចម្រើនគឺបឋមវ័យ មិនឈ្លក់នៅក្នុងកាមទាំងឡាយ ប្រព្រឹត្តព្រហ្មចរិយធម៌បរិបូណ៌ បរិសុទ្ធ អស់មួយជីវិត ទាំងញ៉ាំងបវេណិធម៌ឱ្យប្រព្រឹត្តទៅ អស់កាលយូរអង្វែងបាន ។ បពិត្រព្រះភារទ្វាជៈដ៏ចម្រើន ចំណែកខ្ញុំករុណាវិញ សម័យណា មិនបានរក្សាកាយ មិនបានរក្សាវាចា មិនបានរក្សាចិត្ត មិនបានប្រុងស្មារតី មិនបានសង្រួមឥន្ទ្រិយ ចូលទៅក្នុងព្រះរាជវាំង សម័យនោះ លោភធម៌ទាំងឡាយ តែងគ្របសង្កត់ខ្ញុំករុណាពន់ពេក ។ បពិត្រព្រះភារទ្វាជៈដ៏ចម្រើន លុះតែសម័យណា ខ្ញុំករុណាបានរក្សាកាយ រក្សាវាចា រក្សាចិត្ត ប្រុងស្មារតី សង្រួមឥន្ទ្រិយ ចូលទៅក្នុងព្រះរាជវាំង លោភធម៌ទាំងឡាយ ក៏មិនបានគ្របសង្កត់ចិត្តខ្ញុំករុណាក្នុងសម័យនោះឡើយ ។ បពិត្រព្រះភារ-ទ្វាជៈដ៏ចម្រើន ច្បាស់ណាស់ បពិត្រព្រះភារទ្វាជៈដ៏ចម្រើន ច្បាស់ណាស់ ។ បពិត្រព្រះភារទ្វាជៈដ៏ចម្រើន ដូចគេផ្ងាររបស់ដែលផ្កាប់ ឬបើកបង្ហាញរបស់ដែលគេបិទបាំងទុក ឬដូចគេបង្ហាញផ្លូវដល់

បុគ្គលអ្នកវង្វេងទិស ពុំនោះសោត ដូចបុគ្គលទ្រោលបំភ្លឺប្រទីប ប្រេងក្នុងទីងងឹត ដោយគិតថា បុគ្គលទាំងឡាយមានចក្ខុ នឹងមើលឃើញរូបទាំងឡាយបាន មានឧបមាយ៉ាងណា ព្រះភារទ្វាជៈដ៏ចម្រើន បានប្រកាសធម៌ដោយអនេកបរិយាយ មានឧបមេយ្យយ៉ាងនោះដែរ ។ បពិត្រព្រះភារទ្វាជៈដ៏ចម្រើន ខ្ញុំករុណាសូមដល់ព្រះមានព្រះភាគនោះផង ព្រះធម៌ផង ព្រះសង្ឃផង ជាទីពឹងទីរលឹក សូមព្រះភារទ្វាជៈដ៏ចម្រើន ចាំទុកនូវខ្ញុំករុណាថាជាឧបាសក អ្នកដល់នូវសរណគមន៍ស្មើដោយជីវិត តាំងពីថ្ងៃនេះជាដើមរៀងទៅ ។

ក្នុងសាសនាព្រះពុទ្ធបទុមុត្តរៈ ព្រះថេរៈ លោកកើតជារាជសីហ៍នៅជើងភ្នំ ។ ព្រះសម្មាសម្ពុទ្ធទ្រង់បានយាងទៅចូលនិរោធសមាបត្តិក្នុងគុហារបស់រាជសីហ៍នោះឯង ។ រាជសីហ៍មានសេចក្តីជ្រះថ្លា បានបូជាដោយបុប្ផាសនៈ ទាំងដែលមានគំនិតថា បុគ្គលនេះពិតជាកំពូលនៃបូជនីយបុគ្គលក្នុងលោក ។ បានបន្លឺសីហនាទក្នុងបំណងបណ្តេញសត្វព្រៃទាំងឡាយ កុំឱ្យមកបៀត-បៀនព្រះសម្មាសម្ពុទ្ធ ព្រមទាំងប្រទក្សិណហើយថ្វាយបង្គំព្រះពុទ្ធដោយចិត្តជ្រះថ្លា ។

រាជសីហ៍អស់ជីវិត បានបដិសន្ធិជាមនុស្សនៅក្រុងហង្សវតី





បានបំពេញបុណ្យបារមីជាមួយព្រះសម្មាសម្ពុទ្ធបទុមុត្តរៈទៀត អស់ជីវិតបានទៅកាន់ទេវលោក និងមនុស្សលោក រហូតមកដល់ជាតិចុងក្រោយ លោកកើតក្នុងត្រកូលព្រាហ្មណមហាសាល នាក្រុងរាជគ្រឹះហ្នឹងឯង ។

**១២ -ព្រះរាធត្ថេរ**

ព្រះរាធៈ បដិសន្ធិក្នុងត្រកូលព្រាហ្មណ៍ ក្នុងក្រុងរាជគ្រឹះ ចម្រើនវ័យឡើងក៏បានរៀបការមានគ្រួសារ ប្រពន្ធកូនចៅ ប៉ុន្តែដល់ពេលចាស់ជរា បុត្រភរិយាត្រឡប់ជាមិនយកចិត្តទុកដាក់មើលថែរក្សាឡើយ ។

រាធព្រាហ្មណ៍គិតថា ប្រពន្ធកូនគេមិនត្រូវការខ្លួនហើយ ដូច្នេះយើងគួរតែទៅបួស មិនត្រូវឱ្យពេលវេលាកន្លងហួសទៅឥតប្រយោជន៍ទៀតឡើយ ។ គាត់ធ្វើដំណើរទៅវត្ត សូមបព្វជ្ជានឹងព្រះថេរៈទាំងឡាយ ប៉ុន្តែមិនមានអង្គណាប្រាថ្នាឱ្យគាត់បួសឡើយ ព្រោះថាគាត់ចាស់ជរាណាស់ទៅហើយ ។ ទោះជាយ៉ាងនេះក្តី គាត់ក៏មិនលះបង់នូវសេចក្តីព្យាយាមឡើយ បានជួយការងារព្រះសង្ឃផ្សេងៗ បោចស្មៅ បោសសម្អាតបរិវេណ និងថ្វាយវត្ថុមានទឹកសម្រាប់ប្រើប្រាស់ជាដើម ។

ក្រោយមកថ្ងៃមួយ ព្រះបរមសាស្តាបានត្រួតមើលសត្វលោកក្នុងវេលាជិតភ្លឺ បានឃើញឧបនិស្ស័យព្រះអរហន្តរបស់រាធ-ព្រាហ្មណ៍ ។ មានពេលវេលាដ៏សមគួរទើបទ្រង់យាងទៅកាន់សំណាក់រាធៈហើយទ្រង់ត្រាស់សួរថា :

**ពុទ្ធ–** ម្នាលព្រាហ្មណ៍ អ្នកដើរចុះឡើងធ្វើអ្វីហ្នឹង ?

**រាធៈ–** បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គធ្វើវត្តប្បដិបត្តិចំពោះភិក្ខុទាំងឡាយ ។

**ពុទ្ធ–** អ្នកបាននូវការសង្គ្រោះពីសំណាក់ភិក្ខុទាំងនោះឬ?

**រាធៈ–** បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបាននូវការសង្គ្រោះអំពីសំណាក់នៃភិក្ខុទាំងនោះចំពោះតែអាហារ ឯការបួសវិញពុំបានឡើយ ។

ព្រះសាស្តាទ្រង់ត្រាស់ឱ្យប្រជុំភិក្ខុសង្ឃ ព្រោះរឿងនេះឯងព្រះអង្គទ្រង់ត្រាស់សួរថា :

**ពុទ្ធ–** ម្នាលភិក្ខុទាំងឡាយ មានអង្គណារលឹកឃើញគុណរបស់ព្រាហ្មណ៍នេះ ដែរឬទេ ?

**សារីបុត្ត–**បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គរលឹកបាន គឺកាលខ្ញុំព្រះអង្គបិណ្ឌបាតនៅក្រុងរាជគ្រឹះ ព្រាហ្មណ៍បានថ្វាយភិក្ខា ១ វែក ខ្ញុំព្រះអង្គឃើញគុណរបស់ព្រាហ្មណ៍នេះឯង ។



**ពុទ្ធ–** សារីបុត្ត អ្នកចូរសង្គ្រោះព្រាហ្មណ៍ដែលមាននូវឧបការៈដល់អ្នក ឱ្យរួចផុតចាកទុក្ខមិនគួរឬ ?

**សារីបុត្ត–**ក្រាបទូលព្រះអង្គ សាធុ ! សាធុ ! ខ្ញុំព្រះអង្គនឹងបំបួសព្រាហ្មណ៍នេះ ។

ព្រះសារីបុត្ត ទទួលព្រះពុទ្ធតម្រាស់ ឱ្យរាធព្រាហ្មណ៍បួសលោកគិតថា « ព្រះសាស្តាទ្រង់ចាត់ចែងឱ្យព្រាហ្មណ៍នេះបានបួសដោយព្រះទ័យអើពើ ដូច្នេះអាត្មាអញមិនសមគួរមើលថែព្រាហ្មណ៍ដោយការមិនអើពើនោះឡើយ » ។ ព្រះសារីបុត្ត បានមើលថែព្រាហ្មណ៍ ដោយបានប្រគេនទីនៅដ៏ល្អស្អាត ប្រគេនបិណ្ឌបាតដ៏ប្រណីត ព្រមទាំងប្រាប់នូវព្រះកម្មដ្ឋានដ៏សមគួរទៀតផង។ ក្រោយមកព្រះរាធៈបានទូលសួរបញ្ហាធម៌ ចំពោះព្រះដ៏មានព្រះភាគក្រោយពីបានស្តាប់ធម៌របស់ព្រះបរមសាស្តាមក មិនយូរប៉ុន្មានព្រះរាធៈក៏បានសម្រេចនូវព្រះអរហត្ត ។

គ្រាកាលបន្ទាប់មក ព្រះសារីបុត្តបាននាំព្រះរាធៈចូលគាល់ព្រះសាស្តា :

**ពុទ្ធ–** សារីបុត្ត សិស្សរបស់លោកជាបុគ្គលទូន្មាន បានដោយងាយទេ ?

**សារីបុត្ត–** បពិត្រព្រះអង្គដ៏ចម្រើន ងាយទូន្មានណាស់ព្រះ-

អង្គ កាលដែលមានទោសទាស់ខុសក្នុងរឿងអ្វីៗ ខ្ញុំព្រះអង្គណែនាំ ហើយ លោកមិនដែលក្រោធឡើយ ។

**ពុទ្ធ**–សារីបុត្ត បើអ្នកបាននូវសទ្ធិវិហារិកដូចរាធៈទៀត តើអ្នកទទួលទេ ?

**សារីបុត្ត**–បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គទទួលទៀត សូម្បីច្រើនអង្គក៏ដោយ ។

ភិក្ខុទាំងឡាយបានពោលសរសើរព្រះសារីបុត្ត និងរាធៈ ក្នុងពេលដែលជួបសន្ទនាគ្នាថា « ព្រះសារីបុត្ត មានការដឹងគុណ និងការតបគុណណាស់ បានរលឹកឃើញនូវឧបការគុណរបស់ព្រាហ្មណ៍ សូម្បីគ្រាន់តែបាយ ១ វែក ។ ចំណែកព្រះរាធៈ ក៏ជាបុគ្គលមិនប្រមាទ ដឹងថាខ្លួនឯងចាស់ ក៏ខំប្រឹងប្រែងព្យាយាម អត់ធន់ចំពោះឱវាទ ជាបុគ្គលដែលទូន្មានបានដោយងាយ » ។

ព្រះរាធត្ថេរ មានបដិភាណអាចសម្ដែងធម៌តាមព្រះដ៏មានព្រះភាគដែលទ្រង់សម្ដែងហើយ បានយ៉ាងល្អឥតខ្ចោះ ដូច្នេះទើបព្រះសម្មាសម្ពុទ្ធតែងតាំងលោកជាភិក្ខុកំពូលគឺ ឯតទគ្គៈផ្នែកខាងប្រកបដោយបដិភាណ ។



## ១៣–ព្រះចន្ទាភត្ថេរ

ក្នុងធម្មបទដ្ឋកថា ព្រាហ្មណវគ្គ បានសម្ដែងអំពីប្រវត្តិរបស់លោក ។ នាមដើមរបស់លោកគឺ **ចន្ទាភកុមារ** កើតក្នុងត្រកូលព្រាហ្មណមហាសាល ក្នុងក្រុងរាជគ្រឹះ នៅពេលដែលលោកកើតមកភ្លាម មានពន្លឺអស្ចារ្យចេញពីខ្លួនដូចមណ្ឌលព្រះចន្ទ្រ មានផ្ចិតលោកជាចំណុចកណ្ដាលនៃពន្លឺនោះ ។

ក្នុងអតីតជាតិ លោកបានធ្វើបុណ្យដោយការយកលម្អិតខ្លឹមចន្ទន៍ក្រហម ទៅបូជាដល់ព្រះចេតិយមាសនៃព្រះកស្សបទសពលដល់ក្នុងបន្ទប់ចេតិយ រោយធ្វើជាមណ្ឌលព្រះចន្ទ្រក្នុងព្រះសុវណ្ណ-ចេតិយនោះ ។ ដោយអានិសង្សនេះឯង ទើបធ្វើឱ្យលោកកើតមកជាមនុស្សក្នុងជាតិចុងក្រោយនេះ មានពន្លឺរស្មីចេញពីខ្លួន ទៅណាមកណា មានពន្លឺដូចមណ្ឌលព្រះចន្ទ្រ ជាទីរីករាយនៃមាតាបិតាជាដើមដ៏ក្រៃលែង ដូច្នេះទើបត្រូវគេហៅថា **ចន្ទាភៈ** (ពន្លឺរស្មីនៃព្រះចន្ទ) ។

ពួកព្រាហ្មណ៍ បានឃើញថាជាការប្លែកដូច្នេះ ទើបនាំចន្ទាភកុមារ ទៅបង្ហាញដល់មហាជន ឱ្យមហាជនបានឃើញ បានស្ទាប ដោយប្រកាសថា ការបានស្ទាបដូច្នេះ នឹងបាននូវឥស្សរិយ-យស ។ ពួកជនបានចំណាយប្រាក់ច្រើនៗ ដើម្បីបានស្ទាបចន្ទាភ-

កុមារដោយការភ្ញាក់ផ្អើល ។ ដំណើរនេះ ព្រាហ្មណ៍ទាំងនោះបាន នាំចន្ទាភៈទៅដល់នគរសាវត្ថីជាលំដាប់ ហើយបានឈប់ត្រង់រវាងក្រុងនិងវត្តជេតពន ។

ពួកព្រាហ្មណ៍ទាំងនោះ បានឃើញអ្នកក្រុងសាវត្ថី នាំយកគ្រឿងសក្ការបូជាដើរចូលទៅកាន់វត្តជេតពនមហាវិហារ ដោយមិនបានយកចិត្តទុកដាក់នឹងចន្ទាភៈ មានតែការពោលសរសើរនូវព្រះដ៏មានព្រះភាគប៉ុណ្ណោះ ។ ព្រាហ្មណ៍បាននាំចន្ទាភៈចូលទៅក្នុងវត្ត ដើម្បីប្រកួតនូវពន្លឺនឹងព្រះដ៏មានព្រះភាគ ប៉ុន្តែលុះដល់ចូលទៅជិតព្រះសាស្តា រស្មីដូចមណ្ឌលព្រះចន្ទ្រនោះ ក៏រលត់បាត់ទៅអស់ ដល់ចេញឆ្ងាយពីព្រះសាស្តា រស្មីនោះក៏ត្រឡប់មានដូចដើម ព្រាហ្មណ៍បានពិសោធមើលយ៉ាងនេះ រហូតដល់ ២ ដងថែមទៀត។ ចន្ទាភៈបានគិតថា ព្រះគោតមប្រាកដជាចេះមន្តដែលធ្វើឱ្យពន្លឺបាត់អស់ទៅ ទើបទូលសួរបញ្ជាក់ :

**ចន្ទាភៈ–** ព្រះអង្គទ្រង់ជ្រាបនូវមន្ត ដែលសម្រាប់ធ្វើឱ្យបាត់ពន្លឺរស្មីពិតមែនឬ ?

**ពុទ្ធ–** ម្នាលចន្ទាភៈ ពិតមែនហើយ តថាគតដឹង ។

**ចន្ទាភៈ–** បើដូច្នោះ សូមព្រះអង្គទ្រង់ប្រទានឱ្យខ្ញុំព្រះអង្គផង ។





**ពុទ្ធ–** តថាគតមិនអាចឱ្យដល់បុគ្គលអ្នកមិនបួសបានឡើយ។

ចន្ទាភៈបានពោលជាមួយនឹងព្រាហ្មណ៍ទាំងនោះថា «បើខ្ញុំបានរៀនមន្តនេះហើយ ខ្ញុំនឹងបានជាបុគ្គលប្រសើរក្នុងជម្ពូទ្វីប បើដូច្នេះ សូមពួកលោក រង់ចាំបន្តិចសិនចុះ ខ្ញុំនឹងបួសរៀនមន្តត្រឹមតែ ២-៣ ថ្ងៃតែប៉ុណ្ណោះ » ។ ចន្ទាភៈបានទូលសូមបព្វជ្ជា ហើយក៏បានបួសក្នុងថ្ងៃនោះឯង ។ ព្រះបរមសាស្តាបានត្រាស់ប្រាប់អាការ ៣២ ដល់ព្រះចន្ទាភៈដែលទើបនឹងបួសថ្មី ព្រះអង្គត្រាស់ថា « នេះជាបរិកម្មនៃមន្ត អ្នកគប្បីស្វាធ្យាយចុះ »។

ពួកព្រាហ្មណ៍មកក្នុងរវាង១នោះ ហើយសួរថា លោករៀនមន្តបានហើយឬ ? ព្រះចន្ទាភៈតបថា អាត្មាកំពុងរៀន ។

ព្រះចន្ទាភៈ បានសម្រេចនូវព្រះអរហត្តផលដោយ ២-៣ ថ្ងៃតែប៉ុណ្ណោះ បន្ទាប់ពីបួសមកនោះឯង ។ ក្នុងពេលដែលពួកព្រាហ្មណ៍មកសួរលើកក្រោយ លោកពោលថា « អ្នកទាំងឡាយចូរទៅចុះ ឥឡូវនេះអាត្មាជាអ្នកមានធម៌ ដែលជាគ្រឿងសម្រាប់មិនចាំបាច់ទៅហើយ » ។

ព្រះដ៏មានព្រះភាគទ្រង់ត្រាស់នូវព្រះគាថា ប្រារព្ធចំពោះព្រះចន្ទាភៈដូច្នេះថា :

**ចន្ទំវ វិមលំ សុទ្ធំ វិប្បសន្នមនាវិលំ**
**នន្ទីភវបរិក្ខីណំ តមហំ ព្រូមិ ព្រាហ្មណំ ។**

តថាគត ហៅបុគ្គលដែលជាអ្នកបរិសុទ្ធ មានចិត្តថ្លាស្អាត មិនកករល្អក់ មានការរីករាយក្នុងភពរលត់អស់ហើយ ដូចព្រះចន្ទ ដែលប្រាសចាកនូវមន្ទិលនោះ ថាជាព្រាហ្មណ៍ ។

## ផ្នែកភិក្ខុនីអរិយសាវិកា

### ១-ព្រះនាងខេមាថេរី

ព្រះនាងខេមាភិក្ខុនី កើតក្នុងត្រកូលក្សត្រ ជាព្រះរាជធីតា នៃព្រះបាទមទ្ទរាជ នៃសាគលនគរ ព្រះនាងមានពណ៌សម្បុរដូចមាស ។

ព្រះនាងចម្រើនវ័យហើយក៏បានទៅជាអគ្គមហេសីនៃព្រះ-បាទពិម្ពិសារ នគរមគធៈ ។ គ្រាកាលព្រះបរមសាស្តា ទ្រង់គង់ប្រថាប់នៅនាវត្តវេឡុវន័ ព្រះនាងខេមាក្នុងកាលនោះ កំពុងស្រវឹងនឹងរូបរបស់ខ្លួន ព្រះនាងក្រែងថាព្រះសាស្តាទ្រង់សម្តែងនូវទោសរបស់រូប ទើបមិនដែលយាងទៅគាល់ព្រះសាស្តាម្តងណាឡើយ ។





ព្រះរាជា បានបញ្ជាឱ្យមនុស្សទាំងឡាយ ច្រៀងសរសើរវត្តវេឡុវន័ បីដូចនន្ទវន័ឧទ្យាននៅឋានទេវលោក ដែលធ្វើឱ្យព្រះ-ទេវីមានព្រះហឫទ័យចង់ទៅកំសាន្តព្រះវេឡុវន័មហាវិហារក្នុងគ្រានោះឯង ។ កាលព្រះទេវីក្រាបទូលព្រះរាជាអំពីបំណងរបស់ខ្លួន ព្រះរាជាត្រាស់ថា « បើនាងទៅព្រះវិហារ មិនបានជួបព្រះសាស្តាទេ នាងកុំត្រឡប់មកវិញឡើយ » រួចហើយព្រះរាជា បានឱ្យសញ្ញាដល់ពួករាជបុរសថា « ពួកលោកចូរឱ្យព្រះទេវីបានចូលគាល់ព្រះ-សាស្តាឱ្យខាងតែបាន ដោយកម្លាំងអាជ្ញា » ។

ព្រះទេវីបានយាងទៅកំសាន្តព្រះវិហារវេឡុវន័ រហូតកន្លះថ្ងៃ មិនបានជួបព្រះសាស្តា ព្រះនាងប្រាថ្នានឹងយាងត្រឡប់ ប៉ុន្តែត្រូវពួករាជបុរស បង្ខំនាំព្រះទេវីចូលគាល់ព្រះបរមសាស្តា រហូតទាល់តែបាន ។ ព្រះបរមសាស្តាទ្រង់ជ្រាបថា ព្រះទេវីកំពុងតែចូលមក ទ្រង់បាននិម្មិតស្រីម្នាក់រូបស្អាតដូចទេពអប្សរ ឈរនៅមិនឆ្ងាយអំពីព្រះអង្គឡើយ ហើយកាន់ផ្លិតបក់ថ្វាយព្រះអង្គទៀតផង។ ព្រះនាងខេមាទេវី បានទតឃើញស្ត្រីនោះ ទ្រង់ព្រះចិន្តាថា «នាងនេះរូបសែនស្អាត ប្រៀបបាននឹងស្រីទេពអប្សរ ឈរនៅមិនឆ្ងាយពីព្រះដ៏មានព្រះភាគ ចំណែកយើង មិនអាចប្រៀបនឹងនាងបានទេ » ។ ព្រះនាងខេមា បានកាន់យកនូវនិមិត្ត សម្លឹងមើលស្រី

នោះមិនដាក់ព្រះនេត្រ ដោយមិនបានយកចិត្តទុកដាក់នឹងសំឡេងព្រះធម៌ ដែលព្រះសាស្ដាកំពុងតែសម្ដែងនោះឡើយ ។ នៅពេលដែលព្រះនាងកំពុងតែសម្លឹងមើលនោះឯង ស្ត្រីនោះក៏កន្លងបឋមវ័យ មជ្ឈិមវ័យ ចូលដល់បច្ឆិមវ័យ ហើយធ្មេញបាក់ សក់ស្កូវ ស្បែកជ្រីវជ្រួញ ដួលចុះព្រមដោយផ្ចិតនៅនឹងដៃ ទៅតាមកម្លាំងអធិដ្ឋានរបស់ព្រះបរមសាស្ដា ។

ព្រោះហេតុដែលព្រះនាងបានបំពេញបារមីទុកមក ព្រះនាងបានទតឃើញហើយ ក៏បានគិតថា « សរីរៈនេះ សូម្បីស្អាតដល់ម្លឹងក៏គង់ដល់នូវវិបត្តិដូចនេះ ឯចំណែកសរីរៈរបស់យើង ក៏នឹងមាននូវគតិដូចគ្នាដែរ »។ លំដាប់នោះព្រះបរមសាស្ដា ទ្រង់បានជ្រាបនូវសេចក្តីត្រិះរិះរបស់ព្រះនាងខេមាដោយប្រការដូច្នេះហើយ ទ្រង់បានត្រាស់ព្រះធម៌ទេសនាដោយប្រការផ្សេងៗ ប្រារព្ធចំពោះរូបដែលប្រកបដោយទោសជាអនេក កាលព្រះនាងចុះកាន់ក្រសែធម៌ហើយ ព្រះអង្គទើបត្រាស់នូវព្រះគាថាធម្មបទក្នុងតណ្ហាវគ្គ :

**យេ រាគរត្តានុបតន្តិ សោតំ**
**សយំ កតំ មក្កដកោវ ជាលំ ។**
**ឯតម្បិ ឆេត្វាន វជន្តិ ធីរា**
**អនបេក្ខិនោ សព្វទុក្ខំ បហាយ ។**





សត្វទាំងឡាយណា ជាអ្នកត្រេកអរហើយដោយរាគៈ សត្វទាំងឡាយនោះ រមែងធ្លាក់ទៅដល់ក្រសែនៃតណ្ហា ដូចជាសត្វពីងពាងធ្លាក់ទៅកាន់សំបុក ដែលខ្លួនបានធ្វើហើយ យ៉ាងដូច្នោះឯង ។ អ្នកប្រាជ្ញទាំងឡាយ កាត់នូវក្រសែនៃតណ្ហានោះបានហើយ ជាអ្នកមិនមានសេចក្តីអាល័យ លះបង់នូវទុក្ខទាំងពួងទៅបាន ។

ព្រះនាងខេមា បានសម្រេចនូវព្រះអរហត្តផល ទូលលាព្រះរាជាបួសក្នុងព្រះពុទ្ធសាសនា ជាបុគ្គលអស់កង្វល់ទាំងពួងក្នុងលោក ព្រះនាងខេមា ជាអគ្គសាវិកាស្ដាំរបស់ព្រះដ៏មានព្រះភាគ និងជាកំពូលលើភិក្ខុនីទាំងឡាយផ្នែកខាងមានបញ្ញាច្រើន ។

ថ្ងៃមួយព្រះនាងខេមាថេរី អង្គុយសម្រាកពេលថ្ងៃនៅនឹងគល់ឈើមួយ ក្នុងខណៈនោះ មារមានចិត្តបាបបានប្លែងកាយជាមនុស្សប្រុសកំលោះចូលទៅរកព្រះនាង ហើយបានពោលលួងលោមដោយពាក្យថា :

ហៃនាងខេមា នាងនៅក្មេង ជាស្រីមានរូបស្អាត យើងសោតក៏នៅក្មេងកំលោះ នាងចូរមក យើងនឹងត្រេកត្រអាលដោយតូរ្យតន្ត្រីប្រកបដោយអង្គ ៥ ។

ព្រះនាងខេមាថេរី បានពោលគាថា (នៅក្នុងព្រះថេរីគាថា បិដកលេខ ៥៧,ទំព័រ ១៧១) ដោយសេចក្តីថា :

អាត្មានឿយណាយ ធុញទ្រាន់ ដោយកាយស្អុយ ដែលមានជំងឺជានិច្ច និងពុកផុយនេះ កាមតណ្ហា អាត្មាបានដកចេញហើយ។

កាមទាំងឡាយ មានឧបមាដូចជាលំពែង និងអណ្តោត ជាគ្រឿងកាប់ចិញ្ច្រាំនូវខន្ធទាំងឡាយ អ្នកនិយាយចំពោះតម្រេកក្នុងកាមណា ឥឡូវនេះ តម្រេកក្នុងកាមនោះ មិនជាទីត្រេកអរនៃអាត្មាទេ។

សេចក្តីរីករាយក្នុងអារម្មណ៍ទាំងពួង អាត្មាបានកម្ចាត់ចេញហើយ គំនរងងឹត អាត្មាក៏បានទម្លាយហើយ ម្នាលមារមានចិត្តបាប អ្នកចូរដឹងយ៉ាងនេះចុះ ម្នាលមារលាមក អ្នកឯងអាត្មាបានកម្ចាត់ចេញហើយ ។

ពួកជនពាល មិនដឹងតាមពិត សំពះនក្ខត្តឫក្សទាំងឡាយ បូជាភ្លើងក្នុងព្រៃ ហើយសម្គាល់ថាជាការបរិសុទ្ធ ។ ចំណែកខាងអាត្មា នមស្ការចំពោះព្រះសម្ពុទ្ធ ជាបុរសដ៏ខ្ពង់ខ្ពស់ អាត្មាជាអ្នកធ្វើតាមសាសនារបស់ព្រះសាស្តា បានរួចស្រឡះហើយចាកទុក្ខទាំងពួង ។



## ២ -ព្រះនាងភទ្ទកាបិលានីថេរី

ក្នុងកាលនៃព្រះសម្មាសម្ពុទ្ធ **បទុមុត្តរៈ** ព្រះថេរីកើតក្នុងនគរ **ហង្សវតី** ដឹងក្តីហើយ បានស្តាប់ព្រះធម៌ក្នុងសំណាក់ព្រះ-សាស្តា ឃើញព្រះសាស្តាតែងតាំងភិក្ខុនីមួយអង្គក្នុងតំណែងលើសភិក្ខុនីទាំងឡាយ ផ្នែកខាងរលឹកជាតិបាន ទើបបានបំពេញបុញ្ញាធិការប្រាថ្នាតំណែងនោះ ។

នាងបានបំពេញបុណ្យរហូតដល់អស់ជីវិត វិលវល់ក្នុងទេវ-លោក និងក្នុងមនុស្សលោក ។ កាលព្រះសម្មាសម្ពុទ្ធមិនទាន់បានត្រាស់ នាងកើតក្នុងក្រុងពារាណសី លុះដល់ពេញវ័យ ក៏បានទៅកាន់ត្រកូលខាងប្តី ។ ថ្ងៃមួយនាងបានឈ្លោះជាមួយនឹងប្អូនស្រីរបស់ប្តី កាលប្អូនថ្លៃស្រីថ្វាយបិណ្ឌបាតដល់ព្រះបច្ចេកពុទ្ធ នាងគិតថា « ស្រីនេះថ្វាយទានដល់ព្រះបច្ចេកពុទ្ធនេះហើយ នឹងបាននូវសម្បត្តិដ៏ច្រើនក្រៃលែង » លុះគិតដូច្នេះហើយ ក៏បានទៅយកបាត្រអំពីព្រះហស្តនៃព្រះបច្ចេកពុទ្ធ មកចាក់នូវភត្តាហារចោល ហើយដួសទឹកជ្រាំមកដាក់ពេញបាត្រថ្វាយព្រះបច្ចេកពុទ្ធ។ មហា-ជនបានត្មះតិះដៀលនាងថា « ស្រីពាល ព្រះបច្ចេកពុទ្ធធ្វើអ្វីខុសចំពោះនាងឯង បានជានាងឯងធ្វើយ៉ាងហ្នឹង » ។ នាងខ្មាសចំពោះពាក្យរបស់មនុស្សទាំងឡាយនោះ ហើយបានរត់ទៅទទួល

យកបាត្រមកម្តងទៀត ចាក់ទឹកជ្រាំចោល លាងបាត្រឱ្យស្អាត ជូត ឱ្យស្ងួត ហើយខាត់ដោយគ្រឿងក្រអូប យករបស់ដែលមានរស ឆ្ងាញ់ ៤ មុខ ដាក់ពេញក្នុងបាត្រ ហើយដាក់ដុំទឹកដោះគោដែល គេធ្វើដោយល្អ មានពណ៌ដូចផ្កាឈូក នៅពីខាងលើ រួចយកទៅ ថ្វាយដល់ព្រះបច្ចេកពុទ្ធ តាំងប្រាថ្នាថា « បិណ្ឌបាតនេះមានពណ៌ ល្អស្អាតយ៉ាងណា សូមឱ្យរូបកាយរបស់ខ្ញុំ មានពណ៌សម្បុរភ្លឺស្វាង យ៉ាងនោះឯង » ។

នាងចាកពីអត្តភាពនោះហើយ ទៅកើតនៅឯសុគតិភូមិ ទាំងឡាយតែប៉ុណ្ណោះ ក្នុងកាលនៃព្រះពុទ្ធកស្សបៈ នាងបានកើត នៅក្នុងក្រុងពារាណសី ជាសេដ្ឋីធីតា មានសម្បត្តិច្រើន ។ ដោយ ផលនៃកម្មចាស់ ធ្វើឱ្យនាងមានរូបស្អាត តែក្លិនស្អុយ មនុស្ស ទាំងឡាយរង្កៀសចំពោះនាង ព្រោះក្លិនស្អុយនោះឯង។ នាងកើត សេចក្តីសង្វេគពន់ពេក ទើបយកគ្រឿងអលង្ការប្រដាប់ប្រដាពាក់ នឹងខ្លួន សាងឥដ្ឋមាស ប្រតិស្ឋានព្រះចេតិយដើម្បីបញ្ចុះព្រះធាតុ នៃព្រះសម្មាសម្ពុទ្ធ ហើយបានយកផ្កាឧប្បលបូជាដល់ព្រះចេតិយ ទៀតផង ។

ដោយបុញ្ញកម្មនេះ រាងកាយរបស់នាង ស្រាប់តែមានក្លិន ក្រអូបផ្សព្វផ្សាយ ជាទីពេញចិត្តនៃពពួកជន នៅក្នុងជាតិនោះឯង



តែម្តង ។ នាងទើបជាទីពេញចិត្តរបស់ស្វាមី ហើយនាងបាន បំពេញកុសលរហូតអស់ជីវិត ចាកអត្តភាពនោះកើតក្នុងទេវលោក ទៀត សោយទិព្វសុខក្នុងទេវលោកអស់កាលយូរ ចាកទេវលោក មកជាព្រះរាជធីតានៃព្រះរាជានគរពារាណសី សោយសម្បត្តិដូច ជាសម្បត្តិទេវតាក្នុងក្រុងពារាណសីនោះឯង ។ នាងបានទំនុក-បម្រុងព្រះបច្ចេកពុទ្ធប្រមាណ ៥០០ អង្គ អស់កាលដ៏យូរ ជាមួយ នឹងព្រះបាទនន្ទរាជជាព្រះស្វាមី ។ កាលព្រះបច្ចេកពុទ្ធបរិនិព្វាន ទៅ ក៏កើតសេចក្តីសង្វេគ រួចក៏បានបួសជាតបស្សិនី ឯព្រះស្វាមីគឺ ព្រះបាទនន្ទរាជ ក៏បានបួសជាតាបសដូចគ្នា នៅនឹងព្រះរាជឧទ្យាន បានសម្រេចឈាន អស់ជីវិតក៏បានទៅកាន់ព្រហ្មលោក ។

លុះចុតិចាកព្រហ្មលោក ទាំងពីរអង្គគឺ បិប្ផលិមាណពនៅ នគរមគធៈ និងព្រះនាងភទ្ទកាបិលានីនៅសាគលនគរ ។ លុះព្រះ-នាងពេញវ័យហើយ មានរូបរាង និងពណ៌សម្បុរស្អាតជាងបដិមា មាសដែលវិចិត្រដោយស្នាដៃដ៏ចំណានទៅទៀត ។ ព្រះនាងបាន មកនៅនគរមគធៈ ក្នុងនាមជាភរិយារបស់បិប្ផលិមាណព តាម ឧបនិស្ស័យដែលធ្លាប់មានមក ។ កាលដែលបិប្ផលិមាណពចេញ បួស ព្រះនាងបានលះគំនរទ្រព្យរាប់ពាន់ដឹករទេះ លះបង់ពួកញាតិ និងលះអ្វីៗទាំងអស់ មិនអាឡោះអាល័យឡើយ ហើយចូលកាន់

ផ្នួសជាអ្នកមិនមានផ្ទះ ។

ព្រះនាងនៅក្នុងសំណាក់ដទៃ ៥ ឆ្នាំ ក្រោយមកមានភិក្ខុនីក្នុងព្រះពុទ្ធសាសនា ទើបព្រះនាងមកបព្វជ្ជាឧបសម្បទាក្នុងសំណាក់នៃព្រះនាងមហាបជាបតិគោតមីថេរី ចម្រើនវិបស្សនាបានសម្រេចព្រះអរហត្តផល ទ្រទ្រង់នូវសរីរកាយជាចុងក្រោយដោយមិនប្រាថ្នាអ្វីទាំងអស់ពីលោកនេះ រលត់តណ្ហា ជាបុគ្គលស្ងប់ ។

ព្រះនាងបានសម្រេចនូវឯតទគ្គៈលើភិក្ខុនីទាំងឡាយ ផ្នែកខាងការរលឹកជាតិបាន តាមដែលព្រះសាស្ដាទ្រង់បានតែងតាំង ។ មុនការរំលត់ខន្ធបរិនិព្វាន ផុតចាកវដ្តសង្សារដែលគួរភ័យខ្លាច និងខ្ពើមឆ្អើម ព្រះនាងបានឧទានជាព្រះថេរីគាថា ដែលមានសេចក្ដីដូចតទៅ :

ព្រះថេរៈនាមកស្សបៈ ជាបុត្រពុទ្ធទាយាទ មានចិត្តតម្កល់មាំល្អ លោកបានដឹងនូវបុព្វេនិវាស ទាំងបានឃើញនូវស្ថានសួគ៌ និងអបាយ ។

លំដាប់អំពីនោះមក លោកបានដល់នូវធម៌ជាទីអស់ទៅនៃជាតិ បានសម្រេចនូវអភិញ្ញា ជាអ្នកប្រាជ្ញ ជាព្រាហ្មណ៍ ប្រកបព្រមដោយវិជ្ជា ៣ គឺវិជ្ជា ៣ ដែលបានពោលហើយនោះឯង ។

(ព្រះថេរីពោលចំពោះខ្លួនឯងដូចពោលចំពោះអ្នកដទៃ)





ព្រះថេរីនាម ភទ្ទកាបិលានី ក៏យ៉ាងនោះដែរ បានសម្រេចវិជ្ជា ៣ ញាំងមច្ចុឱ្យសាបសូន្យ ឈ្នះមារព្រមទាំងវាហនៈ ហើយទ្រទ្រង់រាងកាយជាទីបំផុត ។

**( ព្រះថេរីគាថាចុងក្រោយដែលគួរឱ្យជ្រះថ្លាក្រៃលែង )**

**ទិស្វា អាទីនវំ លោកេ ឧភោ បព្វជិតា មយំ**
**ត្យម្ហ ខីណាសវា ទន្តា សីតិភូតម្ហ និព្វុតាតិ ។**

យើងទាំងពីររូបបានឃើញទោសក្នុងលោក ហើយមកបួសយើងទាំងពីរជាព្រះខីណាស្រព បានទូន្មានខ្លួនហើយ ជាអ្នកមានចិត្តត្រជាក់ បាននិព្វានហើយដែរ (ដោយសឧបាទិសេសនិព្វាន) ។

* -ព្រះនាងភទ្ទកាបិលានីថេរី មានអតីតជាតិមួយនោះ ជាមាតារបស់ព្រះសុវណ្ណសាមបរមពោធិសត្វ នាមនាងបារិកា ។

## ៣ -ព្រះនាងសិង្គាលមាតាថេរី

ព្រះនាងសិង្គាលមាតាថេរី ជាបុត្រីនៃសេដ្ឋីដែលមានទ្រព្យច្រើនក្នុងក្រុងរាជគ្រឹះ កាលដែលចម្រើនវ័យហើយ ក៏បានរៀបការមកនៅត្រកូលខាងប្ដី ដែលជាត្រកូលសេដ្ឋីនៅក្រុងរាជគ្រឹះផងដែរ ។ ព្រះនាងបានសម្រេចសោតាបត្តិផលជាមួយនឹងស្វាមី តាំងតែអំពីព្រះនាងមិនទាន់បានមកបួសម្ល៉េះ ជាពុទ្ធបរិស័ទដែលមាន

ចិត្តតាំងមាំក្នុងព្រះពុទ្ធសាសនា ។ ដោយសារព្រះនាងមានកូនប្រុសមួយ ដាក់ឈ្មោះថា « សិង្គាលកុមារ » ទើបព្រះនាងមាននាមថា « សិង្គាលមាតា » ។

សិង្គាលកុមារ ជាក្មេងរឹងរូស សូម្បីមាតាបិតាជាព្រះសោតាបន្នបុគ្គល ទូន្មានអប់រំគេយ៉ាងណា ក៏គេមិនព្រមស្តាប់ គេតែងពោលថា « ការចូលទៅរកសមណៈទាំងឡាយ ត្រូវថ្វាយបង្គំ កាលថ្វាយបង្គំត្រូវឱន ម្ល៉ោះហើយ ត្រូវឈឺខ្នងផង ឈឺជង្គង់ផង ប្រឡាក់ខោអាវផង នៅមានទៀត កាលអង្គុយជិតសមណៈទាំងនោះ ត្រូវសន្ទនា កាលសន្ទនាហើយរមែងស្និទ្ធស្នាល រួចត្រូវនិមន្ត ត្រូវថ្វាយចីវរ ថ្វាយបិណ្ឌបាតជាដើម ដែលធ្វើឱ្យវិនាសនូវទ្រព្យសម្បត្តិ ព្រោះហេតុដូច្នេះ ទើបកិច្ចដែលត្រូវចូលទៅរកសមណៈមិនមានដល់ខ្ញុំឡើយ » ។

ក្រោយមកបិតាមានជំងឺឈឺធ្ងន់ តែក៏នៅគិតដល់កូនដែលជាបុគ្គលមិច្ឆាទិដ្ឋិ ទើបប្រើឧបាយវិធីប្រាប់ឱ្យកូនប្រុសក្រោកអំពីព្រឹក ហើយទៅកាន់ផ្លូវបែកជា ៤ ធ្វើការសំពះទិសទាំង ៦ ។ ក្រោយពីបិតាអស់ជីវិតទៅ សិង្គាលមាណពចេះតែនឹកដល់បិតានោះឯង ហើយបានទៅកាន់ផ្លូវបែកជា ៤ ឈរសំពះទិសទាំង ៦ រាល់ព្រឹកព្រហាម ។



ថ្ងៃមួយព្រះបរមសាស្តា ទ្រង់ត្រួតមើលសត្វលោកដោយព្រះមហាករុណាសមាបត្តិញ្ញាណ ទើបឃើញឧបនិស្ស័យនៃសិង្គាលមាណព ទ្រង់យាងមកសម្តែងព្រះធម៌អំពីទិសទាំង ៦ ជាដើមដែលត្រូវគោរព ធ្វើឱ្យសង្គាលមាណពបានដល់នូវព្រះត្រៃសរណគមន៍ ថ្វាយបង្គំព្រះដ៏មានព្រះភាគ។ ក្រោយៗមកសិង្គាលមាណពបានបរិច្ចាគទ្រព្យ ៤០ កោដិ ទំនុកបម្រុងព្រះពុទ្ធសាសនា ក្រោយពីអស់ជីវិតបានទៅកាន់សុគតិភូមិ ។

ចំណែកសិង្គាលមាតា ក្រោយអំពីស្វាមីចែកឋានទៅ និងក្រោយអំពីកូនប្រុសបានដល់នូវព្រះត្រៃសរណគមន៍ហើយ ទើបបានបួសជាភិក្ខុនី នៅក្នុងសំណាក់ភិក្ខុនីនាក្រុងរាជគ្រឹះ ហើយប្រព្រឹត្តធម៌បានយ៉ាងល្អប្រពៃ មិនយូរប៉ុន្មាន ក៏បានសម្រេចនូវព្រះអរហត្តផល និងជាកំពូលលើភិក្ខុនីទាំងឡាយ ផ្នែកខាងរួចផុតដោយសទ្ធា ។

## ៩-ព្រះនាងសុភាជីវកម្ពវនិកាថេរី

ព្រះនាងសុភា ជាកូនស្រីនៃត្រកូលមហាសាលក្នុងក្រុងរាជគ្រឹះ កាលចម្រើនវ័យហើយ ក៏ជាស្ត្រីមានរូបស្អាត ជាពិសេសគឺភ្នែកទាំងគូរបស់នាង គឺស្អាតដូចជាភ្នែកកូនម្រឹគ រមែងជាទីគាប់

ភ្នែក គាប់ចិត្តនៃប្រុសៗទាំងឡាយ ។ កាលដែលមាតាបិតាឃើញថាមានបញ្ហា ព្រោះហេតុតែការដណ្តើមគ្នារវាងត្រកូលទាំងឡាយ ដែលចូលមកស្តីដណ្តឹងដើម្បីបានកូនស្រីខ្លួនដូច្នេះ ទើបសាកសួរកូនស្រី ថាតើត្រូវដោះស្រាយយ៉ាងណាក្នុងរឿងនេះ ។ កូនស្រីពោរពេញដោយឧបនិស្ស័យ នាងទើបឆ្លើយថា « កូននឹងបួសជាភិក្ខុនីដើម្បីដោះស្រាយបញ្ហាទាំងអស់នេះ ព្រមទាំងបញ្ហាផ្សេងទៀតក្នុងជីវិត សូមមាតាបិតា អនុញ្ញាតឱ្យកូនផងចុះ » ។

ព្រះនាងសុភា បានអប់រំបន្ទុំបារមីមករាប់ជាតិជាអនេកព្រះនាងមិនត្រូវការនូវកាមឡើយ កាលដែលមាតាបិតាអនុញ្ញាតហើយ ក៏បានចូលកាន់ផ្នួសក្នុងសំណាក់ភិក្ខុនី នាក្រុងរាជគ្រឹះហ្នឹងឯង ។ បន្ទាប់អំពីបួសហើយ បានតាំងចិត្តប្រព្រឹត្តតាមព្រះធម៌ព្រះវិន័យ ២-៣ ថ្ងៃប៉ុណ្ណោះក៏បានសម្រេចនូវព្រះអនាគាមិផល ។

ថ្ងៃមួយ មានបុរសអ្នកលេងស្រីម្នាក់ ជាអ្នកក្រុងរាជគ្រឹះហ្នឹងដែរ ឃើញព្រះថេរីនិមន្តដើរចូលទៅកាន់ជីវកម្ពវ័ន ក៏មានចិត្តស្រឡាញ់កើតឡើង ហើយបានឈរពាំងអំពីមុខព្រះនាង ហើយបបួលទៅក្នុងកាមគុណទាំងឡាយ ។

ដើម្បីប្រកាសទោសនៃកាមទាំងឡាយ និងអធ្យាស្រ័យក្នុងនេក្ខម្មៈរបស់ខ្លួនដោយប្រការផ្សេងៗ ទើបព្រះថេរីពោលពាក្យជា





ធម៌ ជាព្រះថេរីគាថាឱ្យអ្នកលេងនោះបានស្តាប់ មានសេចក្តីទាំងស្រុងដូចតទៅ :

(សុវណ្ណការបុត្រ ) ជាអ្នកលេង រារាំងភិក្ខុនីឈ្មោះសុភា កំពុងដើរទៅកាន់ជីវកម្ពវ័ន ជាទីរីករាយ ភិក្ខុនីឈ្មោះសុភា ក៏បានពោលនឹងសុវណ្ណការបុត្រនោះថា កំហុសដូចម្តេច ដែលអាត្មាប្រទូស្តដល់អ្នក បានជាអ្នកឈររារាំងអាត្មា នៃអាវុសោ បុរសមិនគួរប៉ះពាល់នូវស្ត្រីជាបព្វជិតទេ ។ សិក្ខាទាំងឡាយក្នុងសាសនារបស់ព្រះសាស្តា ជាសិក្ខាគួរគោរព ព្រះសុគតបានសម្តែងហើយដល់អាត្មា ហេតុដូចម្តេច ក៏អ្នកមកឈររាំងអាត្មា ដែលជាស្រីមានចំណែកនៃធម៌ដ៏បរិសុទ្ធ មិនមានទីទូលគឺកិលេស ។ អ្នកជាបុគ្គលមានចិត្តល្អក់ ប្រកបដោយធូលីគឺរាគៈ ហេតុដូចម្តេច ក៏អ្នកមកឈររាំងអាត្មា ដែលជាស្រីមានចិត្តថ្លាស្អាត ប្រាសចាកធូលី គឺរាគៈ មិនមានទីទូលគឺកិលេស មានចិត្តផុតស្រឡះហើយ (ចាកឧទ្ធបញ្ចកៈ ) ទាំងអស់ ។

(អ្នកលេងពោលថា ) នាងជាស្រីនៅក្រមុំផង មិនអាក្រក់ផង បព្វជ្ជានឹងធ្វើប្រយោជន៍អ្វីដល់នាង ចូរនាងបោះចោលកាសាយចីវរចេញទៅ ហើយចូរមក យើងនឹងបានត្រេកត្រអាលក្នុងព្រៃដែលមានផ្ការីកល្អ ។ ដើមឈើទាំងឡាយ ហាក់ដូចជាតាំង

ឡើងដោយលំអងផ្កា បក់ផ្សព្វផ្សាយនូវក្លិនដ៏ក្រអូបសព្វទិស (នេះ) ជាវសន្តរដូវ ជាដំបូង ជារដូវនាំមកនូវសុខ នាងចូរមក យើងនឹងត្រេកត្រអាលក្នុងព្រៃ ដែលមានផ្ការីកល្អ ។ ដើមឈើទាំងឡាយមានចុងស្កុះស្កាយដោយផ្កា លុះត្រូវខ្យល់បក់មក ក៏ហាក់ដូចជាបន្លឺសំឡេងឡើង ប្រសិនបើ នាងនឹងចូលទៅក្នុងព្រៃម្នាក់ឯង នាងនឹងត្រេកត្រអាលដូចម្ដេចកើត ។ នាងជាស្ត្រីឥតមិត្តសម្លាញ់ ចង់ទៅកាន់ព្រៃធំ ដែលប្រាសចាក (មនុស្ស )គួរឱ្យស្ញប់ស្ញែង ជាព្រៃដែលហ្វូងម្រឹគសាហាវនៅអាស្រ័យ ជាព្រៃដែលដំរីចុះប្រេង និងមេដំរីបុកបែន ។ នាងប្រៀបដូចរូបតុក្កតាដែលសូនដោយមាសឆ្អិន ឬដូចជាស្ត្រីទេពអប្សរ ត្រាច់ទៅក្នុងឧទ្យានឈ្មោះចិត្តរថ ម្នាលនាងជាស្ត្រីល្អឥតឧបមា នាងល្អដោយសំពត់សម្រាប់ស្លៀកដណ្ដប់ មានសាច់ដ៏ល្អិតសុខុម ដែលកើតក្នុងដែនកាសី ។ បើនាងនៅក្នុងចន្លោះព្រៃ ខ្ញុំនឹងលុះក្នុងអំណាចនៃនាង ម្នាលនាងជាស្ត្រីមានភ្នែកស្រទន់ដូចកិន្នរី ជីវិត (របស់ខ្ញុំ ) ជាទីស្រឡាញ់ក្រៃលែងជាងនាងមិនមានទេ ។ បើនាងនឹងធ្វើតាមពាក្យខ្ញុំ នាងចូរមក ចូរនៅគ្រប់គ្រងផ្ទះជាសុខចុះ នាងនឹងនៅក្នុងប្រាសាទមិនមានខ្យល់ ពួកនាងនារី ចូរធ្វើនូវការខ្វល់ខ្វាយបម្រើដល់នាង ។ ចូរនាងទ្រទ្រង់នូវសំពត់ មានសាច់ម៉ដ្ឋដែលនាំមកអំពីដែនកាសី





ចូរនាងតែងខ្លួនដោយផ្កាកម្រងនិងគ្រឿងលាបចុះ ខ្ញុំនឹងផ្គត់ផ្គង់គ្រឿងអាភរណៈផ្សេងៗច្រើនយ៉ាង ដែលរចនាហើយដោយមាសកែវមណី និងកែវមុក្តាដល់នាង ។ ចូរនាងឡើងកាន់ដំណេកថ្មីល្អដែលស្អាតគ្មានធូលី ព្រោះជម្រះលាងប្រពៃ ដែលក្រាលដោយកម្រាលរោមចៀម ញាត់ដោយសំឡី មានតម្លៃច្រើន ប្រដាប់ដោយខ្លឹមចន្ទន៍ មានក្លិនក្រអូប ។ នាងជាស្ត្រីប្រព្រឹត្តព្រហ្មចារ្យ នាងនឹងដល់នូវការចាស់គ្រាំគ្រា ត្រង់អវយវៈទាំងឡាយរបស់ខ្លួន ដូចជាផ្កាឧប្បលលូតផុតពីទឹក ដែលអមនុស្សហួងហែងរក្សា (នឹងជាវត្ថុឥតមានអ្នកណាប្រើប្រាស់កើត ) ។

(នាងថេរីពោលថា ) ហេតុដូចម្ដេច ក៏អ្នកមានគំនិតខុសសម្លឹងមើល (អាត្មា ) ព្រោះឃើញនូវអារម្មណ៍ដែលសន្មតថាមានខ្លឹម ក្នុងរាងកាយនេះ ដ៏ពេញដោយសាកសព គ្រាន់តែការចម្រើនរបស់ព្រៃស្មសាន ជារាងកាយបែកធ្លាយជាធម្មតា ។

(អ្នកលេងពោលថា ) ភ្នែកទាំងឡាយ (របស់នាង ) ដូចជាភ្នែកកូនម្រឹគញី ឬដូចជាភ្នែកនៃកិន្នរី ក្នុងចន្លោះនៃភ្នំ តម្រេកក្នុងកាមរបស់ខ្ញុំ រមែងចម្រើនក្រៃលែង ព្រោះឃើញនូវភ្នែករបស់នាង ។ កាមគុណរបស់ខ្ញុំ រមែងចម្រើនឡើងក្រៃលែង ព្រោះឃើញភ្នែករបស់នាង ដែលប្រៀបដោយត្របកនៃផ្កាឧប្បល ត្រង់

មុខប្រាសចាកមន្ទិល ប្រាកដស្មើដោយមាស ។ នែនាងមានរូបស្រស់ស្រោង មានភ្នែកថ្លាស្អាត បើទុកជាយើងទៅកាន់ទីឆ្ងាយ ក៏នៅតែឃើញ ម្នាលនាងមានភ្នែកថ្លាដូចភ្នែកកិន្នរី ឥតមានអ្វីមួយជាទីស្រឡាញ់នៃខ្ញុំ ជាងភ្នែករបស់នាងទេ ។

(នាងថេរីពោលថា ) អ្នកប្រាថ្នានូវធីតា ជាឱរសរបស់ព្រះពុទ្ធ (នេះ ) ឈ្មោះថាប្រាថ្នាដើម្បីដើរទៅកាន់ផ្លូវខុស ឈ្មោះថាស្វែងរកព្រះចន្ទមកធ្វើជាល្បែង ឈ្មោះថាប្រាថ្នាដើម្បីលោតឡើងកាន់ភ្នំសិនេរុ ។ ឥឡូវនេះ ប្រសិនបើរាគៈគប្បីមានដល់អាត្មាក្នុងអារម្មណ៍ណា អារម្មណ៍នេះមិនមានក្នុងលោក ព្រមទាំងទេវ-លោក អាត្មាមិនដឹងនូវដំណើរនោះថា មានភាវៈអ្វីស្មើ (ដោយរាគៈ ) ទេ បានជា (រាគៈនោះ ) អាត្មាដកចោលទាំងឫសដោយអរិយមគ្គហើយ ។ (រាគៈនោះ ) អាត្មាបានកម្ចាត់ចេញហើយ ដូចជាភាជនៈដាក់នូវថ្នាំពិស ដែលបុគ្គលបោះចោលក្នុងរងើកភ្លើងហើយ អាត្មាមិនឃើញនូវដំណើរនោះថា មានសភាវៈអ្វីស្មើ (ដោយរាគៈ ) ទេ បានជា (រាគៈនោះ )អាត្មាដកចោលទាំងឫសដោយអរិយមគ្គហើយ ។ ខន្ធបញ្ចកៈ ដែលស្ត្រីណា មិនបានពិចារណាឃើញ ឬថាស្ត្រីណាដែលមិនបានចូលទៅអង្គុយជិតព្រះ-សាស្តា អ្នកចូរប្រលោមនូវស្ត្រីប្រាកដដូច្នោះចុះ អ្នកនោះនឹង





ចង្អៀតចង្អល់ (ព្រោះអាស្រ័យ ) ភិក្ខុនីនេះ ជាអ្នកដឹង (អរិយ-សច្ចៈ ) ។ ព្រោះថាស្មារតីរបស់អាត្មាបានតម្កល់ខ្ជាប់ហើយ ក្នុងបុគ្គលអ្នកជេរ និងអ្នកថ្វាយបង្គំ ក្នុងសុខនិងទុក្ខ ចិត្តរបស់អាត្មាមិនជាប់ក្នុងអារម្មណ៍ទាំងអស់នោះ ព្រោះដឹងច្បាស់ថា សង្ខតា-រម្មណ៍ ជារបស់មិនស្អាត ។ អាត្មាជាសាវិការបស់ព្រះសុគត ជាអ្នកដើរទៅដោយយានគឺអដ្ឋង្គិកមគ្គ មានសរគឺកិលេសដកចោលហើយ ឥតមានអាសវៈ ជាអ្នកត្រេកអរក្នុងផ្ទះស្ងាត់ ។ ព្រោះថាអាត្មាបានឃើញរូបយន្តឈើជាគ្រោងថ្មីដែលតាក់តែងដ៏វិចិត្រ ចងរឹតដោយខ្សែសរសៃទាំងឡាយ និងឈើកន្លាស់ទាំងឡាយដូចជាគេរាំដោយអាការផ្សេងៗ ។ កាលដែលខ្សែសរសៃនិងឈើកន្លាស់ដាច់រដកចេញរាត់រាយរលុងរង្គោះបាក់បែកខ្ចាត់ខ្ចាយ កាលបើរូប-យន្តរង្គោះដាច់ខ្ចាត់ខ្ចាយហើយ បុគ្គលមិនគប្បីបាន (រូបយន្តនោះ) ទេ បុគ្គលគប្បីតម្កល់ចិត្តក្នុងរូបនោះ ដូចម្តេចកើត ។ រាងកាយទាំងឡាយរបស់ខ្ញុំដូចគ្នានឹងរូបយន្តដែរ បើវៀរចាករូបធម៌មានចក្ខុជាដើមនោះហើយ រមែងប្រព្រឹត្តទៅមិនបាន រាងកាយបើវៀរចាករូបធម៌ហើយ ប្រព្រឹត្តទៅមិនបានទេ បុគ្គលគប្បីតម្កល់ចិត្តក្នុងរាងកាយនោះដូចម្តេចកើត ។ បុគ្គលឃើញរូបស្ត្រី ដែលគេគូរនឹងជញ្ជាំង លាបលនដោយថ្នាំដ៏ស្រស់យ៉ាងណាមិញ អ្នកមានការ

ឃើញវិបរិតក្នុងរូបនោះ ក៏យ៉ាងនោះដែរ បញ្ញាជារបស់មនុស្សឥតប្រយោជន៍ទេឬ ។ នៃបុគ្គលអន្ធពាល អ្នកស្ទុះចូលមកជិតនូវអត្តភាពដ៏ទទេ ដែលប្រៀបដូចជាថ្ងៃបណ្តើរកូនតាំងនៅក្នុងខាងមុខ ឬដូចជាយល់សប្តិឃើញដើមឈើមាស ពុំនោះដូចជារូបយន្តគ្រាំគ្រាក្នុងកណ្តាលនៃជន ។ ពពុះបាំងស្បែកកណ្តាលភ្នែក ឬពព្រៀកភ្នែក ឬក៏ពកបាយភ្នែក តែងកើតក្នុងមណ្ឌលនៃភ្នែកនោះ ដូចជាពពុះទឹកល័ក្ត ដែលបុគ្គលប្រោះលើកម្រាលរោមចៀមស្ងួត ព្រោះថា សណ្ឋានរបស់ភ្នែក មានពណ៌ផ្សេងៗ ដែលសង្ខារតាក់តែងហើយ ។

នាងសុភាភិក្ខុនី មានចិត្តឥតជាប់ជំពាក់ បានឆ្កៀលភ្នែកជាទីស្រឡាញ់ មិនជាប់ជំពាក់ ហើយក៏ឱ្យដល់បុរសនោះក្នុងពេលនោះ ដោយពាក្យថា ហ៏!អាត្មាឱ្យភ្នែកដល់អ្នក ចូរអ្នកយកភ្នែកនេះទៅចុះ ។ រាគៈរបស់បុរសនោះ ក៏ប្រាសចេញក្នុងខណៈនោះផង បុរសនោះបានញ៉ាំងភិក្ខុនីនោះឱ្យអត់ទោសក្នុងទីនោះផង ដោយពាក្យថា ម្នាលនាងជាព្រហ្មចារិនី សួស្តីចូរមាន (ដល់នាង ) ការប្រព្រឹត្តអនាចារបែបនេះ នឹងមិនមានដល់ខ្ញុំទេ ។ បើខ្ញុំបៀតបៀនជន (ដែលគ្មានរាគៈ) យ៉ាងនេះ ក៏ហាក់ដូចជា ខ្ញុំឱបភ្លើងកំពុងឆេះសន្ធោសន្ធៅ ឬចាប់នូវអាសិរ្ពិស បើដូច្នោះ សូមសួស្តីកើត



មានដល់នាង សូមនាងអត់ទោសដល់ខ្ញុំ ។

ភិក្ខុនីនោះ លុះរួចអំពីបុរសជាអ្នកលេងនោះហើយ ក៏បានទៅកាន់សំណាក់នៃព្រះពុទ្ធដ៏ប្រសើរ ចក្ខុក៏កើតឡើងដូចពីដើម ព្រោះបានឃើញនូវមហាបុរិសលក្ខណៈ ដែលកើតអំពីបុញ្ញសម្ភារដ៏ប្រសើរ ។

(សុភាថេរីនៅក្នុងជីវកម្ពវន័ បិដកលេខ ៥៧ ទំព័រ ២១១-២១៧ )

## ៥ -ព្រះនាងកុណ្ឌលកេសីថេរី

ព្រះនាងកុណ្ឌលកេសី មាននាមដើមថា នាង **ភទ្ទា** ជាកូនស្រីនៃមហាសេដ្ឋីក្រុងរាជគ្រឹះ ។ នាងចម្រើនវ័យឡើង មានរូបឆោមស្អាតស្រស់ត្រកាល ជាទីស្រឡាញ់ និងជាទីហួងហែងនៃមាតាបិតាដ៏ក្រៃលែង បានឱ្យកូនស្រីនៅតែលើប្រាសាទជាន់ទី ៧ ប៉ុណ្ណោះ ។

ក្រោយមក នាងភទ្ទាបានមើលពីលើប្រាសាទមកក្រោម ឃើញចោរម្នាក់ដែលគេចាប់បាន វាយបណ្តើរតាមថ្នល់ ដើម្បីប្រកាសឱ្យអ្នកក្រុងបានដឹងថា ធ្វើចោរត្រូវមានទោសប្រហារជីវិត។ ពេលនោះនាងភទ្ទា ស្រាប់តែមានចិត្តស្រឡាញ់ចោរនោះ រហូត

ដល់ថ្នាក់ដកចិត្តមិនរួច ទើបដេកអត់អាហារ ។ មាតាបិតាបានជ្រាបដំណឹងទើបឡើងមកសាកសួរ នាងបានជម្រាបថា « បើមិនបានចោរនោះជាប្តីទេ កូនប្រាកដជា មិនមានជីវិតបន្តទៅទៀតឡើយ » ។ មាតាបិតាបានត្រឹមតែអង្វរករកូនស្រីថា កុំធ្វើដូច្នេះឡើយ មាតាបិតានឹងរកស្វាមីដែលមានត្រកូលល្អ ថានៈល្អមកឱ្យប៉ុន្តែត្រូវកូនបដិសេធដាច់អហង្ការថា អត់ត្រូវការប្តីដទៃឡើយបានតែប្រុសនោះឯង ។ ម៉ែឪទាល់គំនិត ភ័យខ្លាចកូនស្រីស្លាប់ត្រូវចំណាយប្រាក់ដ៏ច្រើនគិតគូឱ្យបានចោរនោះមកនៅក្នុងផ្ទះ លុះបានហើយក៏ប្រគល់ឱ្យកូនស្រីយកធ្វើជាប្តី ។ គ្រាកាលដែលបានសមតាមបំណង នាងក៏សប្បាយចិត្តឥតឧបមា ដោយពុំបានគិតថាមាតាបិតាខ្មាសគេប៉ុនណានោះឡើយ ។

ជាភ័ព្វសំណាងរបស់ចោរមួយគ្រាដែលបានរួចជីវិត ហើយថែមទាំងបានកូនក្រមុំលោកមហាសេដ្ឋី ដែលនាងឋិតនៅក្នុងវ័យ ១៦ ឆ្នាំ ព្រមទាំងរូបស្រស់សោភា ... ។ ក្រោយមកចិត្តចោរបានកើតឡើងសាជាថ្មី ដើម្បីនឹងប្លន់យកសម្បត្តិរបស់ប្រពន្ធខ្លួន បានប្រើឧបាយកលពោលទៅកាន់នាងជាភរិយាដូច្នេះថា « ហៃនាងដ៏ចម្រើនអើយ ពេលដែលបងត្រូវបានគេចាប់នោះ បងបានបន់-ស្រន់អស់ពពួកទេវតា ថាសូមឱ្យជួយផង ខ្ញុំនឹងធ្វើពលិកម្មថ្វាយ



ឥឡូវនេះ បានផុតពីស្លាប់ហើយ ថែមទាំងមកបានអូនជាប្រពន្ធទៀត ដូច្នេះ សូមប្រពន្ធសម្លាញ់ចាត់ចែងគ្រឿងសម្រាប់ធ្វើនូវទេវតាពលី ហើយព្រឹកស្អែកនេះ អូនត្រូវប្រដាប់ដោយគ្រឿងអលង្ការគ្រប់យ៉ាង នឹងឡើងភ្នំជាមួយប្តី » ។

កាលដែលបានដឹងរឿងនេះ នាងជាភរិយាមិនមានរួញរាអ្វីឡើយ បានរៀបចំសព្វគ្រប់សុទ្ធតែរបស់ល្អ និងមានតម្លៃថ្លៃៗ ដើម្បីធ្វើនូវទេវតាពលី ព្រមទាំងបានប្រដាប់ខ្លួនប្រាណដោយរតន-វត្ថុសព្វបែបយ៉ាង ដើម្បីជាការយកចិត្តយកថ្លើមស្វាមីរបស់នាង ។ ព្រលឹមស្រាងឡើង ក៏បានចេញដំណើរព្រមដោយបរិវារ មកដល់ជើងភ្នំទើបបង្គាប់ឱ្យបរិវារត្រឡប់ ព្រោះអាងថា ត្រូវធ្វើតែពីរនាក់ប៉ុណ្ណោះ ។ លុះមកដល់កំពូលភ្នំ ប្តីជាចោរបែរជានៅស្ងៀមព្រងើយទៅវិញ កាលដែលនាងភទ្ទាជាភរិយាសាកសួរ ចោរក៏បានតបថា ដែលមកទីនេះមិនបានមកធ្វើពលិកម្មអ្វីឡើយ តែយើងបោកនាងឯងយកមកសម្លាប់ ហើយនាំយកទ្រព្យដែលជាប់នឹងខ្លួននាងឯងទៅតែប៉ុណ្ណោះ ។ ភរិយាធ្លាក់ថ្លើមក្តុក ក្តុកក្តួលក្នុងចិត្តប្រញាប់តបទៅវិញថា ដូចម្តេចបានជាប្តីគិតយ៉ាងនេះ ព្រោះថាសម្បត្តិទាំងអស់របស់ភរិយា គឺជាសម្បត្តិរបស់ស្វាមីផងដែរ ដូច្នេះសម្បត្តិទាំងអស់ជារបស់ប្តីស្រេចហើយតើ ។ ទោះជាភរិយា

អធិប្បាយយ៉ាងណា ក៏ចោរពុំព្រមឡើយ រហូតទាល់តែអស់បញ្ញា ដែលនឹងត្រូវពន្យល់ប្រាប់ប្តីឱ្យយល់ ។ ប៉ុន្តែភ្លាមនោះ គំនិតដែលនឹងគិតយករួចខ្លួន បានកើតឡើង នាងគិតថា ធម្មតាបញ្ញាគេមិនមែនទុកសម្រាប់ស្ងួស៊ីនោះទេ គេទុកសម្រាប់ដោះស្រាយបញ្ហា ទើបនាងចាប់ផ្តើមសូមពរពីស្វាមី ថាបើយ៉ាងដូច្នេះ សូមឱ្យឱកាសដល់ខ្ញុំជាប្រពន្ធផងចុះ ព្រោះកាលដែលប្តីត្រូវគេចាប់នោះ នាងខ្ញុំនេះឯងដែលបានសូមឱ្យមាតាបិតា ចាត់ការយ៉ាងណា យកអ្នកមកធ្វើជាប្តីឱ្យខាងតែបាន បើពុំបានទេ នាងខ្ញុំសុខចិត្តស្លាប់ កាលនោះបិតាបានចំណាយប្រាក់អស់ ១០០០ កហាបណៈ កាត់ក្តើកាត់ខ្នាស ដើម្បីបានអ្នកមកជាប្តីនាងខ្ញុំ ចាប់តាំងពីនោះមកនាងខ្ញុំបានយកចិត្តទុកដាក់គោរពបម្រើប្តី ដូចគោរពបម្រើទេវតា អស់កាលជានិច្ច ថ្ងៃនេះនាងខ្ញុំសូមមើលប្តីឱ្យពេញភ្នែក សូមថ្វាយបង្គំប្តីឱ្យសមចិត្ត និងសូមឱ្យនាងខ្ញុំបានឱបថើបអ្នកជាប្តីក្នុងពេលចុងក្រោយ សព្វគ្រប់កន្លែងជុំវិញខ្លួនផងចុះ ។

កាលដែលប្តីអនុញ្ញាតហើយ នាងបានសម្លឹងមើលប្តី ថ្វាយ-បង្គំប្តី ឱបថើបប្តីជុំវិញខ្លួន ពេលដែលប្តីកំពុងតែភ្លេចខ្លួន ទើបបានរុញប្តីពេញទំហឹង ទម្លាក់ក្នុងជ្រោះស្លាប់បាត់បង់ជីវិតក្នុងគ្រានោះទៅ ។





នាងមិនហ៊ានត្រឡប់ទៅផ្ទះវិញឡើយ ព្រោះគិតខ្លាចក្រែងផ្សេងៗ ហើយក៏បានទៅបួសក្នុងសំណាក់ពួកបរិព្វាជក តែមុននឹងឱ្យនាងបួស ពួកគេបានដកសក់នាងទាល់តែអស់ ដល់បានបួសហើយ ក្រោយមកសក់នាងដុះខ្មៀនៗខ្វង់ៗ ទើបនាងឈ្មោះថា «កុណ្ឌលកេសី »តាំងពីពេលនោះមក ។

នាងបានសិក្សានូវវាទៈអំពីសំណាក់បរិព្វាជក រហូតដល់ល្បីល្បាញក្នុងជម្ពូទ្វីប នាងដើរកាន់មែកព្រីង លើកឡើងនូវវាទៈចំពោះអ្នកដទៃ (មែកព្រីងនោះ ជាការបញ្ជាក់ថា ខ្លួនឯងខ្លាំងពូកែក្នុងជម្ពូទ្វីប ) ។ ទីបំផុតនាងបានមកជួបនឹង **ព្រះសារីបុត្ត** ហើយប្រកាសសាកសួរបញ្ហាដល់គ្នាទៅវិញទៅមក ដែលធ្វើឱ្យមហាជននាំគ្នាមកស្តាប់យ៉ាងច្រើនកុះករ ហើយមហាជនប្រកាន់ម្ខាងៗទៅតាមការដែលខ្លួនរាប់អាន ។ ជាការចាប់ផ្តើម នាងបរិព្វាជិកាកុណ្ឌលកេសី បានលើកវាទៈរបស់ខ្លួន ដែលខ្លួនខំរៀនមកទាំងប៉ុន្មានសួរដល់ព្រះថេរៈ។ សំនួរទាំងនោះត្រូវព្រះថេរៈដោះស្រាយឆ្លើយយ៉ាងត្រឹមត្រូវទៅតាមបញ្ហា ប្រៀបដូចជាកាត់ដើមឈូកនឹងកាំបិតដ៏មុត ។ លុះដល់គ្រា ព្រះថេរៈសួរវិញតែមួយសំនួរ នាងឆ្លើយពុំរួចឡើយ ហើយបានសូមព្រះថេរៈជាទីពឹងទីរលឹក ។

**សារីបុត្ត-** នាងដល់យើងជាសរណៈមិនបានឡើយ ព្រះសម្មាសម្ពុទ្ធជាបុគ្គលប្រសើរខ្ពង់ខ្ពស់លើសលោក ទ្រង់គង់នៅក្នុងវិហារជិតនេះឯង នាងចូរដល់ព្រះអង្គជាទីពឹងទីរលឹកចុះ ។

**កុណ្ឌលកេសី-** ខ្ញុំម្ចាស់នឹងធ្វើតាមលោកម្ចាស់គ្រប់យ៉ាង ។

នៅពេលល្ងាច ជាពេលដែលព្រះបរមសាស្តាទ្រង់សម្តែងព្រះធម៌ ទើបនាងទៅកាន់សំណាក់នៃព្រះបរមសាស្តា ថ្វាយបង្គំដោយសេចក្តីគោរព ហើយក្រោកឈរនៅក្នុងទីដ៏សមគួរ ។ ព្រះបរមសាស្តាទ្រង់ត្រាស់នូវព្រះគាថា ឱ្យសមទៅតាមចរិតអធ្យាស្រ័យរបស់នាង :

**សហស្សមបិ ចេ គាថា　　　អនត្ថបទសញ្ហិតា**
**ឯកំ គាថាបទំ សេយ្យោ　　　យំ សុត្វា ឧបសម្មតិ ។**

ប្រសិនបើគាថាប្រកបដោយបទមិនជាប្រយោជន៍ ទោះជា ១ ពាន់គាថាក៏ដោយ (មិនប្រសើរឡើយ) ឯបទគាថាណាតែមួយដែលបុគ្គលស្តាប់ហើយស្ងប់រម្ងាប់បាន (បទនៃគាថានោះ) ទើបប្រសើរ (គឺប្រសើរជាង ១ ពាន់គាថាដែលឥតប្រយោជន៍) ។

ក្នុងវេលាចប់ព្រះគាថា ទាំងដែលនាងកំពុងឈរស្តាប់នោះឯង នាងបានសម្រេចនូវព្រះអរហត្តផល ព្រមដោយបដិសម្ភិទា ទើបទូលសូមបព្វជ្ជា ។ ព្រះបរមសាស្តាទ្រង់ទទួលឱ្យនាងបព្វជ្ជា





ឧបសម្បទា ហើយនៅក្នុងសំណាក់ភិក្ខុនី ។

ក្នុងកាលតមក មានការសន្ទនាគ្នារវាងបរិស័ទទាំង ៤ ថា « ព្រះនាងកុណ្ឌលកេសីថេរីនេះ អស្ចារ្យក្រៃលែងណាស់ហ្ន៎ ព្រះនាងបានសម្រេចនូវព្រះអរហត្តផល ក្នុងពេលស្តាប់ចប់គាថា ៤ បាទ » ។ ព្រះបរមសាស្តាទ្រង់ធ្វើហេតុនោះឱ្យប្រាកដ ហើយទ្រង់បានស្ថាបនាតែងតាំងព្រះថេរីក្នុងតំណែង ឯតទគ្គៈលើភិក្ខុនីទាំងឡាយ ផ្នែកខាងត្រាស់ដឹងឆាប់រហ័ស ដោយប្រការដូច្នេះឯង ។

ប្រារព្ធព្រះនាងកុណ្ឌលកេសីថេរីនេះ ព្រះបរមសាស្តា ទ្រង់មិនសរសើរនូវការឈ្នះអ្នកដទៃឡើយ ប៉ុន្តែ ព្រះអង្គទ្រង់ត្រាស់សរសើរការឈ្នះខ្លួនឯង ដូចព្រះពុទ្ធគាថាដ៏ពីរោះនេះគឺ

**យោ សហស្សំ សហស្សេន　សង្គាមេ មានុសេ ជិនេ**
**ឯកញ្ច ជេយ្យមត្តានំ　　　ស វេ សង្គាមជុត្តមោ ។**

បុគ្គលណា ឈ្នះមនុស្ស ១ លាននាក់ក្នុងសមរភូមិ បុគ្គលនោះមិនឈ្មោះថា ជាអ្នកឈ្នះដ៏ប្រសើរក្នុងសង្គ្រាមឡើយ ចំណែកឯបុគ្គលណា ឈ្នះខ្លួនឯងម្នាក់បានហើយ បុគ្គលនោះ គឺជាអ្នកឈ្នះដ៏ប្រសើរបំផុត នៅក្នុងសមរភូមិ ។

## ៦-ព្រះនាងធម្មទិន្នាថេរី

ព្រះនាងធម្មទិន្នាថេរី មុននឹងបានមកបួស នាងជាភរិយារបស់វិសាខសេដ្ឋីនៅនាក្រុងរាជគ្រឹះហ្នឹងឯង ។ ជាប្រក្រតីនៃភរិយាស្វាមីមួយគូនេះ គឺតែងតែញញឹមរកគ្នា បើស្វាមីមកពីគាល់ព្រះរាជា ឬមកពីណាដទៃផ្សេងក៏ដោយ ភរិយាតែងតែចាំទទួលនៅមាត់ជណ្តើរ និងចាប់ដៃប្តីឡើងផ្ទះ ព្រមទាំងបម្រើបាយទឹកសព្វគ្រប់ ។

ក្រោយមកវិសាខសេដ្ឋី បានស្តាប់ព្រះធម៌នៅ **តាលវ័ន** ព្រៃត្នោត រួមជាមួយនឹងព្រះបាទពិម្ពិសារជាដើម ក៏បានសម្រេចសោតាបត្តិផល បន្ទាប់មកទៀត ក៏បានធ្វើឱ្យជាក់ច្បាស់នូវព្រះ-អនាគាមិផល ។

នៅពេលដែលវិសាខឧបាសក បានសម្រេចនូវព្រះអនាគា-មិផលហ្នឹងឯង ទើបមានហេតុការណ៍កើតឡើងជាមួយនឹងភរិយាដោយការមិនញញឹមដូចប្រក្រតី មិនឱ្យភរិយាចាប់ដៃ មិនឱ្យបម្រើបាយទឹក ព្រមទាំងបែកដំណេកគ្នាទៀតផង ។

នាងជាភរិយា មានការសង្ស័យជាខ្លាំងក្នុងរឿងទាំងនេះ ហើយក៏មានគំនិតគិតច្រឡំទៅក្នុងរឿងផ្សេងៗ ដូចជាគិតថា ខ្លួនមានកំហុសអ្វីឬ ប្តីមានស្រីក្រៅផ្ទះឬ ហេតុអ្វីបានជាប្តីក្រោធ ជា-





ដើម ។ ព្រោះហេតុនាងតឹងដើមទ្រូងពេក ទើបមិនអាចទុកតទៅទៀតបាន ក៏ជម្រាបសួរលោកសេដ្ឋីដែលជាស្វាមីក្នុងពេលយប់ជ្រៅនោះឯង ។ ព្រោះការអនុគ្រោះដល់នាងជា ស្រីគ្រប់លក្ខណ៍ វិសាខឧបាសក ទើបបានប្រាប់អំពីការបានសម្រេចនូវគុណធម៌ដ៏វិសេសក្នុងព្រះពុទ្ធសាសនានេះ ។

ទោះជាវិសាខឧបាសក ប្រគល់ទ្រព្យសម្បត្តិគ្រប់យ៉ាងឱ្យដល់នាងក៏ដោយ ក៏នាងមិនព្រមទទួលដូចជាការឱនលិទ្ធនូវកំហាកនោះឡើយ ព្រោះកាលដែលបានសួរស្វាមីទៅ បានដឹងថា គុណវិសេសនេះមានទូទៅដល់ស្រ្តីផងដែរ នាងមានតែចិត្តឱនទៅរកបព្វជ្ជាតែប៉ុណ្ណោះ ហើយបានសូមស្វាមីថា « សូមអ្នកជាម្ចាស់អនុញ្ញាតឱ្យនាងខ្ញុំបានបួសក្នុងព្រះពុទ្ធសាសនា ដែលជាសាសនាដឹកនាំសត្វឱ្យរួចផុតចាកទុក្ខផងចុះ » ។

វិសាខសេដ្ឋី បាននូវបីតិក្នុងរឿងនេះ ហើយក៏អនុញ្ញាតឱ្យភរិយាបានសម្រេចតាមបំណង ព្រមទាំងចាត់ចែងជូននាងទៅបួសក្នុងសភាពគគ្រឹកគគ្រេងដោយពពួកញាតិ ។ លុះនាងបានបួសជាភិក្ខុនីហើយ ក៏គេចពីកិច្ចរវល់ផ្សេងៗ ដូចជាការរវល់នឹងទទួលពួកញាតិជាភ្ញៀវជាដើម បដិបត្តិក្នុងវិវេកធម៌ មិនយូរឡើយ ព្រះ-នាងក៏បានសម្រេចនូវព្រះអរហត្តផល ព្រមដោយបដិសម្ភិទា ។

លុះចប់កិច្ចក្នុងព្រះសាសនាហើយ ក៏បានត្រឡប់មកក្រុងរាជគ្រឹះវិញដើម្បីឱ្យពពួកញាតិបានធ្វើបុណ្យ ។

វិសាខឧបាសក នឹកក្រែងថា ព្រះនាងធម្មទិន្នាថេរី ត្រឡប់មកក្រុងវិញ ដោយការធុញទ្រាន់នឹងផ្នួស ចង់លាសិក្ខាឬយ៉ាងណា ទើបវិសាខឧបាសកទៅកាន់សំណាក់របស់ភិក្ខុនី ថ្វាយបង្គំព្រះនាងធម្មទិន្នាថេរីហើយ អង្គុយចុះក្នុងទីដ៏សមគួរ ហើយគិតថា បើយើងសួរថាព្រះនាងម្ចាស់ប្រាថ្នាលាសិក្ខាបទឬ ទំនងជាពុំសមរម្យឡើយ ដូច្នេះយើងត្រូវសួរបញ្ហាព្រះធម៌វិញ ។

វិសាខឧបាសក សួរសំណួរទាក់ទងនឹងខន្ធ ៥ ព្រះនាងធម្មទិន្នាថេរី វិសជ្ជនា ដូចបុគ្គលកាត់ដើមឈូកដោយសស្ត្រាដ៏មុតដូច្នេះឯង ។ ហើយក៏បានសួរបន្តទៀត ក្នុងវិស័យនៃសោតាបត្តិមគ្គ សកទាគាមិមគ្គ អនាគាមិមគ្គ រហូតសួរដល់អរហត្តមគ្គតាមដែលខ្លួនបានស្តាប់មក សំណួរ និងចម្លើយទាំងអស់មានក្នុង **ចូឡវេទល្លសូត្រ** មជ្ឈិមនិកាយ វិសាខឧបាសកសួរទាល់តែហួសបញ្ហា ទើបព្រះនាងថេរី បញ្ជូនវិសាខឧបាសក ឱ្យចូលគាល់ព្រះដ៏មានព្រះភាគ ។ វិសាខឧបាសកបានក្រាបទូលពាក្យបុច្ឆា និងពាក្យវិសជ្ជនាទាំងអស់ ដែលខ្លួនបានសន្ទនាជាមួយនឹងព្រះថេរី ថ្វាយព្រះដ៏មានព្រះភាគឱ្យទ្រង់បានជ្រាប ។





ព្រះអង្គទ្រង់ត្រាស់ថា « ម្នាលវិសាខ បើអ្នកសួរបញ្ហានេះចំពោះតថាគត តថាគតក៏វិសជ្ជនាដូច្នោះដែរ » ហើយព្រះអង្គទ្រង់ត្រាស់ព្រះគាថាធម្មបទ :

**យស្ស បុរេ ច បច្ឆា ច មជ្ឈេ ច នត្ថិ កិញ្ចនំ**
**អកិញ្ចនំ អនាទានំ តមហំ ព្រូមិ ព្រាហ្មណំ ។**

កង្វល់ក្នុងពេលមុនក្តី ក្នុងពេលក្រោយក្តី និងក្នុងពេលជាកណ្តាលក្តី របស់អ្នកណាមិនមានទេ តថាគតហៅអ្នកនោះ ដែលជាអ្នកមិនមាននូវកង្វល់ មិនមានការប្រកាន់មាំថាជាព្រាហ្មណ៍ ។

ព្រះបរមសាស្តា ទ្រង់អាស្រ័យនូវចូឡវេទល្លសូត្រនោះឯង ទើបតែងតាំងព្រះនាងធម្មទិន្នាថេរី ឱ្យជាភិក្ខុនីកំពូលលើភិក្ខុនីទាំងឡាយ ផ្នែកខាងធម្មកថិក ។

## ៧-ព្រះនាងសុភាកម្មារធីតាថេរី

ព្រះថេរីរូបនេះ បានបំពេញបារមីមកក្នុងព្រះពុទ្ធសាសនានៃព្រះអង្គមុនៗ បានសន្សំកុសលដែលជាឧបនិស្ស័យនៃព្រះនិព្វានមកក្នុងភពនោះៗ អប់រំកុសលមូល សន្សំធម៌ដែលជាគ្រឿងសម្រាប់តាក់តែងនូវវិមោក្ខតាមលំដាប់ អន្ទោលទៅនៅតែក្នុងសុគតិភពប៉ុណ្ណោះ ។ លុះដល់ញាណចាស់ក្លា បារមីគ្រប់គ្រាន់ មក

ក្នុងសម័យពុទ្ធកាលនេះ ព្រះនាងបានកើតជាធីតានៃជាងមាសម្នាក់ ក្នុងក្រុងរាជគ្រឹះ ។ ព្រោះអាស្រ័យរូបសម្បត្តិល្អស្អាត ស្រស់បស់ ទើបបានឈ្មោះថា «សុភា» ។ នាងសុភា ចម្រើនវ័យដោយលំដាប់ កើតសេចក្តីជ្រះថ្លាក្នុងព្រះសាស្តា កាលព្រះសាស្តាស្តេចយាងទៅ ក្រុងរាជគ្រឹះ ។ ថ្ងៃមួយនាងទើបបានឱកាសចូលទៅគាល់ព្រះអង្គ ហើយថ្វាយបង្គំ ដោយសេចក្តីគោរព រួចទើបអង្គុយក្នុងទីដ៏សមគួរ ។ ព្រះបរមសាស្តាទ្រង់ទតឃើញឥន្ទ្រិយចាស់ក្លារបស់នាង ទើបព្រះអង្គទ្រង់ប្រកាសសម្តែងនូវអរិយសច្ចៈ ៤ ដ៏សមគួរតាមអធ្យាស្រ័យ ទាន់ពេលនោះឯង នាងក៏បានសម្រេចនូវសោតាបត្តិផល ។ ក្រោយមកនាងឃើញទោសក្នុងឃរាវាសវិស័យ ក៏បួសក្នុងសំណាក់ព្រះនាងបជាបតិគោតមី តាំងនៅក្នុងសីលភិក្ខុនី ប្រកបរឿយៗនូវភាវនាដើម្បីមគ្គជាន់លើ ។

ពោលអំពីពួកញាតិរបស់ព្រះនាងសុភាកម្មារធីតាថេរី រាល់ថ្ងៃមានប្រក្រតីចូលមករកព្រះនាង បបួលនាងឱ្យចាកសិក្ខាបទ លើកឡើងនូវទ្រព្យសម្បត្តិចំនួនច្រើន ហើយលួងលោមព្រះនាងដោយកាមគុណទាំងឡាយ ។ ថ្ងៃមួយ កាលពួកញាតិចូលមករកព្រះនាងដូចមុនៗ ព្រះនាងបានប្រកាសទោសក្នុងឃរាវាសវិស័យ និងកាមទាំងឡាយ ទើបពោលធម៌ដោយគាថា មាន ២៤ គាថា





ប្រកបដោយការលះបង់ ដែលធ្វើឱ្យពពួកញាតិអស់សង្ឃឹម ។ ព្រះនាងចម្រើនវិបស្សនា ប្រកបដោយឥន្ទ្រិយទាំងឡាយ មិនយូរប៉ុន្មាន ព្រះនាងក៏បានសម្រេចនូវព្រះអរហត្តផល ព្រមដោយបដិសម្ភិទា ៤ ។ កាលដែលបានសម្រេចនូវព្រះអរហត្តផលហើយ ក៏បានពោលនូវព្រះគាថាសាជាថ្មី តាមដូចដែលបានពោលចំពោះពួកញាតិ ដែលមានសេចក្តីដូចតទៅ :

កាលពីដើម ខ្ញុំនៅក្រមុំ មានគ្រឿងស្លៀកពាក់ដ៏ស្អាត បានស្តាប់ធម៌ ការត្រាស់ដឹងសច្ចធម៌ក៏កើតមានដល់ខ្ញុំនោះ ជាស្ត្រីមិនប្រហែសធ្វេស ។ ហេតុនោះ ខ្ញុំមិនត្រេកអរក្រៃពេកក្នុងកាមារម្មណ៍ទាំងអស់ ឃើញភ័យក្នុងសក្កាយ ហើយពេញចិត្តនឹងការចេញសាងផ្នួសតែម្យ៉ាង ។ ខ្ញុំលះបង់ពួកញាតិ ទាសកម្មករ ស្រុកស្រែទាំងឡាយដ៏ស្តុកស្តម្ភ (និងគំនរនៃភោគៈទាំងឡាយ) ដែលគួរត្រេកអរ គួររីករាយ ខ្ញុំលះបង់នូវសម្បត្តិដ៏ច្រើន ហើយបួស ។ ខ្ញុំចេញ (ចាកផ្ទះ) ដោយសទ្ធាយ៉ាងនេះហើយ (បួស) ក្នុងព្រះសទ្ធម្ម ដែលព្រះសម្មាសម្ពុទ្ធ ត្រាស់សម្តែងហើយដោយប្រពៃ ខ្ញុំប្រាថ្នានូវសេចក្តីមិនកង្វល់ ព្រោះការត្រឡប់មករកកាមនោះមិនសមគួរដល់ខ្ញុំទេ អ្នកណាលះចោលមាសនិងប្រាក់ហើយគប្បីត្រឡប់មករកវិញ ។ ប្រាក់ក្តីមាសក្តីរបស់បុគ្គលនោះ មិនមែនជាទ្រព្យប្រសើរ

ទេ ។ ការទទួលនូវប្រាក់និងមាសនោះ សុទ្ធតែជាគ្រឿងឱ្យកើតលោភៈ ជាគ្រឿងស្រវឹង ជាគ្រឿងវង្វេង ជាគ្រឿងព័ន្ធព័ទ្ធដោយធូលីគឺកិលេស ប្រកបដោយសេចក្ដីរង្កៀស មានសេចក្ដីចង្អៀត-ចង្អល់ច្រើន សេចក្ដីទៀងទាត់ឋិតថេរក្នុងទ្រព្យនោះមិនមានទេ ។ ពួកនរជន (ដែលត្រេកអរ ) ដោយទ្រព្យប៉ុណ្ណេះ ឈ្មោះថាជាអ្នកប្រហែសធ្វេស ជាអ្នកមានចិត្តសៅហ្មង ជាអ្នកអាក់អន់ រមែងធ្វើនូវ ជម្លោះជាច្រើនទៅវិញទៅមក ។ សេចក្ដីវិនាសច្រើនប្រការ គឺការសម្លាប់ ការចង ការសៅហ្មង សេចក្ដីវិនាស សេចក្ដីសោកខ្សឹកខ្សួល រមែងកើតប្រាកដដល់ពួកជន ដែលដេកត្រាំក្នុងកាមទាំងឡាយ ។ អ្នកទាំងឡាយជាញាតិមែន តែហាក់ដូចជាសត្រូវល្បួងខ្ញុំនោះក្នុងកាមទាំងឡាយធ្វើអ្វី (ព្រោះ)អ្នកទាំងឡាយជ្រាបនូវខ្ញុំថាជាអ្នកបួស ជាស្ត្រីឃើញនូវភ័យក្នុងកាមទាំងឡាយ ។ អាសវៈទាំងឡាយមិនមែនអស់ទៅព្រោះប្រាក់និងមាស កាមទាំង-ឡាយមិនមែនជាមិត្ត ជាសភាវៈសម្លាប់ (នូវប្រយោជន៍) ជាសត្រូវជាគ្រឿងចងទុកនូវសរគឺកិលេស ។ អ្នកទាំងឡាយជាញាតិមែនតែហាក់ដូចជាសត្រូវ ល្បួងខ្ញុំនោះក្នុងកាមទាំងឡាយធ្វើអ្វី (ព្រោះ) អ្នកទាំងឡាយជ្រាបនូវខ្ញុំថាជាអ្នកបួស មានក្បាលត្រងោល ដណ្ដប់នូវសង្ឃាដី ។ ដុំបាយតាមលំដាប់ផ្ទះក្ដី អាហារចំណីក្ដី បង្សុកូល-





ចីវរក្ដី នេះឯងជាអំពើដ៏សមគួរដល់ខ្ញុំ ជាបរិក្ខារ ជាទីអាស្រ័យរបស់អ្នកបួស ។ លោកអ្នកស្វែងរកនូវគុណដ៏ធំទាំងឡាយ ខ្ជាក់ចោលនូវកាមទាំងឡាយដែលជាទិព្វនិងជារបស់មនុស្ស បុគ្គលអ្នកស្វែងរកនូវគុណធំទាំងនោះ មានចិត្តឱនទៅក្នុងព្រះនិព្វាន ជាទីដ៏ក្សេម បុគ្គលអ្នកស្វែងរកគុណធំទាំងនោះ បានដល់នូវសេចក្ដីសុខឥតកម្រើក ។ ទីជម្រករមែងមិនមានក្នុងកាមទាំងឡាយណា ខ្ញុំមិនសមគប់ ដោយកាមទាំងឡាយនោះទៀតទេ កាមទាំងឡាយមិនមែនជាមិត្ត ដូចជាអ្នកសម្លាប់ ឬដូចជាគំនរភ្លើង នាំមកនូវសេចក្ដីព្រួយ ។ កាមនោះមិនស្អាត ប្រកបដោយភ័យ ប្រកបដោយសេចក្ដីចង្អៀតចង្អល់ ដូចជាបន្លា កាមនុ៎ះជាគ្រឿងញ៉ាម ជាគ្រឿងកង្វល់ក្រៃលែង មានមុខឈមទៅរកសេចក្ដីវង្វេងដ៏ធំ ។ កាមគុណជាឧបសគ្គៈផង មានសភាពគួរខ្លាចផង កាមារម្មណ៍ទាំងឡាយ មានឧបមាដូចក្បាលពស់ ពួកបុថុជ្ជនល្ងង់ខ្លៅដូចជាបុគ្គលខ្វាក់ តែងត្រេកត្រអាល ។ ព្រោះថា ពួកជនច្រើនរូបដែលជំពាក់ដោយគ្រឿងជំពាក់គឺកាម រមែងបាន (សេចក្ដីទុក្ខ )ក្នុងលោក រមែងមិនដឹងច្បាស់នូវទីបំផុតនៃជាតិនិងមរណៈ ។ មនុស្សទាំងឡាយជាច្រើនតែងដើរទៅកាន់ផ្លូវ ជាទីទៅកាន់ទុគ្គតិ មានកាមជាហេតុជាគ្រឿងនាំមកនូវរោគដល់ខ្លួន ។ កាមទាំងឡាយ ជាគ្រឿងញុំាង

សត្រូវឱ្យកើតយ៉ាងនេះ ជាហេតុញ៉ាំងសត្វឱ្យក្តៅក្រហាយ នាំមកនូវសេចក្តីសៅហ្មង ជានុយរបស់សត្វលោក ជាទីតាំងនៃគ្រឿងចង ជាចំណងនៃសេចក្តីស្លាប់ ។ កាមទាំងឡាយជាគ្រឿងញ៉ាំងសត្វឱ្យឆ្កួត (ឆ្កួតមែនទែន) ឱ្យនិយាយប៉ប៉ាច់ប៉ប៉ោច ញ៉ាំងចិត្តឱ្យភ្លាំងភ្លាត់ មារគឺកាមរបស់ពួកសត្វ តែងរួបរឹតដោយសេចក្តីសៅហ្មង យ៉ាងឆាប់រហ័ស ។ កាមទាំងឡាយមានទោសរកទីបំផុតគ្មាន មានទុក្ខច្រើនយ៉ាង មានពិសដ៏ខ្លាំងក្លា មានរសឆ្ងាញ់តិច ជាគ្រឿងធ្វើនូវចម្បាំង ញ៉ាំងចំណែកនៃធម៌សឱ្យសាបសូន្យទៅ ។ ខ្ញុំនោះលះបង់នូវសេចក្តីវិនាសដែលមានកាមជាហេតុ បែបនេះ ត្រេកអរចំពោះព្រះនិព្វានសព្វៗកាល មិនត្រឡប់មកកាន់កាមនោះវិញទេ ។ ខ្ញុំជាស្ត្រីប្រាថ្នានូវភាពដ៏ត្រជាក់ (ព្រះអរហត្ត) ធ្វើនូវចម្បាំងចំពោះកាមទាំងឡាយ ជាអ្នកមិនប្រមាទ ត្រេកអរចំពោះព្រះនិព្វានជាទីអស់ទៅនៃសំយោជនៈ ។ បុគ្គលអ្នកស្វែងរកនូវគុណដ៏ធំទាំងឡាយ ឆ្លងហើយតាមផ្លូវណា ខ្ញុំនឹងដើរទៅតាមផ្លូវនោះ ជាផ្លូវឥតសោក មានធូលីទៅប្រាសហើយ ជាផ្លូវក្សេមដ៏ត្រង់ ប្រកបដោយអង្គ ៨ ដ៏ប្រសើរ ។

(ព្រះមានព្រះភាគត្រាស់ថា) អ្នកទាំងឡាយ ចូរមើលនូវនាងសុភាកម្មារធីតានេះ ជាស្ត្រីឋិតនៅក្នុងធម៌ នាងបានចូលទៅកាន់ឈាន ឥតមានសេចក្តីញាប់ញ័រ ហើយស្ថិងស្មាធិ៍ទៀបគល់ឈើ ។ នាងសុភាកម្មារធីតា បួសបាន ៨ ថ្ងៃនឹងថ្ងៃនេះហើយ ជាភិក្ខុនីមានសទ្ធា ល្អក្នុងព្រះសទ្ធម្ម ដែលនាងឧប្បលវណ្ណាទូន្មានហើយ ជាស្ត្រីមានវិជ្ជា ៣ លះបង់នូវមច្ចុបាន ។ ភិក្ខុនីនេះ ជាអ្នកនៅឥតមានបំណុល មានឥន្ទ្រិយចម្រើនហើយ ប្រាសចាកកិលេសគ្រឿងប្រកបទាំងពួង មានកិច្ចធ្វើរួចហើយ មិនមានអាសវៈ ។ ទេវរាជឈ្មោះសក្កៈ ជាម្ចាស់នៃពួកសត្វ ព្រមទាំងពួកទេវតា ចូលទៅនមស្ការចំពោះភិក្ខុនីឈ្មោះសុភាកម្មារធីតានោះ ដោយឫទ្ធិ (របស់ខ្លួន) ។

(សុភាកម្មារធីតាថេរី បិដកលេខ ៥៧ ទំព័រ ២០៦-២១០)

### ៨-ព្រះនាងចាលាថេរី

បងប្អូនស្រីៗ ៣ នាក់គឺ ព្រះនាង **ចាលា** ១ ព្រះនាង **ឧបចាលា** ១ និងព្រះនាង **សីសុបចាលា** ១ ។ បានជ្រាបថា ព្រះធម្មសេនាបតីបួសហើយ ក៏បាននាំគ្នាគិតថា ព្រះធម្មវិន័យដែលបងប្រុសរបស់យើងបួស ប្រាកដជាមិនអន់ថយឡើយ បព្វជ្ជាមុខតែប្រសើរដោយពិត ។ លុះគិតដូច្នេះហើយ ក៏កើតឧស្សាហៈ មានឆន្ទៈខ្លាំងក្លា បាននាំគ្នាទាំង ៣ នាក់លះញាតិ និងអ្នកជិតខាងដែលកំពុងតែយំសោក ចេញបួស ។ លុះបួសហើយ ក៏ព្យាយាមក្នុងកិច្ច

បដិបត្តិ មិនយូរប៉ុន្មានក៏បានសម្រេចនូវអរហត្តផល នៅដោយនិព្វានសុខ និងផលសុខ ។

ថ្ងៃមួយ ព្រះនាងចាលាថេរី ត្រឡប់មកអំពីបិណ្ឌបាត ក្រោយអំពីឆាន់រួចហើយ បានចូលទៅកាន់ព្រៃ ដើម្បីសម្រាកក្នុងពេលថ្ងៃ ។ គ្រានោះមារមានចិត្តបាប បានចូលទៅរកព្រះនាងចាលាថេរី លុះចូលទៅដល់ហើយ ក៏បានពោលឱ្យព្រះថេរីដូច្នេះថា (តាមបិដកលេខ ៣០ ,ទំព័រ ១២) :

**មារ**-ម្នាលភិក្ខុនី នាងមិនគាប់ចិត្តនឹងអ្វី ?

**ថេរី**- ម្នាលអាវុសោ យើងមិនគាប់ចិត្តនឹងជាតិកំណើត ។

**មារ**-ហេតុអ្វីបានជានាងមិនគាប់ចិត្តនឹងជាតិកំណើត បុគ្គលកាលកើតមកហើយ រមែងបរិភោគនូវកាមទាំងឡាយ អ្នកណាបង្គាប់នាងឱ្យប្រកាន់នូវសេចក្ដីនេះថា ម្នាលភិក្ខុនី ចូរនាងកុំគាប់ចិត្តនឹងជាតិកំណើតដូច្នេះ ?

**ថេរី**- សត្វកើតមកហើយ រមែងតែងតែស្លាប់ សត្វកើតហើយរមែងឃើញទុក្ខទាំងឡាយ គឺការចង ការបៀតបៀន និងឧបទ្រពផ្សេងៗ ព្រោះហេតុដូច្នេះ ទើបយើងមិនគាប់ចិត្តនឹងការកើតឡើយ ។

ព្រះពុទ្ធទ្រង់សម្ដែងធម៌ ជាគ្រឿងប្រព្រឹត្តកន្លងនូវការកើត





ព្រះអង្គញ៉ាំងយើងឱ្យតាំងនៅក្នុងសច្ចធម៌ ដើម្បីលះបង់នូវទុក្ខទាំងអស់ ។

សត្វទាំងឡាយណា កើតក្នុងរូបភពក្ដី សត្វទាំងឡាយណាមានចំណែកក្នុងអរូបភពក្ដី សត្វទាំងអស់នោះ កាលបើមិនដឹងនូវនិរោធទេ រមែងមកកាន់ភពថ្មីទៀត ។

លំដាប់នោះ មារមានចិត្តបាបដឹងថា ព្រះនាងចាលាភិក្ខុនីស្គាល់អញហើយ ក៏មានសេចក្ដីទុក្ខ តូចចិត្ត បាត់អំពីទីនោះទៅ ។

## ៩-ព្រះនាងឧបចាលាថេរី

ព្រះនាងឧបចាលាថេរី ជាប្អូនស្រីរបស់ព្រះនាងចាលាថេរី បួសហើយចម្រើនវិបស្សនា ក៏បានសម្រេចនូវអរហត្តផល ហើយបានឧទានឡើងថា « យើងជាភិក្ខុនី មានសតិ មានចក្ខុ មានឥន្ទ្រិយបានអប់រំហើយ ចាក់ធ្លុះនូវសន្តិបទ ដែលឧត្តមបុរសបានសេពហើយ » ។

មារមានចិត្តបាប បានពោលពាក្យនេះនឹងព្រះនាងឧបចា-លាថេរីថា (តាមបិដកលេខ ៣០ , ទំព័រ ១៤) :

**មារ**- ម្នាលភិក្ខុនី ហេតុដូចម្ដេចបានជានាងចង់កើត ?

**ថេរី**- ម្នាលអាវុសោ យើងអត់ចង់កើត ក្នុងទីណាឡើយ ។

**មារ-** ពួកទេវតាណា ដែលឋិតនៅក្នុងជាន់តាវត្តិង្សក្តី ជាន់យាមៈក្តី ជាន់តុសិតក្តី ពួកទេវតាដែលឋិតនៅក្នុងជាន់និម្មានរតីក្តី ជាន់វសវត្តីក្តី នាងចូរតម្កល់ចិត្តក្នុងពួកទេវតានោះ នឹងបានទទួលនូវតម្រេកមិនខាន ។

**ថេរី-** ពួកទេវតាណា ដែលឋិតនៅក្នុងជាន់តាវត្តិង្សក្តី ជាន់យាមៈក្តី ជាន់តុសិតក្តី ពួកទេវតាដែលឋិតនៅក្នុងជាន់និម្មានរតីក្តី ជាន់វសវត្តីក្តី ទេវតាទាំងនោះ ជំពាក់ដោយគ្រឿងចងគឺកាម រមែងមកកាន់អំណាចនៃមារទៀត ។

លោកទាំងអស់ត្រូវភ្លើងឆេះ លោកទាំងអស់ក្តៅក្រហាយ លោកទាំងអស់ភ្លឺច្រាលរន្ទាល លោកទាំងអស់ញាប់ញ័រហើយ ។

ទីណាដែលមិនញាប់ញ័រ មិនកក្រើក មិនមែនជាសំណេពនៃបុថុជ្ជន មិនមែនជាដំណើរនៃមារ ចិត្តយើងត្រេកអរហើយក្នុងទីនោះ ។

លំដាប់នោះ មារមានចិត្តបាបដឹងថា ព្រះនាងឧបចាលាភិក្ខុនីស្គាល់អញហើយ ក៏មានសេចក្តីទុក្ខតូចចិត្ត បាត់អំពីទីនោះទៅ ។





## ១០-ព្រះនាងសីសុបចាលាថេរី

ព្រះនាងសីលូបចាលាថេរី ជាប្អូនស្រីរបស់ព្រះនាងឧបចាលាថេរី បានឆ្លើយតបចំពោះសំណួររបស់មារ មានសេចក្តីបញ្ជាក់អំពីលទ្ធិដទៃ និងព្រះពុទ្ធសាសនា :

**មារ-** ម្នាលភិក្ខុនី នាងគាប់ចិត្តនឹងលទ្ធិរបស់បុគ្គលណា ?

**ថេរី-** ម្នាលអាវុសោ យើងមិនគាប់ចិត្តនឹងលទ្ធិរបស់បុគ្គលណាមួយទេ ។

**មារ-** នាងឧទ្ទិសចំពោះបុគ្គលណា បានជាកោរក្បាល ប្រាកដដូចជាសមណី បើនាងមិនគាប់ចិត្តនឹងលទ្ធិរបស់បុគ្គលណាទេ ហេតុអ្វីបានជានាងប្រព្រឹត្តដូចជាស្រីវង្វេង ?

**ថេរី-** បុគ្គលទាំងនោះដែលមានលទ្ធិក្រៅព្រះពុទ្ធសាសនា រមែងលិចចុះក្នុងទិដ្ឋិទាំងឡាយ យើងមិនគាប់ចិត្តនឹងធម៌របស់បុគ្គលទាំងនោះទេ ព្រោះថាបុគ្គលទាំងនោះ មិនមែនជាអ្នកឈ្លាសក្នុងធម៌ឡើយ ។

ព្រះពុទ្ធទ្រង់កើតក្នុងសក្យត្រកូល រកបុគ្គលប្រៀបគ្មាន ទ្រង់គ្របសង្កត់នូវធម៌ទាំងពួង ទ្រង់កម្ចាត់បង់នូវមារ ទ្រង់មិនចាញ់នូវមារទាំងអស់ ទ្រង់ផុតចាកកិលេសទាំងពួង មិនអាស្រ័យដោយតណ្ហា ។

ព្រះអង្គទ្រង់មានចក្ខុឃើញធម៌ទាំងអស់ ដល់នូវកិរិយាអស់ទៅនៃកម្មទាំងពួង ទ្រង់មានចិត្តចុះស៊ប់ក្នុងធម៌ជាគ្រឿងអស់ទៅនៃឧបធិ ព្រះដ៏មានព្រះភាគអង្គនោះ ជាគ្រូរបស់យើង យើងគាប់ចិត្តនឹងសាសនារបស់ព្រះអង្គ ។

## ១១-កុមារកស្សបមាតាថេរី

ព្រះថេរីរូបនេះ ជាអ្នកមានសទ្ធាជ្រះថ្លាក្នុងការសាងផ្នួស មានការតាំងចិត្តពិតប្រាកដ សូម្បីមានឧបសគ្គក៏មិនចុះចាញ់ មិនបោះបង់នូវការតាំងចិត្តនោះដែរ ។ ព្រោះព្យាយាមក្នុងបំណងឱ្យបានសម្រេច តាមការតាំងចិត្តរបស់ខ្លួន ទីបំផុតក៏បានចូលកាន់ផ្នួសបួសជាភិក្ខុនី សម្រេចតាមឧបនិស្ស័យដែលបានសន្សំទុកមក។

ប្រវត្តិរបស់ព្រះថេរី មានក្នុងអដ្ឋកថានិគ្រោធជាតក និងអដ្ឋកថាធម្មបទអត្តវគ្គ ។ នាងកើតក្នុងត្រកូលសេដ្ឋីក្រុងរាជគ្រឹះ ជាកុលធីតាមានបំណងប្រាថ្នាចូលកាន់ផ្នួសតែម្យ៉ាង ប៉ុន្តែមាតាបិតាហួងហែងកូនស្រី សូម្បីសូមយ៉ាងណាៗ ក៏មាតាបិតាមិនឱ្យកូនស្រីបួសឡើយ ហើយទីបំផុតក៏ទុកដាក់នាងឱ្យមានស្វាមីនៅក្នុងក្រុងរាជគ្រឹះជាមួយគ្នា ។

នាងគិតថា ចាំយើងទៅនៅត្រកូលខាងប្ដីហើយ យើងនឹង





សូមប្ដីបួសក្នុងព្រះពុទ្ធសាសនា ។ នាងបានរៀបការ ចេញចាកផ្ទះទៅនៅឯត្រកូលខាងប្ដី ជាអ្នកមានសីលមានកល្យាណធម៌ល្អស្អាតបីដូចទេវតានៅគ្រប់គ្រងផ្ទះ ។ ការនៅគ្រប់គ្រងផ្ទះរបស់នាង រួមជាមួយនឹងស្វាមី មិនយូរប៉ុន្មាន នាងក៏តាំងគភ៌ តែនាងនៅមិនទាន់ដឹងខ្លួនថា មានគភ៌នៅឡើយ ។

ពេលនោះ ព្រះនគរត្រូវដល់កាលនក្ខត្តឫក្ស ប្រុសស្រីរីករាយសប្បាយ កំសាន្តក្នុងព្រះនគរ មើលមហោស្រពជាដើម ។ ស្វាមីបានឱ្យនាងជាភរិយាតាក់តែងកាយ ទៅដើរលេងសប្បាយនឹងគេ។ ជាឱកាសល្អ ក្នុងពេលនោះឯង នាងបានរៀបរាប់អំពីទុក្ខទោសនៃរូបកាយ ជារបស់មិនស្អាត ជាសម្បុកនៃរោគ និងជាភារៈធ្ងន់ដោយអនេកបរិយាយ ហើយជាចុងក្រោយ នាងបានពោលថា « ខ្ញុំម្ចាស់ធុញទ្រាន់ចំពោះរូបកាយនេះណាស់ តើឱ្យនាងខ្ញុំតាក់តែងរូបកាយនេះដើម្បីអ្វី ការដែលយើងប្រដាប់តាក់តែងរូបរាងកាយនេះ ដូចគ្នានឹងការប្រដាប់តាក់តែងធ្នាំងដីដែលពេញទៅដោយឧច្ចារៈ ធ្វើឱ្យស្អាតតែខាងក្រៅ មិនមែនទេឬ » ។ សេដ្ឋីបុត្រដែលជាស្វាមីរបស់នាង កាលបានស្ដាប់ពាក្យរបស់ភរិយាហើយ ទើបពោលពាក្យសួរថា « ម្នាលនាងដ៏ចម្រើន កាល

បើនាងឃើញទោសនៃរូបកាយយ៉ាងនេះហើយ ដូចម្ដេចបានជានាងមិនបួស ? » ។

នាងបានពោលនឹងស្វាមីថា « បើខ្ញុំម្ចាស់មានឱកាសអាចបួសបាន ខ្ញុំម្ចាស់នឹងបួសក្នុងថ្ងៃនេះឯង » ។

ស្វាមីរបស់នាង បានអនុញ្ញាតឱ្យនាងបួសក្នុងពេលនោះ ។ បានបរិច្ចាគនូវទ្រព្យសម្បត្តិយ៉ាងច្រើនក្នុងពិធីរៀបចំឱ្យភរិយាចេញបួស និងបាននាំនាងទៅកាន់សំណាក់ភិក្ខុនីដោយបរិវារយ៉ាងគគ្រឹកគគ្រេង ។ ជាការសមតាមបំណងដែលបានប្រាថ្នា តាំងតែពីនៅក្រមុំ និងសមតាមឧបនិស្ស័យអំពីអតីតជាតិ ។ ការដែលស្វាមីព្រមទាំងបរិវារដ៏ច្រើនជូននាងទៅបួសនេះ គឺជាការជូនដំណើរដ៏អស្ចារ្យមួយ សមនឹងទឹកចិត្តល្អ ប្រកបដោយឧត្តមគតិខ្ពស់របស់ស្វាមី នាងក៏មានដំណើរចេញចាកអំពីភពបីដោយមិនមានអាល័យផងដែរ ។

ព្រះនាងបានប្រសូតបុត្រនៅក្នុងសំណាក់ភិក្ខុនី ។ ទោះជាមានបញ្ហាអ្វីៗ ក្នុងការតាំងគភ៌ក៏ដោយ ព្រះនាងដឹងតែពីស្មោះក្នុងព្រះសាសនា ស្មោះក្នុងផ្នួសឥតកែប្រែ ដោយមិនខ្លាចពាក្យរិះគន់ពីអ្នកណាៗឡើយ ។

ប៉ុន្តែទោះជាចិត្តតាំងមាំក្នុងផ្នួសយ៉ាងណាក៏ដោយ ព្រះនាង





មានចិត្តជាម្ដាយ តែងតែនឹកដល់កូន ដែលព្រះរាជាបានយកទៅចិញ្ចឹម ។ រយៈកាល ១២ ឆ្នាំ មុខនាងទទឹកជោកដោយទឹកភ្នែករាល់ពេលដែលនឹកដល់បុត្រ ជាកូនដែលកើតពីផ្ទៃ ។ ព្រះនាងឆាន់តិច សិងតិច មិនមានចិត្តបដិបត្តិធម៌ ព្រោះចិត្តរបស់នាងទៅនៅនឹងបុត្រប៉ុណ្ណោះគ្រប់វេលា ។

ព្រឹកថ្ងៃមួយ ព្រះនាងនិមន្តទៅបិណ្ឌបាត ក៏បានជួបនឹងព្រះកុមារកស្សបៈដែលជាកូនបង្កើតនោះឯង។ព្រះកុមារកស្សបៈធំដឹងក្ដីឡើង បានចូលទៅកាន់ផ្នួសក្នុងព្រះពុទ្ធសាសនា បានសម្រេចជាព្រះអរហន្ត ក្នុងពេលស្ដាប់ **វម្មិកសូត្រ** (បិដកលេខ ២១ ) ។ កាលដែលព្រះនាងបានជួបនិងដឹងថាជាកូនហើយ ទើបស្រែកហៅថា « កូន » ហើយក៏ស្ទុះចូលទៅរក ដោយចិត្តត្រេកអរឥតឧបមា ប៉ុន្តែដោយស្ទុះប្រញាប់ពេក ក៏ភ្លាត់ជើងដួលក្នុងទីនោះ ។ ដោយអំណាចការស្រឡាញ់ចំពោះបុត្រ ទឹកដោះរបស់ភិក្ខុនីនៅតែមាន ពេលដួលនោះ ទឹកដោះបានហូរចេញមកទទឹកចីវររបស់ព្រះនាង ។ ព្រះនាងខំប្រឹងក្រោកឡើងហើយចូលទៅចាប់ចីវររបស់លោកកូន ដោយចិត្តរំភើបពន់ពេក ។

ព្រះកុមារកស្សបៈ មានព្រះហឫទ័យបំណងនឹងសង្គ្រោះញោមមាតា បានមានព្រះវាចាមិនឱ្យភិក្ខុនីម្ដាយជាប់ជំពាក់ដោយ

សេចក្ដីថា « អ្នកប្រព្រឹត្តអ្វី ទើបមិនអាចកាត់សេចក្ដីស្រឡាញ់បានក្នុងពេលដ៏យូរយារមកហើយនេះ »។ ព្រះភិក្ខុនីស្ដាប់ហើយ មិនជឿត្រចៀករបស់ខ្លួន ក្រែងថាខ្លួនឯងស្ដាប់ច្រឡំ ទើបសួរបញ្ជាក់ថា « កូន ! កូននិយាយថាដូចម្ដេចហ្នឹង »។ ព្រះកុមារកស្សបៈបានមានព្រះវាចាដូចមុនទៀត ។ ព្រះភិក្ខុនីទើបគិតថា « យើងមិនអាចអត់ទ្រាំមិនបង្ហូរទឹកភ្នែកបាន អស់ ១២ ឆ្នាំ ព្រោះហេតុនៃបុត្រ ប៉ុន្តែបុត្ររបស់យើងនេះ មានចិត្តរឹងគ្រោតគ្រាត មិនបាននឹកយើង ស្រឡាញ់យើងអ្វីបន្តិចសោះឡើយ ប្រយោជន៍អ្វីដោយបុត្រនេះ ដែលយើងមកវង្វេងនឹក វង្វេងស្រឡាញ់គេតែម្នាក់ឯងដូច្នេះ »។ ចិត្តរបស់ព្រះនាងភិក្ខុនី បីដូចផ្ទៃមេឃស្រឡះ កាត់អាល័យពីបុត្រ តាំងចិត្តប្រព្រឹត្តធម៌ ឃើញច្បាស់ថាមិនមានអ្វីជាខ្លួន និងជារបស់ខ្លួនឡើយ ហើយក៏បានសម្រេចនូវព្រះអរហត្តក្នុងថ្ងៃនោះឯង ។

ព្រះដ៏មានព្រះភាគ ទ្រង់ប្រកាសសេចក្ដីដែលព្រះថេរីកាត់ការស្រឡាញ់ចំពោះបុត្រ ហើយធ្វើទីពឹងឱ្យដល់ខ្លួនឯងបាន ទើបទ្រង់ត្រាស់ថា « ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលអាស្រ័យអ្នកដទៃមិនអាចនឹងសម្រេចបាននូវទេវលោក ឬមគ្គផលឡើយ ដូច្នោះហើយ ខ្លួនហ្នឹងឯងដែលជាទីពឹងរបស់ខ្លួន អ្នកដទៃនឹងធ្វើអ្វីឱ្យ





បាន » រួចហើយព្រះអង្គទ្រង់ត្រាស់នូវព្រះគាថា :

**អត្តា ហិ អត្តនោ នាថោ  កោ ហិ នាថោ បរោ សិយា**
**អត្តនា ហិ សុទន្តេន  នាថំ លភតិ ទុល្លភំ ។**

ខ្លួនជាទីពឹងនៃខ្លួនឯង បុគ្គលដទៃណាហ្ន៎ ដែលអាចជាទីពឹងបាន បុគ្គលដែលមានខ្លួនទូន្មានបានល្អហើយ រមែងបាននូវទីពឹងដែលគេបានដោយក្រ ។

ពាក្យថា « ទីពឹង » ក្នុងទីនេះ គឺសំដៅយកអំណាចនៃកុសលកម្ម រហូតដល់មគ្គផល ដែលមិនអាចអ្នកដទៃណាមួយមកជំនួសអំណាចនេះបានឡើយ ប៉ុន្តែកល្យាណមិត្តរមែងមានឧបការៈក្នុងទីពឹងនេះបាន ដោយពិតប្រាកដ ។

# ផ្នែកឧបាសក

## ១-ព្រះបាទពិម្ពិសារ

ព្រះបាទពិម្ពិសារមានប្រវត្តិដែលគួរឱ្យកត់សម្គាល់ដូចតទៅ:

-ព្រះរាជានគរមគធ: ។

-បានសម្រេចសោតាបត្តិផល ។

-ថ្វាយវេឡុវ័នមហាវិហារជាវត្តទី ១ ។

-មានប្រេតធ្លាប់ជាញាតិរបស់ព្រះអង្គ ។

-ចារអក្សរដាក់ក្រាំងមាស រៀបរាប់អំពីព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ កើតមានក្នុងលោក ផ្ញើក្រាំងមាសនោះទៅថ្វាយព្រះ-បាទបុក្កុសាតិ នគរតក្កសិលា ។

-បានទតរោមបាទជើងដ៏យ៉ាងស្អាតល្អអស្ចារ្យ របស់សោ-ណកោឡិវិស: ហើយបានណែនាំឱ្យសោណកោឡិវិស: ចូលគាល់ព្រះដ៏មានព្រះភាគ ដែលព្រះអង្គពេលនោះទ្រង់គង់ប្រថាប់នៅភ្នំគិជ្ឈកូដ ។

-មានព្រះរាជសទ្ធាជ្រះថ្លានឹងព្រះដ៏មានព្រះភាគដ៏ក្រៃលែង បានចាត់ចែងផ្លូវដ៏យ៉ាងពិសេស ក្នុងដំណើរព្រះសម្មាសម្ពុទ្ធទ្រង់យាងទៅកាន់នគរវេសាលី ។

-បានចាត់ការឱ្យព្រះនាងខេមា អគ្គមហេសីចូលគាល់ព្រះ-





ដ៏មានព្រះភាគ ។

-ជាព្រះរាជាទ្រង់ធម៌ មានព្រះទ័យករុណា អនុគ្រោះ បរិច្ចាគព្រះលោហិត ឱ្យដល់ព្រះនាងវេទេហី ដែលចាញ់គភ៌ ។

-ទោះជាបានជ្រាបថា មានបុត្រមកជាសត្រូវក៏ដោយ ក៏ព្រះអង្គទ្រង់ការពារបុត្រជានិច្ច ឱ្យជីវិតបុត្រ ថ្នមបុត្រ និងលះបង់អ្វីៗដើម្បីសមតាមប្រាថ្នារបស់បុត្ររហូត ។

-ពេលមួយដែលព្រះដ៏មានព្រះភាគ ទ្រង់គង់ប្រថាប់នៅព្រះគន្ធកុដិ នាភ្នំគិជ្ឈកូដ ព្រះបាទពិម្ពិសារ បានចូលគាល់ ហើយបានសូមនូវវរោកាសអំពីព្រះអង្គ សូមឱ្យភិក្ខុសង្ឃទាំងឡាយ ប្រជុំគ្នាក្នុងថ្ងៃបកតិឧបោសថរបស់ឧបាសក ឧបាសិកា ជាប្រយោជន៍ក្នុងការសម្តែងព្រះធម៌ ។

-ព្រះរាជា មានទំនាក់ទំនងជាមួយនឹងព្រះបិលិន្ទវច្ឆត្ថេរ ព្រះរាជាសូមប្រទានមនុស្សអ្នកស្រុកឱ្យមកជួយធ្វើការវត្ត ។ លុះជ្រាបដល់ព្រះដ៏មានព្រះភាគ ព្រះអង្គទ្រង់អនុញ្ញាតឱ្យមាន អារា-មិក: គឺ មនុស្សដែលធ្វើការទំនុកបម្រុងវត្ត បម្រើវត្ត ។ ព្រះរាជាបានប្រទានមនុស្សសម្រាប់ធ្វើការងារបម្រើវត្ត ៥០០ នាក់ដល់ព្រះបិលិន្ទវច្ឆត្ថេរ មនុស្សទាំងនោះបានរស់នៅជុំគ្នាជាភូមិមួយ ហៅថា « ភូមិអារាមិក: » ឬ « ភូមិបិលិន្ទវច្ឆ: » ។



-១២៤-

-ពេលមួយព្រះរាជា មានព្រះរាជបំណង ដើម្បីនឹងស្រង់ទឹកតបោទា នៅខាងជើងក្រុងរាជគ្រឹះ ក្រៅខ្លោងទ្វារ ប៉ុន្តែដោយសារភិក្ខុសាមណេរស្រង់ទឹកក្ដៅយូរពេក ព្រះរាជានៅរង់ចាំទាល់តែគេបិទទ្វារនគរ ។ ដោយសម័យនោះ ក្រុងរាជគ្រឹះមានសត្រូវច្រើន ព្រះរាជាបានត្រាស់បង្គាប់ឱ្យគេរក្សាព្រះនគរយ៉ាងតឹងរ៉ឹង ទ្វារធំៗនៃក្រុងត្រូវបើកបិទតាមពេលវេលា មិនមានលើក-លែងឱ្យអ្នកណាម្នាក់ឡើយ សូម្បីតែព្រះអង្គជាស្ដេចហ្នឹងក៏ដោយដូច្នេះ រាត្រីនោះទ្រង់ត្រូវគង់នៅក្រៅក្រុងរហូតវាស់ព្រឹក ។

-ជាចុងក្រោយនៃព្រះជន្មរបស់ព្រះអង្គ ត្រូវព្រះរាជបុត្រអជាតសត្តុគ្រប់គ្រងរាជសម្បត្តិ ហើយចាប់ព្រះអង្គជាព្រះបិតាឃុំឃាំង តាមការញុះញង់របស់ភិក្ខុទេវទត្ត ទីបំផុតព្រះរាជាត្រូវអស់ព្រះជន្មក្នុងទីឃុំឃាំងនោះឯង ព្រមជាមួយគ្នានិងបុត្ររបស់ ព្រះ-បាទអជាតសត្តុត្រូវបានប្រសូត ។ ព្រះអង្គបដិសន្ធិក្នុងទេវលោកជាសម្លាញ់នៃព្រះបាទវេស្សវណ្ណ ។

## ២ -ព្រះបាទអជាតសត្តុ

ព្រះបាទអជាតសត្តុ ជាបុត្ររបស់ព្រះបាទពិម្ពិសារ ជាមួយនឹងព្រះនាងវេទេហី មានប្រវត្តិដែលគួរឱ្យកត់សម្គាល់ដូចតទៅ :



-កាលពីនៅក្នុងព្រះគភ៌ ព្រះមាតាបានចាញ់គភ៌ ចង់សោយព្រះលោហិតរបស់ព្រះស្វាមី ។

-កាលដែលនៅជាព្រះរាជកុមារ បានសេពគប់ ជិតដិតស្និទ្ធស្នាលជាមួយនឹងភិក្ខុទេវទត្ត ។

-បានធ្វើបិតុឃាតជាអនន្តរិយកម្មរួចហើយទើបមានសេចក្ដីក្ដៅក្រហាយស្ដាយក្រោយ ។

-ក្រោយមកបានឃើញទោសភិក្ខុទេវទត្ត ឈប់ទំនុកបម្រុងហើយបានសេពគប់ជាមួយពេទ្យ **ជីវកកោមារភច្ច** ។

-អាស្រ័យពេទ្យជីវកជាកល្យាណមិត្ត ព្រះបាទអជាតសត្តុបានចូលទៅគាល់ព្រះបរមសាស្ដា នៅជីវកម្ពវន័ បានស្ដាប់សាមញ្ញផលសូត្រ បានដល់ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃជាទីពឹងទីរលឹក និងបានសូមខមាទោសចំពោះព្រះដ៏មានព្រះភាគ ។

-ចាប់តាំងតែពីធ្វើបិតុឃាតបានសម្រេចហើយមក ព្រះបាទអជាតសត្តុមិនបានផ្ទុំលក់ឡើយ ទាំងយប់ទាំងថ្ងៃ ប៉ុន្តែក្រោយពេលដែលស្ដេចបានចូលគាល់ព្រះបរមសាស្ដា បានស្ដាប់ព្រះធម៌ទេសនាដ៏ពីរោះ មាននូវឱជាដ៏ពិសេសនោះហើយ ព្រះអង្គបានផ្ទុំលក់ និងទ្រង់បានធ្វើសក្ការៈដ៏ធំក្រៃលែងចំពោះព្រះរតនត្រៃ ។

-ក្នុងបណ្ដាបុថុជ្ជនទាំងឡាយ អ្នកដែលមាននូវសទ្ធាជ្រះថ្លា

ចំពោះព្រះរតនត្រៃ ស្មើដោយព្រះបាទអជាតសត្តុមិនមានឡើយ ។

-នៅពេលដែលព្រះរាជាបានជ្រាបថា ព្រះបរមសាស្តាទ្រង់បរិនិព្វានហើយ ព្រះរាជាទ្រង់សន្លប់អស់ ៣ ដង ក្រោយមកក៏កន្ទក់កន្ទេញដោយសេចក្តីសោក ទ្រង់យាងចេញពីព្រះរាជវាំងមកតាមថ្នល់ មានអាការដូចមនុស្សវិកលចរិត ទ្រង់យាងចូលកាន់ជីវកម្ពវ័ន ទ្រង់ពោលរៀបរាប់រកព្រះដ៏មានព្រះភាគដោយប្រការផ្សេងៗ ។

-ព្រះបាទអជាតសត្តុវេទេហីបុត្រ បានទទួលព្រះបរមសារីរិកធាតុនៃព្រះសម្មាសម្ពុទ្ធ ១ ភាគក្នុង ៨ ភាគ ពីនគរកុសិនារាដង្ហែមកកាន់ក្រុងរាជគ្រឹះយ៉ាងគគ្រឹកគគ្រេង ហើយបញ្ចុះព្រះធាតុក្នុងព្រះចេតិយ ឱ្យជាទីគោរពបូជានៃមហាជន ។

-ព្រះរាជាបានចាត់ចែងឱ្យជាងជួសជុល (បដិសង្ខរណៈ ) រៀបចំវត្ត ១៨ ជុំវិញក្រុងរាជគ្រឹះ រួចហើយបានឧបត្ថម្ភនូវបឋមសង្គាយនា ដែលក្នុងនោះមានព្រះអរហន្ត ៥០០ អង្គសុទ្ធតែបាននូវអភិញ្ញា និងបដិសម្ភិទា មានព្រះមហាកស្សបត្ថេរជាប្រធាន ព្រះឧបាលិត្ថេរវិសជ្ជនាព្រះវិន័យ ឯព្រះអានន្ទត្ថេរវិសជ្ជនានូវព្រះសូត្រ និងព្រះអភិធម្ម ប្រព្រឹត្តទៅអស់ ៧ ខែទើបចប់បិដកទាំង ៣ នៅសត្តបណ្ណគុហា នាភ្នំវេភារៈជាប់ក្រុងរាជគ្រឹះ ពេលនោះផែនដី



កក្រើកញាប់ញ័រ ។

-ព្រះរាជា បានរួមសហការជាមួយនឹងព្រះមហាកស្សបត្ថេររៀបចំនូវការងារដ៏ធំមួយទៀតហៅថា « ធាតុនិធាន » កប់ព្រះធាតុ ៧ ចំណែកក្នុងទីតែមួយនៅទិសអគ្នេយ៍ក្រុងរាជគ្រឹះ បានរៀបចំកន្លែងកប់ព្រះធាតុនោះ ពោរពេញដោយរតនវត្ថុ និងដោយការអធិដ្ឋានរបស់ព្រះមហាកស្សបត្ថេរ ។

-កាលព្រះមហាកស្សបត្ថេរបរិនិព្វានថ្មីៗ ព្រះរាជាព្រមដោយបរិវារដ៏ច្រើន បានយាងទៅថ្វាយបង្គំព្រះសរីរសពនៃព្រះថេរៈនៅភ្នំកុក្កុដសមបាត ដែលមុននឹងបរិនិព្វាន ព្រះថេរៈបានអធិដ្ឋានឱ្យព្រះរាជា ព្រមទាំងបរិវារបានឃើញសរីរសពក្នុងចន្លោះភ្នំទាំង ៣ ។

-នៅខាងចុងនៃសាមញ្ញផលសូត្រ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា«ប្រសិនបើព្រះរាជាអង្គនេះ មិនបានផ្តាច់បង់ព្រះជន្មាយុនៃព្រះបិតាដែលជាព្រះធម្មរាជា ប្រកបដោយធម៌ទេ ធម្មចក្ខុ គឺសោតាបត្តិមគ្គ ដែលប្រាសចាកធូលី ប្រាសចាកមន្ទិល នឹងកើតឡើង ដល់ព្រះរាជាលើអាសនៈនេះ មិនខានឡើយ »។ ព្រះបាទអជាតសត្តុត្រូវអស់ព្រះជន្ម ដោយឧទយភទ្ទជាបុត្រ ធ្វើឃាតដណ្តើមរាជសម្បត្តិ ហើយបដិសន្ធិក្នុងលោហកុម្ភីនរក ។

-ក្នុងអនាគតជាតិ នៃព្រះបាទអជាតសត្តុ កាលដែលបាន រួចទុក្ខទោសពីក្នុងអបាយភូមិហើយ នឹងបានត្រាស់ជាព្រះបច្ចេក-ពុទ្ធមួយព្រះអង្គមានព្រះនាមថា « ជីវិតវិសេស » ហើយបរិនិព្វាន ដែលជាបរិយោសាននៃជីវិតក្នុងវដ្តសង្សារ ។

## ៣-ពេទ្យជីវកកោមារភច្ច

ពេទ្យជីវកកោមារភច្ច កើតនៅក្នុងរាជគ្រឹះ ម្ដាយឈ្មោះ **សាលវតី** ជានគរសោភិនីប្រចាំក្រុងរាជគ្រឹះ មានប្រវត្តិដែលគួរកត់សម្គាល់ដូចតទៅ :

-ព្រោះម្ដាយបោះបង់ចោល ទើបបានអភយរាជកុមាររើស យកមកចិញ្ចឹមឱ្យមានជីវិត ។

-ធំឡើងបានទៅរៀនវិជ្ជាពេទ្យ នៅឯនគរតក្កសិលា មាន ព្យាយាមមោះមុត ចេះចប់វិជ្ជាក្នុងវេលាតិចជាងសិស្សធម្មតា និង ជាពេទ្យពូកែបំផុត ។

-មានការដឹងគុណអភយរាជកុមារជាបិតាចិញ្ចឹមណាស់ ដែលធ្វើឱ្យអភយរាជកុមាររឹងរឹតតែស្រឡាញ់ ។

-ពេទ្យជីវកកោមារភច្ច បានថ្វាយការព្យាបាលដល់ព្រះបាទ ពិម្ពិសារ និងក្លាយជាពេទ្យប្រចាំរាជវាំង ។





-បានថ្វាយការព្យាបាលដល់ព្រះរាជានគរដទៃ មាននគរ ឧជ្ជេនីជាដើម បានរង្វាន់ថ្លៃព្យាបាលច្រើនសន្ធឹកសន្ធាប់ ។

-បានថ្វាយការព្យាបាលដល់ព្រះដ៏មានព្រះភាគ ថ្វាយសំពត់ ដ៏មានតម្លៃប្រមាណមិនបានដល់ព្រះសម្មាសម្ពុទ្ធ និងសំពត់ដទៃ ១០០០ ផ្ទាំងដល់ភិក្ខុសង្ឃ ព្រមទាំងសូមពរ សូមព្រះមានព្រះភាគ អនុញ្ញាតគហបតិចីវរ ដល់ភិក្ខុសង្ឃទទួលប្រើប្រាស់ ។ ព្រះអង្គ ទ្រង់អនុញ្ញាតគហបតិចីវរចាប់ពីពេលនោះមក ។

-ព្រះពុទ្ធគង់លើភ្នំគិជ្ឈកូដ សម្ដែងព្រះធម៌ ពេទ្យជីវកបាន សម្រេចសោតាបត្តិផល ។

-បានកសាងវត្តនៅនឹងចម្ការស្វាយរបស់ខ្លួន ថ្វាយសង្ឃ មានព្រះពុទ្ធជាប្រធាន ។ វត្តនោះឈ្មោះថា **ជីវកម្ពវ័ន** នៅក្នុងក្រុង រាជគ្រឹះ ចុះពីភ្នំគិជ្ឈកូដចូលមកខាងក្នុង ។

-ក្នុងមហាខន្ធកៈ វិន័យបិដកលេខ ៦ , ទំព័រ ២៣៩ ពេទ្យ ជីវកបានពិនិត្យឃើញមានបញ្ហា មនុស្សមានរោគ ៥ យ៉ាង គឺ **កុដ្ឋំ** ឃ្លង់ ១ , **គណ្ឌោ** ពកឬបូស ១ , **កិលាសោ** ស្រែង ១ , **សោសោ** រោគរីងរៃ ១ និង **អបមារោ** ឆ្កួតជ្រូក ១ នាំគ្នាបួសដោយគ្រាន់តែ ដើម្បីងាយស្រួលក្នុងការរក្សាព្យាបាល ជាហើយក៏សឹកវិញ ។ ពេទ្យជីវកបានចូលគាល់ព្រះដ៏មានព្រះភាគ ក្រាបទូលព្រះអង្គថា

« បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសូមពរថា លោកម្ចាស់ ទាំង-ឡាយកុំបំបួសមនុស្សដែលមានអាពាធទាំង ៥ យ៉ាងឡើយ » ...។ ទើបព្រះអង្គទ្រង់បញ្ញត្តថា « ម្នាលភិក្ខុទាំងឡាយ មនុស្សដែលមានអាពាធទាំង ៥ យ៉ាងហើយ អ្នកទាំងឡាយមិនគប្បីបំបួសឡើយ ភិក្ខុណាបំបួស ត្រូវអាបត្តិទុក្កដ » ។

-ក្នុងខុទ្ទកវត្ថុក្ខន្ធក បិដកលេខ ១០ , ទំព័រ ១៦៩ ពេទ្យជីវកបានពិនិត្យឃើញភិក្ខុទាំងឡាយ មានកាយច្រើនទៅដោយទោស (រោគទល់) មានអាពាធច្រើន។ ពេទ្យជីវកបានចូលគាល់ព្រះដ៏មានព្រះភាគ ក្រាបទូលព្រះអង្គថា « បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ភិក្ខុទាំងឡាយមានកាយច្រើនទៅដោយទោស មានអាពាធច្រើន បពិត្រព្រះដ៏មានព្រះភាគដ៏ចម្រើន ខ្ញុំព្រះអង្គសូមអង្វរ សូមព្រះអង្គអនុញ្ញាតទីចង្ក្រម និងរោងភ្លើងដល់ភិក្ខុទាំងឡាយ ជាការប្រពៃ កាលបើយ៉ាងនេះភិក្ខុទាំងឡាយនឹងមិនសូវមានអាពាធ »។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ធ្វើធម្មីកថាក្នុងវេលានោះ ហើយត្រាស់ហៅភិក្ខុទាំងឡាយមកថា « ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតទីចង្ក្រម និងរោងភ្លើង » ...។

-ប្រវត្តិរឿងរ៉ាវរបស់ពេទ្យជីវកកោមារភច្ច មានពិស្តារក្នុងវិន័យបិដកលេខ ៨ , ចីវរក្ខន្ធកៈ , ទំព័រ ៦១ បញ្ជាក់អំពីសមត្ថភាព





និងទឹកចិត្តមនុស្សល្អ ដែលគួរឱ្យសិក្សាចម្រើនសេចក្តីជ្រះថ្លា ។

-ក្នុងគាថាធម្មបទ អរហន្តវគ្គ បានប្រារព្ធចំពោះព្រះអង្គទ្រង់ត្រូវរបួស ពងព្រះលោហិត ដោយសារភិក្ខុទេវទត្ត បំណងធ្វើឃាតព្រះអង្គ នៅភ្នំគិជ្ឈកូដ ។ ភិក្ខុទេវទត្តមានចិត្តប្រទូស្តចំពោះព្រះសម្មាសម្ពុទ្ធ ទម្លាក់ថ្មលើព្រះអង្គ ឯពេទ្យ **ជីវក** ជ្រះថ្លានិងព្រះដ៏មានព្រះភាគដ៏ក្រៃលែង បានថ្វាយការរក្សា និងព្យាបាលដល់ព្រះអង្គនៅជីវកម្ពវ័ន ដោយការបិទថ្នាំថ្វាយ ហើយបានក្រាបទូលសួរព្រះអង្គថា « បពិត្រព្រះអង្គដ៏ចម្រើន សេចក្តីក្តៅក្រហាយកើតឡើងក្នុងព្រះសរីរៈរបស់ព្រះអង្គឬទេ ? » ។

ព្រះសាស្តាទ្រង់ត្រាស់ថា « ជីវក សេចក្តីក្តៅក្រហាយទាំងពួងរបស់តថាគត ស្ងប់រម្ងាប់ហើយ នៅគល់ពោធិព្រឹក្សនោះឯង »។ ដូច្នេះហើយ ព្រះអង្គទ្រង់បន្តអនុសន្ធិ ត្រាស់នូវព្រះគាថានេះថា :

**គតទ្ធិនោ វិសោកស្ស វិប្បមុត្តស្ស សព្វធិ**
**សព្វគន្ថប្បហីនស្ស បរិឡាហោ ន វិជ្ជតិ ។**

សេចក្តីក្តៅក្រហាយ រមែងមិនមានដល់បុគ្គលដែលមានផ្លូវឆ្ងាយបានដល់ហើយ មិនមានសេចក្តីសោក រួចផុតហើយពីធម៌ទាំងពួងមានខន្ធ ៥ ជាដើម និងជាអ្នកលះបង់នូវកិលេសដែលជា

គ្រឿងដោតក្រងទាំងពួងបានហើយ ។

-ជីវកម្ពវនារាម ជាអារាមដែលពេទ្យជីវកបានសាងថ្វាយសង្ឃមានព្រះពុទ្ធជាប្រធាន ។ វត្តនេះឯងហើយ ដែលព្រះចូឡបន្ថកៈបានសម្រេចនូវគុណធម៌ដ៏ខ្ពង់ខ្ពស់ ចប់កិច្ចរបស់បព្វជិតក្នុងព្រះសាសនា ។

-ក្នុងបិដកលេខ ៤៨ , ទំព័រ ១៣២ សម័យមួយព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងជីវកម្ពវ័ន ។ ពេទ្យជីវកបានទូលសួរព្រះដ៏មានព្រះភាគអំពី ឧបាសកអ្នកមានសីល រហូតដល់ខាងចុងព្រះសូត្រ បានទូលសួរព្រះអង្គថា « បពិត្រព្រះអង្គដ៏ចម្រើន ឧបាសកអ្នកប្រតិបត្តិ ដើម្បីជាប្រយោជន៍ដល់ខ្លួនឯងផង ដើម្បីជាប្រយោជន៍ដល់បុគ្គលដទៃផង តើដោយហេតុដូចម្តេច ? » ។

ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ធម៌ ៨ គឺ :

១-ឧបាសកបរិបូណ៌ដោយសទ្ធា ដោយខ្លួនឯងផង ទាំងបបួលបុគ្គលដទៃឱ្យបរិបូណ៌ដោយសទ្ធាផង ។

២-ជាអ្នកបរិបូណ៌ដោយសីល ដោយខ្លួនឯងផង ទាំងបបួលបុគ្គលដទៃឱ្យបរិបូណ៌ដោយសីលផង ។

៣-ជាអ្នកបរិបូណ៌ដោយចាគៈ ដោយខ្លួនឯងផង ទាំងបបួលបុគ្គលដទៃឱ្យបរិបូណ៌ដោយចាគៈផង ។



៤-ជាអ្នកចង់ឃើញពួកភិក្ខុ ដោយខ្លួនឯងផង ទាំងបបួលបុគ្គលដទៃឱ្យបានឃើញពួកភិក្ខុផង ។

៥-ជាអ្នកចង់ស្តាប់ព្រះសទ្ធម្ម ដោយខ្លួនឯងផង ទាំងបបួលបុគ្គលដទៃឱ្យបានស្តាប់នូវព្រះសទ្ធម្មផង ។

៦-ជាអ្នកទ្រទ្រង់នូវធម៌ទាំងឡាយ ដែលបានស្តាប់ហើយ ដោយខ្លួនឯងផង ទាំងបបួលបុគ្គលដទៃឱ្យទ្រទ្រង់នូវធម៌ផង ។

៧-ជាអ្នកពិចារណានូវអត្ថនៃធម៌ទាំងឡាយ ដែលបានស្តាប់ហើយ ដោយខ្លួនឯងផង ទាំងបបួលបុគ្គលដទៃឱ្យពិចារណានូវអត្ថផង ។

៨-ជាអ្នកដឹងច្បាស់នូវអត្ថ ដឹងច្បាស់នូវធម៌ ហើយប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ ដោយខ្លួនឯងផង ទាំងបបួលបុគ្គលដទៃឱ្យប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ផង ។

ម្នាលជីវក ដោយហេតុមានប្រមាណប៉ុណ្ណេះឯង ឧបាសកទើបមានឈ្មោះថា ជាអ្នកប្រតិបត្តិដើម្បីជាប្រយោជន៍ដល់ខ្លួនឯងផង ដើម្បីជាប្រយោជន៍ដល់អ្នកដទៃផង ។

-ក្នុងបិដកលេខ ២៣ ,ទំព័រ ៨៣ **ជីវកសូត្រ** ពេទ្យជីវកបានទូលសួរព្រះដ៏មានព្រះភាគអំពីត្រី និងសាច់ដែលជាអាហារកិច្ចសម្រាប់បព្វជិត ។ ព្រះអង្គទ្រង់ត្រាស់សម្តែងអំពីត្រីនិងសាច់យ៉ាង

ដូចម្តេចគួរ និងយ៉ាងដូចម្តេចមិនគួរ ។ សម្តែងអំពីព្រហ្មវិហារ ៤ យ៉ាង និងការសម្លាប់សត្វចំពោះតថាគត ឬសាវ័ករបស់តថាគត រមែងមានបាបច្រើន ដោយហេតុ ៥ យ៉ាង ។ បានសិក្សាក្នុងព្រះសូត្រនេះហើយ នឹងបានដឹងថា « អាហារបរិសុទ្ធ » នោះ តើដូចម្តេចតាមសេចក្តីពិត ។

-ដែលគួរកោតស្ញប់ស្ញែងដ៏ក្រៃលែង ដល់សមត្ថភាពរបស់ពេទ្យជីវក គឺពេទ្យជីវកអាចយាងព្រះបាទអជាតសត្តុ ឱ្យបានមកគាល់ព្រះដ៏មានព្រះភាគ នេះជាគុណូបការៈដ៏ធំធេងរបស់ពេទ្យជីវកកោមារភច្ច ដែលមានចំពោះព្រះបាទអជាតសត្តុ ក៏ដូចជាមានចំពោះព្រះពុទ្ធសាសនា ។

-ក្នុងជីវិតរបស់ពេទ្យជីវក មានអ្នកដទៃស្រឡាញ់រាប់អានច្រើន ទាំងស្តេចទាំងរាស្ត្រ ទាំងអ្នកតូចទាំងអ្នកធំ ទាំងគ្រហស្ថទាំងបព្វជិត ដោយអាស្រ័យលើការឆ្លាតវាងវៃ សមត្ថភាពជាក់ស្តែង មានទឹកចិត្តប្រកបដោយមេត្តាករុណាច្រើន ទាំងជាព្រះអរិយបុគ្គលទៀតផង។ ព្រះអង្គទ្រង់ស្ថាបនាក្នុងតំណែងជាឯតទគ្គៈលើឧបាសកទាំងឡាយផ្នែកខាង មានសេចក្តីជ្រះថ្លាក្នុងបុគ្គល គឺជ្រះថ្លាក្នុងបុគ្គលដែលគួរជ្រះថ្លាពិតៗ ។





### ៩-ទីឃនខបរិព្វាជក

បរិព្វាជកនេះ ឈ្មោះថា **ទីឃនខៈ** (អានថា ទីឃៈនៈខៈ)ប្រែថា ក្រចកវែង គឺបរិព្វាជកនេះគាត់មានក្រចកវែង កើតក្នុងត្រកូលអគ្គិវេស្សនៈ ត្រូវជាក្មួយព្រះសារីបុត្ត ។ ពេលដែលព្រះដ៏មានព្រះ-ភាគសម្តែងវេទនាបរិគ្គហសូត្រ ប្រោសបរិព្វាជកនេះ នៅគុហាសុករខាតា ភ្នំគិជ្ឈកូដ ព្រះសារីបុត្តកំពុងបក់ផ្លិតថ្វាយព្រះបរមគ្រូបានស្តាប់ទេសនានោះ ហើយបានសម្រេចជាព្រះអរហន្ត នៅក្នុងថ្ងៃ ១៥ កើតខែមាឃ ក្នុងវេលាល្ងាច ។ ចំណែក ទីឃនខៈក៏បានសម្រេចនូវសោតាបត្តិផល សម្តែងខ្លួនជាឧបាសកក្នុងព្រះ-ពុទ្ធសាសនា ។

សេចក្តីពិស្តារនៃការសន្ទនារវាងទីឃនខៈ និងព្រះដ៏មាន-ព្រះភាគ រួមទាំងព្រះធម៌ដែលព្រះអង្គទ្រង់សម្តែងអំពីរូបកម្មដ្ឋាន និងអរូបកម្មដ្ឋាន ក្នុងពេលនោះផង មានក្នុងបិដកលេខ ២៤ , ទំព័រ ៤៨ **ទីឃនខសូត្រ** ។ ព្រះសូត្រនេះព្រះអង្គសម្តែងនៅពេលល្ងាច ថ្ងៃ១៥ កើតខែមាឃ ក្រោយអំពីការត្រាស់ដឹងបាន ៩ ខែ ។ ថ្ងៃនោះមានចតុរង្គសន្និបាតសម្តែងឱវាទបាតិមោក្ខក្នុងវត្តវេឡុវ័នក្រោមពន្លឺដួងចន្ទពេញបូណ៌មី ។

## ៥-កុម្ភឃោសកសេដ្ឋី

កុម្ភឃោសកៈ ជាបុត្រសេដ្ឋីក្រុងរាជគ្រឹះ មានសម្បត្តិ ៤០ កោដិកហាបណៈ ។ កាលក្នុងផ្ទះកើតរោគឆ្លងដ៏សាហាវ មាតាបិតាបានឱ្យកូនរត់គេចខ្លួន ទាំងបានប្រាប់ទីដែលកប់ទ្រព្យចំនួន ៤០ កោដិនោះផង ។ ក្រោយពីរត់គេចទៅនៅព្រៃភ្នំអស់ ១២ ឆ្នាំ ទើបបានមកវិញ មិនមានអ្នកណាស្គាល់សោះ ។ ដោយស្គាល់កាលៈទេសៈ ក៏មិនបាននាំយកទ្រព្យពីទីដែលកប់នោះមកចាយវាយឡើយ ។ កុម្ភឃោសកៈ រស់នៅដោយធ្វើការស៊ីឈ្នួលគេ រហូតទាល់តែព្រះបាទពិម្ពិសារទ្រង់បានស្គាល់សម្តី ដឹងថាមិនមែនជាអ្នកក្រ គឺប្រាកដជាអ្នកមានសម្បត្តិច្រើន ។

ប្រវត្តិរឿងរ៉ាវរបស់កុម្ភឃោសកសេដ្ឋី មានពិស្តារនៅក្នុងអដ្ឋកថាធម្មបទ ត្រង់ **អប្បមាទវគ្គ** ។ ព្រះរាជាបានជួយឱ្យកុម្ភឃោសកៈ គ្រប់គ្រងទ្រព្យសម្បត្តិ ក្នុងតំណែងជាសេដ្ឋីក្រុងរាជគ្រឹះ មួយអន្លើដោយការប្រទានបុត្រីរបស់ព្រះអង្គ ឱ្យបានជាភរិយានៃកុម្ភឃោសកសេដ្ឋីទៀតផង ។

ព្រះរាជា នៅមានឧបការគុណដ៏ធំក្រៃលែងមួយមុខទៀត គឺបាននាំកុម្ភឃោសកសេដ្ឋី ចូលគាល់ព្រះបរមសាស្តា ហើយបានក្រាបទូលរឿងរ៉ាវសព្វគ្រប់ថ្វាយដល់ព្រះអង្គ ។ ព្រះដ៏មានព្រះភាគ





ទ្រង់ត្រាស់ថា « មហាបពិត្រ ជីវិតនៃបុគ្គលរស់នៅយ៉ាងនេះ ឈ្មោះថារស់នៅប្រកបដោយធម៌ ។ អំពើបាបកម្មទាំងឡាយ មានចោរកម្មជាដើម រមែងបៀតបៀននូវអ្នកដែលធ្វើនោះឯង ទាំងក្នុងលោកនេះ ទាំងក្នុងលោកខាងមុខ មិនមានសេចក្តីសុខព្រោះចោរកម្មនេះឡើយ ។ ឯបុគ្គលធ្វើការស៊ីឈ្នួលគេក្តី ធ្វើស្រែចំការក្តី ចិញ្ចឹមជីវិតដោយប្រពៃក្នុងការងារដទៃទៀតក្តី ជីវិតរមែងមានតែសេចក្តីចម្រើនដោយគុណ ដល់ព្រមដោយសេចក្តីព្យាយាម និងបរិបូណ៌ដោយសតិជាដើម »។ ព្រះអង្គទ្រង់ត្រាស់បន្តនូវព្រះគាថានេះថា :

**ឧដ្ឋានវតោ សតីមតោ សុចិកម្មស្ស និសម្មការិនោ**
**សញ្ញតស្ស ច ធម្មជីវិនោ អប្បមត្តស្ស យសោភិវឌ្ឍតិ។**

យស រមែងចម្រើនដ៏ក្រៃលែង ដល់បុគ្គលដែលមាននូវសេចក្តីព្យាយាមប្រឹងប្រែង មានស្មារតី មានការងារស្អាតល្អប្រពៃ មានប្រក្រតីពិនិត្យពិចារណាហើយទើបធ្វើ ជាអ្នកសង្រួមហើយ (ដោយការសង្រួមកាយជាដើម) ចិញ្ចឹមជីវិតឱ្យរស់នៅប្រកបដោយធម៌ និងជាអ្នកមិនប្រមាទ ។

ក្នុងកាលចប់នូវព្រះគាថា កុម្ភឃោសកសេដ្ឋីក៏បានសម្រេចនូវសោតាបត្តិផល ជាឧបាសករាប់អានព្រះរតនត្រ័យរហូតជីវិត

និងមានការជួយទំនុកបម្រុងព្រះពុទ្ធសាសនា ឱ្យចម្រើនរុងរឿង ក្នុងក្រុងរាជគ្រឹះជាដើម រហូតដល់អស់ជីវិតក៏បានទៅកាន់សុគតិ-ភព ជាបុគ្គលទៀងតែបានសម្រេចនូវព្រះអរហត្តជាពិតប្រាកដ ក្នុងជាតិដ៏ខ្លីខាងមុខ ពុំខានឡើយ ។

## ៦-កោសិយសេដ្ឋី

រឿងពិស្តារក្នុងអដ្ឋកថាធម្មបទ បុប្ផវគ្គ ដោយសង្ខេបគឺថា នៅក្នុងនគរមគធៈជិតក្រុងរាជគ្រឹះ មានសេដ្ឋីម្នាក់ឈ្មោះកោសិយ មានសេចក្តីកំណាញ់ណាស់ សូម្បីតែចំពោះខ្លួនឯង ឯទ្រព្យសម្បត្តិវិញមានដល់ទៅ ៨០ កោដិ ។

ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ឱ្យព្រះមហាមោគ្គល្លាន និមន្តទៅទូន្មានដល់កោសិយសេដ្ឋី ។ ព្រះថេរៈបានសម្តែងឫទ្ធិអធិដ្ឋានក្នុងរឿងនំអំបែង រហូតទាល់តែកោសិយសេដ្ឋីមានសេចក្តីជ្រះថ្លាក្នុងធម្មកថា ដែលព្រះមហាថេរៈបានសម្តែងអំពីគុណព្រះ-រតនត្រៃនិងអានិសង្សនៃការឱ្យទានជាដើម។ ព្រះមហាមោគ្គល្លាន បាននាំលោកសេដ្ឋីជាមួយនឹងភរិយាមកគាល់ព្រះបរមសាស្តា ឱ្យអ្នកទាំងពីរបានថ្វាយនំអំបែងដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន រួចហើយព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សម្តែងព្រះធម៌ទេសនា ឱ្យ



អ្នកទាំងពីរបានស្តាប់ ។

កាលចប់ព្រះធម៌ទេសនា លោកសេដ្ឋីព្រមទាំងភរិយា ទាំងពីរអង្គក៏បានសម្រេចសោតាបត្តិផល ថ្វាយបង្គំព្រះបរមសាស្តា ប្រកាសខ្លួនជាឧបាសក ឧបាសិកា ។ តាំងតែពីកាលនោះមក លោកសេដ្ឋីបានចំណាយទ្រព្យចំនួន ៨០ កោដិកហាបណៈ កប់ទុកក្នុងព្រះពុទ្ធសាសនានោះឯង ។

រឿងបន្តមកទៀត គឺភិក្ខុទាំងឡាយបានពោលសរសើរព្រះ-មហាមោគ្គល្លាន ដែលមិនបានទៅធ្វើឱ្យគេខូចទ្រព្យសម្បត្តិ ថែមទាំងញុំាងសទ្ធាឱ្យកើតឡើង លះបង់មច្ឆរិយៈ រហូតដល់បានថ្វាយទានដ៏អស្ចារ្យ ស្តាប់ធម៌ទេសនាអំពីព្រះសាស្តា បានសម្រេចសោតាបត្តិផលទៀត ។ ព្រះថេរៈចំជាអស្ចារ្យ ព្រះថេរៈមានអានុភាពច្រើន ... ។

ព្រះបរមសាស្តាទ្រង់ជ្រាបហើយ បានត្រាស់សរសើរព្រះ-មហាមោគ្គល្លាន ជាការបញ្ជាក់ថាជាការប្រសើរពិតហើយ រួចទ្រង់ត្រាស់នូវព្រះគាថា :

**យថាបិ ភមរោ បុប្ផំ វណ្ណគន្ធំ អហេឋយំ**
**បលេតិ រសមាទាយ ឯវំ គាមេ មុនី ចរេ ។**

មុនីគប្បីចូលទៅក្នុងផ្ទះ ដូចជាភមរជាតិ មិនធ្វើឱ្យខូចនូវ

ពណ៌ និងក្លិនផ្កា ក្រេបយកតែរសនៃកេសរផ្កា ហើយហើរទៅយ៉ាងដូច្នោះឯង ។

បាទនៃព្រះគាថា ថា « **ឯវំ គាមេ មុនី ចរេ** » ដោយសេចក្តីថា ព្រះអនាគារិយមុនី មានព្រះសេក្ខ និងព្រះអសេក្ខនិមន្តបិណ្ឌបាតទៅតាមលំដាប់ផ្ទះ ។

ពិតណាស់ ការវិនាសខូចនូវសទ្ធា ឬវិនាសខូចខាតនូវទ្រព្យសម្បត្តិ មិនមានដល់ត្រកូលទាំងឡាយ ព្រោះហេតុនៃការនិមន្តចូលស្រុករបស់មុនីនោះជាបច្ច័យឡើយ ។ សទ្ធាក្តី ទ្រព្យសម្បត្តិក្តី ឋិតនៅជាប្រក្រតីនោះឯង រីឯព្រះសេក្ខមុនី និងព្រះអសេក្ខមុនីកាលនិមន្តទៅបិណ្ឌបាតក្នុងស្រុក ហើយចេញមកវិញ ព្រះសេក្ខ-មុនី ក្រាលសង្ឃាដី គង់អង្គុយក្នុងទីសប្បាយនៅជិតស្រះទឹកក្រោមម្លប់ឈើក្រៅស្រុក ហើយពិចារណាអាហារបិណ្ឌបាត ។ កាលពិចារណាអាហារឱ្យដូចជាសាច់កូនឬដូចជាសំពត់បិទដំបៅជាដើមហើយ ក៏ឆាន់ដោយការស្គាល់ប្រមាណ រួចចូលទៅកាន់ទីស្ងាត់ក្នុងព្រៃ ពិចារណាកម្មដ្ឋាន បដិបត្តិបានសម្រេចនូវគុណធម៌ជាន់ខ្ពស់ធ្វើមគ្គ ៤ ផល ៤ ឱ្យនៅក្នុងកណ្តាប់ដៃ ។ ចំណែកព្រះអសេក្ខមុនីប្រកបនៅដោយការសប្បាយក្នុងធម៌ដែលជាក់ច្បាស់ហើយ ។ បណ្ឌិតគប្បីជ្រាបភាពនៃមុនីនោះៗ ដូចគ្នានឹងមេឃ្មុំដែលនាំយកលំអងកេសរផ្កាមកធ្វើជាទឹកផ្អែម (ក្បាលទឹក ) ដូច្នោះឯង ។ តែក្នុងទីនេះ ទ្រង់សំដៅយកព្រះខីណាស្រព ។





### ៧-សុប្បពុទ្ធកុដ្ឋិ

សុប្បពុទ្ធកុដ្ឋិ ជាឧបាសកបានសម្រេចសោតាបត្តិផល ។ គាត់មានភាពពិការរូបកាយយ៉ាងខ្លាំង ព្រមទាំងខ្វះខាតនូវទ្រព្យសម្បត្តិ កំសត់ដើរសូមទាន នេះជាប្រវត្តិនៃជីវិតរបស់គាត់មុននឹងបានជួបព្រះធម៌ ។

ក្នុងគម្ពីរឧទាន បិដកលេខ ៥២ , ទំព័រ ២២៨ មានសម្តែងទាំងប្រវត្តិអតីតកាល និងបច្ចុប្បន្នកាល ព្រមទាំងព្រះពុទ្ធឧទានដែលគួរឱ្យសិក្សាពិចារណា មានទាំងស្រុងដូចតទៅ :

ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងវត្តវេឡុវ័នជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ។ សម័យនោះឯងមនុស្សឃ្លង់ម្នាក់ ជាមនុស្សកំសត់ មនុស្សកំព្រា មនុស្សថោកទាបឈ្មោះសុប្បពុទ្ធ នៅក្នុងក្រុងរាជគ្រឹះ ។ សម័យនោះឯងព្រះដ៏មានព្រះភាគមានបរិស័ទច្រើនគាល់ជុំវិញ កំពុងគង់សម្តែងធម៌ ។ សុប្បពុទ្ធកុដ្ឋិ បានឃើញអំពីចម្ងាយ នូវពួកមហាជនប្រជុំគ្នា លុះឃើញហើយ គាត់មានសេចក្តីត្រិះរិះថា គេនឹងចែក

ខាទនីយៈ ឬភោជនីយាហារណាមួយ ក្នុងទីនោះដោយឥតសង្ស័យ បើដូច្នោះអញនឹងចូលទៅរកពួកមហាជនដោយគិតថា ធ្វើម្ដេចទៅហ្ន៎ អញនឹងបានខាទនីយៈឬភោជនីយាហារណាមួយក្នុងទីនុ៎ះ។ លំដាប់នោះ សុប្បពុទ្ធកុដ្ឋិ ចូលសំដៅទៅរកពួកមហាជន សុប្បពុទ្ធកុដ្ឋិ បានឃើញព្រះមានព្រះភាគ ដែលបរិស័ទជាច្រើន គាល់ជុំវិញ កំពុងគង់សម្ដែងធម៌ លុះឃើញហើយ គាត់ក៏មានសេចក្ដីត្រិះរិះដូច្នេះថា ឱហ្ន៎ គេមិនចែកខាទនីយៈ ឬភោជនីយាហារណាមួយក្នុងទីនេះទេ ព្រះសមណគោតមនេះ ទ្រង់សម្ដែងធម៌ ក្នុងកណ្ដាលបរិស័ទ បើដូច្នោះ គួរតែអាត្មាអញស្ដាប់ធម៌ដែរ គាត់ក៏អង្គុយក្នុងទីសមគួរ ក្នុងទីនោះគិតថា អាត្មាអញនឹងស្ដាប់ធម៌ដែរ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ធ្វើទុកក្នុងព្រះទ័យកំណត់ចិត្តបរិស័ទទាំងអស់ ដោយព្រះហឫទ័យថា នរណាហ្ន៎ គួរត្រាស់ដឹងធម៌ក្នុងទីនេះបាន ។ ព្រះមានព្រះភាគ ទ្រង់ទតឃើញសុប្បពុទ្ធកុដ្ឋិ ដែលអង្គុយក្នុងបរិស័ទនោះ លុះទ្រង់ឃើញហើយ ព្រះមានព្រះភាគត្រិះរិះថា សុប្បពុទ្ធកុដ្ឋិនេះឯង គួរដើម្បីដឹងធម៌ក្នុងទីនេះ ទើបទ្រង់សម្ដែងអនុបុព្វីកថា ប្រារព្ធសុប្បពុទ្ធកុដ្ឋិ គឺទ្រង់ប្រកាសទានកថា សីលកថា សគ្គកថា ទោសដ៏លាមកសៅហ្មងនៃកាមគុណ និងអានិសង្សក្នុងការចេញបួស ។ ព្រះមានព្រះភាគបានជ្រាបថា





សុប្បពុទ្ធកុដ្ឋិ មានចិត្តស្រួល មានចិត្តទន់ មានចិត្តប្រាសចាកនីវរណៈ មានចិត្តខ្ពស់ឡើង មានចិត្តជ្រះថ្លា ក្នុងកាលណាហើយ ទ្រង់ប្រកាសធម៌ទេសនា ដែលព្រះពុទ្ធទាំងឡាយ ទ្រង់លើកឡើងសម្ដែងព្រះអង្គឯង គឺសម្ដែងទុក្ខសមុទយ និរោធ និងមគ្គ ក្នុងកាលនោះ ។ ធម្មចក្ខុប្រាសចាកធូលី ប្រាសចាកមន្ទិលកើតឡើងដល់សុប្បពុទ្ធកុដ្ឋិក្នុងទីអង្គុយនោះថា ធម្មជាតិណាមួយ ដែលកើតឡើងជាធម្មតា ធម្មជាតិទាំងអស់នោះ តែងរលត់ទៅវិញជាធម្មតា ដូច្នេះ ដូចសំពត់សស្អាតប្រាសចាកពណ៌ខ្មៅ គួរទទួលគ្រឿងជ្រលក់បានដោយប្រពៃ យ៉ាងដូច្នោះឯង ។

គ្រានោះ សុប្បពុទ្ធកុដ្ឋិ ឃើញធម៌ហើយ បានធម៌ហើយ ដឹងធម៌ហើយ ចុះកាន់ធម៌ស៊ប់ហើយ ឆ្លងសេចក្ដីសង្ស័យ ប្រាសចាកសេចក្ដីងឿងឆ្ងល់ ដល់នូវភាពក្លៀវក្លា មិនជឿបុគ្គលដទៃ ក្នុងសាសនា នៃព្រះសាស្ដា ហើយក្រោកចាកទីអង្គុយ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះសុប្បពុទ្ធកុដ្ឋិអង្គុយក្នុងទីដ៏សមគួរហើយ សរសើរព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ច្បាស់ណាស់ បពិត្រព្រះអង្គដ៏ចម្រើន ច្បាស់ណាស់ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទេសនាដែលព្រះមានព្រះភាគសម្ដែង

ហើយ ដោយអនេកបរិយាយ ដូចបុរសផ្ងាររបស់ដែលផ្កាប់ ឬបើករបស់ដែលបិទបាំង ពុំនោះដូចគេប្រាប់ផ្លូវដល់អ្នកវង្វេង ពុំនោះដូចគេទ្រោលប្រទីបប្រេងក្នុងទីងងឹត ដោយគិតថា ពួកអ្នកមានភ្នែកឃើញរូបទាំងឡាយ ដូច្នោះឯង បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គន៎ះ សូមដល់ព្រះមានព្រះភាគផង ព្រះធម៌ផង ព្រះសង្ឃផង ជាទីពឹង សូមព្រះមានព្រះភាគ ចាំទុកខ្ញុំព្រះអង្គថាជាឧបាសក ដល់សរណៈស្មើដោយជីវិត តាំងពីថ្ងៃនេះរៀងទៅ ។ គ្រានោះ សុប្បពុទ្ធកុដ្ឋិ ដែលព្រះដ៏មានព្រះភាគ ទ្រង់ពន្យល់ឱ្យកាន់យក ឱ្យអាចហ៊ាន ឱ្យរីករាយដោយធម្មីកថាហើយ ក៏ត្រេកអររីករាយនឹងភាសិតរបស់ព្រះមានព្រះភាគ ទើបក្រោកចាកទីអង្គុយ ថ្វាយបង្គំលាព្រះមានព្រះភាគ ធ្វើប្រទក្សិណ ចៀសចេញទៅ ។ គ្រានោះ មេគោមានកូនខ្ចីមកបុះសុប្បពុទ្ធកុដ្ឋិ ដែលទើបនឹងចេញទៅមិនយូរប៉ុន្មាន ឱ្យដាច់ចាកជីវិត ។ គ្រានោះ ភិក្ខុច្រើនរូប ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមាន-ព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះភិក្ខុទាំងនោះអង្គុយក្នុងទីដ៏សមគួរហើយ ទូលសួរព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន សុប្បពុទ្ធកុដ្ឋិ ដែលព្រះមានព្រះភាគ ទ្រង់ពន្យល់ឱ្យកាន់យក ឱ្យអង់អាច ឱ្យរីករាយដោយធម្មីកថា(ឥឡូវនេះ) សុប្បពុទ្ធកុដ្ឋិ



នោះស្លាប់ហើយ គតិរបស់គាត់ តើដូចម្តេច បរលោករបស់គាត់ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សុប្បពុទ្ធកុដ្ឋិ ជាបណ្ឌិត បានដឹងធម៌សមគួរតាមធម៌ហើយ មិនបៀតបៀនតថាគត ព្រោះហេតុនៃការសម្តែងធម៌ទៀតទេ ម្នាលភិក្ខុទាំងឡាយ សុប្បពុទ្ធកុដ្ឋិ ជាសោតាបន្នបុគ្គល មានសណ្តាប់ធ្នាប់មិនធ្លាក់ចុះ មានគតិទៀងទាត់ មានសម្ពោធិធម៌ប្រព្រឹត្តទៅខាងមុខ ព្រោះអស់ទៅនៃសញ្ញោជនធម៌ ៣ ប្រការ ។

កាលដែលព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះ ភិក្ខុ ១ រូប ទូលសួរព្រះមានព្រះភាគទៀតថា បពិត្រព្រះអង្គដ៏ចម្រើន អ្វីជាហេតុ អ្វីជាបច្ច័យ ដែលនាំឱ្យសុប្បពុទ្ធកុដ្ឋិ ជាមនុស្សកំសត់ ជាមនុស្សកំព្រា ជាមនុស្សថោកទាប ។ ម្នាលភិក្ខុទាំងឡាយ កាលពីព្រេងនាយ សុប្បពុទ្ធកុដ្ឋិ កើតជាសេដ្ឋីបុត្រ ក្នុងក្រុងរាជគ្រឹះនេះឯង សេដ្ឋីបុត្រនោះចេញទៅកាន់ឧទ្យានភូមិ បានឃើញព្រះតគរ-សិខីបច្ចេកពុទ្ធ ដែលកំពុងត្រាច់ទៅបិណ្ឌបាតក្នុងក្រុង លុះឃើញហើយ ទើបសេដ្ឋីបុត្រនោះគិតថា សមណៈគម្លង់នេះ ដើរធ្វើអ្វី ហើយស្តោះទឹកមាត់ ធ្វើដោយអាការពេបជ្រាយ ហើយចៀសចេញទៅ ។ ដោយផលនៃកម្មនោះ សេដ្ឋីបុត្រនោះ ក៏ទៅឆេះនៅក្នុងនរក អស់ឆ្នាំជាច្រើន គឺអស់រយនៃឆ្នាំជាច្រើន អស់ពាន់នៃឆ្នាំ

និងសែននៃឆ្នាំជាច្រើន ដោយសំណល់នៃផលកម្មនោះ ទើបគាត់កើតមកជាមនុស្សកំសត់ មនុស្សកំព្រា មនុស្សថោកទាប ក្នុងក្រុងរាជគ្រឹះនេះឯង សុប្បពុទ្ធកុដ្ឋិនោះ បានអាស្រ័យធម្មវិន័យដែលព្រះតថាគតសម្តែងហើយ កាន់យកសទ្ធាដោយប្រពៃ កាន់យកសីលដោយប្រពៃ កាន់យកសុតៈដោយប្រពៃ កាន់យកចាគៈដោយប្រពៃ កាន់យកបញ្ញាដោយប្រពៃ សុប្បពុទ្ធកុដ្ឋិនោះ លុះអាស្រ័យធម្មវិន័យ ដែលតថាគតសម្តែងហើយ ក៏កាន់យកសទ្ធាដោយប្រពៃ កាន់យកសីលដោយប្រពៃ កាន់យកសុតៈដោយប្រពៃ កាន់យកចាគៈដោយប្រពៃ កាន់យកបញ្ញាដោយប្រពៃ លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតឯសុគតិសួគ៌ទេវលោក ជាមួយនឹងពួកទេវតាជាន់តាវត្តិង្ស ទេវបុត្រនោះ ក៏រុងរឿងកន្លងលើសពួកទេវតាឯទៀត ក្នុងទីនោះ ដោយពណ៌សម្បុរផង ដោយយសបរិវារផង ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ជ្រាបសេចក្តីនុ៎ះហើយ ទើបទ្រង់បន្លឺឧទាននេះ ក្នុងវេលានោះថា

បណ្ឌិតគប្បីវៀរស្រឡះកម្មដ៏លាមក ក្នុងជីវលោកចេញ ដូចបុរសមានចក្ខុ វៀរស្រឡះទីមិនស្មើ ក្នុងកាលដែលដើរទៅ ។

ក្នុងអដ្ឋកថាធម្មបទ ពាលវគ្គ មានរឿងជជែកគ្នារវាងសុប្បពុទ្ធកុដ្ឋិ និងសក្កទេវរាជ ដោយសក្កទេវរាជយាងមកសាក



ពិសោធ ។

**សក្ក-** សុប្បពុទ្ធ អ្នកជាមនុស្សក្រ កំសត់តោកយ៉ាក យើងនឹងឱ្យទ្រព្យយ៉ាងច្រើនដល់អ្នក ចូរអ្នកពោលថា « ព្រះពុទ្ធមិនមែនព្រះពុទ្ធ ព្រះធម៌មិនមែនព្រះធម៌ ព្រះសង្ឃមិនមែនព្រះសង្ឃ » ។

**សុប្ប-** លោកជាអ្នកណា ?

**សក្ក-** យើងជាសក្កទេវរាជ ។

**សុប្ប-** អ្នកជាជនអន្ធពាល មិនចេះអៀនខ្មាស អ្នកមិនសមគួរមកនិយាយជាមួយនឹងយើងឡើយ ។ អ្នកនិយាយស្អី ថាយើងក្រ កំសត់តោកយ៉ាកឬ យើងមិនមែនជាមនុស្សក្រ កំសត់តោកយ៉ាកទេ យើងជាអ្នកដល់នូវសេចក្តីសុខ មានទ្រព្យច្រើន ។ ទ្រព្យទាំងនេះគឺ សទ្ធា ១ ,សីល ១ ,ហិរិ ១ ,ឱត្តប្បៈ ១ ,សុតៈ ១ , ចាគៈ ១ និងបញ្ញា ១ ។ ទ្រព្យទាំង ៧ យ៉ាងនេះ មានដល់បុគ្គលណា ប្រុសក៏ដោយ ស្រីក៏ដោយ បណ្ឌិតទាំងឡាយហៅបុគ្គលនោះថា ជាមនុស្សមិនក្រខ្សត់ ជីវិតពិតជាមិនទទេឡើយ ។

សក្កទេវរាជ បានស្តាប់ពាក្យរបស់សុប្បពុទ្ធកុដ្ឋិនោះហើយទ្រង់ក៏បានគេចចេញទៅកាន់សំណាក់ព្រះបរមសាស្តា រួចហើយបានក្រាបទូលនូវពាក្យទាំងអស់ចំពោះព្រះសាស្តា ។ ព្រះដ៏មាន-ព្រះភាគទ្រង់ត្រាស់ថា សក្កទេវរាជ ទាំងរយ ទាំងពាន់អង្គក៏ដោយ

គឺមិនអាចធ្វើឱ្យសុប្បពុទ្ធកុដ្ឋិពោលថា « ព្រះពុទ្ធមិនមែនព្រះពុទ្ធ ព្រះធម៌មិនមែនព្រះធម៌ ព្រះសង្ឃមិនមែនព្រះសង្ឃ » បានឡើយ។

ព្រះបរមសាស្តា ទ្រង់ប្រារព្ធបុព្វកម្មដែលសុប្បពុទ្ធកុដ្ឋិ បានសាងទុកមក ដែលនាំឱ្យមេគោកូនខ្ចីជល់ស្លាប់ ក្រទ្រព្យសម្បត្តិដើរសូមទាន ព្រមទាំងកើតឃ្លង់ ដោយការសម្តែងនូវព្រះគាថា :

**ចរន្តិ ពាលា ទុម្មេធា អមិត្តេនេវ អត្តនា**
**ករោន្តា បាបកំ កម្មំ យំ ហោតិ កដុកប្ផលំ ។**

ជនពាលទាំងឡាយអាប់ប្រាជ្ញា មានខ្លួនដូចជាសត្រូវ (នឹងខ្លួនឯង) ដើរសាងនូវបាបកម្ម ដែលមានផលក្តៅក្រហាយ ។

### ៤-សុមនមាលាការ

សុមនមាលាការ តែងតែទំនុកបម្រុងព្រះបាទពិម្ពិសារ ដោយផ្កាម្លិះ ៨ នាឡិ រាល់ៗព្រឹក ហើយបានប្រាក់ ៨ កហាបណៈ រាល់ៗថ្ងៃផងដែរ ។

ថ្ងៃមួយសុមនមាលាការ បានជួបនឹងព្រះសម្មាសម្ពុទ្ធតាមផ្លូវ បានគិតថា យើងបានអ្វីបូជាព្រះអង្គហ្ន៎ ។ កាលបើមិនមានវត្ថុអ្វីក្រៅអំពីផ្កាម្លិះ ក៏គិតបូជាដោយផ្កាម្លិះចំពោះព្រះដ៏មានព្រះភាគ។ បានគិតទៀតថា ផ្កានេះសម្រាប់ថ្វាយដល់ព្រះរាជា គឺតែងតែទំនុក-





បម្រុងរាល់ថ្ងៃ កាលណាបើមិនមានផ្កាថ្វាយទេនោះ យើងនឹងត្រូវទទួលទោស ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ត្រូវសម្លាប់ ឬត្រូវនិរទេសក៏ព្រមដែរ ព្រោះថាការបូជាដល់ព្រះសាស្តា ប្រព្រឹត្តទៅដើម្បីប្រយោជន៍សុខដ៏ក្រៃលែង ។ សុមនមាលាការគិតដល់ថ្នាក់ព្រមលះបង់ជីវិត ចំពោះព្រះតថាគត មានចិត្តមិនប្រែប្រួលពីសេចក្តីជ្រះថ្លា ថែមទាំងមានបីតិសោមនស្ស រីករាយខ្លាំងក្លា ជាមហាកុសលចិត្តទី ១ បានកើតឡើង ហើយក៏បានបូជាផ្កាថ្វាយព្រះបរមសាស្តាក្នុងពេលនោះឯង ។

សេចក្តីអស្ចារ្យបានកើតឡើង ដោយផ្កាដែលសុមនមាលាការបានថ្វាយទៅនោះ បានអណ្តែតតាមព្រះដ៏មានព្រះភាគ ដែលកំពុងតែយាងចូលក្រុងដើម្បីបិណ្ឌបាតនោះឯង ។ ផ្កាបាំងដូចជារាំងនន ពីឆ្វេងផង ពីស្តាំផង ពីក្រោមផង និងពីលើផង ។ មហាជនច្រើន អូអរក្រៃលែងស្រែកសាធុការក្នុងពេលនោះ ។ ព្រះរាជាមិនត្រឹមតែមិនយកទោសប៉ុណ្ណោះ ថែមទាំងប្រទានរង្វាន់យ៉ាងច្រើនដល់នាយសុមនមាលាការជាការបូជាគុណទៀតផង ។

ព្រះបរមសាស្តា ព្រះអង្គទ្រង់ត្រាស់ចំពោះព្រះអានន្ទត្ថេរក្នុងកាលនោះថា « ម្នាលអានន្ទ អ្នកកុំគប្បីកំណត់ថា កម្មមានប្រមាណតិចតួច ដែលសុមនមាលាការនេះបានធ្វើហើយនោះ

ព្រះសុមនមាលាការបានលះបង់នូវជីវិត ធ្វើការបូជាចំពោះតថាគត គេញាំងចិត្តឱ្យជ្រះថ្លា ក្នុងការបូជាបែបនេះ នឹងមិនទៅកាន់ទុគ្គតិរហូតអស់មួយសែនកប្ប » ។ ពេលនោះព្រះអង្គបានត្រាស់ព្យាករដូច្នេះថា :

**នាយសុមនមាលាការ នឹងតាំងនៅក្នុងកំណើតទេវតានិងមនុស្សទាំងឡាយ រមែងមិនទៅកាន់ទុគ្គតិអស់សែនកប្បនេះជាផលនៃកម្មនោះ ក្រោយមកគេនឹងបានត្រាស់ជាព្រះ-បច្ចេកពុទ្ធ មានព្រះនាមថា សុមនៈ ។**

ក្នុងពេលដែលព្រះបរមសាស្តា ស្តេចយាងទៅដល់វេឡុវន័មហាវិហារ ហើយទ្រង់យាងចូលទៅកាន់ព្រះគន្ធកុដិ ផ្កាម្លិះទាំងនោះបានធ្លាក់ចុះនៅត្រង់ខ្លោងទ្វារនាព្រះគន្ធកុដិនោះឯង ។

ក្នុងវេលាល្ងាចថ្ងៃនោះ ភិក្ខុទាំងឡាយ បានសន្ទនាគ្នា និងពោលសរសើរគុណរបស់សុមនមាលាការ ។ ព្រះបរមសាស្តាទ្រង់យាងចេញអំពីព្រះគន្ធកុដិមក ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយនោះថា « ម្នាលភិក្ខុទាំងឡាយ បុគ្គលធ្វើនូវកម្មណាហើយ មិនក្តៅក្រហាយតាមក្រោយ មានតែសោមនស្សរីករាយប៉ុណ្ណោះ នៅពេលដែលឃើញនូវអំពើដែលខ្លួនបានធ្វើនោះ កម្មនោះឯងដែលបុគ្គលគួរធ្វើ » ។



ព្រះអង្គទ្រង់បន្តនូវអនុសន្ធិសម្តែងធម៌ ទើបត្រាស់នូវព្រះគាថា :

**តញ្ច កម្មំ កតំ សាធុ យំ កត្វា នានុតប្បតិ**
**យស្ស បតីតោ សុមនោ វិបាកំ បដិសេវតិ ។**

បុគ្គលធ្វើកម្មណាហើយ រមែងមិនក្តៅក្រហាយតាមក្រោយ (ឬថា ) មានចិត្តសប្បាយរីករាយ បីតិបាមោជ្ជ ក្នុងការសោយនូវវិបាកនៃកម្មណា កម្មដែលធ្វើហើយនោះឯង គឺជាកម្មល្អ ។

## ៩-អភយរាជកុមារ

អភយរាជកុមារ ជាព្រះរាជបុត្ររបស់ព្រះបាទពិម្ពិសារជាមួយនាងបទុមវតី ស្រីស្អាតប្រចាំនគរឧជ្ជេនី ។

អភយរាជកុមារ បានចិញ្ចឹមពេទ្យជីវក និងបានទំនុកបម្រុងពេទ្យជីវក រហូតទាល់តែពេទ្យជីវក បានសម្រេចនូវប្រយោជន៍ដ៏ឧត្តម ។

អភយរាជកុមារមុននឹងមករាប់អានព្រះពុទ្ធសាសនា បានរាប់អាននិគន្ថនាដបុត្រ ។ ក្នុងបិដកលេខ ២៣ , ទំព័រ ១៤៩ មានព្រះសូត្រមួយឈ្មោះថា « អភយរាជកុមារសូត្រ » ព្រោះបានស្តាប់នូវព្រះធម៌ទេសនាក្នុងព្រះសូត្រនេះ អភយរាជកុមារបាន

ប្រកាសខ្លួនជាឧបាសកចំពោះព្រះដ៏មានព្រះភាគ ។

អភយរាជកុមារ ចូលចិត្តសិក្សាព្រះធម៌ តាមរយៈនៃការសាកសួរ ។ ក្នុងបិដកលេខ ៣៧ , ទំព័រ ៣១៦ **អភយសូត្រ** ក្នុងកាលនោះ ព្រះអង្គគង់នៅលើភ្នំគិជ្ឈកូដ ដែលអភយរាជកុមារចូលទៅក្រាបទូលសួរក្នុងបញ្ហាហេតុ-បច្ច័យផ្សេងៗ ។

នៅក្នុងអដ្ឋកថាធម្មបទ លោកវគ្គ បានសម្តែងរឿងសោក-សៅ របស់អភយរាជកុមារ ព្រោះការព្រាត់ប្រាសនូវស្រីស្នេហ៍ ដោយនាងដ៏ជាទីស្រឡាញ់នោះបានបាត់បង់ជីវិតទៅ ។ ទ្រង់គិតថា « អ្នកដទៃក្រៅអំពីព្រះសាស្តាហើយ ពិតជាមិនអាចធ្វើឱ្យសេចក្តីសោករបស់អាត្មាអញរលត់បានឡើយ » ។

ទ្រង់គិតដូច្នេះហើយ ទើបចូលទៅគាល់ព្រះបរមសាស្តា ដែលព្រះអង្គគង់ប្រថាប់នៅក្នុងវត្តវេឡុវន័ ហើយក្រាបទូលថា «បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គទ្រង់ឱ្យសេចក្តីសោករបស់ខ្ញុំព្រះអង្គរលត់ផងចុះ » ។

ព្រះបរមសាស្តា ទ្រង់សម្តែងអំពីសេចក្តីទុក្ខសោកក្នុងវដ្ត-សង្សារ មហាធំធេង ធ្វើឱ្យសេចក្តីទុក្ខសោកធូរស្រាលហើយ ទើបព្រះអង្គទ្រង់ត្រាស់នូវព្រះគាថា :



**ឯថ បស្សថិមំ លោកំ ចិត្តំ រាជរថូបមំ**
**យត្ថ ពាលា វិសីទន្តិ នត្ថិ សង្គោ វិជានតំ ។**

អ្នកទាំងឡាយ ចូរមកមើលនូវលោកនេះ ដែលវិចិត្រដ៏ត្រកាលដូចជារាជរថ ដែលជាទីលិចចុះនៃជនពាលទាំងឡាយ ឯពួកអ្នកចេះដឹង មិនជាប់ជំពាក់នៅឡើយ ។

ព្រះបរមសាស្តា ត្រាស់ហៅអភយរាជកុមារ ឱ្យមកមើលនូវលោក គឺអត្តភាពខន្ធបញ្ចកៈ។ នៅពេលចប់ព្រះគាថា ព្រះរាជ-កុមារក៏បានសម្រេចនូវសោតាបត្តិផល ។

អដ្ឋកថា អភយថេរគាថា បានសម្តែងថា អភយរាជកុមារបួសក្នុងសាសនានៃព្រះពុទ្ធបទុមុត្តរៈ ជាព្រះធម្មកថិក មុននឹងសម្តែងព្រះធម៌ លោកតែងពោលសរសើរគុណរបស់ព្រះដ៏មាន-ព្រះភាគ ៤ គាថាជានិច្ច រួចហើយទើបសម្តែងព្រះធម៌តាមក្រោយ ។ ដោយកម្លាំងនៃបុញ្ញកម្មនេះ លោកមិនដែលបដិសន្ធិក្នុងអបាយភូមិរហូតមក ១ សែនកប្ប ។

កាលព្រះបាទពិម្ពិសារសោយព្រះទិវង្គតហើយ អភយរាជ-កុមារ មានសេចក្តីសង្វេគចំពោះកិលេសរបស់សត្វលោក សង្វេគចំពោះទុក្ខទោសនៃវដ្តសង្សារ ទ្រង់ក៏បានចូលកាន់ផ្នួស ប្រារព្ធវិបស្សនា ហើយក៏បានសម្រេចនូវព្រះអរហត្ត ។

ក្នុងបិដកលេខ ៥៦ , ទំព័រ ១៤៣ លោកបានសម្តែងនូវព្រះគាថា :

**សុត្វា សុភាសិតំ វាចំ ពុទ្ធស្សាទិច្ចពន្ធុនោ**
**បច្ចព្យាធឹ ហិ និបុណំ វាលគ្គំ ឧសុនា យថាតិ ។**

ខ្ញុំបានស្តាប់ព្រះវាចា ជាសុភាសិត របស់ព្រះពុទ្ធជាផៅពង្ស នៃព្រះអាទិត្យហើយ ទើបបានត្រាស់ដឹងនូវអរិយសច្ចធម៌ដ៏ល្អិតដូច បុគ្គលបាញ់ចុងរោមកន្ទុយនៃសត្វទ្រាយ ដោយព្រួញ ដូច្នោះឯង។

## ១០ -ចិត្តគហបតី

ចិត្តគហបតី ជាឧបាសកកំពូលលើឧបាសកទាំងឡាយ ផ្នែកខាងការសម្តែងធម៌ ។ គាត់កើតក្នុងត្រកូលសេដ្ឋី ស្រុកមច្ឆិកា-សណ្ឌៈ ក្នុងដែនដីនគរមគធៈ ។

ដើមហេតុដែលចូលមកកាន់ព្រះសាសនា ព្រោះសេចក្តីជ្រះថ្លានឹងឥរិយាបថរបស់ព្រះមហានាមត្ថេរ (ព្រះថេរមួយអង្គក្នុងចំណោមបញ្ចវគ្គិយភិក្ខុ ) ។ បន្ទាប់អំពីឆាន់ចង្ហាន់បិណ្ឌបាតហើយ ព្រះថេរៈបានសម្តែងព្រះធម៌អំពីអាយតនៈ ធ្វើឱ្យចិត្តគហបតី ស្តាប់ហើយបានសម្រេចសោតាបត្តិផល ។

ចិត្តគហបតី បានវេរចម្ការម្នាក់របស់គាត់ ឱ្យជាសង្ឃារាម





ដែលមានឈ្មោះថា **អម្ពាដការាម** ។

ពេលមួយព្រះធម្មសេនាបតីសារីបុត្ត ព្រមដោយភិក្ខុសង្ឃបាននិមន្តទៅអាស្រ័យនៅ អម្ពាដការាម ។ ចិត្តគហបតីបានស្តាប់នូវធម្មកថារបស់ព្រះសារីបុត្ត គាត់បានសម្រេចដល់អនាគាមិផល ទាំងដែលមិនទាន់បានគាល់ព្រះដ៏មានព្រះភាគម្តងផង ។

ក្នុងបិដកលេខ ៣៦ , ទំព័រ ១៧៤ ដល់ទំព័រ ២២៦ បានសម្តែងអំពីគុណានុភាពរបស់ចិត្តគហបតី ជាសំយុត្តមួយឈ្មោះថា « ចិត្តគហបតិបុច្ឆាសំយុត្ត » អានហើយមានចិត្តជ្រះថ្លា ។

ក្នុងធម្មបទដ្ឋកថា ពាលវគ្គ មានសម្តែងអំពីចៅអាវាស អម្ពាដការាម ព្រះនាម **សុធម្មត្ថេរ** ។ ព្រះថេរៈខឹងក្រោធនឹងចិត្តគហបតី ច្រណែននឹងព្រះអគ្គសាវ័កទាំង ២ ដោយអាស្រ័យមានះថា ខ្លួនជាចៅអាវាស ។ ខឹងក្រោធរហូតដល់ថ្នាក់ជេរចិត្តគហបតីទៀតផង ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ឱ្យព្រះ-សុធម្មត្ថេរ ដែលនិមន្តមកវត្តជេតពន ព្រោះការខឹងក្រោធនោះ ត្រឡប់ទៅសូមខមាទោសចិត្តគហបតី នៅឯមច្ឆិកាសណ្ឌៈវិញ ព្រមដោយព្រះឱវាទថា « ធម្មតាសមណៈមិនគួរធ្វើមានះ ឬឥស្សាថា វិហាររបស់អញ អាវាសរបស់អញ ឧបាសក ឧបាសិការបស់អញដូច្នេះឡើយ ព្រោះបើសមណៈធ្វើដូច្នោះ ពួកកិលេសមាន

ឥស្សា និងមានះជាដើម រមែងចម្រើន » ។ ព្រះអង្គទ្រង់បន្តអនុសន្ធិត្រាស់នូវព្រះគាថា :

**អសន្តំ ភាវមិច្ឆេយ្យ   បុរេក្ខារញ្ច ភិក្ខុសុ**
**អាវាសេសុ ច ឥស្សរិយំ   បូជា បរកុលេសុ ច ។**
**មមេវ កត មញ្ញន្តុ   គិហិប្បព្វជិតា ឧភោ**
**មមេវ អតិវសា អស្សុ   កិច្ចាកិច្ចេសុ កិស្មិចិ**
**ឥតិ ពាលស្ស សង្កប្បោ   ឥស្សា មានោ ច វឌ្ឍតិ ។**

ភិក្ខុពាល រមែងប្រាថ្នានូវសេចក្តីសរសើរ ដែលមិនមាន (ក្នុងខ្លួន) ផង នូវភាពមានអ្នកហែហម គឺជាប្រមុខក្នុងពួកភិក្ខុផង នូវភាពជាឥស្សរៈក្នុងអាវាសទាំងឡាយផង នូវការបូជាទាំងឡាយក្នុងត្រកូលនៃជនទាំងឡាយដទៃផង ។

ភិក្ខុពាលតែងមានសេចក្តីត្រិះរិះថា គ្រហស្ថ និងបព្វជិតទាំងពីរពួក ចូរសម្គាល់នូវកិច្ចដែលមនុស្សដទៃធ្វើហើយ ថាជាកិច្ចរបស់អញវិញ អំណាចដ៏ក្រៃលែងរបស់អញ ចូរមានក្នុងកិច្ចតូចធំកិច្ចណាមួយក៏ដោយ (កាលបើយ៉ាងនេះ) ឥស្សា និងមានះ រមែងចម្រើន (ដល់ភិក្ខុពាលនោះឯង) ។

ក្នុងពេលដែលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សម្តែងនូវព្រះធម៌ទេសនានេះចប់ហើយ ជនដ៏ច្រើនបានសម្រេចនូវអរិយ-





ផលទាំងឡាយមានសោតាបត្តិផលជាដើម ។ ឯព្រះសុធម្មត្ថេរបានស្តាប់ព្រះពុទ្ធោវាទនេះហើយ បានក្រាបថ្វាយបង្គំព្រះបរមសាស្តា និងក្រោកចាកអាសនៈ ធ្វើប្រទក្សិណហើយ បាននិមន្តទៅជាមួយនឹងព្រះភិក្ខុជាអនុទូត (ភិក្ខុដែលសង្ឃបានសន្មតឱ្យជាតំណាងក្នុងការរួមដំណើរទៅជាមួយ) ក្នុងចម្ងាយផ្លូវ ៣០ យោជន៍ ។ ព្រះសុធម្មត្ថេរ បានសម្តែងនូវទោសតាមទោសដែលខ្លួនមាន ហើយឱ្យចិត្តគហបតីអត់នូវទោសនោះឱ្យ ។ ចិត្តគហបតីបានអត់នូវទោសឱ្យដល់ព្រះសុធម្មត្ថេរថា «ខ្ញុំព្រះករុណាអត់ទោសឱ្យដល់ព្រះគុណម្ចាស់ បពិត្រព្រះគុណម្ចាស់ បើទោសរបស់ខ្ញុំព្រះករុណាមាន សូមព្រះគុណម្ចាស់អត់នូវទោសនោះឱ្យដល់ខ្ញុំព្រះករុណាផងចុះ » ។

គ្រាកាលព្រះសុធម្មត្ថេរ បានទទួលការអត់ទោសអំពីចិត្តគហបតីហើយ ក៏បាននិមន្តទៅគង់នៅក្នុងអម្ពាដការាម ។ លោកបានប្រព្រឹត្តល្អ ឈប់រឹងត្អឹង ត្រឡប់ខ្លួនមកបានយ៉ាងត្រឹមត្រូវ ហើយលោកបានតាំងនៅក្នុងព្រះបរមពុទ្ធោវាទ ដែលព្រះអង្គទ្រង់បានប្រទានហើយ ដោយ ២-៣ ថ្ងៃប៉ុណ្ណោះ លោកក៏បានសម្រេចនូវព្រះអរហត្ត ព្រមដោយបដិសម្ភិទា ។

ចិត្តគហបតី ជាអ្នកមានបុណ្យបានធ្វើមកច្រើន នៅពេលបានឱកាសទៅគាល់ព្រះដ៏មានព្រះភាគ មានភិក្ខុ ភិក្ខុនី ឧបាសក

ឧបាសិកា ព្រមទាំងបរិវាររបស់គាត់យ៉ាងគគ្រឹកគគ្រេង រួមដំណើរទៅជាមួយ ក្នុងដំណើរផ្លូវរយៈពេល ១ ខែ ។ រទេះ ៥០០ ពេញទៅដោយទេយ្យវត្ថុមានអង្ករ ទឹកដោះ និងម្ហូបអាហារជាដើម ដែលបានដឹកនាំយកទៅ។ ទេវតាបានបូជាតាមផ្លូវដោយការទំនុកបម្រុងបាយទឹកជាដើម រហូតដល់វត្តជេតពន ។ មនុស្សទាំងឡាយបានមកជួបជុំគ្នាណែនណាន់តាន់តាប់ ដើម្បីមើលចិត្តគហបតីដែលជាអ្នកមានបុណ្យច្រើន ។ បាដិហារិយ៍ដ៏អស្ចារ្យបានកើតឡើងនៅពេលចិត្តគហបតីថ្វាយបង្គំព្រះបាទានៃព្រះដ៏មានព្រះភាគ គឺភ្លៀងផ្កាឈើបានធ្លាក់ចុះមកក្នុងពេលនោះឯង។ សំឡេងសាធុការបានលាន់ឡើងកងរំពងថា « សាធុ ! សាធុ ! »។ ចិត្តគហបតីបានថ្វាយទាន ១ ខែដល់សង្ឃមានព្រះពុទ្ធជាប្រធាន ពុំមានអស់របស់ពីរទេះគាត់ឡើយ ដោយសារមនុស្ស និងទេវតារួមក្នុងការបូជា ។ ចិត្តគហបតីបានថ្វាយទេយ្យធម៌ទាំងអស់ទុកដាក់ក្នុងកប្បិយភូមិ ដែលព្រះដ៏មានព្រះភាគទ្រង់អនុញ្ញាតហើយ ក្រាបថ្វាយបង្គំលាព្រះបរមសាស្តាត្រឡប់មកមច្ឆិកាសណ្ឌៈវិញ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់នូវព្រះគាថាធម្មបទ ក្នុងបកិណ្ណកវគ្គថា:

**សទ្ធោ សីលេន សម្បន្នោ យសោភោគសមប្បិតោ**
**យំ យំ បទេសំ ភជតិ តត្ថ តត្ថេវ បូជិតោ ។**



អ្នកមានសទ្ធា សម្បូណ៌ដោយសីល ព្រមព្រៀងដោយយស និងភោគៈ នឹងទៅក្នុងប្រទេសណា១ រមែងជាអ្នកដែលគេបូជាហើយ ក្នុងប្រទេសនោះ១ដូច្នោះឯង ។

## ១១-បាវារិកសេដ្ឋី

នៅក្នុងអដ្ឋកថា **ឧបាលិវាទសូត្រ** បានសម្តែងអំពី បាវារិកសេដ្ឋី បានស្តាប់ព្រះធម៌របស់ព្រះដ៏មានព្រះភាគហើយជ្រះថ្លា បានសាងវិហារ មានសេនាសនៈដ៏ច្រើនខ្នង មានកុដិ មានទីពួនសម្ងំ និងមណ្ឌបជាដើម ក្នុងចម្ការស្វាយរបស់គាត់ នៅស្រុកនាលន្ទា ហើយថ្វាយដល់ព្រះដ៏មានព្រះភាគ ។ វិហារនោះមានឈ្មោះថា **បាវារិកម្ពវ័ន** ដូចវិហារដែលមានឈ្មោះថា **ជីវកម្ពវ័ន** ដែរ ។

ក្នុងបិដកលេខ ២៣,ទំព័រ ៩២ ដល់ទំព័រ ១៣៤ **ឧបាលិវាទសូត្រ** បានសម្តែងថា សម័យមួយព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងបាវារិកម្ពវ័ននោះឯង ។ នៅក្នុងព្រះសូត្រនេះ មានរឿងរ៉ាវ និងសាច់ធម៌ដែលគួរអាន មិនគួរខានឡើយ ព្រោះនាំមកនូវសេចក្តីជ្រះថ្លាចំពោះព្រះគុណនៃព្រះដ៏មានព្រះភាគ និងសង្វេគចំពោះសត្វលោកដែលមាននូវមិច្ឆាទិដ្ឋិ ។

ម្យ៉ាងទៀតអានព្រះសូត្រនេះហើយ ធ្វើឱ្យយើងបានស្តាប់

ឧបាសកម្នាក់ទៀតដ៏អស្ចារ្យឈ្មោះ **ឧបាលិ** ។ ឧបាលិគហបតី កាលដើមជាសាវ័ករបស់និគន្ថនាដបុត្រ ក្រោយមកបានទៅលើកវាទៈ (សួរដេញដោលក្នុងបំណងផ្ចាញ់ផ្ចាល)ចំពោះព្រះដ៏មានព្រះភាគ។ ទីបំផុត បានស្តាប់យល់ហេតុផល ក៏ឃើញសច្ចធម៌ ជាព្រះអរិយ-បុគ្គល ។ ព្រឹត្តិការណ៍មួយនេះឯង ដែលធ្វើឱ្យនិគន្ថនាដបុត្រឈឺចិត្ត ក្អួតឈាម ហើយបានឈឺគ្រាំគ្រារហូតស្លាប់នៅនគរបាវ៉ា ។

បាវ៉ារិកម្ពវ័ន តាមការស្រាវជ្រាវបានឱ្យដឹងថា ក្រោយមកជា **មហាវិទ្យាល័យនាលន្ទា** ដោយនៅជាសង្ឃារាមដដែល ដែលព្រះសង្ឃអាចរៀនបាន ១០.០០០ (ដប់ពាន់ ) អង្គ ។ សព្វថ្ងៃជាកន្លែងបុរាណមួយ ដែលគេរក្សាទុកជាកន្លែងអនុស្សាវរីយ៍ មានទេសចរណ៍កុះករចូលទៅទស្សនា និងមានស្តូបព្រះសារីបុត្ត ចាប់ផ្តើមកសាងដោយព្រះបាទធម្មាសោក ។

សម័យពុទ្ធកាល បាវ៉ារិការាម (អារាមរបស់បាវ៉ារិកសេដ្ឋី ) មាន ២ មួយនៅនាលន្ទា ក្នុងនគរមគធៈ មួយទៀតនៅនគរកោសម្ពី គឺជាវត្ត ២ ដោយឡែកពីគ្នា ។





**១២ -វិសាខឧបាសក**

វិសាខឧបាសក បានសម្រេចនូវសោតាបត្តិផល ជាមួយគ្នានឹងព្រះបាទពិម្ពិសារ ។ ក្រោយមកបានស្តាប់បន្ត១ក៏បានសម្រេចដល់ថ្នាក់អនាគាមិផល ។

ពេលដែលបានសម្រេចនូវព្រះអនាគាមិផលហើយ មកកាន់ផ្ទះវិញមិនបានដូចថ្ងៃមុនៗឡើយ គឺពេលនេះជាអ្នកមានឥន្ទ្រិយស្ងប់ ព្រោះចិត្តស្ងប់ដើរចូលមក ។

នាងធម្មទិន្នាជាភរិយា ឃើញប្លែកហើយក៏គិតថា « យ៉ាងម៉េចហ្នឹងហ្ន៎ »។ វិសាខឧបាសកមិនហុចដៃឱ្យភរិយាដែលធ្លាប់តែទទួលប្តីដោយការចាប់ដៃ មិនបរិភោគរួម និងចាត់ចែងរៀបចំគ្រែទទួលទានដំណេកមួយតែឯងទៀតផង ។

នាងធម្មទិន្នាតានតឹងក្នុងចិត្តដ៏យ៉ាងក្រៃលែង លំបាកទ្រាំណាស់ក្នុងពេល ១ ថ្ងៃ , ២ ថ្ងៃ ទើបសម្រេចចិត្តសួរឱ្យដឹងរឿង ។ នាង បានចូលទៅកន្លែងទទួលទានដំណេកថ្មីរបស់វិសាខឧបាសក សំពះឧបាសកហើយឈរក្នុងទីដ៏សមគួរ ។ ឧបាសកសួរថា «ធម្ម-ទិន្នា ដូចម្តេចទើបមកខុសពេល ? » ។

**ធម្ម-** ចា៎ះ នាងខ្ញុំមក ព្រោះលោកមិនដូចមុន សូមសួរបន្តិច លោកមានសេចក្តីប្រាថ្នាស្រីដទៃឬ ?

**វិសាខ-** មិនមានឡើយ ធម្មទិន្នា ។

**ធម្ម-** មាននរណាញុះញង់ឬ ?

**វិសាខ-** អត់ទេ ។

**ធម្ម-** បើអីចឹង ខ្លួននាងខ្ញុំនេះមានកំហុសអ្វីឬ ?

**វិសាខ-** ធម្មទិន្នា នាងមិនមានខុសអ្វីឡើយ ។

**ធម្ម-** ចុះហេតុអ្វីទើបលោកធ្វើអីចឹង សូម្បីគ្រាន់តែនិយាយប្រាស្រ័យជាមួយនាងខ្ញុំតាមធម្មតា ក៏គ្មានដែរនោះ ?

ឧបាសកគិតថា « ឈ្មោះថាលោកុត្តរធម៌នេះជាភារៈធ្ងន់ មិនគប្បីបើកបញ្ចេញឡើយ តែបើយើងមិនប្រាប់ ធម្មទិន្នានេះ នឹងបែកទ្រូងស្លាប់ក្នុងទីនេះឯង » ដើម្បីអនុគ្រោះនាងទើបប្រាប់ថា « ធម្មទិន្នា ខ្ញុំស្តាប់ព្រះធម៌ទេសនារបស់ព្រះសាស្តាហើយ បានសម្រេចនូវលោកុត្តរធម៌ ។ អ្នកដែលបានសម្រេចនូវលោកុត្តរធម៌នោះហើយ រមែងមិនធ្វើអ្វីតាមបែបដែលលោកនោះត្រេកត្រអាលឡើយ។ ទ្រព្យខ្ញុំ ៤០ កោដិ ទ្រព្យនាង ៤០ កោដិ នាងចូរគ្រប់គ្រងទាំងអស់ចុះ ហើយនាងឋិតនៅក្នុងតំណែងជាម៉ែ ឬជាប្អូនស្រីរបស់ខ្ញុំក៏បាន ខ្ញុំគ្រាន់តែសូមដុំបាយសម្រាប់ចិញ្ចឹមជីវិតតែប៉ុណ្ណោះ ប៉ុន្តែបើនាងត្រូវការស្វាមីដទៃថ្មីទៀតក៏បាន » ។

ធម្មទិន្នាគិតថា « មនុស្សប្រុសធម្មតា មិនមានអ្នកណា





និយាយយ៉ាងនេះឡើយ គាត់ប្រាកដជាបានសម្រេចនូវលោកុត្តរធម៌មែនហើយ » ។

**ធម្ម-**លោកុត្តរធម៌នោះសម្រាប់តែបុរសប៉ុណ្ណោះទេឬដែលគប្បីបាន ឬសូម្បីស្ត្រីក៏អាចសម្រេចបានដែរ ?

**វិសាខ-** ធម្មទិន្នាអើយ នាងសួរអ្វីយ៉ាងហ្នឹង បុគ្គលដែលជាអ្នកបដិបត្តិនោះ រមែងជាទាយាទនៃធម៌នោះឯង ព្រោះបុគ្គលអ្នកដែលមានឧបនិស្ស័យ គឺរមែងបានទទួលនូវលោកុត្តរធម៌នោះដោយពិត ។

**ធម្ម-** បើដូច្នោះ នាងខ្ញុំសូមអនុញ្ញាតចូលកាន់ផ្នួស សូមលោកព្រមផងចុះ ។

**វិសាខ-** សាធុ ! សាធុ ! ខ្ញុំក៏ចង់ណែនាំនាងក្នុងផ្លូវនេះដែរ ប៉ុន្តែ ខ្ញុំមិនដឹងអធ្យាស្រ័យរបស់នាង ទើបបានជាមិននិយាយ ។ វិសាខឧបាសក បានទៅគាល់ព្រះបាទពិម្ពិសារ ក្នុងពេលនោះភ្លាម ថ្វាយបង្គំហើយ ឈរក្នុងទីដ៏សមគួរ ។ ព្រះរាជាត្រាស់សួរថា «គហបតី មានការអ្វីបានជាមកខុសពេល ? » ។

**វិសាខ-** បពិត្រព្រះសម្មតិទេព នាងធម្មទិន្នានិយាយថា «នាងខ្ញុំ សូមអនុញ្ញាតចូលកាន់ផ្នួស » ។

**ព្រះរាជា-** តើនាងសមគួរនឹងបានអ្វី ?

**វិសាខ-** មិនមានអ្វីដទៃ បានតែអង្រឹងមាស និងសូមទ្រង់ព្រះរាជបញ្ញា ឱ្យគេរៀបចំតាក់តែងព្រះនគរប៉ុណ្ណឹង ក៏សមរម្យហើយ ។

ព្រះរាជាប្រទានអង្រឹងមាស ហើយបង្គាប់ឱ្យគេរៀបចំតាក់តែងនូវព្រះនគរ ។ សូមជ្រាបថា វិសាខឧបាសក និងព្រះរាជាមានការស្រឡាញ់រាប់អានគ្នាយ៉ាងជិតស្និទ្ធ ព្រោះធ្លាប់ធ្វើបុណ្យជាមួយគ្នាពីជាតិមុនមក ។

វិសាខឧបាសក បានឱ្យនាងធម្មទិន្នាងូតទឹកក្រអូប ប្រដាប់កាយដោយគ្រឿងប្រដាប់គ្រប់យ៉ាង និងឱ្យអង្គុយលើអង្រឹងមាស ហែហមដោយពពួកញាតិ ព្រមទាំងបូជាដោយផ្កាក្រអូបទាំងឡាយ ហើយទៅកាន់សំណាក់ភិក្ខុនី ។ កាលដែលព្រះនាងធម្មទិន្នាបួសហើយ វិសាខឧបាសកបានពោលថា « ព្រះនាងម្ចាស់ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ព្រះធម៌ទុកល្អហើយ ចូរព្រះនាងត្រេកអរចុះ » ថ្វាយបង្គំហើយ ក៏បាននាំគ្នាត្រឡប់មកផ្ទះវិញ ។ ព្រះនាងបដិបត្តិធម៌ក្នុងទីស្ងប់ស្ងាត់ មិនយូរឡើយ ព្រោះសម្បូណ៌ដោយឧបនិស្ស័យ ២-៣ ថ្ងៃក៏បានសម្រេចនូវព្រះអរហត្ត ។



# មហាសេដ្ឋីក្រុងរាជគ្រឹះ

## ១-ជោតិកសេដ្ឋី

មានប្រាសាទ ៧ ជាន់ប្រកបដោយកែវ ៧ ប្រការ ប្រាសាទនោះមានកំពែង ៧ ជាន់ មានដើមកប្បព្រឹក្សដុះតាមកំពែងដោយជុំវិញ និងមានកំណប់ទ្រព្យធំៗព្រមទាំងភរិយាឈ្មោះ នាង **សតុលកាយា** ដែលទេវតានាំមកពីឧត្តរកុរុទ្វីប ជាភរិយា ។

ជោតិកសេដ្ឋីបានសម្បត្តិទាំងនេះ ព្រោះផលានិសង្សកសាងព្រះគន្ធកុដិថ្វាយព្រះសម្មាសម្ពុទ្ធ **វិបស្សី** ។ ពេលមួយបានកើតសេចក្ដីសង្វេគជាខ្លាំងចំពោះលោភៈដែលជាហេតុនៃទុក្ខ ព្រោះឮព្រះបាទអជាតសត្តុ ដែលលើកទ័ពមកដណ្ដើមយកប្រាសាទរបស់ខ្លួន ហើយបានលះបង់សម្បត្តិគ្រប់យ៉ាង សូមផ្នួសនឹងព្រះដ៏មាន-ព្រះភាគ មិនយូរប៉ុន្មានក៏បានសម្រេចនូវព្រះអរហត្តផល ជាព្រះ-អសេក្ខបុគ្គលក្នុងលោកមួយព្រះអង្គ ។

## ២-ផដិលសេដ្ឋី

មានភ្នំមាសប្រមាណ ៨០ ហត្ថ ជ្រែកផែនដីផុសឡើង នៅក្រោយផ្ទះ ។ នេះជាផលនៃការបូជាផ្កាមាសចំពោះព្រះ-ចេតិយបញ្ចុះព្រះធាតុនៃព្រះសម្មាសម្ពុទ្ធកស្សបទសពល ។ ក្រោយមកក៏បានចូលកាន់ផ្នួស បួសហើយ ២-៣ ថ្ងៃប៉ុណ្ណោះ ក៏បានសម្រេចជាព្រះអរហន្ត ។

ព្រះដ៏មានព្រះភាគសម្ដែងព្រះគាថាធម្មបទ :

**យោធ តណ្ហំ បហន្ត្វាន អនាគារោ បរិព្វជេ**
**តណ្ហាភវបរិក្ខីណំ តមហំ ព្រូមិ ព្រាហ្មណំ ។**

បុគ្គលណា លះតណ្ហាក្នុងលោកនេះបានហើយ ជាអ្នកមិនមានផ្ទះ មានការលះបង់បាន តថាគតហៅបុគ្គលនោះ ដែលមានតណ្ហា និងភពអស់ហើយ ថាជាព្រាហ្មណ៍ ។



## ៣-មេណ្ឌកសេដ្ឋី

មានពពែមាសទាំងឡាយប៉ុនដំរីក៏មាន ប៉ុនសេះក៏មាន ប៉ុនគោឧសភក៏មាន ផុសឡើងក្រោយផ្ទះ ក្នុងផ្ទៃដីប្រមាណ ៨ ករីស ដោយជុំវិញ (១ ករីស=១២៥ ហត្ថ)។ ក្នុងពពែមាសទាំងនោះមានដុំអំបោះជាផ្ទុកមាត់ ឯក្នុងខ្លួនពេញដោយវត្ថុតាមដែលត្រូវការ ។ ព្រោះមានសម្បត្តិដូច្នេះទើបមានឈ្មោះថា **សេដ្ឋីពពែ** ។

ទាំងនេះ ជាផលនៃការដែលបានកសាងពពែមាសទ្រជើងគ្រែធម្មាសនៈ ៤ ពពែមាស ២ ទៀតទ្រជើងតាំងសម្រាប់ដាក់ និងពពែមាស ៦ ដទៃទៀត នៅព័ទ្ធជុំវិញមណ្ឌលជាដើមនៅក្នុងសាសនាព្រះពុទ្ធវិបស្សី ។

មេណ្ឌកសេដ្ឋី ជាព្រះសោតាបន្ន មានការទំនុកបម្រុងព្រះសាសនាដោយបច្ច័យ ៤ ។ រឿងរ៉ាវរបស់គាត់មានក្នុងអដ្ឋកថាធម្មបទ មលវគ្គ និងក្នុងភេសជ្ជក្ខន្ធកៈជាដើម ។

## ៤-បុណ្ណសេដ្ឋី

ស៊ីឈ្នួលភ្ជួរស្រែឱ្យសុមនសេដ្ឋី បានសុទ្ធតែដុំមាស ។ រាជបុរសជញ្ជូនយកមកដាក់គរ មានកម្ពស់ ៨០ ហត្ថ ដែលក្នុងព្រះនគរជាអ្នកមានដុំមាសច្រើនជាងគេ ។ ព្រះរាជាបានតែងតាំងជាសេដ្ឋីមានឈ្មោះថ្មីថា **ពហុធនសេដ្ឋី** ។

នេះជាផលនៃបុណ្យបច្ចុប្បន្ន ដោយបានថ្វាយចង្ហាន់ដល់ព្រះសារីបុត្ត ដែលទើបតែចេញពីនិរោធសមាបត្តិ ។

បានជាសេដ្ឋីហើយ ក៏បានថ្វាយចង្ហាន់បិណ្ឌបាតដល់សង្ឃមានព្រះពុទ្ធជាប្រធាន ៧ ថ្ងៃ បានស្តាប់ព្រះធម៌របស់ព្រះដ៏មានព្រះភាគ ក៏បានសម្រេចសោតាបត្តិផល ជាមួយនឹងភរិយាព្រមទាំងធីតាឈ្មោះនាងឧត្តរា ។



## ៥-កាកវល្លិយសេដ្ឋី

បានកំណប់ទ្រព្យ ៧ រណ្តៅធំៗ នេះជាផលបុណ្យដែលបានថ្វាយបបរយាគូដល់ព្រះមហាកស្សបត្ថេរ ដែលទើបតែចេញពីនិរោធសមាបត្តិ ។

នៅក្នុងអដ្ឋកថាឯតទគ្គៈនៃនាងវិសាខាមិគារមាតា បានសម្តែងថា នៅក្នុងរាជាណាចក្ររបស់ព្រះបាទពិម្ពិសារ បុគ្គលដែលមានទ្រព្យសម្បត្តិរាប់មិនអស់នោះ មានចំនួន ៥ នាក់ គឺ ជោតិកៈ១,ជដិលៈ ១ ,មេណ្ឌកៈ ១ ,បុណ្ណៈ ១ និងកាកវល្លិយៈ ១។

*-សេចក្តីអស្ចារ្យនៃកំណើតមនុស្ស គឺមនុស្សអាចអភិវឌ្ឍផ្លូវចិត្តរបស់ខ្លួនបាន ដូច្នេះចូរកុំប្រមាទ ចូរតាមរក្សាចិត្តរបស់ខ្លួន ។

*-មនុស្សអាចឱ្យទានបានដោយសទ្ធា គ្រាន់តែប៉ុណ្ណេះក៏ជារឿងអស្ចារ្យណាស់ទៅហើយ ព្រោះនេះជាលក្ខណៈនៃចិត្តល្អ ។

*-ចិត្តល្អ មិនមែនសង្ឃឹមផលតបស្នងទេ ចិត្តល្អគឺជាចិត្តដែលបានអប់រំ ចិត្តដែលមានសេចក្តីសុខដោយខ្លួន ឯង។

*-ការទូន្មានចិត្តរបស់ខ្លួនបាន រមែងបាននូវទីពឹងដែលគេបានដោយក្រ ។

## ផ្នែកឧបាសិកា

### ១-នាងសារីព្រាហ្មណី

នាងសារីព្រាហ្មណី ជាព្រះអរិយបុគ្គលបានសម្រេចសោតាបត្តិផល ។ នាងជាស្រីមានបុណ្យបារមីពិសេស ព្រោះត្រូវបានជាញោមម៉ែរបស់ព្រះអរហន្ត ៤ អង្គ និងព្រះអរហន្តី ៣ អង្គ ។ ក្នុង ៧ អង្គនោះមានព្រះធម្មសេនាបតីជាបងបង្អស់ មានព្រះរេវតៈជាប្អូនពៅ ។ នាងសារីមានស្វាមីឈ្មោះវង្គន្តៈ កើតក្នុងត្រកូលព្រាហ្មណ៍ស្រុកនាលន្ទា ជាប់ក្រុងរាជគ្រឹះ ក្នុងនគរមគធៈ ។ ត្រកូលរបស់នាងមានទ្រព្យ ៥៦០ កោដិកហាបណៈ ។

នៅក្នុងអដ្ឋកថាធម្មបទ ព្រាហ្មណវគ្គ បានសម្ដែងអំពីនាងសារីព្រាហ្មណីកាលដែលនៅជាបុគ្គលមិច្ឆាទិដ្ឋិនៅឡើយ បានខឹងក្រោធនឹងព្រះសារីបុត្ត ។

ក្នុងកាលនោះ ព្រះធម្មសេនាបតី និមន្តបិណ្ឌបាតជាមួយនឹងភិក្ខុ ៥០០ អង្គ បានទៅដល់ទ្វារផ្ទះនៃញោមមាតា ។ ញោមមាតាបាននិមន្តឱ្យព្រះសង្ឃគង់ហើយ ប្រគេនចង្ហាន់ ព្រមទាំងជេរ





កូនថា « អ្នកឯងមិនបាននូវសំណល់អាហារ មិនបាននូវសំណល់នៃទឹកបាយ ដូច្នេះសមគួរនឹងលិទ្ធនូវទឹកបាយដែលជាប់នឹងខ្នងវែកក្នុងផ្ទះនៃអ្នកដទៃ ។ អ្នកឯងលះបង់ទ្រព្យ ៨០ កោដិទៅបួស ធ្វើឱ្យយើងក្ដៅក្រហាយ ឥឡូវនេះចូរបរិភោគចុះ » ។ រួចហើយនាងបានថ្វាយភត្តដល់ភិក្ខុសង្ឃទាំងឡាយ ព្រមដោយការពោលថា « បុត្ររបស់យើង ត្រូវអ្នកទាំងឡាយ ធ្វើឱ្យទៅជាអ្នកបម្រើនៃពួកអ្នកទាំងអស់គ្នាហើយ ឥឡូវនេះ ពួកលោកចូរបរិភោគចុះ » ។ ព្រះថេរៈទទួលចង្ហាន់ហើយ បាននិមន្តមកកាន់វត្តវិញ ។

គ្រានោះ ព្រះរាហុលបានចូលគាល់ព្រះដ៏មានព្រះភាគដោយការអើពើក្នុងរឿងបិណ្ឌបាត ។

**ព្រះពុទ្ធ-** រាហុល ពួកអ្នកនិមន្តទៅណា ?

**រាហុល-** បពិត្រព្រះអង្គ ពួកខ្ញុំព្រះអង្គទៅកាន់ផ្ទះលោកយាយ ។

**ព្រះពុទ្ធ-** ចុះព្រះឧបជ្ឈាយ៍របស់អ្នក ត្រូវលោកយាយស្ដីឱ្យយ៉ាងដូចម្ដេចដែរ ?

**រាហុល-** បពិត្រព្រះអង្គ ព្រះឧបជ្ឈាយ៍របស់ខ្ញុំព្រះអង្គ ត្រូវលោកយាយជេរស្ដី ។

**ព្រះពុទ្ធ-** ព្រះឧបជ្ឈាយ៍របស់អ្នក ត្រូវលោកយាយជេរស្ដី

ថាម៉េច ?

**រាហុល -** បពិត្រព្រះអង្គ ត្រូវលោកយាយជេរដោយពាក្យដូចនេះ ... ។

**ព្រះពុទ្ធ-**ចំណែកព្រះឧបជ្ឈាយ៍របស់អ្នក ថាយ៉ាងម៉េចដែរ?

**រាហុល-** បពិត្រព្រះអង្គ អត់មានថាអ្វីទាំងអស់ ។

ភិក្ខុទាំងឡាយ ស្តាប់ពាក្យនេះហើយ បានសន្ទនាគ្នាថា «អ្នកដ៏មានអាយុទាំងឡាយ គុណទាំងឡាយរបស់ព្រះសារីបុត្តគួរអស្ចារ្យណាស់ហ្ន៎ កាលមាតារបស់លោកជេរយ៉ាងនេះហើយ សូម្បីគ្រាន់តែសេចក្តីក្រោធក៏មិនមានឡើយ » ។

ព្រះបរមសាស្តា ទ្រង់យាងចេញមកហើយ ត្រាស់សួរថា « ម្នាលភិក្ខុទាំងឡាយ ពួកអ្នកអង្គុយសន្ទនាគ្នាដោយកថាអ្វី ? » កាលភិក្ខុទាំងនោះ ក្រាបទូលដល់ព្រះអង្គហើយ ទ្រង់ត្រាស់ថា « ម្នាលភិក្ខុទាំងឡាយ ធម្មតាព្រះខីណាស្រពទាំងឡាយ ជាបុគ្គលមិនមានសេចក្តីក្រោធឡើយ » ដូច្នេះហើយ ទើបទ្រង់ត្រាស់នូវព្រះគាថា :

**អក្កោធនំ វតវន្តំ សីលវន្តំ អនុស្សទំ**
**ទន្តំ អន្តិមសារីរំ តមហំ ព្រូមិ ព្រាហ្មណំ។**

តថាគតហៅបុគ្គលដែលមិនក្រោធ មានវត្តប្រតិបត្តិ មាន



សីល មិនមានតណ្ហាជាគ្រឿងធ្វើឱ្យស្រើបស្រាល ជាអ្នកហ្វឹកហាត់មានសរីរៈក្នុងទីបំផុតនោះថាជាព្រាហ្មណ៍ ។

នៅពេលចប់ទេសនា ជនដ៏ច្រើនបានសម្រេចនូវអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

នាងសារីព្រាហ្មណី បានសម្រេចនូវសោតាបត្តិផល ដោយអាស្រ័យព្រះសារីបុត្ត ប្រកាសសម្តែងនូវព្រះគុណ នៃព្រះសម្មាសម្ពុទ្ធ ។ រាត្រីដែលមាតាបានឃើញព្រះសម្មាសម្ពុទ្ធដោយញាណចក្ខុនោះឯង គឺជារាត្រីនៃការបរិនិព្វានរបស់ព្រះសារីបុត្ត ។ នាងមានការសោកស្តាយ ថែមទាំងមានការយំរៀបរាប់ដូច្នេះថា «កូនអើយ កាលមុនម៉ែមិនដឹងអំពីសេចក្តីល្អរបស់កូន ឥឡូវនេះ ម៉ែមិនមានឱកាសដើម្បីនឹងនិមន្តព្រះភិក្ខុទាំងឡាយ ច្រើនរយពាន់អង្គដែលមានកូនជាដើម មកគង់ឆាន់អាហារនៅនឹងផ្ទះនេះឡើយ ម៉ែមិនមានឱកាស បានប្រគេនស្បង់ចីវរឡើយ ... » ។

រឿងរ៉ាវដោយសង្ខេបប៉ុណ្ណេះ ក៏អាចរំលឹកដាស់តឿនឱ្យយើងប្រញាប់ធ្វើល្អដល់គ្នានឹងគ្នា កុំឱ្យក្តៅក្រហាយស្តាយក្រោយឡើយ ។

## ២-នាងសេសវតីឧបាសិកា

នាងសេសវតីឧបាសិកា បានសន្សំបុណ្យជាឧបនិស្ស័យមក ដោយកាលនោះ មានការកសាងនូវព្រះសុវណ្ណចេតិយ បញ្ចុះព្រះធាតុនៃព្រះសម្មាសម្ពុទ្ធកស្សបៈ នាងបានទៅទីនោះជាមួយនឹងមាតា ហើយបានដោះខ្សែកមាស ចូលក្នុងការកសាងនូវព្រះសុវណ្ណចេតិយនោះឯង ។

មនុស្សយើងអាចធ្វើបុណ្យបាន បុណ្យគឺជាសេចក្តីល្អរបស់ចិត្ត ចិត្តល្អគឺចិត្តមានសេចក្តីចម្រើន និងមានសេចក្តីសុខដោយខ្លួនឯង ។ នាងសេសវតីសន្សំសេចក្តីល្អទុកជាឧបនិស្ស័យ ម្យ៉ាងទៀតអាស្រ័យសេចក្តីល្អនោះ ពេលដែលនាងស្លាប់ទៅ នាងបានទៅកាន់ទេវលោកមួយចន្លោះព្រះពុទ្ធ ។ ក្នុងពុទ្ធកាលនេះ នាងទើបបានមកកើតនៅស្រុកនាលន្ទា ដែនមគធៈ ។ លុះដល់នាងពេញវ័យហើយ មានការឧបត្ថម្ភពីបុណ្យ នាងបានជាកូនប្រសានៃអ្នកមានទ្រព្យច្រើនក្នុងស្រុកនាលន្ទាហ្នឹងឯង ។

បុគ្គលគួរពិចារណាអំពីការពាក់ខ្សែកឱ្យរូបកាយ និងការបំពាក់បុណ្យឱ្យចិត្ត ។ នាងសេសវតីមានឧបនិស្ស័យបុណ្យដែលធ្លាប់បានធ្វើមក ចិត្តបុណ្យបានកើតឡើងជាថ្មីទៀត ។ ចំពេលព្រះសារីបុត្តបរិនិព្វាន នាងបានទៅចូលរួមក្នុងការបូជាព្រះសព ត្រូវ





គេជាន់ស្លាប់នៅពេលនោះ ហើយនាងបានបដិសន្ធិនៅឋានទេវលោកជាន់ទី ២ ដោយសេចក្តីជ្រះថ្លានឹងព្រះធម្មសេនាបតីសារីបុត្ត ជាបច្ច័យ ។ នាងមានវិមានទិព្វ ព្រមដោយនាងទេពអប្សរ ១000 ជាបរិវារ ចុះមកគាល់ព្រះបរមសាស្តា ... ។ មានក្នុងបិដកលេខ ៥៥ ព្រមទាំងអដ្ឋកថា **សេសវតីវិមាន** ។

## ៣-សុនន្ទាឧបាសិកា

កាលព្រះដ៏មានព្រះភាគទ្រង់បរិនិព្វានទៅហើយ ព្រះបាទអជាតសត្តុ ទ្រង់បានទទួលនូវព្រះបរមសារីរិកធាតុរបស់ព្រះដ៏មានព្រះភាគ ដង្ហែយកមកបញ្ចុះក្នុងព្រះចេតិយនៃក្រុងរាជគ្រឹះ ។

មានកូនស្រីអ្នកក្រងផ្កាម្នាក់នៅក្រុងរាជគ្រឹះ ឈ្មោះ **សុនន្ទា** ជាឧបាសិកាបានសម្រេចនូវសោតាបត្តិផលហើយ ។ នាងបានបូជាផ្កាថ្វាយព្រះចេតិយ ដោយសេចក្តីជ្រះថ្លាក្នុងព្រះគុណនៃព្រះសម្មាសម្ពុទ្ធរៀងរាល់ថ្ងៃ ។ ភាគច្រើនគឺជាផ្ការបស់បិតា ប៉ុន្តែក្នុងថ្ងៃឧបោសថសីល នាងបានសមាទានឧបោសថសីលហើយ ថ្វាយផ្កាដល់ព្រះចេតិយ ដែលផ្កានោះជារបស់នាងផ្ទាល់ ។

នាងសុនន្ទាឧបាសិកា នៅក្រុងរាជគ្រឹះដ៏ជាទីរីករាយ នាងដល់ព្រមដោយសទ្ធា និងសីល ត្រេកអរក្នុងការឱ្យទានគ្រប់ពេល។

នាងសុនន្ទា មានចិត្តជ្រះថ្លាក្នុងបុគ្គលដែលគួរជ្រះថ្លាពិតៗ នាងបានថ្វាយចីវរ ភត្តាហារ សេនាសនៈ និងប្រទីប ព្រមទាំងបានរក្សាឧបោសថប្រកបដោយអង្គ ៨ ប្រការ ទាំងប្រក្រតី ទាំងបាដិហារិយបក្ខ ។ នាងមានការសង្រួមក្នុងសីល ៥ ជានិច្ច គឺវៀរចាកការសម្លាប់សត្វ ១ , វៀរចាកការលួចប្លន់ ១ , វៀរចាកការប្រព្រឹត្តខុសក្នុងកាម ១ , វៀរចាកការកុហក ១ និងវៀរចាកការបរិភោគនូវទឹកស្រវឹង ១ ។ នាងជាអ្នកឆ្លាតក្នុងអរិយសច្ចធម៌ ជាឧបាសិការបស់ព្រះគោតមទ្រង់មានចក្ខុ មានយស នាងបូជាព្រះចេតិយដោយដៃរបស់ខ្លួនផ្ទាល់នូវផ្កា និងគ្រឿងក្រអូប ។

នាងសុនន្ទាឧបាសិកា មានជំងឺហើយស្លាប់ទៅកាន់ទេវលោកជាន់ទី ២ នាងជាទេពធីតាដែលមានរូបស្អាតដូចជាផ្កាទិព្វ មានពន្លឺរស្មីគ្របដណ្តប់លើទេវតាដទៃ និងជាទីពេញព្រះហឫទ័យនៃព្រះឥន្ទ្រាធិរាជ ... ។ ព្រះវង្គីសត្ថេរបាននាំដំណឹងរឿងនាងសុនន្ទាទេពធីតា មកដល់ស្រុកមនុស្ស ហើយរឿងនេះបានចូលកាន់សង្គាយនាលើកទី ២ ។ មានក្នុងបិដកលេខ ៥៥ វិមានវត្ថុ ព្រមទាំងអដ្ឋកថា បារិច្ឆត្តកវគ្គ **វិសាលក្ខិវិមាន** ។



## ៤ -នាងឧត្តរាឧបាសិកា

នាងឧត្តរាឧបាសិកា មានចិត្តប្រសើរដ៏ខ្ពង់ខ្ពស់ក្នុងការឱ្យអភ័យចំពោះអ្នកដែលប្រទូស្តនឹងខ្លួន នាងជាអរិយសាវិកា និងជាកំពូលលើឧបាសិកាទាំងឡាយ ផ្នែកខាងការចូលឈាន ។

នៅក្នុងអដ្ឋកថាធម្មបទ **កោធវគ្គ** បានសម្តែងប្រវត្តិរបស់នាង ដែលមានចំណុចល្អគួរឱ្យកត់សម្គាល់ :

-នាងជាធីតារបស់បុណ្ណសេដ្ឋីក្រុងរាជគ្រឹះ ជាស្ត្រីមានបុណ្យបានធ្វើទុកមកដ៏ច្រើន គិតតាំងពីក្នុងសាសនាព្រះសម្មាសម្ពុទ្ធបទុមុត្តរៈមក ។

-ស្តាប់ព្រះធម៌ដែលព្រះបរមសាស្តាទ្រង់ត្រាស់សម្តែង បានសម្រេចសោតាបត្តិផល ជាមួយមាតាបិតា នៅនឹងផ្ទះថ្មីរបស់ខ្លួន ដែលមាតាទើបតែឡើងជាសេដ្ឋី ។

-នាងបានស្វាមីមិច្ឆាទិដ្ឋិ ហើយនាងទៅនៅត្រកូលខាងប្តីក្នុងថ្ងៃ ១៥ កើតខែអាសាឍ ។ កន្លងទៅពីរខែកន្លះក្នុងវស្សានោះ នាងពុំបានថ្វាយទាន ពុំបានស្តាប់ធម៌ឡើយ ។ ដើម្បីដោះស្រាយបញ្ហាឱ្យកូនស្រី បុណ្ណសេដ្ឋី បានឱ្យប្រាក់មកជូលនាង **សិរិមា** ស្រីសោភិនីប្រចាំក្រុងរាជគ្រឹះ ក្នុងតម្លៃ ១៥០០០ កហាបណៈ សម្រាប់កន្លះខែប៉ុណ្ណោះ យកមកឱ្យបម្រើប្តីរបស់នាង ។ កាលដែលប្តីព្រម

ទទួលយកនាងសិរិមាហើយ ខ្លួនឯងដូចបានរួចពីទីឃុំឃាំង ឬពុំនោះសោត ដូចបានរួចពីទាសីគេ ហើយបាននិមន្តព្រះសង្ឃមានព្រះពុទ្ធជាព្រះប្រធាន ១៥ ថ្ងៃថ្វាយចង្ហាន់បិណ្ឌបាត ។

-នាងសិរិមា បានមកនៅក្នុងផ្ទះកន្លះខែ វង្វេងភ្លេចខ្លួន គិតថាខ្លួនឯងជាស្ត្រីក្នុងផ្ទះ ហើយបានប្រច័ណ្ឌជាមួយនឹងនាងឧត្តរា-ឧបាសិកា ។ នាងសិរិមាបានប្រទូស្តនឹងនាងឧត្តរា ដោយការយកវែកធំដងទឹកដោះដែលកំពុងដាំពុះ ទៅចាក់លើ ប៉ុន្តែនាងឧត្តរា-ឧបាសិកាបានផ្សាយមេត្តាចិត្តទៅរកនាងសិរិមាទាន់ពេល ។ នាងឧត្តរាបានគិតថា « ព្រោះអាស្រ័យនាង ទើបយើងបានថ្វាយទានសមាទានឧបោសថ និងបានស្តាប់ធម៌ ... »។ ដោយមេត្តានុភាពពិតៗ ទឹកដោះក្តៅនោះ ពុំបានរលាកនាងឡើយ ហាក់ដូចជាទឹកត្រជាក់ ។

-នាងសិរិមាភ្ញាក់ខ្លួន ហើយបានសូមខមាទោសនឹងនាងឧត្តរា ។ នាងឧត្តរាមានបំណងល្អ ចង់ឱ្យនាងសិរិមាបានគាល់ព្រះបរមសាស្តា ទើបឱ្យនាងទៅថ្វាយបង្គំព្រះអង្គ សូមព្រះអង្គទ្រង់អត់ទោសឱ្យ ដោយនាងឧត្តរាបញ្ជាក់ប្រាប់នាងសិរិមាថា « ខ្ញុំជាធីតាដែលមានបិតា បិតាវិវដ្តៈរបស់ខ្ញុំគឺព្រះសម្មាសម្ពុទ្ធ កាលបើព្រះបិតាអត់ទោសឱ្យ ក៏ជាការស្រេច » ។





-ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សរសើរនាងឧត្តរាឧបាសិកាថា « សាធុ ! សាធុ ! ឧត្តរា ការឈ្នះសេចក្តីក្រោធយ៉ាងនោះ ជាការសមគួរណាស់ »។ រួចហើយព្រះអង្គទ្រង់ត្រាស់នូវព្រះគាថា :

**អក្កោធេន ជិនេ កោធំ អសាធុំ សាធុនា ជិនេ**
**ជិនេ កទរិយំ ទានេន សច្ចេនាលិកវាទិនំ ។**

គប្បីឈ្នះមនុស្សក្រោធ ដោយការមិនក្រោធ គប្បីឈ្នះមនុស្សមិនល្អដោយសេចក្តីល្អ គប្បីឈ្នះមនុស្សកំណាញ់ដោយការឱ្យទាន គប្បីឈ្នះមនុស្សនិយាយឡេះឡោះដោយពាក្យពិត ។

នាងសិរិមាបានសម្រេចសោតាបត្តិផល ដោយព្រះធម៌ទេសនានេះឯង ។

-ក្នុងអដ្ឋកថាវិមានវត្ថុ បានសម្តែងថា នាងឧត្តរាឧបាសិកាបានស្តាប់នូវព្រះធម៌ព្រមដោយព្រះគាថា **អក្កោធេន ជិនេ កោធំ** ជាដើមហើយ ក៏បានសម្រេចនូវព្រះសកទាគាមិផល ។ រីឯប្តី និងមាតាបិតាក្មេករបស់នាង ក៏បានសម្រេចនូវព្រះសោតាបត្តិផលក្នុងគ្រានោះឯង ។ ជាលាភដ៏ធំធេងដែលបានប្តីត្រឡប់មកជាមនុស្សមានទូវសម្មាទិដ្ឋិ ក្នុងភាពជាព្រះអរិយបុគ្គលទៀតផងនោះ ។

*-តាមការស្រាវជ្រាវផ្ទៀងផ្ទាត់ នាងឧត្តរាឧបាសិកានេះ ក៏ជានន្ទមាតាដែរ ដូចក្នុងបាលីឯតទគ្គៈថា « **ឈាយិនីនំ យទិទំ**

**ឧត្តរា នន្ទមាតា** » ប៉ុន្តែមិនមែនជានន្ទមាតាឧបាសិកា ក្នុងអង្គុត្តរនិកាយ សត្តកនិបាត មាតាសូត្រ នោះឡើយ (បិដកលេខ ៤៧ , ទំព័រ ១១៦ ) ។ នន្ទមាតានៅក្រុងវេឡុកណ្តកៈ ជាព្រះ-អនាគាមិបុគ្គល រីឯនាងឧត្តរានន្ទមាតានៅក្រុងរាជគ្រឹះជាព្រះ-សកទាគាមិបុគ្គល ។

*-ក្នុងបិដកលេខ ៧៧ , ទំព័រ ៣៣ ព្រះពុទ្ធ **ទីបង្ករ** ទ្រង់បានព្យាករសុមេធបណ្ឌិត ថានឹងបានត្រាស់ជាព្រះសម្មាសម្ពុទ្ធព្រះនាម **គោតម** មាននាង **នន្ទមាតា** និងនាង **ឧត្តរា** ជាឧបដ្ឋាយិកាដ៏ប្រសើរ ។

## ៥-នាងសិរិមាឧបាសិកា

នាងសិរិមា ជាឧបាសិកាដែលមានរូបរាងស្អាត សូម្បីជីវិតខាងដើមរបស់នាង បានធ្លាក់ចូលក្នុងភាពជាស្រីសោភិនីប្រចាំនគរដែលគេបាននាំគ្នាស្គាល់ពេញក្រុងរាជគ្រឹះ ទោះជាមិនបានឃើញរូបក៏ឮឈ្មោះល្បីថាជាស្រីស្អាត ប៉ុន្តែជីវិតចុងក្រោយបានក្លាយជាអរិយសាវិកា ក្នុងព្រះពុទ្ធសាសនា ទើបគួរយកជាឧទាហរណ៍បានថា ជីវិតដែលដើរខុសផ្លូវ ត្រូវត្រឡប់មករកផ្លូវត្រូវវិញបាន ទាំងគួរឱ្យសរសើរទៀតផង ។



នាងសិរិមា ជាប្អូនស្រីរបស់ពេទ្យជីវកកោមារភច្ច ដែលមានម្តាយគឺ **នាងសាលវតី** ជាមួយគ្នា ។ ព្រោះអាស្រ័យនាងឧត្តរា-ឧបាសិកា នាងសិរិមាបានចូលគាល់ព្រះដ៏មានព្រះភាគព្រមដោយបរិវាររបស់ខ្លួន ហើយក៏បានសម្រេចសោតាបត្តិផល ព្រោះបានស្តាប់ព្រះធម៌របស់ព្រះដ៏មានព្រះភាគ ។ ក្រោយអំពីបានសម្រេចនូវលោកុត្តរធម៌ហើយ នាងសិរិមាបានលះបង់នូវការងារដែលសៅហ្មងរបស់នាងពីមុនចោល ហើយចាប់ផ្តើមជីវិតថ្មី ។

ក្នុងអដ្ឋកថាធម្មបទ ជរាវគ្គ បានសម្តែងថា នាងសិរិមានេះកាលដែលបានសម្រេចនូវសោតាបត្តិផលហើយ ក៏បានអារាធនាព្រះទសពលព្រមដោយភិក្ខុសង្ឃ ទទួលទានរបស់ខ្លួន ។ ហើយបន្តមកក្រោយទៀតបាននិមន្តព្រះសង្ឃ ៨ អង្គជាប្រចាំ ទៅកាន់ផ្ទះរបស់នាង ដើម្បីនាងបានថ្វាយភត្ត ។

នាងសិរិមាដែលកំពុងតែនៅពេញស្អាត សូម្បីតែភិក្ខុដែលទៅទទួលនិច្ចភត្តឯផ្ទះរបស់នាង ក៏ចាប់ចិត្តស្រឡាញ់នាងដែរនោះ នាងត្រូវមានជំងឺ ហើយធ្វើកាលកិរិយាចោលសរីរៈដែលពពួកជនតែងតែត្រិះរិះជានិច្ច ។

ព្រះដ៏មានព្រះភាគ បានត្រាស់ឱ្យព្រះបាទពិម្ពិសារចាត់ការប្រជុំមហាជន ទៅមើលសាកសពនាងសិរិមា នៅព្រៃស្មសាន

បន្ទាប់ពីនាងស្លាប់ទៅបាន ៤ ថ្ងៃ ។ ក្នុងទីប្រជុំមហាជនទាំងគ្រហស្ថ ទាំងបព្វជិត ព្រះអង្គទ្រង់ត្រាស់ថា « អ្នកទាំងឡាយចូរមើលនូវមាតុគ្រាមដែលជាទីស្រឡាញ់នៃមហាជន ក្នុងកាលមុនជនទាំងឡាយក្នុងនគរនេះ ចំណាយទ្រព្យ ១០០០ កហាបណៈ ទើបបានអភិរម្យជាមួយនាង ១ ថ្ងៃ ឥឡូវនេះសូម្បីឱ្យយកទៅទទេក៏មិនមានអ្នកណាយកឡើយ ។ រូបនេះដល់នូវការបែកធ្លាយហើយ អ្នកទាំងឡាយចូរមើលនូវអត្តភាពដែលជារបស់ក្តៅគួរឱ្យសង្វេគ » រួចហើយទ្រង់ត្រាស់នូវព្រះគាថា :

**បស្ស ចិត្តកតំ ពិម្ពំ អរុកាយំ សមុស្សិតំ**

**អាតុរំ ពហុសង្កប្បំ យស្ស នត្ថិ ធុវំ ឋិតិ ។**

អ្នកចូរមើលនូវអត្តភាព ដែលមិនយឺនយូរឋិតថេរ (អត្តភាពនេះ )កម្មបានធ្វើឱ្យវិចិត្រហើយ (ព្រមដោយការតាក់តែងផ្សេងៗ ) ជាកាយដែលមានដំបៅ (បពេញនូវគ្រឿងស្មោកគ្រោក ) សាងដោយឆ្អឹង ៣០០ កំណាត់ ជារបស់ក្តៅក្រហាយ (ដោយការស្រេកឃ្លាន ឈឺ និងជារបស់ដែលត្រូវរក្សាដោយឥរិយាបថ ដោយការងូតទឹកដុសលាង បរិភោគ ព្យាបាល ។ល។ ) ដែលមហាជនត្រិះរិះយ៉ាងខ្លាំង (ដល់រូបកាយនេះ ) ។

វេលាចប់ព្រះធម៌ទេសនាមហាជនរាប់ម៉ឺនបាននូវអមតធម៌





រួមទាំងភិក្ខុដែលស្រឡាញ់នាងសិរិមាពីមុននោះផងដែរ ។

ក្នុងអដ្ឋកថា **វិជយសូត្រ** សុត្តនិបាត បានសម្តែងថា សិរិ-មាទេពកញ្ញា មានបរិវារហែហមមកកាន់ទីសមាគមនោះ ដែលព្រះអង្គទ្រង់ប្រារព្ធនូវសរីរៈរបស់ខ្លួន ដែលទើបតែស្លាប់ទៅបាន ៤ ថ្ងៃ ទ្រង់សម្តែងនូវវិជយសូត្រ (បិដកលេខ ៥៤ ,ទំព័រ ៦៥ ) ។ ក្នុងកាលចប់ព្រះធម៌ទេសនាសត្វ ៨៤.០០០ បានសម្រេចលោកុត្តរធម៌ សិរិមាទេពកញ្ញាបានសម្រេចនូវអនាគាមិផល ចំណែកភិក្ខុនោះ (ភិក្ខុដែលស្រឡាញ់នាងមុនស្លាប់ ) បាននូវសោតាបត្តិផល ។

## ៦ -រាជគហសេដ្ឋីធីតា

នាងជាឧបាសិកាល្បីឈ្មោះម្នាក់ដែរ ព្រោះជីវិតរបស់នាងជាប់ទាក់ទងនឹងនាយកុក្កុដមិត្ត ។ ក្នុងអតីតជាតិធ្លាប់ជាប្តីប្រពន្ធនឹងគ្នា មានកូនប្រុស ៧ នាក់ កូនប្រសាស្រី ៧ នាក់ ក្នុងសាសនាព្រះពុទ្ធកស្សបៈ ទាំង ១៦ នាក់នោះបានលះបង់អ្វីៗគ្រប់យ៉ាង មកជាទាសាទាសីនៃព្រះសុវណ្ណចេតិយបញ្ចុះព្រះបរមសារីរិកធាតុ ។ ទាំងអស់គ្នាចុតិហើយបដិសន្ធិក្នុងទេវលោក ។ ក្នុងពុទ្ធកាលនេះ ឧបាសិកាបានកើតជាធីតានៃសេដ្ឋីក្រុងរាជគ្រឹះ នាងបានសម្រេច

សោតាបត្តិផលតាំងពីក្មេង លុះដល់ពេញវ័យក៏បានប្តី ហើយទៅនៅជាមួយកុក្កុដមិត្ត ។ កុក្កុដមិត្ត គឺជាប្តីរបស់នាងពីជាតិមុន ប៉ុន្តែកុក្កុដមិត្តបដិសន្ធិកើតក្នុងត្រកូលព្រាន លុះដល់ពេញវ័យហើយគេក៏ជាព្រានសម្លាប់សត្វយកសាច់លក់ ។ សេដ្ឋីធីតាបានទៅនៅជាមួយនឹងកុក្កុដមិត្ត បំពេញតួនាទីជាភរិយា រហូតដល់មានកូននិងកូនប្រសាតាមដែលធ្លាប់ជាកូនពីជាតិមុន បម្រើព្រះសុវណ្ណចេតិយទាំងអស់គ្នា ។

ដល់ពេលវេលា ព្រះដ៏មានព្រះភាគ ទ្រង់យាងទៅកាន់ទីដែលកុក្កុដមិត្តដាក់អន្ទាក់ចាប់សត្វតាំងតែពីព្រលឹម ។ ការប្រទូស-រ៉ាយនឹងព្រះដ៏មានព្រះភាគ បានកើតឡើងដល់កុក្កុដមិត្តព្រមទាំងកូនប្រុស១ ព្រោះហេតុតែពួកគេមិនទាន់បានស្គាល់ព្រះសម្មា-សម្ពុទ្ធ ។ សេដ្ឋីធីតាបានចូលទៅធ្វើអន្តរាគមន៍ដ៏យ៉ាងប្រឹងប្រែងនិងដ៏យ៉ាងឆ្លាតវៃ ទីបំផុតក៏បានជោគជ័យ ។ នាងបានញ៉ាំងប្តី និងកូនបង្កើត ៧ នាក់ ឱ្យថ្វាយបង្គំព្រះបរមសាស្តា ឱ្យសូមខមាទោសចំពោះព្រះអង្គ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែងព្រះធម៌ទេសនា ញ៉ាំងជនទាំង ១៥ នាក់ គឺកុក្កុដមិត្តម្នាក់ កូនបង្កើត និងកូនប្រសា ១៤ នាក់ ឱ្យបានសម្រេចនូវសោតាបត្តិផល ។ ស្រេចកិច្ចហើយ ព្រះអង្គទ្រង់យាងបិណ្ឌបាត ពេលបច្ឆាភត្តព្រះអង្គបាន





យាងមកកាន់វត្តវេឡុវ័នវិញ ។

**ព្រះអានន្ទ-** បពិត្រព្រះអង្គដ៏ចម្រើន ថ្ងៃនេះព្រះអង្គទ្រង់យាងទៅណា ព្រះអង្គ ?

**ព្រះសាស្តា-** តថាគត ទៅកាន់សំណាក់របស់កុក្កុដមិត្ត អានន្ទ ។

**ព្រះអានន្ទ-** បពិត្រព្រះអង្គដ៏ចម្រើន នាយព្រានកុក្កុដមិត្ត ព្រះអង្គធ្វើឱ្យជាអ្នកឈប់សម្លាប់សត្វហើយឬ ព្រះអង្គ ?

**ព្រះសាស្តា-** ម្នាលអានន្ទ នាយព្រានកុក្កុដមិត្តនោះមានខ្លួនជាគម្រប់ ១៥ នាក់ បានតាំងនៅក្នុងសទ្ធាមិនញាប់ញ័រ ជាបុគ្គលអស់ការសង្ស័យក្នុងរតនៈទាំង ៣ ជាអ្នកមិនធ្វើកម្ម គឺបាណាតិបាតទៀតហើយ ។

**ភិក្ខុទាំងឡាយ-** បពិត្រព្រះអង្គដ៏ចម្រើន ចុះចំណែកភរិយារបស់កុក្កុដមិត្ត ព្រះអង្គ ?

**ព្រះសាស្តា-** ម្នាលភិក្ខុទាំងឡាយ កាលដែលនាងនៅជាកុមារីក្នុងផ្ទះត្រកូលសេដ្ឋីនោះ នាងបានសម្រេចសោតាបត្តិផលហើយ។ ភិក្ខុទាំងឡាយមានការសង្ស័យថា «ព្រះសោតាបន្នបុគ្គលទាំងឡាយនៅធ្វើបាណាតិបាតឬហ្ន៎ ? » ព្រោះដូចជាភរិយារបស់កុក្កុដមិត្ត ប្តីនាងតែងតែប្រើឱ្យហុចធ្នូ ហុចព្រួញ និងឧបករណ៍

សម្រាប់សម្លាប់សត្វផ្សេងៗទៀត ហើយនាយព្រានបាននាំយកឧបករណ៍ទាំងនោះ ទៅសម្លាប់សត្វអស់កាលជានិច្ច ។

កាលដែលភិក្ខុទាំងឡាយ កំពុងសន្ទនាគ្នាក្នុងរឿងនេះ ព្រះបរមសាស្តាទ្រង់យាងមក ហើយទ្រង់ក៏បានត្រាស់សួរ ។ កាលភិក្ខុក្រាបទូលព្រះអង្គហើយ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំង-ឡាយ ព្រះសោតាបន្នបុគ្គល រមែងមិនធ្វើនូវបាណាតិបាតឡើយ ។ ឯនាងដែលជាភរិយារបស់កុក្កុដមិត្តបានធ្វើយ៉ាងនោះ ដោយគិតថា « យើងនឹងធ្វើតាមពាក្យស្វាមី » ចិត្តរបស់នាង មិនបានគិតថា សូមស្វាមីយកគ្រឿងប្រហារនេះទៅសម្លាប់សត្វចុះ ដូច្នេះឡើយ។ ពិតណាស់ កាលដៃមិនមានដំបៅទេ ថ្នាំពិសក៏មិនអាចនឹងឱ្យទោសដល់អ្នកកាន់ថ្នាំពិសនោះបានដែរ យ៉ាងណា បាបរមែងមិនមានដល់អ្នកដែលមិនធ្វើបាប សូម្បីនាំគ្រឿងប្រហារទាំងឡាយមានធ្នូជាដើមឱ្យអ្នកដទៃ ព្រោះមិនមានអកុសលចេតនា ដូច្នោះឯង ។ ព្រះអង្គទ្រង់បន្តអនុសន្ធិសម្តែងព្រះធម៌ ទើបទ្រង់ត្រាស់សម្តែងនូវព្រះគាថាធម្មបទ ក្នុងបាបវគ្គ ដូច្នេះថា :

**បាណម្ហិ ចេ វណោ នាស្ស ហរេយ្យ បាណិនា វិសំ**
**នាព្វណំ វិសមន្វេតិ នត្ថិ បាបំ អកុព្វតោ ។**



បើដំបៅមិនមានលើបាតដៃទេ បុគ្គលគប្បីកាន់យកថ្នាំពិសនឹងបាតដៃបាន ថ្នាំពិសមិនអាចជ្រាបចូលទៅក្នុងបាតដៃ ដែលមិនមានដំបៅ យ៉ាងណាមិញ បាបក៏មិនមានដល់អ្នកដែលមិនធ្វើ (នូវបាប) យ៉ាងនោះឯង ។

# ៥-ស្រុកកំណើតនៃឯតទគ្គបុគ្គល

## ភិក្ខុ ៤១ អង្គ

១-ព្រះអញ្ញាកោណ្ឌញ្ញៈ ឯតទគ្គៈលើភិក្ខុទាំងឡាយខាងរត្តញ្ញូ ។ លោកកើតក្នុងត្រកូលព្រាហ្មណមហាសាល ស្រុកទោណវត្ថុ មិនឆ្ងាយពីក្រុងកបិលពស្តុ ។

២-ព្រះសារីបុត្ត ឯតទគ្គៈខាងមានបញ្ញាច្រើន ។ លោកកើតក្នុងត្រកូលព្រាហ្មណមហាសាល ស្រុកនាលន្ទា មិនឆ្ងាយពីក្រុងរាជគ្រឹះ ។

៣-ព្រះមហាមោគ្គល្លាន ឯតទគ្គៈខាងមានឫទ្ធិ ។ លោកកើតក្នុងត្រកូលព្រាហ្មណមហាសាល ស្រុកនាលន្ទា មិនឆ្ងាយពីក្រុងរាជគ្រឹះ ។

៤-ព្រះមហាកស្សប ឯតទគ្គៈខាងការទ្រទ្រង់ធុតង្គ និងការពោលសរសើរគុណនៃធុតង្គ ។ លោកកើតក្នុងត្រកូលព្រាហ្មណ-មហាសាល ស្រុកព្រាហ្មណ៍ឈ្មោះមហាតិត្ថៈ ក្នុងនគរមគធៈ ។

៥-ព្រះអនុរុទ្ធ ឯតទគ្គៈខាងមានទិព្វចក្ខុ ។ លោកកើតក្នុងសក្យត្រកូល នាក្រុងកបិលពស្តុ ។ បិតារបស់លោកព្រះនាម





**អមិតោទនៈ**ត្រូវជាប្អូនបង្កើតរបស់ព្រះបាទ**សិរីសុទ្ធោទនៈ** ពុទ្ធបិតា។

៦-ព្រះភទ្ទិយកាឡិគោធាបុត្ត ឯតទគ្គៈខាងកើតក្នុងត្រកូលខ្ពង់ខ្ពស់ ។ លោកកើតក្នុងខត្តិយត្រកូល នាក្រុងកបិលពស្តុ ។

៧-ព្រះលកុណ្ឌកភទ្ទិយៈ ឯតទគ្គៈខាងមានសំឡេងពីរោះ ។ លោកកើតក្នុងត្រកូលអ្នកមានទ្រព្យច្រើន ក្នុងក្រុងសាវត្ថី ។

៨-ព្រះបិណ្ឌោលភារទ្វាជៈ ឯតទគ្គៈខាងការបន្លឺសីហនាទ។ លោកកើតក្នុងត្រកូលព្រាហ្មណមហាសាល នៅក្រុងរាជគ្រឹះ ។

៩-ព្រះបុណ្ណមន្តានីបុត្ត ឯតទគ្គៈខាងការសម្តែងធម៌ ។ លោកកើតក្នុងត្រកូលព្រាហ្មណមហាសាល ស្រុកទោណវត្ថុ មិនឆ្ងាយពីក្រុងកបិលពស្តុ ។ មាតារបស់លោកមាននាមថា **មន្តានី** ជាប្អូនស្រីបង្កើតរបស់ព្រះអញ្ញាកោណ្ឌញ្ញៈ ។

១០-ព្រះមហាកច្ចាយនៈ ឯតទគ្គៈខាងការចែកអត្ថនៃភាសិតដោយសង្ខេបឱ្យពិស្តារ ។ លោកកើតក្នុងត្រកូលព្រាហ្មណ៍ បិតាជាបុរោហិតក្នុងនគរឧជ្ជេនី ។

១១-ព្រះចូឡបន្ថកៈ ឯតទគ្គៈខាងការនិម្មិតកាយឱ្យសម្រេចតាមចិត្តផង ខាងការឆ្លាតក្នុងចេតោវិវដ្តៈផង ។ លោកកើតក្នុងផ្ទៃម្តាយដែលជាធនសេដ្ឋីធីតាក្រុងរាជគ្រឹះ ឯឪពុករបស់លោកធ្លាប់ជាទាសៈក្នុងផ្ទះធនសេដ្ឋីនោះឯង ។

១២.ព្រះមហាបន្ថកៈ ឯតទគ្គៈខាងការឆ្លាតក្នុងបញ្ញាវិវដ្តៈ។ លោកជាបងបង្កើតរបស់ព្រះចូឡបន្ថកៈ មាតាបិតាជាមួយគ្នា ។

១៣.ព្រះសុភូតិ ឯតទគ្គៈខាងការនៅដោយឥតកិលេសផង ខាងការគួរដល់ទក្ខិណាទានផង ។ លោកកើតក្នុងត្រកូលសុមនសេដ្ឋី ក្នុងក្រុងសាវត្ថី ត្រូវជាប្អូនបង្កើតរបស់អនាថបិណ្ឌិកសេដ្ឋី ។

១៤.ព្រះរេវតខទិរវនិយៈ ឯតទគ្គៈខាងការនៅក្នុងព្រៃ ។ លោកកើតក្នុងត្រកូលព្រាហ្មណមហាសាល ជាប្អូនបង្កើតរបស់ព្រះសារីបុត្ត នៅស្រុកនាលន្ទា ជាប់ក្រុងរាជគ្រឹះ ។

១៥.ព្រះកង្ខារេវតៈ ឯតទគ្គៈខាងការបានឈាន ។ លោកកើតក្នុងត្រកូលអ្នកមានទ្រព្យច្រើន ក្នុងក្រុងសាវត្ថី ។

១៦.ព្រះសោណកោឡិវិសៈ ឯតទគ្គៈខាងការប្រារព្ធព្យាយាម ។ លោកកើតក្នុងត្រកូលឧសភសេដ្ឋី ក្នុងនគរកាលចម្បាក ។

១៧.ព្រះសោណកុដិកណ្ណៈ ឯតទគ្គៈខាងមានវាចាពីរោះ ។ លោកកើតក្នុងផ្ទៃនៃស្ត្រីមេផ្ទះឈ្មោះកាឡី ក្នុងក្រុងរាជគ្រឹះ ។ លោកប្រសូតក្នុងរាត្រី ថ្ងៃដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់ព្រះធម្មចក្កប្បវត្តនសូត្រ។ ពេលដែលលោកប្រសូត មាតារបស់លោកក៏បានសម្រេចសោតាបត្តិផលផងដែរ ព្រោះបានស្តាប់ព្រះធម៌ដែលសាតាគិរីយក្ខ សម្តែងឱ្យហេមវតយក្ខស្តាប់ នៅឰដ៏អាកាសចំពីលើដំបូលផ្ទះរបស់ខ្លួន នាក្រុងរាជគ្រឹះហ្នឹងឯង ។ ឧបាសិកាកាឡីមានប្តីទៅនៅឯកុលឃរនគរ តែមកប្រសូតបុត្រនៅស្រុករបស់ខ្លួន ។

១៨.ព្រះសីវលី ឯតទគ្គៈខាងមានលាភ ។ លោកកើតក្នុងខត្តិយត្រកូលនៃនគរកុណ្ឌិយា ។ ព្រះមាតារបស់លោកមានព្រះនាមថាសុប្បវាសាកោលិយធីតា ជាសោតាបន្នបុគ្គល ។

១៩.ព្រះវក្កលិ ឯតទគ្គៈខាងការបង្អោនចិត្តទៅដោយសទ្ធាជឿស៊ប់ ។ លោកកើតក្នុងត្រកូលព្រាហ្មណ៍ក្រុងសាវត្ថី ។

២០.ព្រះរាហុល ឯតទគ្គៈខាងមានបំណងប្រាថ្នាក្នុងការសិក្សា ។ លោកកើតក្នុងសក្យត្រកូល នគរកបិលពស្តុ ។

២១.ព្រះរដ្ឋបាល ឯតទគ្គៈខាងការសាងផ្នួសដោយសទ្ធា ។ លោកកើតក្នុងត្រកូលរដ្ឋបាលសេដ្ឋី ក្នុងនគរកុរុ ។

២២.ព្រះកុណ្ឌធាន ឯតទគ្គៈខាងការចាប់ស្លាកបានមុន ។ លោកកើតក្នុងត្រកូលព្រាហ្មណ៍ ក្នុងក្រុងសាវត្ថី ។

២៣.ព្រះវង្គីសៈ ឯតទគ្គៈខាងមានបដិភាណ (បដិភាណក្នុងការពោលគាថាជាសុភាសិត ) ។ លោកកើតក្នុងត្រកូលព្រាហ្មណ៍ក្នុងក្រុងសាវត្ថី ។

២៤.ព្រះឧបសេនវង្គន្តបុត្ត ឯតទគ្គៈខាងការនាំសេចក្តី

ជ្រះថ្លាមកដល់ជនទាំងពួង ។ លោកកើតក្នុងត្រកូលព្រាហ្មណ-មហាសាល ស្រុកនាលន្ទា នគរមគធៈ ត្រូវជាប្អូនប្រុសរបស់ព្រះ-សារីបុត្ត ។

២៥.ព្រះទព្វមល្លបុត្ត ឯតទគ្គៈខាងការចាត់ចែងសេនា-សនៈ ។ លោកកើតក្នុងត្រកូលមល្លក្សត្រ ក្នុងអនុបិយនគរ ។

២៦.ព្រះបិលិន្ទវច្ឆៈ ឯតទគ្គៈខាងជាទីស្រឡាញ់ពេញចិត្តនៃពួកទេវតា ។ លោកកើតក្នុងត្រកូលព្រាហ្មណ៍ ក្នុងក្រុងសាវត្ថី ។

២៧.ព្រះពាហិយទារុចិរិយៈ ឯតទគ្គៈខាងការត្រាស់ដឹងដោយឆាប់រហ័ស ។ លោកកើតក្នុងត្រកូលអ្នកជំនួញក្នុងនគរពាហិយៈ ។

២៨.ព្រះកុមារកស្សបៈ ឯតទគ្គៈខាងការសម្ដែងធម៌ដ៏វិចិត្រ ។ លោកបដិសន្ធិក្នុងផ្ទៃនៃស្រីម្នាក់ក្នុងក្រុងរាជគ្រឹះ ប៉ុន្តែនៅពេលលោកប្រសូត មាតារបស់លោក បានបួសជាភិក្ខុនីទៅហើយ ។ លោកប្រសូតក្នុងសំណាក់ភិក្ខុនីនានគរសាវត្ថី ព្រះបាទបសេនទិកោសល ទ្រង់ទទួលយកទារកនោះទៅចិញ្ចឹម ។

២៩.ព្រះមហាកោដ្ឋិតៈ ឯតទគ្គៈខាងការបានសម្រេចចាក់-ធ្លុះនូវបដិសម្ភិទា ៤ ។ លោកកើតក្នុងត្រកូលព្រាហ្មណ៍ ក្នុងក្រុងសាវត្ថី ។



៣០.ព្រះអានន្ទ ឯតទគ្គៈ ៥ មុខគឺ :

(១).ពហុស្សូត (រៀនច្រើន ស្ដាប់ច្រើន)

(២).ការមានសតិ (ស្មារតីក្នុងការងារគ្រប់យ៉ាង)

(៣).ការមានគតិ (ញាណគតិ)

(៤).ការមានធិតិ (ការអត់ធន់ និងព្យាយាម)

(៥).ការឧបដ្ឋាក (ការបម្រើព្រះពុទ្ធ)

លោកកើតក្នុងសក្យត្រកូល នាក្រុងកបិលពស្ដុ។ បិតារបស់ព្រះអានន្ទព្រះនាម **សុក្កោទនៈ** ត្រូវជាប្អូនបង្កើតរបស់ព្រះបាទ **សិរីសុទ្ធោទនៈ** ពុទ្ធបិតា ។

៣១.ព្រះឧរុវេលកស្សបៈ ឯតទគ្គៈខាងមានបរិស័ទច្រើន ។ លោកកើតក្នុងត្រកូលព្រាហ្មណ៍ ក្នុងនគរមគធៈ ។

៣២.ព្រះកាឡុទាយី ឯតទគ្គៈខាងការធ្វើឱ្យត្រកូលមានសេចក្ដីជ្រះថ្លា ។ លោកកើតក្នុងត្រកូលអាមាត្យ នាក្រុងកបិលពស្ដុ ។ លោកប្រសូតក្នុងថ្ងៃដែលព្រះសិទ្ធត្ថបរមពោធិសត្វទ្រង់បានប្រសូត ទាំងព្រះបរមពោធិព្រឹក្សក៏ដុះក្នុងថ្ងៃនោះដែរ...។

៣៣.ព្រះពក្កុលៈ ឯតទគ្គៈខាងមានអាពាធតិច ។ លោកកើតក្នុងត្រកូលសេដ្ឋី ក្រុងកោសម្ពី ។ កាលនៅពីទារក គេនាំយកទៅងូតទឹកទន្លេ **យមុនា** ត្រូវត្រីលេបនាំទៅដល់នគរពារាណសី

បានលោកសេដ្ឋីមានទ្រព្យ ៨០ កោដិ ទទួលយកបានអំពីពោះត្រី នោះ ហើយចិញ្ចឹមប្រកបដោយសេចក្ដីស្រឡាញ់ ។ ក្រោយមក សេដ្ឋីបិតាបង្កើតក៏បានរកកូនឃើញ ។ ព្រះរាជាសម្រេចឱ្យជា មាតាបិតាទាំង ២ ត្រកូល ។

៣៤.ព្រះសោភិតៈ ឯតទគ្គៈខាងការរលឹកជាតិមុនបាន ។ លោកកើតក្នុងត្រកូលព្រាហ្មណ៍ ក្នុងក្រុងសាវត្ថី ។

៣៥.ព្រះឧបាលី ឯតទគ្គៈខាងការទ្រទ្រង់នូវព្រះវិន័យ ។ លោកកើតក្នុងត្រកូលអ្នកកាត់សក់ នៅនគរកបិលពស្ដុ ។ លោកជាខ្ញាន់ព្រះកេសនៃសក្យត្រកូល ។

៣៦.ព្រះនន្ទកៈ ឯតទគ្គៈខាងការឱ្យឱវាទដល់ពួកភិក្ខុនី ។ លោកកើតក្នុងត្រកូលអ្នកក្រុងសាវត្ថី ។

៣៧.ព្រះនន្ទ ឯតទគ្គៈខាងការគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយ ។ លោកកើតក្នុងព្រះគភ៌នៃព្រះនាងមហាបជាបតិ-គោតមី នាក្រុងកបិលពស្ដុ ។ ព្រះបិតារបស់លោកគឺព្រះបាទ **សិរីសុទ្ធោទនៈ** ពុទ្ធបិតា ។

៣៨.ព្រះមហាកប្បិន ឯតទគ្គៈខាងការឱ្យឱវាទដល់ពួកភិក្ខុ ។ លោកកើតក្នុងខត្តិយត្រកូល នៃនគរកុក្កុដវតី បច្ចន្ត-ប្រទេស ។ ក្រោយមកលោកបានសោយរាជ្យ មានអគ្គមហេសី គឺ





ព្រះនាងអនោជាទេវី ។ ពេលមួយបានដឹងដំណឹងតាមអ្នករទេះថា ព្រះពុទ្ធបរមគ្រូបានត្រាស់ ឥឡូវព្រះអង្គទ្រង់ប្រថាប់គង់នៅក្រុង សាវត្ថី ព្រះមហាកប្បិនក៏បានចេញបួសមួយអន្លើដោយពួកអាមាត្យ ១០០០ នាក់ក្នុងគ្រានោះឯង ។

៣៩.ព្រះសាគតៈ ឯតទគ្គៈខាងការឆ្លាតក្នុងការចូលតេជោ-ធាតុ ។ លោកកើតក្នុងត្រកូលព្រាហ្មណ៍ ក្នុងក្រុងសាវត្ថី ។

៤០.ព្រះរាធៈ ឯតទគ្គៈខាងការឈ្លាសវៃក្នុងបដិភាណ (អាចពោលធម៌តាមព្រះដ៏មានព្រះភាគបាន នៅពេលដែលព្រះអង្គ សម្ដែងចប់ហើយនោះ ព្រោះលោកបានយល់ច្បាស់ក្នុងព្រះធម៌ )។ លោកកើតក្នុងត្រកូលព្រាហ្មណ៍ ក្នុងក្រុងរាជគ្រឹះ ។

៤១.ព្រះមោឃរាជ ឯតទគ្គៈខាងការទ្រទ្រង់ចីវរសៅហ្មង។ លោកកើតក្នុងត្រកូលព្រាហ្មណ៍ ក្នុងក្រុងសាវត្ថី ។

## ភិក្ខុនី ១៣ អង្គ

១.ព្រះនាងមហាបជាបតិគោតមី ឯតទគ្គៈលើភិក្ខុនីទាំង - ឡាយខាងរត្តញ្ញូ ។ ព្រះនាងកើតក្នុងកោលិយវង្ស ក្នុងក្រុង ទេវទហៈ ជាប្អូនស្រីបង្កើតរបស់ **ព្រះមហាមាយាទេវី** ពុទ្ធមាតា ។

២.ព្រះនាងខេមា ឯតទគ្គៈខាងមានបញ្ញា ។ ព្រះនាងកើត

ក្នុងព្រះរាជត្រកូល ក្នុងសាគលនគរ ។ លុះដល់ព្រះនាងពេញវ័យ ក៏បានមកជាព្រះអគ្គមហេសីនៃព្រះបាទពិម្ពិសារ នគរ មគធៈ ។

៣.ព្រះនាងឧប្បលវណ្ណា ឯតទគ្គៈខាងមានឫទ្ធិ ។ ព្រះនាងកើតក្នុងត្រកូលសេដ្ឋី ក្នុងក្រុងសាវត្ថី ។

៤.ព្រះនាងបដាចារា ឯតទគ្គៈខាងការទ្រទ្រង់ព្រះវិន័យ ។ ព្រះនាងកើតក្នុងត្រកូលសេដ្ឋី ក្រុងសាវត្ថី ។

៥.ព្រះនាងធម្មទិន្នា ឯតទគ្គៈខាងការសម្តែងធម៌ ។ ព្រះនាងកើតក្នុងត្រកូលសេដ្ឋី ក្រុងរាជគ្រឹះ ។

៦.ព្រះនាងនន្ទា ឯតទគ្គៈខាងការចូលឈាន ។ ព្រះនាងកើតក្នុងផ្ទៃនៃព្រះនាងមហាបជាបតិគោតមី នៅក្រុងកបិលពស្តុ។ ព្រះបាទ **សិរីសុទ្ធោទនៈ** ជាព្រះបិតា ឯព្រះនន្ទជាបងប្រុសបង្កើត ។

៧.ព្រះនាងសោណា ឯតទគ្គៈខាងការប្រារព្ធសេចក្តីព្យាយាម ។ ព្រះនាងកើតក្នុងត្រកូលសេដ្ឋី ក្រុងសាវត្ថី ។

៨.ព្រះនាងសកុលា ឯតទគ្គៈខាងមានទិព្វចក្ខុ ។ ព្រះនាងកើតក្នុងត្រកូលព្រាហ្មណមហាសាល ក្រុងសាវត្ថី ។

៩.ព្រះនាងភទ្ទាកុណ្ឌលកេសា (ហៅព្រះនាងកុណ្ឌលកេសីក៏មានដែរ ) ឯតទគ្គៈខាងការត្រាស់ដឹងដោយឆាប់រហ័ស ។ ព្រះនាងកើតក្នុងត្រកូលសេដ្ឋី ក្រុងរាជគ្រឹះ ។





១០.ព្រះនាងភទ្ទាកបិលានី (ហៅព្រះនាងភទ្ទកាបិលានីក៏មានដែរ ) ឯតទគ្គៈខាងការដឹងជាតិមុន ។ ព្រះនាងកើតក្នុងត្រកូលព្រាហ្មណ៍កោសិយគោត្រ ក្នុងសាគលនគរ ដែនមទ្ទៈ ។ មុននឹងចេញបួសព្រះនាងជាភរិយា ដោយគ្រាន់តែរៀបការមកនៅជាមួយបិប្ផលិមាណព ក្នុងនគរមគធៈ ដោយអ្នកទាំងពីរមិនមានរាគៈជាមួយគ្នាឡើយ ។

១១.ព្រះនាងភទ្ទាកច្ចានា ឯតទគ្គៈខាងការបានសម្រេចនូវមហាភិញ្ញា គឺអភិញ្ញាដ៏ធំ ។ ព្រះនាងរលឹកជាតិក្នុងពេលតែមួយលើកបាន ១ អសង្ខេយ្យ កម្រៃ ១ សែនកប្ប ។ ព្រះនាងជាព្រះមាតានៃព្រះរាហុល ។

១២.ព្រះនាងកីសាគោតមី ឯតទគ្គៈខាងការទ្រទ្រង់ចីវរសៅហ្មង ។ ព្រះនាងកើតក្នុងត្រកូលអ្នកក្រសម្បត្តិ ក្រុងសាវត្ថី ប៉ុន្តែក្រោយមកនាងបានគ្រប់គ្រងសម្បត្តិ ៤០ កោដិកហាបណៈ ក្នុងត្រកូលខាងប្តី ។

១៣.ព្រះនាងសិគាលមាតា (ហៅព្រះនាងសិង្គាលមាតាក៏មាន ) ឯតទគ្គៈ ខាងការបង្អោនចិត្តទៅដោយសទ្ធាជឿស៊ប់ ។ ព្រះនាងកើតក្នុងត្រកូលសេដ្ឋី ក្រុងរាជគ្រឹះ ។

## ឧបាសក ១០ នាក់

១.តបុស្ស: និងភល្លិក: បងប្អូនពាណិជទាំងពីរនាក់នេះ ឯតទគ្គៈលើឧបាសកទាំងឡាយខាងការដល់នូវសរណៈ(ព្រះពុទ្ធនិងព្រះធម៌ ) មុនគេ ។ គាត់កើតក្នុងត្រកូលកុដុម្ពិកៈ ក្នុងអសិតញ្ជន-នគរ (បានឮមកថា ជាប្រទេសភូមាសព្វថ្ងៃ ) ។ អ្នកទាំងពីរបានទទួលផ្ទាល់ពីព្រះដ៏មានព្រះភាគនូវព្រះកេសាធាតុ ៨ សរសៃដាក់ក្នុងប្រអប់មាស មកកសាងព្រះចេតិយឯនគររបស់ខ្លួន ។

២.សុទត្តអនាថបិណ្ឌិកសេដ្ឋី ឯតទគ្គៈខាងការថ្វាយទាន ។ គាត់កើតក្នុងត្រកូលសុមនសេដ្ឋី ក្រុងសាវត្ថី ។

៣.ចិត្តគហបតី ឯតទគ្គៈខាងការសម្តែងធម៌ ។ គាត់កើតក្នុងត្រកូលសេដ្ឋី ស្រុកមច្ឆិកសណ្ឌ: (កន្លែងខ្លះថាមច្ឆិកាសណ្ឌ: ) ក្នុងដែនដីនគរមគធ: ។

៤.ហត្ថកអាឡវក: ឯតទគ្គៈខាងការសង្គ្រោះបរិស័ទដោយសង្គហវត្ថុ ៤ យ៉ាង។ ទ្រង់ប្រសូតក្នុងព្រះរាជត្រកូល ក្រុងអាឡវី។

៥.សក្យមហានាម ឯតទគ្គៈខាងការថ្វាយទានដ៏ប្រណីត (បានដល់ភោជនដែលមានរសប្រណីត ) ។ ទ្រង់កើតក្នុងសក្យ-ត្រកូល ក្រុងកបិលពស្តុ ។

៦.ឧគ្គគហបតីអ្នកស្រុកវេសាលី ឯតទគ្គៈខាងការឱ្យរបស់



ជាទីពេញចិត្ត (គឺតាមការពេញចិត្តរបស់គាត់ ) ។ គាត់កើតក្នុងត្រកូលសេដ្ឋី ក្រុងវេសាលី ។

៧.ឧគ្គតគហបតី ឯតទគ្គៈខាងការបម្រើសង្ឃ ។ គាត់កើតក្នុងត្រកូលសេដ្ឋី អ្នកស្រុកហត្ថិគ្រាម (មិនប្រាកដនគរ ) ។

៨.សូរអម្ពដ្ឋ: ឯតទគ្គៈខាងការជ្រះថ្លាមិនកម្រើក ។ គាត់កើតក្នុងត្រកូលសេដ្ឋី (មិនប្រាកដនគរ ) ។

៩.ពេទ្យជីវកកោមារភច្ច ឯតទគ្គៈខាងសេចក្តីជ្រះថ្លាក្នុងបុគ្គល ។ គាត់កើតក្នុងផ្ទៃនៃស្ត្រីនគរសោភិនី ឈ្មោះសាលវតី នៅក្រុងរាជគ្រឹះ ។

១០.នកុលបិតា ឯតទគ្គៈខាងការស្និទ្ធស្នាល (ជាមួយនឹងព្រះសម្មាសម្ពុទ្ធ ) ។ គាត់កើតក្នុងត្រកូលសេដ្ឋី នគរសុំសុមារគីរី ដែនភគ្គៈ ។

## ឧបាសិកា ១០ នាក់

១.នាងសុជាតាសេនីយធីតា ឯតទគ្គៈលើឧបាសិកាទាំង-ឡាយខាងការដល់ព្រះត្រៃសរណៈមុនគេ នាងកើតក្នុងត្រកូលកុដុម្ពិកៈឈ្មោះសេនីយៈ ក្នុងតំបន់ឧរុវេលាសេនានិគម នគរមគធ: ។

២.នាងវិសាខាមិគារមាតា ឯតទគ្គៈខាងការថ្វាយទាន ។ នាងកើតក្នុងត្រកូលមហាសេដ្ឋី ក្នុងភទ្ទិយនគរ ដែនអង្គៈ ។ នាងអាស្រ័យផ្ទៃនាងសុមនទេវីភរិយារបស់ធនញ្ជ័យសេដ្ឋី ។ ក្រោយមកគ្រួសារនាងបានទទួលការអញ្ជើញពីព្រះបាទបសេនទិកោសលមករស់នៅស្រុកសាកេត ចម្ងាយ ៧ យោជន៍ពីក្រុងសាវត្ថី ។ លុះដល់នាងមានប្តី បានមកនៅនឹងត្រកូលខាងប្តីឯក្រុងសាវត្ថី ។

៣.នាងខុជ្ជុត្តរា ឯតទគ្គៈខាងពហុស្សូត ។ នាងកើតក្នុងផ្ទៃមេដោះក្នុងផ្ទះឃោសកសេដ្ឋី នគរកោសម្ពី ។ នាងជាអ្នកបម្រើនាងសាមាវតីបុត្រីធម៌របស់ឃោសកសេដ្ឋី រហូតមកកាន់ព្រះរាជវាំងនៃព្រះបាទឧទេន ។

៤.នាងសាមាវតី ឯតទគ្គៈខាងការនៅដោយមេត្តា ។ នាងកើតក្នុងត្រកូលភទ្ទវតិយសេដ្ឋី ក្នុងនគរភទ្ទវតីយ៍ ។ នាងមានពណ៌សម្បុរមាស ទើបឈ្មោះថា "សាមាវតី" ទាំងរូបរាងក៏ស្អាត ។ ក្រោយមកក៏បានជាអគ្គមហេសីនៃព្រះបាទឧទេន នគរកោសម្ពី ។

៥.នាងឧត្តរានន្ទមាតា ឯតទគ្គៈខាងការចូលឈាន ។ នាងកើតក្នុងផ្ទៃនៃភរិយារបស់នាយបុណ្ណៈ ក្រុងរាជគ្រឹះ ។ ក្រោយមកបានឡើងជាសេដ្ឋីក្នុងព្រះនគរមគធៈ អាស្រ័យបុណ្យឱ្យផលក្នុងបច្ចុប្បន្ន ។



៦.នាងសុប្បវាសាកោលិយធីតា ឯតទគ្គៈខាងការថ្វាយទានដ៏ប្រណីត (បានដល់ភោជនដែលមានរសប្រណីត ) ។ ព្រះនាងកើតក្នុងខត្តិយត្រកូលក្នុងកោលិយនគរ ។ ព្រះនាងជាព្រះមាតានៃព្រះសីវលី ដែលលោកជាឯតទគ្គៈលើភិក្ខុទាំងឡាយផ្នែកខាងមានលាភ ។

៧.សុប្បិយា ឯតទគ្គៈខាងការបម្រើព្រះសង្ឃមានអាពាធ។ នាងកើតក្នុងត្រកូលធម្មតាមួយនៃនគរពារាណសី ។

៨.នាងកាតិយានី ឯតទគ្គៈខាងការជ្រះថ្លាមិនកម្រើក ។ នាងកើតក្នុងត្រកូលធម្មតាមួយដែរ ក្នុងកុលឃរនគរ (កុររឃរនគរ ) ក្នុងដែនអវន្តីជនបទ ។

៩.នាងនកុលមាតា ឯតទគ្គៈខាងការស្និទ្ធស្នាល (ជាមួយនឹងព្រះសម្មាសម្ពុទ្ធ )។ នាងកើតក្នុងត្រកូលសេដ្ឋី នគរសុំសុមារគិរី ដែនភគ្គៈ ។

១០.នាងកាឡីឧបាសិកានៅនគរកុររឃរិកា ឯតទគ្គៈខាងការជ្រះថ្លាក្នុងការស្តាប់តាមគេ ។ នាងកើតក្នុងត្រកូលធម្មតានៃក្រុងរាជគ្រឹះ ។ កាលចម្រើនវ័យហើយ នាងមានស្វាមីទៅនៅឯកុររឃរនគរ (កុលឃរនគរ ) ដែលជានគរខាងប្តី ។

# ៦-ឈ្មោះព្រះសូត្រធំៗ

**១-ព្រហ្មជាលសូត្រ** បិដកលេខ ១៤,ទំព័រ ១ ដល់ទំព័រ ១១៣ ព្រះអង្គទ្រង់ត្រាស់សម្តែងនៅក្នុងសួននៃព្រះរាជដំណាក់ ឈ្មោះអម្ពលដ្ឋិកា រវាងក្រុងរាជគ្រឹះ និងស្រុកនាលន្ទា ។ ព្រះអង្គសម្តែងឱ្យដល់ភិក្ខុទាំងឡាយស្តាប់ ដោយប្រារព្ធចំពោះសុប្បិយបរិព្វាជកពោលតិះដៀលព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ឯព្រហ្មទត្តមាណពជាសិស្សរបស់សុប្បិយបរិព្វាជកនោះឯង បែរត្រឡប់ជាពោលសរសើរព្រះដ៏មានព្រះភាគវិញ ។ ព្រះអង្គទ្រង់សម្តែងមិនឱ្យក្រោធខឹងដល់អ្នកពោលតិះដៀល និងមិនឱ្យត្រេកអរ បានចិត្ត ចំពោះអ្នកពោលសរសើរ ... ។ ទិដ្ឋិ ៦២ ព្រះអង្គសម្តែងក្នុងព្រះសូត្រនេះឯង ។ ភិក្ខុទាំងឡាយ មានចិត្តត្រេកអររីករាយចំពោះភាសិតរបស់ព្រះដ៏-មានព្រះភាគ ។ នៅពេលចប់ព្រហ្មជាលសូត្រនេះ លោកធាតុទាំងមួយហ្មឺនក៏កម្រើកញាប់ញ័រ ។

**២-សាមញ្ញផលសូត្រ** បិដកលេខ ១៤, ទំព័រ ១១៤ ដល់ទំព័រ ២១៤ ព្រះអង្គទ្រង់ត្រាស់សម្តែងនៅជីវកម្ពវ័ន ក្រុងរាជគ្រឹះ ។





ព្រះអង្គទ្រង់ឆ្លើយតបបញ្ហារបស់ព្រះបាទអជាតសត្តុ ដែលទូលសួរព្រះអង្គអំពីផលនៃសមណប្បដិបត្តិ ដែលត្រូវឃើញច្បាស់ដោយខ្លួនឯងក្នុងបច្ចុប្បន្ន ។ ព្រះបាទអជាតសត្តុពោលសរសើរព្រះធម៌ទេសនា ហើយថ្វាយខ្លួនជាឧបាសកអ្នកដល់ព្រះរតនត្រៃជាទីពឹងទីរលឹក ។

**៣-កូដទន្តសូត្រ** បិដកលេខ ១៥,ទំព័រ ១ ដល់ទំព័រ៥៤ ព្រះអង្គទ្រង់ត្រាស់សម្តែង នៅស្រុកព្រាហ្មណ៍ឈ្មោះខានុមត្តៈ ក្នុងមគធជនបទ ។ កូដទន្តព្រាហ្មណ៍ បានចាត់ចែងមហាយញ្ញដោយសត្វទាំងឡាយមួយមុខ ៧០០ ហើយបានចូលទៅគាល់ព្រះដ៏មាន-ព្រះភាគ ទូលសួរអំពីយញ្ញសម្បទា ៣ ប្រការមានបរិក្ខារ ១៦ ។ កាលដែលបានស្តាប់នូវព្រះធម៌ទេសនាហើយ កូដទន្តព្រាហ្មណ៍ក៏បានសម្រេចនូវសោតាបត្តិផល ហើយអារាធនាព្រះភិក្ខុសង្ឃមានព្រះសម្មាសម្ពុទ្ធជាប្រមុខ ទទួលបិណ្ឌបាត ។

**៤-កេវដ្ដសូត្រ** បិដកលេខ ១៥,ទំព័រ២០១ ដល់ទំព័រ ២២០ ព្រះអង្គទ្រង់ត្រាស់សម្តែងនៅបាវារិកម្ពវ័ន ក្នុងស្រុកនាលន្ទា ។ កេវដ្តៈជាបុត្ររបស់គហបតី ស្នើព្រះដ៏មានព្រះភាគសូមឱ្យភិក្ខុសង្ឃសម្តែងនូវឥទ្ធិប្បាដិហារិយ៍ ដើម្បីធ្វើឱ្យអ្នកស្រុកនាលន្ទារឹតតែជ្រះថ្លាឡើងក្នុងព្រះដ៏មានព្រះភាគ ។ ព្រះដ៏មានព្រះភាគទ្រង់

ត្រាស់សម្តែងព្រះធម៌អំពីបាដិហារិយ៍ ៣ យ៉ាង ។ កេវដ្ដៈជាបុត្ររបស់គហបតី មានចិត្តរីករាយ ត្រេកអរនឹងភាសិត របស់ព្រះដ៏-មានព្រះភាគ ។

**៥-មហាគោវិន្ទសូត្រ** បិដកលេខ ១៧,ទំព័រ ១០៤ ដល់ទំព័រ ១៦៧ ព្រះអង្គទ្រង់ត្រាស់សម្តែង នៅលើភ្នំគិជ្ឈកូដ ជិតក្រុងរាជគ្រឹះ ។ បញ្ចសិខគន្ធព្វបុត្រ បានក្រាបទូលព្រះដ៏មានព្រះភាគ អំពីរឿងសក្កទេវរាជសរសើរព្រះពុទ្ធអង្គ នៅឋានតាវត្តិង្សដោយគុណ ៨ ប្រការ ។ សនង្កុមារព្រហ្មបានសរសើរព្រះដ៏មានព្រះភាគ ហើយបានពោលអំពីមហាគោវិន្ទព្រាហ្មណ៍ ដែលក្រោយមកបានជាព្រះដ៏មានព្រះភាគហ្នឹងឯង ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែងអំពីព្រហ្មចរិយធម៌ ដែលប្រព្រឹត្តទៅដើម្បីនឿយណាយ ដើម្បីប្រាសចាកតម្រេក ដើម្បីរំលត់កិលេស ដើម្បីស្ងប់រម្ងាប់ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹងដើម្បីព្រះនិព្វាន។ បញ្ចសិខគន្ធព្វ-បុត្រ ពេញចិត្ត ត្រេកអរអនុមោទនា ចំពោះភាសិតរបស់ព្រះដ៏-មានព្រះភាគ ។

**៦-សក្កបញ្ហសូត្រ** បិដកលេខ ១៧, ទំព័រ ១៩១ ដល់ទំព័រ ២៤៣ ព្រះអង្គទ្រង់ត្រាស់សម្តែងនៅគុហាឥន្ទសាលលើភ្នំវេទិយកៈ (សព្វថ្ងៃហៅភ្នំឧទ័យ ខាងត្បូងភ្នំគិជ្ឈកូដ ) ជិតក្រុងរាជគ្រឹះ ។



សក្កទេវរាជ ព្រមទាំងទេវតាដទៃបានចូលគាល់ព្រះដ៏មានព្រះភាគ ក្នុងគុហាឥន្ទសាល សក្កទេវរាជបានក្រាបទូលសួរបញ្ហា ។ ព្រះដ៏មានព្រះភាគទ្រង់ឆ្លើយតប ញ៉ាំងសក្កទេវរាជឱ្យត្រាស់ដឹងនូវសច្ច-ធម៌ បានជាព្រះសោតាបន្នបុគ្គល ។ សក្កទេវរាជ សម្តែងនូវសេចក្តីត្រេកអរ ព្រោះឃើញនូវអំណាចនៃប្រយោជន៍ ៦ យ៉ាង ។

**៧-ឧទុម្ពរិកសូត្រ** បិដកលេខ ១៨,ទំព័រ ៧០ ដល់ទំព័រ ១១៤ ព្រះអង្គយាងចុះពីភ្នំគិជ្ឈកូដ មកកាន់មោរនិវាបស្ថាន ឆ្នេរស្រះបោក្ខរណីឈ្មោះសុមាគធា ក្នុងក្រុងរាជគ្រឹះ ។ និគ្រោធបរិព្វាជក លើកតម្កើងខ្លួនឯង ហើយតិះដៀលព្រះដ៏មានព្រះភាគថា ព្រះ-សមណគោតមចូលចិត្តទីស្ងាត់ ព្រោះមិនមានបញ្ញា មិនអាចចរចាសាកល្បងប្រាជ្ញាជាមួយអ្នកណាបាន ។ ព្រះដ៏មានព្រះភាគទ្រង់យាងចូលទៅបរិព្វាជការាម ជាអារាមរបស់ឧទុម្ពរិកាទេវី ទ្រង់សន្ទនាជាមួយនឹងនិគ្រោធបរិព្វាជក ព្រះអង្គទ្រង់សម្តែងអំពីឧបក្កិលេសរបស់អ្នកដែលមានតបវត្ត ។ និគ្រោធបរិព្វាជកសូមខមាទោសអំពីព្រះដ៏មានព្រះភាគ ។ ព្រះបរមសាស្តាទ្រង់ត្រាស់សម្តែងអំពីមគ្គព្រហ្មចរិយធម៌ហើយ បន្លឺសីហនាទក្នុងអារាមនៃបរិព្វាជក ជារបស់នាងឧទុម្ពរិកាទេវី រួចហើយទ្រង់ហោះឡើងទៅកាន់វេហាសដ្ឋាន ត្រឡប់ទៅគង់លើភ្នំគិជ្ឈកូដវិញ ។

**៨-ចក្កវត្តិសូត្រ** បិដកលេខ ១៨,ទំព័រ ១១៥ ដល់ទំព័រ ១៦០ ព្រះអង្គទ្រង់ត្រាស់សម្តែង នៅក្នុងស្រុកមាតុលា នគរមគធៈ ។ ព្រះអង្គទ្រង់ប្រទានឱវាទឱ្យដល់ភិក្ខុទាំងឡាយ ឱ្យភិក្ខុទាំងឡាយមានខ្លួនជាទីពឹង មានធម៌ជាទីពឹង ចម្រើនសតិប្បដ្ឋាន ៤។ ព្រះអង្គទ្រង់សម្តែងអំពីស្តេចចក្រពត្តិមានរតនៈ ៧ ប្រការ ច្រើនអង្គត។ គ្នារហូតដល់មនុស្សអាយុ ៨ ហ្មឺនឆ្នាំ ព្រះបាទសង្ខៈជាស្តេចចក្រ-ពត្តិក្នុងកាលព្រះអរិយមេត្តេយ្យៈបានត្រាស់ដឹង ។ ព្រះបាទសង្ខៈបានលះបង់រតនៈ ៧ ប្រការព្រមទាំងសម្បត្តិលោកិយគ្រប់យ៉ាងចូលកាន់ផ្នួស ហើយធ្វើនូវទីបំផុតទុក្ខបានសម្រេច ។ ព្រះអង្គទ្រង់សម្តែងឥទ្ធិបាទ ៤ ជាហេតុនៃអាយុ សីលជាហេតុនៃវណ្ណៈ ឈាន ៤ ជាហេតុនៃសុខ ព្រហ្មវិហារធម៌ ៤ ជាភោគៈ និងអរហត្តផលជាកម្លាំង គឺជាកម្លាំងក្នុងការគ្របសង្កត់កម្លាំងមារបាន ។ ក្នុងពេលចប់ព្រះសូត្រ ភិក្ខុ ២ ហ្មឺនអង្គបានសម្រេចនូវព្រះអរហត្តសត្វ ៨៤០០០ បាននូវអមតធម៌ ។

**៩-សម្បសាទនីយសូត្រ** បិដកលេខ ១៨,ទំព័រ ១៩៩ ដល់ទំព័រ ២៣៦ ព្រះអង្គទ្រង់ត្រាស់សម្តែងនៅក្នុងបាវារិកម្ពវ័ន ស្រុកនាលន្ទា ។ ព្រះសារីបុត្តក្រាបទូលព្រះដ៏មានព្រះភាគអំពីសេចក្តីជ្រះថ្លារបស់លោកចំពោះព្រះសាស្តា ព្រមទាំងប្រកាសគុណព្រះដ៏





មានព្រះភាគច្រើនបែបច្រើនយ៉ាង ។ ព្រះឧទាយីសម្តែងសេចក្តីអស្ចារ្យក្នុងគុណព្រះដ៏មានព្រះភាគ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ឱ្យព្រះសារីបុត្តសម្តែងនូវធម្មបរិយាយនេះដល់ភិក្ខុ ភិក្ខុនីឧបាសក ឧបាសិកាឱ្យបានរឿយ។ ។ ព្រះសារីបុត្តសម្តែងនូវអំណរនេះចំពោះព្រះភក្ត្រនៃព្រះដ៏មានព្រះភាគ ដោយប្រការដូច្នេះឯង។ ព្រោះហេតុដូច្នេះ ទើបព្រះសូត្រនេះឈ្មោះថាសម្បសាទនីយ-សូត្រ ។

**១០-សិង្គាលកសូត្រ** បិដកលេខ ១៩ , ទំព័រ ៦៧ ដល់ទំព័រ ៩៣ ព្រះអង្គទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ជិតក្រុងរាជគ្រឹះ។ ព្រះអង្គទ្រង់យាងចូលទៅក្នុងក្រុងរាជគ្រឹះដើម្បីបិណ្ឌបាត ព្រះអង្គទ្រង់ទតឃើញសិង្គាលកគហបតិបុត្រ ធ្វើការសំពះទិសទាំង ៦ តាមបណ្តាំបិតា ។ ព្រះដ៏មានព្រះភាគទ្រង់ទូន្មានសិង្គាលកគហបតិបុត្រឱ្យបានយល់អំពីទិសទាំង ៦ ក្នុងអរិយវិន័យ ។ ព្រះអង្គត្រាស់សម្តែងអំពីកម្មក្កិលេស ៤ អគតិ ៤ អបាយមុខ ៦ យ៉ាង ។ ជាបន្តទ្រង់ត្រាស់សម្តែងអំពីមិត្តប្ញម និងមិត្តមានឧបការៈរហូតដល់ធម៌សង្គ្រោះនៃមនុស្ស ១២ ពួក ។ សិង្គាលកគហបតិបុត្រពោលសរសើរព្រះធម៌ និងប្រកាសខ្លួនជាឧបាសក ដល់នូវព្រះដ៏មាន-ព្រះភាគផង ព្រះធម៌ផង ព្រះសង្ឃផងជាសរណៈរហូតតទៅ ។

**១១-អាដានាដិយសូត្រ** បិដកលេខ ១៩,ទំព័រ ៩៤ ដល់ទំព័រ ១២២ ព្រះអង្គទ្រង់ត្រាស់សម្ដែង នៅលើភ្នំគិជ្ឈកូដ ជិតក្រុងរាជគ្រឹះ ។ មហារាជទាំង ៤ ក្នុងឋានចាតុម្មហារាជិកាព្រមទាំងបរិវារដ៏ច្រើន ចូលគាល់ព្រះដ៏មានព្រះភាគ សូមឱ្យភិក្ខុទាំងឡាយរៀននូវព្រះបរិត្ត ឈ្មោះអាដានាដិយបរិត្ត ដែលប្រកបដោយប្រយោជន៍ ប្រព្រឹត្តទៅដើម្បីគ្រប់គ្រងរក្សា ដើម្បីមិនបៀតបៀន ដើម្បីនៅជាសុខ ដល់ពួកភិក្ខុ ភិក្ខុនី ឧបាសក និងឧបាសិកា ។ លុះរាត្រីនោះកន្លងទៅហើយ ទើបព្រះដ៏មានព្រះភាគទ្រង់ត្រាស់ប្រាប់ភិក្ខុទាំងឡាយ អំពីព្រឹត្តិការណ៍កាលពីយប់មិញ រួចហើយទ្រង់ត្រាស់ឱ្យភិក្ខុទាំងឡាយរៀននូវព្រះបរិត្ត ដែលមានជាអាទិ៍ថា :

**វិបស្សិស្ស នមត្ថុ ចក្ខុមន្តស្ស សិរីមតោ**
**សិខិស្សបិ នមត្ថុ សព្វភូតានុកម្បិនោ ។**
**វេស្សភុស្ស នមត្ថុ ន្ហាតកស្ស តបស្សិនោ**
**នមត្ថុ កកុសន្ធស្ស មារសេនប្បមទ្ទិនោ ។**
**កោនាគមនស្ស នមត្ថុ ព្រាហ្មណស្ស វុសីមតោ**
**កស្សបស្ស នមត្ថុ វិប្បមុត្តស្ស សព្វធិ ។**
**អង្គីរសស្ស នមត្ថុ សក្យបុត្តស្ស សិរីមតោ**
**យោ ឥមំ ធម្មមទេសេសិ សព្វទុក្ខា បនូទនំ ។**



ភិក្ខុទាំងឡាយត្រេកអរទទួលអនុមោទនានឹងភាសិត របស់ព្រះដ៏មានព្រះភាគ ។

**១២-រថវិនីតសូត្រ** បិដកលេខ ២១,ទំព័រ ៨០ ដល់ទំព័រ ៩៩ ព្រះអង្គទ្រង់គង់នៅវត្តវេឡុវន័ ជិតក្រុងរាជគ្រឹះ ។ ព្រះអង្គទ្រង់ត្រាស់សួររកភិក្ខុណា ជាអ្នកប្រាថ្នាតិច ១ ជាអ្នកសន្ដោស ១ ជាអ្នកស្ងប់ស្ងាត់ ១ ជាអ្នកមិនច្រឡូកច្រឡំ ១ ជាអ្នកប្រារព្ធព្យាយាម ១ ជាអ្នកបរិបូណ៌ដោយសីល ១ ជាអ្នកបរិបូណ៌ដោយសមាធិ ១ ជាអ្នកបរិបូណ៌ដោយបញ្ញា ១ ជាអ្នកបរិបូណ៌ដោយវិមុត្តិ គឺអរិយផល ១ ជាអ្នកបរិបូណ៌ដោយវិមុត្តិញ្ញាណទស្សនៈ គឺបច្ចវេក្ខណញ្ញាណ ១ ព្រមទាំងជាអ្នកសម្ដែងនូវកថាវត្ថុទាំង ១០ នេះដល់ពួកសព្រហ្មចារីផង ។ ភិក្ខុទាំងឡាយក្រាបទូលព្រះដ៏-មានព្រះភាគថា « បពិត្រព្រះអង្គដ៏ចម្រើន គឺបុណ្ណមន្តានីបុត្តព្រះអង្គ »។ ជាបន្តទៅគឺព្រះសារីបុត្ត និងព្រះបុណ្ណមន្តានីបុត្តបានសន្ទនាគ្នាអំពីវិសុទ្ធិ ៧ នៅព្រៃអន្ធវន័ ជិតក្រុងសាវត្ថី ។

**១៣-មហាសារោបមសូត្រ** បិដកលេខ ២១, ទំព័រ ២១៦ ដល់ទំព័រ ២៣៥ ព្រះអង្គទ្រង់ត្រាស់សម្ដែងនៅលើភ្នំគិជ្ឈកូដ ជិតក្រុងរាជគ្រឹះ ។ ព្រះអង្គទ្រង់ប្រទានឱវាទដល់ភិក្ខុទាំងឡាយ ឱ្យយល់ដឹងអំពីខ្លឹមនៃព្រហ្មចរិយធម៌ពិតប្រាកដ ។ ព្រះអង្គប្រៀបប្រដូច

លាភសក្ការៈនិងសេចក្តីសរសើរ ទៅនឹងមែក និងស្លឹកឈើ ។ សីលសម្បទាដូចក្រមរឈើ ។ សមាធិសម្បទាដូចសំបកឈើ ។ ញាណទស្សនៈគឺទិព្វចក្ខុដូចស្រាយឈើ ។ អរហត្តផលដូចខ្លឹមឈើ ។

ម្នាលភិក្ខុទាំងឡាយ ព្រហ្មចរិយៈនេះមិនមែនមានលាភសក្ការៈនិងសេចក្តីសរសើរជាអានិសង្ស មិនមែនមានសីលសម្បទាជាអានិសង្ស មិនមែនមានសមាធិសម្បទាជាអានិសង្ស មិនមែនមានញាណទស្សនៈ គឺទិព្វចក្ខុជាអានិសង្សតែប៉ុណ្ណោះទេ ម្នាលភិក្ខុទាំងឡាយ ចេតោវិមុត្តិ ការរួចចាកកិលេសនៃចិត្ត គឺអរហត្តផលជាធម្មជាតិមិនកម្រើកណា ម្នាលភិក្ខុទាំងឡាយ ព្រហ្មចរិយៈនេះមានអរហត្តផលនោះជាប្រយោជន៍ មានអរហត្តផលនោះជាខ្លឹម មានអរហត្តផលនោះជាទីបំផុត ។ ព្រះដ៏មានព្រះភាគបានត្រាស់នូវព្រះសូត្រនេះចប់ហើយ ភិក្ខុទាំងនោះក៏មានការពេញចិត្ត បានត្រេកអរហើយចំពោះភាសិត របស់ព្រះដ៏មានព្រះភាគ ។

**១៤-ចូឡវេទល្លសូត្រ** បិដកលេខ ២២,ទំព័រ ២៨៨ ដល់ទំព័រ ៣០៣ ព្រះអង្គទ្រង់គង់នៅវត្តវេឡុវ័ន ។ វិសាខឧបាសកបានសួរធម៌នឹងព្រះនាងធម្មទិន្នាភិក្ខុនី តាំងពីធម៌លំដាប់សោតាបត្តិផលដល់អរហត្តផល ។ វិសាខឧបាសកបានចូលគាល់ព្រះដ៏មាន



ព្រះភាគ បានទូលព្រះអង្គនូវពាក្យចរចារបស់ខ្លួន ជាមួយនឹងព្រះនាងធម្មទិន្នាភិក្ខុនី។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់នឹងវិសាខឧបាសកយ៉ាងនេះថា « ម្នាលវិសាខៈ ធម្មទិន្នាភិក្ខុនីជាបណ្ឌិត ម្នាលវិសាខៈ ធម្មទិន្នាភិក្ខុនីជាស្ត្រីមានប្រាជ្ញាច្រើន ម្នាលវិសាខៈ បើទុកជាអ្នកត្រឡប់សួរសេចក្តីនោះនឹងតថាគតវិញ តថាគតក៏ត្រូវព្យាករសេចក្តីនោះ ដូចសេចក្តីដែលនាងធម្មទិន្នាភិក្ខុនីព្យាករហើយយ៉ាងនោះដែរ សេចក្តីនៃប្រស្នានោះ យ៉ាងហ្នឹងហើយ អ្នកចូរចាំទុកប្រស្នានោះយ៉ាងនេះចុះ » ។ លុះព្រះដ៏មានព្រះភាគត្រាស់នូវភាសិតនេះហើយ វិសាខឧបាសកក៏ត្រេកអរនឹងភាសិតរបស់ព្រះដ៏មានព្រះភាគ ។

**១៥-ជីវកសូត្រ** បិដកលេខ ២៣ ,ទំព័រ ៨៣ ដល់ទំព័រ ៩១ ព្រះអង្គទ្រង់ត្រាស់សម្តែងនៅជីវកម្ពវ័ន ក្រុងរាជគ្រឹះ ។ ពេទ្យជីវកបានទូលសួរព្រះអង្គអំពីការឆាន់សាច់ ។ ព្រះអង្គទ្រង់ត្រាស់អំពីសាច់ដែលគួរបរិភោគ ដោយហេតុ ៣ យ៉ាង គឺមិនឃើញ មិនឮ និងមិនរង្កៀស ។ ទ្រង់ត្រាស់អំពីការចម្រើនព្រហ្មវិហារធម៌ ៤ របស់ភិក្ខុទាំងឡាយ មិនគិតបៀតបៀនខ្លួនឯង មិនគិតបៀតបៀនអ្នកដទៃ ឆាន់អាហារដោយមិនមានទោស ។ ពេទ្យជីវកប្រកាសខ្លួនជាឧបាសក អ្នកដល់នូវសរណៈទាំង ៣ ស្មើដោយជីវិត ។

**១៦-ឧបាលិវាទសូត្រ** បិដកលេខ ២៣ , ទំព័រ ៩២ ដល់ទំព័រ ១៣៤ ព្រះអង្គទ្រង់ត្រាស់សម្តែងនៅបាវារិកម្ពវ័ន ស្រុកនាលន្ទា ។ កាលដើមឧបាលិគហបតីជាសាវ័ករបស់និគន្ថនាដបុត្រ ព្រោះហេតុតែមិនទាន់ស្គាល់ព្រះសម្មាសម្ពុទ្ធ ក៏អួតអាងខ្លួនឯងហើយទៅលើកវាទៈចំពោះព្រះបរមសាស្តា ។ ដោយព្រះទ័យករុណា និងដោយអាសយានុសយញ្ញាណ (ជ្រាបអធ្យាស្រ័យនិងអនុស័យសត្វ) ទ្រង់ប្រទានព្រះធម៌ទេសនា ញ៉ាំងព្រះសោតាបត្តិផលឱ្យបានសម្រេចដល់ឧបាលិគហបតី ។ និគន្ថនាដបុត្រឈឺចិត្តក្អួតឈាមរហូតទាល់តែស្លាប់ ព្រោះហេតុតែបាត់បង់នូវគហបតីម្នាក់ ដែលប្រៀបបីដូចជាផ្ទាំងបាយនៃពួកខ្លួនពីមុនមក ឥឡូវត្រូវបែក ។ ឧបាលិគហបតីបានពោលសរសើរព្រះគុណរបស់ព្រះដ៏មានព្រះភាគ ដែលគួរឱ្យជ្រះថ្លា ។

**១៧-អភយរាជកុមារសូត្រ** បិដកលេខ ២៣ , ទំព័រ ១៤៩ ដល់ទំព័រ ១៦០ ព្រះអង្គទ្រង់ត្រាស់សម្តែងនៅវត្តវេឡុវ័ន ជិតក្រុងរាជគ្រឹះ ។ កាលដើមអភយរាជកុមារ បានរាប់អាននិគន្ថនាដបុត្រ ហើយបានទទួលពាក្យពីនិគន្ថនាដបុត្រ មកលើកវាទៈដើម្បីចាប់ទោសព្រះដ៏មានព្រះភាគនៅវត្តវេឡុវ័នមហាវិហារ ។ ព្រះដ៏មាន-ព្រះភាគទ្រង់ត្រាស់តែពាក្យពិតហើយមានប្រយោជន៍ ទោះជាទី





គាប់ចិត្ត ឬមិនជាទីគាប់ចិត្តនៃអ្នកដទៃក៏ដោយ ព្រះអង្គទ្រង់ដឹងកាលគួរដែលនឹងត្រូវត្រាស់សម្តែង ព្រះអង្គមានសេចក្តីអនុគ្រោះចំពោះសត្វទាំងឡាយ ។ អភយរាជកុមារជ្រះថ្លាសរសើរព្រះធម៌ថ្វាយខ្លួនជាឧបាសក ដល់នូវព្រះដ៏មានព្រះភាគផង ព្រះធម៌ផង ព្រះសង្ឃផង ជាទីពឹងទីរលឹក ។

**១៨-ចូឡរាហុលោវាទសូត្រ** បិដកលេខ ២៣ , ទំព័រ ២១១ ដល់ទំព័រ ២២៨ ព្រះអង្គគង់នៅវត្តវេឡុវ័ន ហើយទ្រង់ស្តេចយាងទៅអម្ពលដ្ឋិកាវ័ន កន្លែងដែលព្រះរាហុលគង់នៅ ហើយព្រះអង្គទ្រង់ត្រាស់សម្តែងនៅក្នុងអម្ពលដ្ឋិកាវ័ននោះឯង ដែលឋិតនៅរវាងក្រុងរាជគ្រឹះ និងស្រុកនាលន្ទា ។ ព្រះអង្គទ្រង់ត្រាស់សម្តែងអំពីសមណធម៌របស់ពួកភិក្ខុ ដែលមិនមានសេចក្តីអៀនខ្មាស ក្នុងសម្បជានមុសាវាទ ថាដូចជាទឹកដែលមានបន្តិចបន្តួចក្នុងផ្តិល ឬដូចជាផ្តិលចាក់ទឹកចោលអស់ ផ្តិលផ្កាប់ ផ្តិលទទេរលីងធេងអត់ទឹកដូច្នោះដែរ ។ ព្រះអង្គទ្រង់ប្រទានឱវាទថា « ម្នាលរាហុល ព្រោះហេតុដូច្នោះ ក្នុងសាសនានេះ អ្នកគប្បីសិក្សាថា អាត្មាអញនឹងមិនពោលពាក្យកុហក សូម្បីដើម្បីសើចលេង ម្នាលរាហុល អ្នកត្រូវសិក្សាយ៉ាងនេះចុះ »។ កញ្ចក់មានប្រយោជន៍ក្នុងការឆ្លុះមើលមុខ យ៉ាងណា ព្រះអង្គទ្រង់ទូន្មានព្រះរាហុលឱ្យពិចារណាត្រិះរិះ

មើលរួចហើយ សឹមធ្វើកម្មដោយកាយ វាចា ចិត្តយ៉ាងនោះដែរ ។ ព្រះរាហុលដ៏មានអាយុ មានចិត្តត្រេកអរីករាយ ចំពោះភាសិតរបស់ព្រះដ៏មានព្រះភាគ ។

**១៩-គោលិស្សានិសូត្រ** បិដកលេខ ២៣ , ទំព័រ ៣៦៧ ដល់ទំព័រ ៣៨០ ព្រះដ៏មានព្រះភាគទ្រង់គង់នៅវត្តវេឡុវ័នមហាវិហារ។ សម័យនោះ មានភិក្ខុមួយរូបឈ្មោះគោលិស្សានិ ជាអ្នកសមាទាននូវអារញ្ញិកធុតង្គ តែជាអ្នកមានមារយាទមិនរៀបរយ អង្គុយក្នុងកណ្តាលជំនុំសង្ឃ ដោយកិច្ចណាមួយ ។ ព្រះសារីបុត្តបានរំលឹកដាស់តឿនដល់គោលិស្សានិភិក្ខុ ចាប់តាំងតែអំពីអភិសមាចារិកវត្តរហូតដល់ឧត្តរិមនុស្សធម្ម ។ គោលិស្សានិភិក្ខុតាំងនៅក្នុងភាពនៃបុគ្គលគួរដល់ការណែនាំបាន លោកបានសម្រេចនូវព្រះអរហត្តដោយបានស្តាប់ការណែនាំអំពីព្រះធម្មសេនាបតីសារីបុត្ត ។

**២០-មហាវច្ឆគោត្តសូត្រ** បិដកលេខ ២៤ , ទំព័រ ២៥ ដល់ទំព័រ ៤៧ ព្រះអង្គទ្រង់ត្រាស់សម្តែងនៅវត្តវេឡុវ័នមហាវិហារ ។ វច្ឆគោត្តបរិព្វាជកទូលសួរព្រះអង្គអំពីកុសល និងអកុសលដោយសង្ខេប ។ ក្រោយអំពីបានស្តាប់ព្រះធម៌របស់ព្រះដ៏មានព្រះភាគហើយ បានសម្តែងសេចក្តីជ្រះថ្លាចំពោះព្រះធម៌តាមរយៈនៃពុទ្ធបរិស័ទ មានសេចក្តីប្រៀបធៀបដ៏យ៉ាងពីរោះដូច្នេះថា « បពិត្រ





ព្រះគោតមដ៏ចម្រើន ដូចទន្លេគង្គាតែងមានទំនាបទៅរកសមុទ្រ មានទីជ្រាលទៅរកសមុទ្រ មានទីទេរទៅរកសមុទ្រ ដរាបទល់នឹងសមុទ្រទើបឈប់នៅ យ៉ាងណា បរិស័ទទាំងអស់របស់ព្រះគោតមដ៏ចម្រើននេះ ទាំងគ្រហស្ថ ទាំងបព្វជិត តែងមានទំនាបទៅរកព្រះនិព្វាន មានទីជ្រាលទៅរកព្រះនិព្វាន មានទីទេរទៅរកព្រះនិព្វាន ដរាបទល់នឹងព្រះនិព្វានទើបឈប់នៅ ក៏យ៉ាងនោះដែរ »។ វច្ឆគោត្តបរិព្វាជក បានបព្វជ្ជាឧបសម្បទាក្នុងសំណាក់នៃព្រះដ៏មានព្រះភាគ ។ ក្រោយមកព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា « ម្នាលភិក្ខុទាំងឡាយ កាលពីមុន តថាគតបានកំណត់ដឹងចិត្តវច្ឆគោត្តភិក្ខុ ដោយចិត្តរបស់តថាគតថា វច្ឆគោត្តភិក្ខុបានត្រៃវិជ្ជា ជាអ្នកមានឫទ្ធិច្រើន មានអានុភាពច្រើន ។ ទាំងពួកទេវតាក៏បានប្រាប់សេចក្តីនោះ ដល់តថាគតទៀតថា បពិត្រព្រះអង្គដ៏ចម្រើន វច្ឆគោត្តភិក្ខុ បានត្រៃវិជ្ជា ជាអ្នកមានឫទ្ធិច្រើន មានអានុភាពច្រើន »។ ភិក្ខុទាំងឡាយ មានចិត្តត្រេកអរីករាយនឹងភាសិតរបស់ព្រះដ៏មានព្រះភាគ ។

**២១-ទីឃនខសូត្រ** បិដកលេខ ២៤ , ទំព័រ ៤៨ ដល់ទំព័រ ៥៩ ព្រះអង្គទ្រង់ត្រាស់សម្តែងនៅគុហាសូករខាតា នាភ្នំគិជ្ឈកូដជិតក្រុងរាជគ្រឹះ ។ ទីឃនខបរិព្វាជក បានក្រាបទូលព្រះដ៏មាន

ព្រះភាគអំពីទិដ្ឋិរបស់ខ្លួន ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់អំពីការប្រកាន់ទិដ្ឋិនាំឱ្យឈ្លោះទាស់ទែងគ្នា វិញ្ញូជនពិចារណាឃើញច្បាស់នូវការប្រកាន់ ការទាស់ទែង ការគុំកួនគ្នា និងការបៀតបៀនគ្នាថាជាទោសក្នុងខ្លួនដោយប្រការដូច្នេះហើយ ក៏លះបង់នូវទិដ្ឋិនោះចេញ ផង មិនប្រកាន់ទិដ្ឋិឯទៀតផង ។ ព្រះអង្គទ្រង់ត្រាស់សម្តែងអំពីរូបកម្មដ្ឋាន និងអរូបកម្មដ្ឋាន (ទំព័រ ៥៥- ៥៧ ) គួរសាធុជនទន្ទេញឱ្យចាំ ចាប់ពីពាក្យថា « ម្នាលអគ្គិវេស្សនៈ ក៏ឯកាយនេះមានរូបជាទីប្រជុំនៃមហាភូតរូប ៤ ... » ដល់ចុងបំផុតនៃទំព័រ ៥៧ ។ លទ្ធផលនៃការស្តាប់ព្រះសូត្រនេះគួរឱ្យជ្រះថ្លាដ៏ក្រៃលែង ព្រោះថា ទីឃនខបរិព្វាជកបានធម្មចក្ខុសម្រេចនូវសោតាបត្តិផល រីឯព្រះសារីបុត្តគង់នៅក្បែរនោះ ក៏បានសម្រេចនូវព្រះអរហត្ត ដោយបានបញ្ចូនញាណតាមក្រសែធម៌ បានជ្រាបថា ព្រះដ៏មាន-ព្រះភាគទ្រង់ត្រាស់សម្តែងអំពីការលះបង់នូវពួកធម៌នោះៗ ដោយប្រាជ្ញាដ៏ក្រៃលែងដល់យើងទាំងឡាយ ។

**២២-មហាសកុលុទាយិសូត្រ** បិដកលេខ ២៤ ,ទំព័រ ១៣២ ដល់ទំព័រ ១៨៧ ព្រះអង្គទ្រង់គង់នៅវត្តវេឡុវ័ន មហាវិហារ ហើយព្រះអង្គយាងទៅបិណ្ឌបាតក្នុងក្រុងរាជគ្រឹះ ។ ដោយនៅពេលព្រឹកពេក ទ្រង់យាងចូលទៅរកសកុលុទាយិបរិព្វាជក នៅឯបរិព្វាជ-





ការាម ជាមោរនិវាបស្ថាន (កន្លែងសម្រាប់ឱ្យ ចំណីដល់ពួកសត្វក្ងោក ) ។ សកុលុទាយិបរិព្វាជក ក្រាបបង្គំទូល ដល់ព្រះដ៏មាន-ព្រះភាគនូវធម៌ ៥ ប្រការ ដែលជាធម៌នាំពួកសាវ័ក ធ្វើសក្ការៈគោរពរាប់អាន បូជានូវព្រះដ៏មានព្រះភាគ ។ ធម៌ ៥ ប្រការគឺ ១.ព្រះអង្គមានអាហារតិចផង សរសើរបែបភាពនៃបុគ្គលអ្នកមានអាហារតិចផង , ២.ព្រះអង្គទ្រង់សន្តោសដោយចីវរតាមមានតាមបានផង សរសើរសេចក្តីសន្តោសដោយចីវរតាមមានតាមបានផង ៣.ព្រះអង្គទ្រង់សន្តោសដោយចង្ហាន់បិណ្ឌបាត .... , ៤.ព្រះអង្គទ្រង់សន្តោសដោយសេនាសនៈ ... , ៥.ព្រះអង្គទ្រង់ស្ងប់ស្ងាត់ សរសើរសេចក្តីស្ងប់ស្ងាត់ (សកុលុទាយិបរិព្វាជក ពោលពីស្ងាត់កាយ ) ។ ព្រះដ៏មានព្រះភាគទ្រង់បដិសេធ ព្រោះធម៌ទាំង ៥ ប្រការនេះ មានក្នុងសាវ័ករបស់ព្រះអង្គពួកខ្លះ ក្រៃលែងជាងព្រះអង្គទៅទៀត ។ ធម៌ ៥ ប្រការដោយឡែក ដែលជាធម៌នាំឱ្យពួកសាវ័ករបស់ព្រះតថាគត ធ្វើសក្ការៈ គោរពរាប់អាន បូជាចំពោះព្រះអង្គ ។ ធម៌ ៥ ប្រការគឺ ១.អធិសីល , ២.ញាណ-ទស្សនៈ (បានដល់សព្វញ្ញុតញ្ញាណ ) , ៣.អធិប្បញ្ញា (បញ្ញាក្នុងសច្ចធម៌ និងបញ្ញាដទៃទៀតវៀរសព្វញ្ញុតញ្ញាណ ) , ៤.ដោះ-ស្រាយបញ្ហាក្នុងអរិយសច្ចៈទាំង ៤ ដល់សាវ័កដែលមានទុក្ខបៀត-

បៀន ព្រះអង្គញុំាងសាវ័កឱ្យមានចិត្តត្រេកអរ ដោយការដោះស្រាយនូវប្រស្នា , ៥.ព្រះអង្គបានសម្តែងនូវបដិបទាដល់ពួកសាវ័កមានសតិប្បដ្ឋាន ៤ ជាដើម រហូតដល់បារមីញាណជាទីបំផុតនៃអភិញ្ញាក្នុងបដិបទានោះមាន ១៩ បព្វៈ ។ សកុលុទាយិបរិព្វាជកមានចិត្តត្រេកអររីករាយចំពោះភាសិតនៃព្រះដ៏មានភាគ ។

**២៣-ចូឡសកុលុទាយិសូត្រ** បិដកលេខ ២៤ , ទំព័រ២០៥ ដល់ទំព័រ២៣០ ព្រះអង្គទ្រង់ត្រាស់សម្តែងនៅបរិព្វាជការាម ក្រុងរាជគ្រឹះ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរអំពីពន្លឺដ៏ឧត្តម និងអំពីលោកមានសេចក្តីសុខដោយចំណែកមួយ ។ ព្រះអង្គទ្រង់ត្រាស់សម្តែងអំពីបដិបទាប្រកបដោយហេតុ ដើម្បីធ្វើឱ្យជាក់ច្បាស់នូវលោក ដែលមានតែសេចក្តីសុខដោយចំណែកមួយ ។ សកុលុទាយិបរិព្វាជក ពោលសរសើរព្រះធម៌ សូមដល់ព្រះដ៏មានព្រះភាគ ព្រះធម៌ និងព្រះសង្ឃជាសរណៈ ព្រមទាំងសូមបព្វជ្ជាឧបសម្បទាក្នុងសំណាក់ព្រះដ៏មានព្រះភាគ ។ បរិស័ទរបស់សកុលុទាយិបរិព្វាជក បានធ្វើសេចក្តីអន្តរាយដល់សកុលុទាយិ ក្នុងការប្រព្រឹត្តព្រហ្មចរិយធម៌ ពោលគឺអង្វរឱ្យនៅជាអាចារ្យរបស់ខ្លួនទៅទៀត កុំបួសក្នុងសំណាក់ព្រះសមណគោតមឡើយ ។

អដ្ឋកថាសម្តែងថា សកុលុទាយិបរិព្វាជកនេះបានបួសក្នុងសាសនានៃព្រះសម្មាសម្ពុទ្ធកស្សបៈ បានបំពេញសមណធម៌ ។ គ្រានោះមានភិក្ខុជាសម្លាញ់ប្រាថ្នាចាកសិក្ខាបទ សកុលុទាយិក្នុងកាលនោះបានពោលសរសើរគុណនៃការគ្រប់គ្រងផ្ទះ ព្រោះមានលោភៈក្នុងបាត្រ និងចីវររបស់ភិក្ខុជាសម្លាញ់ហ្នឹងឯង ។ ដោយកម្មនោះឯង ឥឡូវនេះទើបកើតអន្តរាយ ដល់ការបួសចំពោះព្រះ-ភក្ត្រនៃព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់សម្តែងនូវព្រះ-សូត្រទាំងពីរហើយ សកុលុទាយិមិនអាចបានសម្រេចនូវមគ្គផលឡើយ ប៉ុន្តែបានជាឧបនិស្សយប្បច្ច័យក្នុងអនាគត ព្រោះហេតុនោះទើបព្រះដ៏មានព្រះភាគត្រាស់សម្តែងនូវព្រះធម៌ ។ ព្រះដ៏មាន-ព្រះភាគទ្រង់ជ្រាបនូវបុគ្គលក្នុងអនាគត ទើបបច្ចុប្បន្នដែលព្រះអង្គគង់ព្រះជន្មនៅឡើយ ទ្រង់មិនបានតែងតាំងនូវភិក្ខុអង្គណាមួយ ឱ្យជាឯតទគ្គៈខាងមេត្តាវិហារីឡើយ ។ ព្រះដ៏មានព្រះភាគទ្រង់ឃើញថា ក្នុងអនាគតសកុលុទាយិបរិព្វាជកនេះ នឹងកើតក្នុងក្រុងបាដ-លិបុត្រ ក្នុងសម័យនៃព្រះបាទធម្មាសោក ហើយបួសក្នុងសាសនារបស់ព្រះអង្គ គ្រាបួសហើយក៏បានសម្រេចនូវព្រះអរហត្ត មានព្រះនាមថា **ព្រះអស្សគុត្តត្ថេរ** កំពូលលើភិក្ខុទាំងឡាយខាងនៅដោយមេត្តា ។ ដោយមេត្តានុភាពរបស់ព្រះថេរៈ សូម្បីសត្វតិរច្ឆានក៏បានទទួលនូវមេត្តាចិត្តដែរ ។

**៧៤-ធនញ្ជានិសូត្រ** បិដកលេខ ២៥ , ទំព័រ ១៧០ ដល់ទំព័រ ២០២ ព្រះអង្គទ្រង់គង់ក្នុងវត្តវេឡុវ័នមហាវិហារ ។ ព្រះសារីបុត្ត បានប្រទានឱវាទដល់ធនញ្ជានិព្រាហ្មណ៍ អ្នកក្រុងរាជគ្រឹះ កុំឱ្យ អាងថាធ្វើអាក្រក់ដើម្បីចិញ្ចឹមអ្នកដទៃ ព្រោះអ្នកដទៃណាក៏ដោយ ក៏មិនអាចជួយអ្នកបានដែរ កាលដែលត្រូវកម្មឱ្យផលនោះ ។ នៅ ពេលឈឺធនញ្ជានិព្រាហ្មណ៍ តាំងនៅក្នុងឱវាទព្រះសារីបុត្តទៀត ហើយគាត់បានផ្ដាំនឹងព្រះសារីបុត្តដូច្នេះថា « បពិត្រព្រះសារីបុត្តដ៏ ចម្រើន បើដូច្នោះ សូមលោកម្ចាស់ក្រាបថ្វាយបង្គំព្រះបាទានៃ ព្រះដ៏មានបុណ្យដោយត្បូង តាមពាក្យរបស់ខ្ញុំព្រះករុណាថា បពិត្រ ព្រះអង្គដ៏ចម្រើន ធនញ្ជានិព្រាហ្មណ៍ មានអាពាធ ដល់នូវទុក្ខ វេទនា មានជំងឺជាទម្ងន់ » គាត់ក្រាបថ្វាយបង្គំព្រះបាទានៃព្រះដ៏-មានបុណ្យដោយត្បូង។ ព្រះសារីបុត្តបាននិមន្តមកកាន់វត្តវេឡុវ័ន វិញ ហើយបានក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគតាមពាក្យធន-ញ្ជានិព្រាហ្មណ៍ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា « ហៃសារី-បុត្ត ធនញ្ជានិព្រាហ្មណ៍ស្លាប់ហើយ គាត់ទៅកើតនៅឯព្រហ្ម-លោកហើយ »។

**៧៥-គោបកមោគ្គល្លានសូត្រ** បិដកលេខ ២៦ , ទំព័រ ១៦៨ ដល់ទំព័រ ១៨៩ ព្រះដ៏មានព្រះភាគទ្រង់បរិនិព្វានទៅមិនយូរប៉ុន្មាន





ពេលមួយព្រះអានន្ទដ៏មានអាយុ គង់នៅក្នុងវេឡុវ័នមហាវិហារ ។ ព្រះអានន្ទនិមន្តបិណ្ឌបាត ប៉ុន្តែនៅព្រឹកពេក ក៏ចូលទៅជួបគោប-កមោគ្គល្លានព្រាហ្មណ៍ ។ បន្ទាប់ពីបដិសណ្ឋារៈហើយ ព្រាហ្មណ៍ បានសួរព្រះអានន្ទដូច្នេះថា « បពិត្រព្រះអានន្ទដ៏ចម្រើន ព្រះ គោតមដ៏ចម្រើនអង្គនោះ ជាព្រះអរហន្តសម្មាសម្ពុទ្ធ ប្រកបដោយ ធម៌ទាំងឡាយណា ភិក្ខុមួយរូបប្រកបដោយធម៌ទាំងឡាយនោះ ដោយអាការទាំងពួង ដោយប្រការទាំងពួង តើមានដែរឬទេ ? » ព្រះអានន្ទតបថា « មិនមានឡើយ ម្នាលព្រាហ្មណ៍ ព្រោះថា ព្រះមានព្រះភាគអង្គនោះ ជាអ្នកបង្កើតផ្លូវដែលមិនទាន់កើតឡើង ជាអ្នករៀបចំផ្លូវដែលគេមិនទាន់រៀបចំ ជាអ្នកប្រាប់ផ្លូវដែលគេមិន ដែលប្រាប់ ជាអ្នកស្គាល់ផ្លូវ ដឹងផ្លូវ ឈ្លាសវៃក្នុងផ្លូវ ពួកសាវ័កក្នុង កាលឥឡូវនេះ គ្រាន់តែជាអ្នកដើរតាមផ្លូវ ប្រកបតាមក្រោយ ប៉ុណ្ណោះ »។ វស្សាការព្រាហ្មណ៍ ជាមហាមាត្យក្នុងដែនមគធៈ បានចូលទៅកាន់ទីនោះ ហើយសួរព្រះអានន្ទថា « បពិត្រព្រះ-អានន្ទដ៏ចម្រើន ក្នុងកាលឥឡូវនេះ លោកម្ចាស់ទាំងឡាយ គប្បី ប្រតិបត្តិតាមបុគ្គលណា បុគ្គលនោះ សូម្បីជាភិក្ខុមួយរូបដែលព្រះ-គោតមដ៏ចម្រើនអង្គនោះ បានតែងតាំងទុកហើយថា ភិក្ខុនេះ អំណើះអំពីតថាគតទៅ នឹងបានជាទីពឹងនៃអ្នកទាំងឡាយ ដូច្នេះ

មានដែរឬ ? »ព្រះអានន្ទតបថា « មិនមានឡើយ »។ បពិត្រព្រះអានន្ទដ៏ចម្រើន កាលបើមិនមានទីពឹងយ៉ាងនេះហើយ ចុះធម៌ដូចម្តេច ដែលជាហេតុនាំឱ្យកើតធម៌សាមគ្គីបាន ? ម្នាលព្រាហ្មណ៍ យើងទាំងឡាយមិនមែនជាអ្នកឥតទីពឹងទេ ម្នាលព្រាហ្មណ៍ យើងទាំងឡាយប្រកបដោយទីពឹង គឺមានធម៌ជាទីពឹង ។ ព្រះអានន្ទបានសម្តែងអំពី **បសាទនីយធម៌** (ធម៌ជាទីតាំងនៃសេចក្តីជ្រះថ្លា ) ១០ យ៉ាង ដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែងហើយ ។

**២៦-ឥសិគិលិសូត្រ** បិដកលេខ ២៦ ទំព័រ ៣២៨ ដល់ទំព័រ ៣៣៤ ព្រះអង្គទ្រង់ត្រាស់សម្តែងនៅលើភ្នំឥសិគិលិ ជិតក្រុងរាជគ្រឹះ ។ ព្រះបរមសាស្តាទ្រង់ត្រាស់សម្តែងដល់ភិក្ខុទាំងឡាយនូវភ្នំទាំង ៥ ដែលព័ទ្ធជុំវិញក្រុងរាជគ្រឹះគឺភ្នំវេភារៈ ១ ភ្នំបណ្ឌវៈ ១ ភ្នំវេបុល្លៈ ១ ភ្នំគិជ្ឈកូដ ១ និងភ្នំឥសិគិលិដែលព្រះអង្គកំពុងគង់ប្រថាប់ ១ ។ ព្រះអង្គទ្រង់ត្រាស់សម្តែងព្រះនាមនៃព្រះបច្ចេកពុទ្ធ ៥០០ អង្គ ដែលជាបុត្រនៃព្រះនាងបទុមវតី ប៉ុន្តែ ២ អង្គក្តី ៣ អង្គក្តី ១០ អង្គក្តី ១២ អង្គក្តី មានព្រះនាមដូចគ្នា ។

**២៧-ពក្កុលត្ថេរច្ឆរិយព្ភូតសូត្រ** បិដកលេខ ២៧ , ទំព័រ ៥៨ ដល់ទំព័រ ៦៤ ព្រះពក្កុលៈដ៏មានអាយុ គង់នៅក្នុងវត្តវេឡុវ័នមហា-វិហារ ។ អចេលឈ្មោះកស្សបៈបានសួរព្រះពក្កុលៈដ៏មានអាយុថា





« លោកម្ចាស់បួសយូរប៉ុន្មានឆ្នាំហើយ ? » ព្រះពក្កុលៈឆ្លើយថា « អាត្មាបួស ៨០ វស្សាហើយ »។ អចេលកស្សបៈសួរទៀតថា «បពិត្រព្រះពក្កុលៈដ៏មានអាយុ ចុះ ៨០ វស្សានេះ លោកសេពមេថុនប៉ុន្មានដង ? » ព្រះថេរៈឆ្លើយថា « ម្នាលអាវុសោកស្សបៈ អ្នកកុំសួរអាត្មាថា បពិត្រព្រះពក្កុលៈដ៏មានអាយុ ចុះ ៨០ វស្សានេះ លោកសេពមេថុនប៉ុន្មានដង យ៉ាងនេះឡើយ ម្នាលអាវុសោកស្សបៈ អ្នកត្រូវសួរអាត្មាថា បពិត្រព្រះពក្កុលៈដ៏មានអាយុ ចុះ ៨០ វស្សានេះ កាមសញ្ញារបស់លោកធ្លាប់កើតប៉ុន្មានដង យ៉ាងនេះវិញ ។ ម្នាលអាវុសោ អាត្មាបួស ៨០ វស្សាហើយ អាត្មាមិនដែលមានកាមសញ្ញាកើតឡើងទេ » ។ សេចក្តីអស្ចារ្យរបស់ព្រះពក្កុលៈនៅមានច្រើនទៀត ក្នុង ៨០ វស្សាលោកមិនដែលសិងឡើយ (អាត្មាបួស ៨០ វស្សាហើយ អាត្មាមិនដែលដេកទេ )។ អចេលកស្សបៈជ្រះថ្លាក្នុងព្រហ្មចរិយធម៌ ហើយបានបព្វជ្ជាឧប-សម្បទាក្នុងព្រះពុទ្ធសាសនា មិនយូរប៉ុន្មានក្រោយពីឧបសម្បទាហើយ លោកបានសម្រេចជាព្រះអរហន្តមួយអង្គដែរ ។

**២៨-ទន្តភូមិសូត្រ** បិដកលេខ ២៧ ,ទំព័រ ៦៥ ដល់ទំព័រ ៨៩ ព្រះអង្គទ្រង់ត្រាស់សម្តែងនៅវត្តវេឡុវ័នមហាវិហារ ។ ប្រារព្ធចំពោះព្រះរាជកុមារព្រះនាម **ជយសេន** ជាព្រះរាជឱរសរបស់ព្រះ

បាទពិម្ពិសារ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា « គុណជាតណា ដែលបុគ្គលគប្បីដឹងដោយនេក្ខម្មៈ គប្បីឃើញដោយនេក្ខម្មៈ គប្បីដល់ដោយនេក្ខម្មៈ គប្បីធ្វើឱ្យជាក់ច្បាស់ដោយនេក្ខម្មៈ តើជ័យសេនរាជកុមារនឹងបាននូវគុណជាតនោះ អំពីទីណា ក្នុងអត្តភាពនេះ ព្រោះថាជ័យសេនរាជកុមារ កំពុងនៅក្នុងកណ្តាលកាម កំពុងបរិភោគកាម កំពុងទំពាស៊ីកាមវិតក្ក កំពុងរោលរាលដោយសេចក្តីក្រហល់ក្រហាយព្រោះកាម ជាអ្នកខ្វល់ខ្វាយដើម្បីស្វែងរកកាម នឹងដឹង នឹងយល់ នឹងធ្វើឱ្យជាក់ច្បាស់នូវគុណជាតនោះដូចម្តេចកើត » ។ ព្រះដ៏មានព្រះភាគសម្តែងអំពីការទូន្មានខ្លួនដោយមានឧបមាផ្សេងៗ នៅក្នុងព្រះសូត្រនេះ ។ អចិរវតសមណុទ្ទេស រីករាយនឹងភាសិតរបស់ព្រះដ៏មានព្រះភាគ ។

**២៩-ភូមិជសូត្រ** បិដកលេខ ២៧,ទំព័រ ៩០ ដល់ទំព័រ ១០៧ ព្រះអង្គទ្រង់ត្រាស់សម្តែងនៅវត្តវេឡុវ័នមហាវិហារ ។ ប្រារព្ធចំពោះ **ជយសេនរាជកុមារ** ដែលក្នុងព្រះសូត្រនេះ ឃើញព្រះរាជកុមារមានសភាពល្អជាងមុន ហើយបានធ្វើទានទៀតផង ។ ព្រះអង្គសម្តែងឧបមា ៤ យ៉ាង គឺ ១.ត្រូវការប្រេងទៅច្របាច់ដីខ្សាច់ , ២.ត្រូវការទឹកដោះស្រស់ទៅមួលស្នែងមេគោ , ៣.ត្រូវការភ្លើងទៅពួតឈើស្រស់ដែលនៅមានជ័រ ។ ក្នុងសេចក្តីនេះ ព្រះដ៏មាន





ព្រះភាគទ្រង់សម្តែងអំពីសមណៈ ឬព្រាហ្មណ៍ ជាអ្នកបដិបត្តិខុសដោយមិច្ឆាទិដ្ឋិជាដើម គឺមិនគួរដើម្បីត្រាស់ដឹងនូវផលឡើយ ។ ព្រះភូមិជៈដ៏មានអាយុ មានសេចក្តីត្រេកអររីករាយនឹងភាសិតរបស់ព្រះដ៏មានព្រះភាគ ។

**៣០-មហាកច្ចានភទ្ទេករត្តសូត្រ** បិដកលេខ ២៨,ទំព័រ ១៩ ដល់ទំព័រ ៤១ ព្រះអង្គទ្រង់គង់នៅក្នុងតបោទារាម ជិតក្រុងរាជគ្រឹះ ។ មានទេវតាចូលមកសន្ទនានឹងព្រះសមិទ្ធិដ៏មានអាយុនៅស្ទឹងតបោទា អំពីភទ្ទេករត្តសូត្រ ប៉ុន្តែដោយព្រះសមិទ្ធិមិនបានចេះចាំ ទើបចូលទៅទូលសួរដល់ព្រះដ៏មានព្រះភាគ ។ ព្រះមានព្រះភាគ ទ្រង់បានត្រាស់គាថានេះថា « បុគ្គលមិនគប្បីអាឡោះអាល័យបញ្ចក្ខន្ធ ជាអតីត មិនគប្បីប្រាថ្នាបញ្ចក្ខន្ធ ជាអនាគត ព្រោះបញ្ចក្ខន្ធណា ជាអតីត បញ្ចក្ខន្ធនោះកន្លងហួសទៅហើយ បញ្ចក្ខន្ធណា ជាអនាគត បញ្ចក្ខន្ធនោះក៏មិនទាន់មកដល់ ។ មួយទៀត បុគ្គលណា ឃើញច្បាស់នូវធម៌ជាបច្ចុប្បន្នក្នុងទីនោះៗ បុគ្គលនោះ លុះដឹងច្បាស់នូវព្រះនិព្វាន ដែលមិនរសេមរសាម មិនកម្រើកហើយ គប្បីចម្រើនឱ្យរឿយៗ នូវផលសមាបត្តិ ដែលមាននិព្វានជាអារម្មណ៍ ។ ឯការព្យាយាមជាគ្រឿងដុតនូវកិលេស បុគ្គលគួរតែធ្វើក្នុងថ្ងៃនេះឯង អ្នកណានឹងដឹងថា សេចក្តីស្លាប់

នឹងមានក្នុងថ្ងៃស្អែកបាន ព្រោះថាការតទល់របស់យើងចំពោះមច្ចុ ដែលមានសេនាដ៏ច្រើននោះ មិនមានសោះឡើយ ។ មុនីជាអ្នកស្ងប់ទុក្ខ តែងហៅបុគ្គល ដែលមានវិហារធម៌យ៉ាងនេះ មានព្យាយាមដុតកម្តៅកិលេស មិនខ្ជិលច្រអូសអស់ថ្ងៃនិងយប់នោះឯងថាជាអ្នកមានរាត្រីមួយដ៏ចម្រើន »។ ព្រះដ៏មានព្រះភាគ បានត្រាស់នូវភាសិតនេះហើយ ទ្រង់ក្រោកចាកអាសនៈ ហើយចូលទៅកាន់ព្រះវិហារ ។ ព្រះភិក្ខុទាំងឡាយ មានព្រះសមិទ្ធិជាដើម បានចូលទៅរកព្រះមហាកច្ចានៈ ដើម្បីចែកសេចក្តីនៃភាសិតរបស់ព្រះដ៏មានព្រះភាគនេះ ដែលមានឈ្មោះថា « អ្នកមានរាត្រីមួយដ៏ចម្រើន »។ ការចែកសេចក្តីដោយសង្ខេបឱ្យបានពិស្តារ ដោយព្រះមហាកច្ចានៈ ត្រូវបានព្រះដ៏មានព្រះភាគគាំទ្រទាំងស្រុង ។ ភិក្ខុទាំងឡាយ ក៏មានចិត្តត្រេកអរ រីករាយ នឹងភាសិតរបស់ព្រះដ៏មានព្រះភាគ ។

**៣១-មហាកម្មវិភង្គសូត្រ** បិដកលេខ ២៨ ,ទំព័រ ៧២ ដល់ទំព័រ ៩៦ ព្រះអង្គទ្រង់ត្រាស់សម្តែងនៅវត្តវេឡុវ័នមហាវិហារ ។ ព្រះសមិទ្ធិឆ្លើយតបបញ្ហាបរិព្វាជកឈ្មោះបោតលិបុត្រ ។ ការឆ្លើយបញ្ហាមិនបានចែកដោយល្អឡើយ ដូច្នេះហើយ ទើបព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែងចែកមហាកម្ម តាមរយៈនៃការប្រព្រឹត្ត



